សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal university of Law and Economics

## សារណាបញ្ចប់ការសិក្សា

# នីតិវិធីគ្រប់គ្រងគ្រោះថ្នាក់ នៃការសាងសង់នៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. ហឿន គឹមលាភ**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **អ៊ុន សកក្កដា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៧ (អាហារូបករណ៍)

ឆ្នាំចូលរៀន ២០១៨

ឆ្នាំសរសេរសារណា ២០២២

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Economiques**

**Royal university of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីគ្រប់គ្រងគ្រោះថ្នាក់ នៃការសាងសង់នៅកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ក. ហឿន គឹមលាភ**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **អ៊ុន សកក្កដា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៧ (អាហារូបករណ៍)

ឆ្នាំចូលរៀន ២០១៨

ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ហឿន គីមលាភ** ជានិស្សិតឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី២៧ ឆ្នាំសិក្សា ២០២១-២០២២ (អាហារូបករណ៍) នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ជាដំបូងនាងខ្ញុំសូមប្រណិបតន៍និងក្រាបបង្គំ លោកឪពុក **ពេញ ហឿន** អ្នកម្តាយ **ទ្រឹង គីមលាន** និងបងស្រី **ហឿន គីមលី** ដែលបានចិញ្ចឹមបីបាច់ថែរក្សាយ៉ាងល្អ ព្រមទាំងផ្គត់ផ្គង់ការសិក្សា ទាំងសម្ភារៈទាំងថវិកា អស់ទាំងកម្លាំងកាយចិត្ត ដើម្បីឱ្យនាងខ្ញុំមានឱកាសបានបន្តការសិក្សានិងទទួលបានផ្លែផ្កាដូចពេលនេះ។ អ្នកមានគុណទាំងពីរ គឺជាពន្លឺ និងជាកម្លាំងចិត្តនៃការតស៊ូនៃជីវិតរបស់នាងខ្ញុំ។ បងស្រីគឺជាអ្នកមានគុណទីពីររបស់ប្អូន បងតែងតែពុះពារជំនះនូវរាល់ឧបសគ្គទោះក្តៅរងា លំបាកយ៉ាងណាក៏បងពុំដែលរាថយឡើយ ដើម្បីផ្គត់ផ្គង់ឱ្យប្អូនបានសិក្សារហូតបញ្ចប់ឧត្តមសិក្សា ដែលជាបំណងប្រាថ្នារបស់បងស្រី។ លោកឪពុក អ្នកម្តាយ និងបងស្រី ព្រមទាំងក្រុមគ្រួសារទាំងមូល គឺជាព្រះអាទិត្យដែលតែងតែចាំងបំភ្លឺនូវមាគ៌ាសម្រាប់កូនស្រីម្នាក់នេះឆ្ពោះទៅកាន់ភាពជោគជ័យទាំងក្នុងការសិក្សា និងគ្រប់ភារកិច្ចការងារផងដែរ។ គុណូបការៈនៃអ្នកមានគុណទាំងទ្វេ និងបងស្រី កូនមិនអាចបំភ្លេចបានឡើយដែលលោកតែងតែអប់រំទូន្មាន បង្ហាត់បង្ហាញឱ្យកូនស្រីខិតខំសិក្សាដើម្បីក្រេបយកនូវចំណេះវិជ្ជាទាំងឡាយដែលសុទ្ធតែជាធនធានមានតម្លៃនៅសាលា និងក្នុងជីវភាពរស់នៅប្រចាំថ្ងៃ សម្រាប់ជាមូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍសង្គមគ្រួសារ និងប្រទេសជាតិឱ្យមានការរីកចម្រើនដរាបតរៀងទៅ។

ជាកិច្ចបន្ទាប់ សូមថ្លែងអំណរគុណ **ឯកឧត្តម លុយ ចណ្ណា សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំងលោក-លោកស្រីសាស្ត្រាចារ្យទាំងអស់ និងបុគ្គលិកគ្រប់ជាន់ថ្នាក់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ទាំងកម្លាំងកាយចិត្តបង្ហាត់បង្រៀន ផ្តល់ដំបូន្មានល្អ និងជួយសម្រួលនូវកិច្ចការជាច្រើនពាក់ព័ន្ធនឹងវិស័យច្បាប់ក៏ដូចជាគន្លឹះទាក់ទងនឹងការស្រាវជ្រាវដើម្បីជាទុនក្នុងការបង្កើតស្នាដៃនេះឡើងដោយភាពជោគជ័យ។

នាងខ្ញុំសូមថ្លែងអំណរគុណនិងធ្វើការគោរពចំពោះ **សាស្ត្រាចារ្យ បណ្ឌិត អ៊ុន សកក្កដា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងលះបង់កម្លាំងកាយ កម្លាំងចិត្ត ប្រាជ្ញា ដោយពុំគិតពីការនឿយហត់ ដើម្បីណែនាំ បង្ហាត់បង្ហាញផ្លូវ និងកែលម្អនូវរាល់ចំណុចខ្វះខាតរបស់នាងខ្ញុំក្នុងការសរសេរសារណានេះ រហូតសម្រេចបានជោគជ័យ។ ជាចុងក្រោយ នាងខ្ញុំសូមអធិដ្ឋានឱ្យលោកទាំងឡាយខាងលើ ទទួលបានសេចក្តីសុខ សុខភាពល្អ សុវត្ថិភាព អាយុយឺនយូរ មានសុភមង្គលក្នុងក្រុមគ្រួសារ និងជោគជ័យគ្រប់ភារកិច្ចការងារគ្រប់ពេលវេលា។

# អារម្ភកថា

ការស្រាវជ្រាវលើប្រធានបទស្តីពី **«នីតិវិធីគ្រប់គ្រងគ្រោះថ្នាក់នៃការសាងសង់នៅកម្ពុជា»** នាងខ្ញុំពិតជាមានសេចក្តីសោមនស្សជាពន់ពេកណាស់ ដោយស្នាដៃនេះកើតចេញពីការខិតខំប្រឹងប្រែងព្យាយាមរបស់នាងខ្ញុំក្រោមការដឹកនាំប្រកបដោយការយកចិត្តទុកដាក់ខ្ពស់ពីសំណាក់សាស្ត្រាចារ្យ **បណ្ឌិត អ៊ុន សភក្តដា**។ នាងខ្ញុំបានស្រាវជ្រាវយ៉ាងស្វិតស្វាញ និងស្វែងរកនូវឯកសារច្បាប់នានា ដែលជាប់ទាក់ទង និងពាក់ព័ន្ធជាមួយប្រធានបទសារណាមួយនេះ លើសពីនេះទៅទៀតនាងខ្ញុំទទួលបាននូវចំណេះដឹងពីសាស្ត្រាចារ្យ រួមទាំងការព្យាយាមសិក្សាឈ្វេងយល់បន្ថែមដោយខ្លួនឯងបានធ្វើឱ្យស្នាដៃនៃការស្រាវជ្រាវនេះផុសជារូបរាងឡើងនាពេលនេះ។ ការស្រាវជ្រាវលើប្រធានបទខាងលើ គឺកើតឡើងដោយការប្រឹងប្រែងយ៉ាងស្វិតស្វាញ រួមផ្សំទាំងការស្វែងរកនូវឯកសារដែលអាចជឿទុកចិត្តបាន ដើម្បីបង្កើតឡើងនូវការតាក់តែងជា លាយកល្ខណ៍អក្សរ។ ការស្រាវជ្រាវនេះបានផ្តល់ឱ្យនាងខ្ញុំនូវចំណេះដឹងជាច្រើនទាក់ទងនឹង **នីតិវិធីគ្រប់គ្រងគ្រោះថ្នាក់នៃការសាងសង់នៅកម្ពុជា** ដែលមានដូចជា៖ **ទិដ្ឋភាពការសាងសង់នៅកម្ពុជា និងនីតិវិធីគ្រប់គ្រងគ្រោះថ្នាក់នៃការសាងសង់នៅកម្ពុជា។**

ការសរសេរសារណាទាក់ទងនឹងប្រធានបទនេះ គឺធ្វើឡើងក្នុងគោលបំណងបង្ហាញឱ្យឃើញអំពីនីតិវិធីក្នុងការការពារ និងដោះស្រាយនៅពេលដែលការសាងសង់បណ្តាលឱ្យមានគ្រោះថ្នាក់កើតឡើង។ ម្យ៉ាងវិញទៀតការរៀបរាងជាសារណាបញ្ចប់ការសិក្សានេះ មានគោលដៅបង្ហាញនិស្សិត និងមិត្តអ្នកអាន ព្រមទាំងអ្នកសិក្សាស្រាវជ្រាវទាំងឡាយបានស្វែងយល់បន្ថែម និងបំពេញនូវចំណេះដឹងដែលមានស្រាប់ទៅលើបទដ្ឋានគតិយុត្ត ដែលពាក់ព័ន្ធនឹងវិស័យសំណង់ ជាពិសេសទៅទៀតនោះគឺការការដោះស្រាយ និងបញ្ចៀសបាននូវរាល់គ្រោះថ្នាក់ដែលកើតមានឡើងក្នុងអំកំឡុងពេលនៃការសាងសង់។

សារណាបញ្ចប់ការសិក្សានេះ គឺជាស្នាដៃ និងជាសមិទ្ធិផលដែលនាងខ្ញុំបានខិតខំប្រឹងប្រែងស្វះស្វែងស្រាវជ្រាវ និងបានធ្វើការពិនិត្យសង្កេតក្នុងដំណាក់កាលនីមួយៗប្រកបដោយការយកចិត្តទុកដាក់យ៉ាងហ្មត់ចត់។ ប៉ុន្តែទោះបីជាយ៉ាងណាកិច្ចការស្រាវជ្រាវនានារមែងតែងតែមានចំណុចលើសលោះ ឬខ្វះចន្លោះមិនទាន់ពេញលេញ សមស្របត្រង់ចំណុចណាមួយជាក់ជាពុំខានឡើយ ទោះតិចទោះច្រើន។ អាស្រ័យហេតុនេះហើយ នាងខ្ញុំជឿជាក់ថាមិត្តអ្នកអាន និងអ្នកសិក្សាស្រាវជ្រាវទាំងអស់ពិតជាខន្តីអភ័យទោសដល់នាងខ្ញុំ។ រាល់កំហុសដែលកើតឡើងដោយអចេតនាត្រង់ប្រការណាមួយ នាងខ្ញុំសូមស្វាគមន៍ និងរង់ចាំទទួលនូវមតិរិះគន់ក្នុងន័យស្ថាបនាពីសំណាក់មិត្តអ្នកអានគ្រប់មជ្ឈដ្ឋាន អ្នកសិក្សាស្រាវជ្រាវ លោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យ ដើម្បីជាការកែលម្អដល់នាងខ្ញុំ ព្រមទាំងជាជំនួយក្នុងការអភិវឌ្ឍសមត្ថភាពឱ្យកាន់តែល្អប្រសើរប្រកបដោយនិរន្តរភាព និងនវានុវត្តន៍។

# មាតិកា

ទំព័រ


**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**ស្ថានភាពនៃការសាងសង់នៅកម្ពុជា**

**១.១. ស្ថានភាពទូទៅនៃការសាងសង់នៅកម្ពុជា** ........ ៥

១.១.១. បញ្ហាប្រឈមនៅក្នុងវិស័យសំណង់នៅកម្ពុជា ........ ៦

១.១.២. និយមន័យ ........ ៧

១.១.៣. ដំណើរការ និងការវិវឌ្ឍនៃការសាងសង់នៅកម្ពុជា ........ ៧

**១.២. បទប្បញ្ញត្តិនៃបច្ចេកទេសសាងសង់** ........ ៧

១.២.១. ការពិនិត្យមើលលើការចេញលិខិតអនុញ្ញាតសាងសង់ ........ ៨

១.២.២. នីតិវិធីនៃការស្នើសុំសាងសង់ ........ ១១

១.២.៣. អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ ........ ២១

**១.៣. ការបង្កើតមន្ទីរពិសោធន៍សំណង់ និងការត្រួតពិនិត្យផលិតផលសំណង់** ........ ២៥

១.៣.១. ការបង្កើតមន្ទីរពិសោធន៍គណៈវិស្វករកម្ពុជា ........ ២៥

១.៣.២. ការបង្កើតមន្ទីរពិសោធន៍សំណង់ ........ ២៦

**ជំពូកទី២**

**នីតិវិធីគ្រប់គ្រងគ្រោះថ្នាក់នៃការសាងសង់នៅកម្ពុជា**

**២.១.ការត្រួតពិនិត្យការងារសាងសង់ និងរុះរើសំណង់** ........ ២៩

២.១.១. ការត្រួតពិនិត្យផលិតផលសំណង់ ........ ២៩

២.១.២. ការត្រួតពិនិត្យការងារសាងសង់ ........ ៣០

២.១.២.១. ការត្រួតពិនិត្យការសាងសង់សំណង់ថ្មី ........ ៣១

២.១.១.២. ការត្រួតពិនិត្យបច្ចេកទេសសំណង់ ........ ៣៣

២.១.៣. ការត្រួតពិនិត្យការជួសជុល កែប្រែ ........ ៣៤

២.១.៣.១. ការត្រួតពិនិត្យនិងបញ្ជាក់ការងារជួសជុល ..... ៣៤
២.១.៣.២. ការត្រួតពិនិត្យនិងបញ្ជាក់ការកែប្រែ ..... ៣៦
២.១.៤. ការត្រួតពិនិត្យការរុះរើសំណង់ ..... ៣៧
២.១.៤.១. ការត្រួតពិនិត្យការរុះរើដោយផ្នែក ..... ៣៧
២.១.៤.២. ការត្រួតពិនិត្យការរុះរើទាំងស្រុង ..... ៣៧
**២.២. ការគ្រប់គ្រងដំណើរការសាងសង់** ..... ៣៨
២.២.១. ការគ្រប់គ្រងគម្រោងប្លង់ ..... ៣៨
២.២.២. ការគ្រប់គ្រងការងារសាងសង់ និងរុះរើ ..... ៣៨
២.២.៣. ការកំណត់កម្រិតនៃស្ថានភាពគ្រោះថ្នាក់ ..... ៣៩
២.២.៣.១. គ្រោះថ្នាក់អាចកើតឡើងភ្លាមៗ ..... ៤០
២.២.៣.២. គ្រោះថ្នាក់មិនអាចកើតឡើងភ្លាមៗ ..... ៤០
**២.៣. ការទទួលខុសត្រូវ និងវិធានការបញ្ចៀសគ្រោះថ្នាក់ការសាងសង់** ..... ៤០
២.៣.១. ស្ថាប័ន និងបុគ្គលដែលពាក់ព័ន្ធ ..... ៤០
២.៣.១.១. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ..... ៤១
២.៣.១.២. ក្រសួងមហាផ្ទៃ ..... ៤១
២.៣.១.៣. អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ ..... ៤៣
២.៣.១.៤. ម្ចាស់សំណង់ ..... ៤៤
២.៣.១.៥. មន្ត្រីអធិការកិច្ចសំណង់ ..... ៤៥
២.៣.១.៦. មេជាងសំណង់ ..... ៤៦
២.៣.២. វិធានការបញ្ចៀសគ្រោះថ្នាក់ការសាងសង់ ..... ៤៨
២.៣.២.១. ការបញ្ចៀសការសាងសង់ និងប្រើប្រាស់សំណង់ដែលត្រូវហាមឃាត់ ..... ៤៨
២.៣.២.២. ការត្រួតពិនិត្យគុណភាពប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ ..... ៥០
២.៣.២.៣. ការជូនដំណឹងរបស់មន្ត្រីសមត្ថកិច្ច ..... ៥០
២.៣.២.៤. ការកំណត់រយៈពេលនៃការអនុវត្តវិធានការ ..... ៥០

២.៣.២.៥. ការកំណត់ទោសបញ្ញត្តិ......................................................................................................៥១
**សេចក្តីសន្និដ្ឋាន**............................................................................................................................ ៥៣
**អនុសាសន៍**......................................................................................................................................៥៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ព្រះរាជាណាចក្រកម្ពុជា ជាប្រទេសមានវ័យចំណាស់ជាងគេនៅតំបន់អាស៊ីអាគ្នេយ៍ មានទីតាំងស្ថិតនៅប៉ែកខាងត្បូងនៃឧបទ្វីបឥណ្ឌូចិន ដែលនៅភាគខាងកើតជាប់នឹងប្រទេសវៀតណាម ភាគខាងជើងជាប់នឹងប្រទេសឡាវ ភាគខាងលិចជាប់នឹងប្រទេសថៃ និងភាគខាងត្បូងជាប់នឹងឈូងសមុទ្រថៃនិងជាចំណុចកណ្តាលនៃឧបទ្វីបអាស៊ីអាគ្នេយ៍ ជាមជ្ឈមណ្ឌលគមនាគមន៍នៅអាស៊ីអាគ្នេយ៍ ជាមជ្ឈមណ្ឌលទីផ្សារពាណិជ្ជកម្មអាស៊ាន ជាមជ្ឈមណ្ឌលកម្សាន្តទេសចរណ៍អាស៊ីអាគ្នេយ៍ ជាមជ្ឈមណ្ឌលថ្មីនៃកំណើនសេដ្ឋកិច្ច និងឧស្សាហកម្មពិភពលោក និងជាកាំតំណរភ្ជាប់រវាងអាស៊ី និងពិភពលោក។ កម្ពុជា គឺជាចំណុចទ្រទ្រង់ដ៏សំខាន់នៅ អាស៊ីអាគ្នេយ៍លើគំនិតផ្តួចផ្តើម "ផ្លូវមួយខ្សែក្រវ៉ាត់" គឺជាទំនាក់ទំនងនៃផ្លូវសូត្រលើសមុទ្រ «ច្រករបៀងសេដ្ឋកិច្ចឧបទ្វីបឥណ្ឌូចិន-ប្រទេសចិន» ជាកាំឥទ្ធិពលដែលចាំបាច់ត្រូវតែឆ្លងកាត់ «ច្រករបៀងសេដ្ឋកិច្ចបង់ក្លាដែស ចិន ឥណ្ឌា និងមីយ៉ាន់ម៉ា» និងជាតំបន់សក្តានុពលផងដែរ។ ប្រទេសកម្ពុជាស្ថិតនៅក្នុងតំបន់ទេសចរណ៍ពិភពលោក ដែលមានធនធានទេសចរណ៍ដ៏សម្បូរបែបក្នុងពិភពលោកដូចជា ទេសភាពតំបន់ ត្រូពិក ផលិតផលសមុទ្រ តំបន់ប្រវត្តិសាស្ត្រ ឆ្នេរសមុទ្រដែលពោរពេញដោយពន្លឺព្រះអាទិត្យ កោះអេកូឡូស៊ី និងជាតំបន់ឆ្នេរដែលគ្មានគ្រោះធម្មជាតិសមុទ្រដ៏កំរនៅអាស៊ីអាគ្នេយ៍។ ប្រទេសកម្ពុជាមានឆ្នេរសមុទ្រសរុបប្រវែង ៤៦០គីឡូម៉ែត្រ ហើយនៅឆ្នាំ ២០១១ បានចាត់ជាសមាជិកក្លឹបឆ្នេរសមុទ្រស្អាតជាងគេក្នុងពិភពលោក។ តាមលក្ខណៈអាកាសធាតុគឺអនុគ្រោះដល់សណ្ឋានដីតំបន់ទំនាបកណ្តាល ដែលជំរុញដល់ការដាំដុះឱ្យកាន់តែរីកចម្រើន មិនតែប៉ុណ្ណោះការកើនឡើងនូវហេដ្ឋានរចនាសម្ព័ន្ធ ផ្លូវថ្នល់ សំណង់អគារ មន្ទីរពេទ្យ សាលារៀន ជាច្រើនក៏មានសន្ទុះខ្លាំងនៅតំបន់ទំនាបកណ្តាលផងដែរ។ ការរៀបចំ និងការគ្រប់គ្រងនូវស្ថាបត្យកម្ម និងសំណង់ទូទៅនៃប្រទេសម្ពុជាមានភាពស្មុគ្រស្មាញ និងលំបាកជាខ្លាំងដោយត្រូវឆ្លងកាត់នូវរបបសង្គ្រាម ជាច្រើនជំនាន់ និងប្រវត្តិសាស្ត្រច្រើនដំណាក់កាលផងដែរ។ ការផ្លាស់ប្តូរពីមួយរបបទៅមួយរបបតែងតែមានការប៉ះទង្គិចនឹងហេដ្ឋារចនាសម្ព័ន្ធ ជាពិសេសសំណង់អគារធំៗដែលមាននៅក្នុងទីក្រុងនិងទីប្រជុំជន។ ជាងនេះទៅទៀតអំឡុងពេលមួយសតវត្សរ៍ចុងក្រោយកម្ពុជា បានទទួលរងនូវសង្គ្រាមរ៉ាំរ៉ៃផ្ទៃក្នុងប្រទេសជាងម្ភៃឆ្នាំបានធ្វើឱ្យខូចខាតយ៉ាងធ្ងន់ធ្ងរនូវសំណង់អគារ រោងចក្រ ឧស្សាហកម្ម ផ្ទះសំបែង ផ្លូវថ្នល់ និងស្ថាបត្យកម្មប្រណីតៗជាច្រើនលើសលប់ ជាពិសេសធនធានមនុស្សដែលសុទ្ធសឹងជាបណ្ឌិតបញ្ញវន្តល្បីៗ។

ប៉ុន្តែនៅក្រោយឆ្នាំ១៩៩៣ មានការរៀបចំនូវរដ្ឋាភិបាលស្របច្បាប់ ព្រមទាំងមានការបង្កើតនូវក្រសួងស្ថាប័ននានាឡើងវិញ ជាហេតុធ្វើឱ្យមានការរីកដុះដាលស្នាដៃសំណង់អគារជាបន្តបន្ទាប់ជាថ្មីម្តងទៀតនៅលើទឹក

ដីនៃព្រះរាជាណាចក្រកម្ពុជា។ ការកើនឡើងនូវសំណង់អគារយ៉ាងគំហុកនៅក្នុងរាជធានីភ្នំពេញ និងតាមបណ្ដាខេត្តនានា ក្នុងអំឡុងពេលចុងក្រោយនេះបានបង្ហាញពីកំណើននៃការរីកចម្រើនក្នុងវិស័យសំណង់របស់កម្ពុជា។ ដើម្បីរៀបចំនូវហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកទេសសំណង់គ្រប់ប្រភេទប្រកបដោយស្តង់ដារ រាជរដ្ឋាភិបាលបានបង្កើតឡើងស្ថាប័នមួយចំនួន ក្នុងគោលបំណងទទួលខុសត្រូវចំពោះវិស័យសំណង់ និងសម្របសម្រួលផលប្រយោជន៍ដល់ប្រជាពលរដ្ឋ និងការវិនិយោគរបស់វិស័យឯកជន។ ស្ថាប័នដែលមានតួនាទីចម្បងនៅក្នុងវិស័យនេះគឺក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ក្នុងបរិបទបច្ចុប្បន្ន ការអភិវឌ្ឍសំណង់ក៏មានភាពស្មុគស្មាញដល់ការគ្រប់គ្រងនៃក្រសួងផងដែរ ដោយហេតុថាសំណង់ខ្លះមានការសុំអនុញ្ញាតសាងសង់បានត្រឹមត្រូវស្របតាមបទដ្ឋានគតិយុត្ត និងអនុវត្តតាមស្តង់ដារបច្ចេកទេស ដែលច្បាប់បានកំណត់ប៉ុន្តែសំណង់មួយខ្លះទៀតពុំបានសុំការអនុញ្ញាតតាមច្បាប់នោះទេ ព្រមទាំងពុំសមស្របតាមស្តង់ដារបច្ចេកទេស ដែលច្បាប់បានកំណត់ទៀតផង។ ជាហេតុធ្វើឱ្យមានកើតឡើងគ្រោះថ្នាក់នានាក្នុងកំឡុងពេលនៃការសាងសង់ ហើយសំណង់ខ្លះទៀតសាងសង់រួចរាល់ប៉ុន្តែពុំអាចប្រើប្រាស់បាន។ ដើម្បីពង្រឹងនូវការអនុវត្ត និងការពារបានចំពោះគ្រោះថ្នាក់កើតឡើងក្នុងវិស័យសំណង់ ក្រសួងរៀបដែនដីនគរូបនីយកម្ម និងសំណង់ បានចេញជាប្រកាស សេចក្តីណែនាំនានាក្នុងន័យជំរុញដល់ការគោរពច្បាប់សម្រាប់អ្នកពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ច។ លើសពីនេះទៅទៀត នៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានរៀបចំឡើងច្បាប់ស្តីពីសំណង់ ដែលមានបញ្ញត្តិអំពីសមត្ថកិច្ចគ្រប់គ្រងវិស័យសំណង់ បទបញ្ញត្តិបច្ចេកទេសសំណង់ ការគ្រប់គ្រងអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ ព្រមទាំងការកំណត់ការប្រើប្រាស់ និងសភាពគ្រោះថ្នាក់នៃសំណង់ផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ទោះជាយ៉ាងណាក្តី ចំពោះជីវភាពរស់នៅប្រចាំថ្ងៃ រួមទាំងក្នុងការងារទូទៅយើងពិនិត្យឃើញថាការយល់ដឹងអំពីគុណភាព សុវត្ថិភាពសំណង់ និងគ្រោះថ្នាក់នៃការសាងសង់ខុសបច្ចេកទេស នៅមានកម្រិតនៅឡើយ។ បន្ថែមពីលើនេះទៀត ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធពុំទាន់យល់ច្បាស់អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួននៅក្នុងការសាងសង់ ព្រមទាំងគម្រោងសំណង់ដែលកំពុងប្រតិបត្តិការ។ ចំណុចខ្វះខាតទាំងនេះគឺជាហេតុនៃការបង្កឱ្យមានការកើតឡើងគ្រោះថ្នាក់ក្នុងការសាងសង់ ជាក់ស្តែងការបាក់រលំអគារ ការស្រុតអគារ បង្កើតជាភយន្តរាយដល់អាយុជីវិតមនុស្សជាច្រើន។

តើការបញ្ចៀស និងគ្រប់គ្រងគ្រោះថ្នាក់នៃការសាងសង់មាននីតិវិធី និងដំណើរការដូចម្តេចខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ដោយសង្កេតឃើញថា ការការពារ និងការយល់ដឹងពីវិធានការបញ្ចៀសគ្រោះថ្នាក់សំណង់ ព្រមទាំងភាពចំបាច់នៃការជំរុញនូវការអនុវត្តច្បាប់ស្តីពីសំណង់ឱ្យកាន់តែមានប្រសិទ្ធភាព គឺពិតជាមានសារៈសំខាន់សម្រាប់ជីវភាពរស់នៅ និងការអភិវឌ្ឍក្នុងវិស័យសំណង់ ទើបនាងខ្ញុំសម្រេចចិត្តជ្រើសរើសយកប្រធានបទ «**នីតិវិធីគ្រប់គ្រងគ្រោះថ្នាក់នៃការសាងសង់នៅកម្ពុជា**» មកធ្វើជាប្រធានបទសារណាបញ្ចប់ការសិក្សា។

## ៤. ទំហំនៃការស្រាវជ្រាវ

ការសិក្សានូវប្រធានបទនេះ គឺធ្វើឡើងក្នុងដែនកំណត់ និងមានវិសាលភាពចំពោះទិដ្ឋភាពនៃគ្រោះថ្នាក់សំណង់ទាំងក្នុងវិស័យឯកជន និងសាធារណៈ(នីតិបុគ្គល និងរូបវន្តបុគ្គល) ព្រមជាមួយគ្នានោះផងដែរក៏បានបង្ហាញអំពីនិតិវិធីនៃការគ្រប់គ្រងគ្រោះថ្នាក់នៃការសាងសង់ ទាំងចំពោះលក្ខខណ្ឌគតិយុត្ត និងផ្នែកមួយចំនួននៃដំណើរការបច្ចេកទេស។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សម្រាប់ការសិក្សាស្រាវជ្រាវមួយនេះ គឺធ្វើឡើងដើម្បីជាប្រយោជន៍ដល់និស្សិត អ្នកសិក្សាស្រាវជ្រាវ និងសាធារណជនគ្រប់ជាន់ថ្នាក់ជាពិសេស គឺអ្នកពាក់ព័ន្ធនឹងវិស័យសំណង់ឱ្យកាន់តែជ្រួតជ្រាប និងយល់ដឹងកាន់តែស៊ីជម្រៅទាក់ទងនឹងការការពារ និងបង្ការនូវគ្រោះថ្នាក់ដែលកើតឡើងដោយថាហេតុ។ មិនតែប៉ុណ្ណោះឯកសារស្រាវជ្រាវមួយនេះក៏ជាប្រយោជន៍សម្រាប់តម្កល់ជាឯកសារដល់អ្នកសិក្សា ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីនីតិវិធីក្នុងដំណើរការនៃការសាងសង់នៅកម្ពុជាផងដែរ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រនៃការស្រាវជ្រាវប្រធានបទនេះ ដោយជ្រើសរើសនូវឯកសារស្របច្បាប់ និងយោងតាមលិខិតបទដ្ឋានគតិយុត្ត សំខាន់ៗមានដូចជា ច្បាប់ ព្រះរាជក្រឹត្យ ព្រះរាជក្រម អនុក្រឹត្យ ប្រកាស សេចក្តីណែនាំ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀតដែលចេញដោយក្រសួង ស្ថាបន ពាក់ព័ន្ធនឹងវិស័យសំណង់។

បន្ថែមពីលើនេះទៀត នាងខ្ញុំបានទទួលការណែនាំ និងមតិយោបល់ពីសំណាកសាស្ត្រាចារ្យដឹកនាំ ដែលលោកមានបទពិសោធច្រើនទាក់ទងនឹង វិស័យនគរូបនីយកម្ម និងសំណង់។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីជាគន្លឹះក្នុងការដោះស្រាយបញ្ហាចោទខាងលើឱ្យកាន់តែមានភាពងាយស្រួល និងក្បោះក្បាយ ព្រមទាំងឆ្លងទៅរកការបកស្រាយប្រធានបទស្តីពី «នីតិវិធីគ្រប់គ្រងគ្រោះថ្នាក់នៃការសាងសង់នៅកម្ពុជា» នាងខ្ញុំសូមធ្វើការបែងចែក និងបកស្រាយជា **២ជំពូក**ដូចខាងក្រោមៈ

❖ **ជំពូកទី១ «ទិដ្ឋភាពនៃការសាងសង់នៅកម្ពុជា»៖** នៅក្នុងជំពូកនេះនាងខ្ញុំ លើកឡើង៣ ចំណុចធំៗដែលចំណុចទី១ នឹងធ្វើការបកស្រាយអំពី ស្ថានភាពទូទៅនៃការសាងសង់នៅកម្ពុជា ចំណុចទី២ បទប្បញ្ញត្តិនៃបច្ចេកទេសសាងសង់ និងចំណុចចុងក្រោយ គឺការបង្កើតមន្ទីរពិសោធន៍សំណង់ និងការត្រួតពិនិត្យផលិតផលសំណង់។

❖ **ជំពូកទី២ «នីតិវិធីគ្រប់គ្រងគ្រោះថ្នាក់នៃការសាងសង់នៅកម្ពុជា»៖** ជំពូកនេះផងដែរ នាងខ្ញុំនឹងធ្វើការបកស្រាយ ទៅលើ ៣ចំណុចដែលផ្សារភ្ជាប់ទៅនឹងចំណុចខាងលើគឺ ទី១ពាក់ព័ន្ធនឹងការត្រួតពិនិត្យការងារសាងសង់ និងរុះរើសំណង់។ ចំណែកឯចំណុចទី២ គឺការគ្រប់គ្រងដំណើរការសាងសង់ និងចំណុចទី៣ចុងក្រោយ គឺការទទួលខុសត្រូវ និងវិធានការបញ្ចៀសគ្រោះថ្នាក់ការសាងសង់។

# ជំពូកទី១
# ទិដ្ឋភាពនៃការសាងសង់នៅកម្ពុជា

# ជំពូកទី១
# ទិដ្ឋភាពនៃការសាងសង់នៅកម្ពុជា

វិស័យសំណង់នៅកម្ពុជា ជាវិស័យមួយដែលមានសក្តានុពលខ្លាំងក្លានាពេលបច្ចុប្បន្ននេះ មិនថាតែក្នុងវិស័យឯកជន ឬវិស័យសាធារណៈនោះទេ។ ជាក់ស្តែងយើងសង្កេតឃើញថាសំណង់អគារធំៗ ផ្ទះល្វែង បុរីវីឡា រោងចក្រ សហគ្រាស បូករួមទាំងអគារក្រសួង ស្ថាប័ន មន្ទីរ នៅរាជធានីភ្នំពេញ និងតាមបណ្តាលខេត្តនានាកំពុងរីកដុះដាលជ្រោងឡើងពាសពេញផ្ទៃប្រទេស។ សំណង់អគារទាំងនោះមានលក្ខណៈចម្រុះ ដែលរួមមានបែបបុរាណខ្មែរនិងបែបសម័យទំនើប។ វិស័យនេះ គឺជាកម្លាំងចលករនៃសេដ្ឋកិច្ចកម្ពុជាមួយផ្នែកធំផងដែរ។ ដូច្នេះកម្ពុជាកំពុងតែប្រឹងប្រែងពេញទំហឹងក្នុងការអភិវឌ្ឍបន្ថែមទៅលើវិស័យសំណង់ ដើម្បីពង្រឹងនូវកំណើននៃការវិនិយោគក្នុងស្រុក ក៏ដូចជាវិនិយោគិនបរទេស។ ទន្ទឹមនឹងការវិវត្តឥតឈប់ឈរនៃសំណង់អគារនៅក្នុងប្រទេសម្ពុជា ក៏មានជាបញ្ហាផ្សេងៗដែលកើតមានឡើង តម្រូវឱ្យមានការដោះស្រាយជាបន្តបន្ទាប់។ ចំពោះការសាងសង់ដែលសមស្របតាមបទដ្ឋានគតិយុត្តច្បាប់បានកំណត់ មានការស្នើសុំសាងសង់ត្រឹមត្រូវ ទាំងប្លង់ស្ថាបត្យកម្ម គ្រឿងបង្គុំ ការត្រួតពិនិត្យបច្ចេកទេសសំណង់ ការត្រួតពិនិត្យគុណភាពសំណង់ ពុំមានជាបញ្ហាចោទនោះទេ។ ប៉ុន្តែចំពោះសំណង់មួយចំនួន ដូចជាសំណង់អនាធិបតេយ្យ និងសំណង់ដែលពុំមានលិខិតអនុញ្ញាតឱ្យសាងសង់ គឺជាបញ្ហាចោទដែលបណ្តាលឱ្យដំណើរការនៃការសាងសង់អាចមានជាគ្រោះថ្នាក់កើតឡើងដោយយថាហេតុ។ ដើម្បីជាដំណោះស្រាយចំពោះបញ្ហាទាំងនេះស្ថាប័នពាក់ព័ន្ធជាពិសេសក្រសួងរៀបចំ-ដែនដី នគរូបនីយកម្ម និងសំណង់ បានតាក់តែងនិងរៀបចំឡើងនូវច្បាប់ បទបញ្ញត្តិ វិធានការ ប្រកាស និងសេចក្តីណែនាំនានាស្តីពីការរក្សាសុវត្ថិភាពក្នុងវិស័យសំណង់។[1]

## ១.១. ស្ថានភាពទូទៅនៃការសាងសង់នៅកម្ពុជា

វិស័យសំណង់នៅក្នុងប្រទេសកម្ពុជាកំពុងមានការរីកចម្រើនយ៉ាងខ្លាំង។ ការរីកចម្រើននៃវិស័យសំណង់នៅកម្ពុជា បានផ្លាស់ប្តូរមុខមាត់នៃទីក្រុងជាច្រើន។ កំណើននៃការសាងសង់នេះនៅតែបន្តកើនឡើង បើទោះបីជាសំណើស្នើសុំការសាងសង់គឺត្រូវចំណាយអស់ថវិកាជាច្រើន និងមានរយៈពេលយូរជាងប្រទេសដទៃទៀតក៏ដោយ។ មតិព្រួយបារម្ភជុំវិញស្តង់ដានៃការសាងសង់ និងសុវត្ថិភាពនៅការដ្ឋានត្រូវបានលើកឡើង។ ទាំងនេះនឹងអាចត្រូវបានយកទៅពិភាក្សាខ្លះៗក្នុងការធ្វើសេចក្តីព្រាងច្បាប់នៃការសាងសង់ថ្មី ដែលកំពុងតែដំណើរការនៅពេលថ្មីៗនេះ។[2]

---

[1] គេហទំព័រ https://opendevelopmentcambodia.net/km/topics/construction/ដកស្រង់នៅថ្ងៃទី៣០ខែឧសភាឆ្នាំ២០២២

[2] គេហទំព័រ https://construction-property.com/km/construction-safety-handbooks-campaign-goes-nationwide/ ដកស្រង់ថ្ងៃទី ០២ ខែមិថុនា ឆ្នាំ២០២២

### ១.១.១. បញ្ហាប្រឈមនៅក្នុងវិស័យសំណង់នៅកម្ពុជា

វិស័យសំណង់ គឺជាវិស័យមួយដែលបាននឹងកំពុងដំណើរការយ៉ាងមមាញឹកនៅរាជធានីភ្នំពេញ ក៏ដូចជានៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

បញ្ហាប្រឈមកើតមានក្នុងវិស័យសំណង់នៅកម្ពុជាមានជាចម្បងដូចជា៖

- ការសាងសង់មុនលិខិតអនុញ្ញាត ឬខុសពីលិខិតអនុញ្ញាត
- ការស្រង់ទិន្នន័យសំណង់នៅពុំទាន់បានកែលម្អស៊ីជម្រៅ
- ការចេញលិខិតអនុញ្ញាតបើក និងបិទការដ្ឋាន មិនទាន់ឆ្លើយតបនឹងចំនួនលិខិតអនុញ្ញាតសាងសង់
- សណ្ដាប់ធ្នាប់នៅការដ្ឋាននៅមានកម្រិត
- ការអនុវត្តប្រកាសអន្តរក្រសួងរវាងក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅពុំទាន់បានពេញលេញដោយខ្វះរបាយការណ៍លម្អិតអំពីការដ្ឋានសំណង់ដែលសាងសង់ ខុសពីលិខិតអនុញ្ញាតសាងសង់ ឬសាងសង់មុនលិខិតអនុញ្ញាតសាងសង់
- សំណង់លំនៅដ្ឋានជាលក្ខណៈបុរីមួយចំនួនបានធ្វើការបំបែកប្លង់ដីជាឡូតិ៍
- ការដោះស្រាយវិវាទពាក់ព័ន្ធនឹងការសាងសង់នៅមានកម្រិត
- ពុំទាន់មានបទដ្ឋានបច្ចេកទេស ឬស្តង់ដារបច្ចេកទេសគ្រប់គ្រាន់ ដែលទទួលស្គាល់ជាផ្លូវការពីស្ថាប័នជំនាញ
- ការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យសំណង់ ពុំទាន់ទូលំទូលាយស្របតាមការវិវត្តនៃវិស័យសំណង់។[3]

ការអភិវឌ្ឍស្ថាប័ន ជាពិសេសការរគ្រប់គ្រងសំណង់ ការពង្រឹងអាជីវកម្មសំណង់ ការជំរុញវិនិយោគក្នុងវិស័យសំណង់ ការកសាងច្បាប់ បទបញ្ញត្តិពាក់ព័ន្ធ ការកំណត់ស្តង់ដារសំណង់ និងការពន្លឿនរយៈពេលចេញលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកបិទការដ្ឋាន ព្រមទាំងការផ្តល់វិញ្ញាបនបត្រប្រកបអាជីវកម្មសំណង់ជូនប្រជាពលរដ្ឋ និងវិនិយោគិន គឺជាកត្តាសំខាន់ចាំបាច់ និងបន្ទាន់។

ក្នុងលក្ខខណ្ឌជាក់ស្តែងស្ថាបត្យករ និងក្រុមអ្នកសាងសង់កម្ពុជាមិនចាំបាច់គិតគូរពីការការពារសម្រាប់ហានិភ័យនានាដែលអាចបង្កដោយគ្រោះរញ្ជួយដីដូចអ្នកសាងសង់នៅជប៉ុន ឬការប្រឈមនៃខ្យល់ព្យុះស៊ីក្លូន និងខ្យល់បក់ខ្លាំងដូចនៅប្រទេសហ្វីលីពីននោះទេ។ គ្រោះធម្មជាតិដែលពួកគេត្រូវតែយកចិត្តទុកដាក់ គឺទឹកជំនន់ដែលជន់ខ្លាំង និងបញ្ហានានាជុំវិញការងារសាងសង់គ្រឹះនៃសំណង់អាគារឱ្យបានរឹងមាំ។ បញ្ហាមួយផ្សេង

[3] គេហទំព័រ https://kohsantepheapdaily.com.kh/article/ ដកស្រង់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០២២

ទៀតក្នុងវិស័យនេះទាក់ទងនឹងទីកន្លែងដាក់លាក់នៃព្រំប្រទល់របស់អាគារអចលនទ្រព្យ ដែលរាំងស្ទះដល់ប្រព័ន្ធនៃការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី។ កត្តាសំខាន់ក្នុងការបញ្ចូលបទបញ្ញត្តិទៅក្នុងកិច្ចសន្យាសាងសង់ ដោយទាមទារឱ្យភាគីម្ខាងក្នុងចំណោមភាគីទាំងពីរចាត់វិធានការរឹងមាំដើម្បីកំណត់ និងរក្សាព្រំប្រទល់នៃអចលនទ្រព្យនោះក្នុងអំឡុងពេលនៃការសាងសង់។ ការពឹងផ្អែកលើសម្ភារៈសំណង់នាំចូលធ្វើឱ្យតម្លៃនៃការសាងសង់ក្នុងប្រទេសកម្ពុជាខ្ពស់ជាងក្នុងប្រទេសថៃ និងប្រទេសវៀតណាម។

### ១.១.២. និយមន័យ

សំណង់ដែលមានសភាពគ្រោះថ្នាក់សំដៅដល់សំណង់ ឬផ្នែកណាមួយនៃសំណង់ ឬសម្ភារៈសំណង់ បរិក្ខារដែលបំពាក់លើសំណង់ដែលអាចបង្កគ្រោះថ្នាក់ដល់សំណង់ជិតខាង ដល់អាយុជីវិត រាងកាយ សុខភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ អ្នកជិតខាង និងសាធារណជន។[4]

### ១.១.៣. ដំណើរការ និងការវិវឌ្ឍនៃការសាងសង់នៅកម្ពុជា

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានចូលរួមចំណែកយ៉ាងសកម្មក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលជារបៀបវារៈអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចកម្ពុជារបស់រាជរដ្ឋាភិបាល។ ក្រសួងបានសម្រេចនូវសមិទ្ធផលសំខាន់ថ្មីៗ ជាច្រើនលើការងារកសាងផែនការរូបវន្តក្នុងចក្ខុវិស័យនៃការរៀបចំដែនដី និងនគរូបនីយកម្មគ្រប់កម្រិត ការងារគ្រប់គ្រងសំណង់គ្រប់ប្រភេទ ការងារគ្រប់គ្រងដីធ្លី និងចុះបញ្ជីដីធ្លី ការងារដោះស្រាយវិវាទដីធ្លី ការងារគ្រប់គ្រង និងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនឹងការងារសម្បទានដីសង្គមកិច្ច និងអភិវឌ្ឍលំនៅឋានតម្លៃសមរម្យសម្រាប់ប្រជាពលរដ្ឋមានចំណូលមធ្យម ចំណូលទាប និងជនងាយរងគ្រោះជាដើម ចូលរួមបង្កើតបាននូវចលករ និងបរិយាកាសល្អប្រសើរសម្រាប់ធុរកិច្ច និងការវិនិយោគ ពង្រឹងភាពសុខដុម-រមនាក្នុងសង្គម និងជំរុញបង្កើនចំណូលរបស់រដ្ឋដែលជាគ្រឹះនៃការអភិវឌ្ឍសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។

## ១.២. បទប្បញ្ញត្តិនៃបច្ចេកទេសសាងសង់

ច្បាប់សម្រាប់វិស័យសំណង់ត្រូវបានតាក់តែងឡើង និងបានចូលជាធរមានក្នុងឆ្នាំ២០១៩។ ចំណុចសំខាន់សម្រាប់ច្បាប់នេះ គឺលក្ខណៈសម្បត្តិរបស់នៃអ្នកអនុវត្តន៍ (វិស្វករ ស្ថាបត្យករ និងជាងសំណង់)សន្តិសុខ និងសុវត្ថិភាព។ ច្បាប់នេះក៏បានបញ្ជាក់ពីកាតព្វកិច្ចរបស់ម្ចាស់នៃការដ្ឋានផងដែរ ក្នុងករណីដែលមានឧបទ្ទវហេតុផ្សេងៗកើតឡើង។ ច្បាប់ និងបទបញ្ញត្តិសម្រាប់ប្រើប្រាស់ក្នុងប្រទេសមួយចំនួនធំ ត្រូវបាន

[4] អនុក្រឹត្យលេខ ២២៦ អនក្រ.បក ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

សិក្សាមុនពេលកើតមានពង្រាងច្បាប់។ បទបញ្ញត្តិសាងសង់ថ្នាក់ជាតិដែលភ្ជាប់ជាមួយនឹងលិខិតប្រកាសដោយឡែកមួយ គឺត្រូវបានស្នើសុំដើម្បីកំណត់លើស្តង់ដារនៃការសាងសង់ទាក់ទងទៅនឹងការងារគ្រប់គ្រងគម្រោងសុវត្ថិភាពនៅការដ្ឋាន សុវត្ថិភាពអគ្គីភ័យ និងការត្រួតពិនិត្យការសាងសង់។

### ១.២.១. ការពិនិត្យមើលលើការចេញលិខិតអនុញ្ញាតសាងសង់

គ្មានលិខិតអនុញ្ញាតសាងសង់ណាមួយ អាចចេញឱ្យបានទេ បើលិខិតអនុញ្ញាតសាងសង់នោះពុំគោរពតាមប្លង់គោល និងប្លង់ប្រើប្រាស់ដីធ្លី(ក្នុងករណីដែលមានប្លង់ទាំងពីរនេះ) ឬប្រសិនបើពុំមានប្លង់ទាំងពីរនេះទេ នោះការអនុញ្ញាត ត្រូវអនុវត្តតាមបទបញ្ញាទូទៅស្តីពីការប្រើប្រាស់ដីធ្លីវិញ។ ជនទាំងឡាយដូចជា នីតិបុគ្គលសារធារណៈ ឬឯកជនត្រូវគោរពវិធាននេះជាចាំបាច់។[5]

**ក. ទំហំ និងលក្ខខណ្ឌនៃសំណង់ដែលត្រូវស្នើសុំលិខិតអនុញ្ញាតសាងសង់**

អនុលោមតាមអនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ រាល់ការសាងសង់ខាងក្រោមនេះតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ជាមុនៈ

- ➢ រាល់ការសាងសង់សំណង់ថ្មីក្នុងទីក្រុង និងទីប្រជុំជន
- ➢ រាល់ការសាងសង់ឡើងវិញជាថ្មី ការពង្រីក និង ការសង់បន្ថែមពីលើអគារដែលមានស្រាប់
- ➢ ការប្តូរទ្រង់ទ្រាយអគារដែលមានស្រាប់ ដែលការងារនេះកែប្រែៈ
  - ការប្រើប្រាស់របស់ផ្នែកអគារ
  - ទិដ្ឋភាពនៃអគារ
  - ការធ្វើបង្គន់អនាម័យ និង ការតភ្ជាប់ទៅបំពង់លូ
  - ការធ្វើអាងប្រព្រឹត្តកម្មទឹកកខ្វក់ តភ្ជាប់ទៅបំពង់លូ
  - បង្កើនផ្ទៃក្រឡាកម្រាលសំណង់
  - កន្លែងទទួលសាធារណជន
  - ទម្រង់ដី (ចាក់ដីបំពេញ ជីកយកដីចេញ ប្តូរប្រភេទដីស្រែចំការជាដីសាងសង់) ឬ ប៉ះពាល់ខ្លាំង ដល់ទិដ្ឋភាពទីដ្ឋានណាមួយ ដូចជាលប់បំបាត់បឹង ឬប្រឡាយបង្ហូរទឹក ឬផ្នែកណាមួយនៃប្រព័ន្ធ បង្ហូរទឹកចេញ ការកាប់ដើមឈើដែលមានស្រាប់ ។ ល។[6]

---

[5] មាត្រា៧ នៃអនុក្រឹត្យលេខ២២៤ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

[6] មាត្រា២ នៃអនុក្រឹត្យលេខ ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧

ដោយឡែក ចំពោះការសាងសង់ ឬការកែទ្រង់ទ្រាយបបនភណ្ឌ[7]ផ្សេងៗ ដែលអាចបង្កគ្រោះថ្នាក់ដោយអគ្គិភ័យ(ការដាក់ស៊ីទែនកន្លែងស្តុកប្រេងឥន្ធនៈ រោងជាងដែលមានផលិតផលគ្រឿងឆេះ កន្លែងទទួលសាធារណជន) ។ល។ ការប្តូរទ្រង់ទ្រាយអគារឧស្សាហកម្ម ការដាក់ប៉ាណូផ្សាយពាណិជ្ជកម្ម ការដាក់អង់តែនទូរទស្សន៍ និងទូរគមនាគមន៍ ប៉ាណូស្រូបពន្លឺព្រះអាទិត្យ ក៏ដូចជារាល់គ្រឿងដទៃទៀតដែលបំពាក់ទៅនឹងអគារ ហើយស្ថិតនៅជិតមាត់ផ្លូវ ឬតាំងចំទិសដែលគេអាចមើលឃើញ សាលាក្រុង និងសាលាខេត្តនឹងធ្វើការណែនាំដោយឡែក។

**ខ. សំណង់ដែលមិនតម្រូវឱ្យស្នើសុំលិខិតអនុញ្ញាតសាងសង់**

ចំពោះសំណង់ខាងក្រោមនេះគឺពុំចំណុះក្រោមលិខិតអនុញ្ញាតសាងសង់ឡើយ៖

❖ សំណង់ជាលំនៅឋានប្រជាពលរដ្ឋដែលស្ថិតនៅទីជនបទ ឬតំបន់ឆ្ងាយពីផ្លូវជាតិ ផ្លូវដែក និង ឆ្ងាយពីតំបន់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភ័ណ្ឌជាតិ តំបន់រក្សាទុកការពារដោយពុំគិតពីទំហំ ឬសម្ភារៈសំណង់ប្រើប្រាស់ឡើយ។

❖ ការជួសជុល និងថែរក្សាទាំងឡាយដែលមិនផ្លាស់ប្តូរទ្រង់ទ្រាយ ឬទិដ្ឋភាពសំណង់លើកលែងតែការជួសជុលនោះអាចបណ្តាលឱ្យប៉ះពាល់ដល់អ្នកជិតខាង។

❖ ការសាងសង់ទីសក្ការបូជា សាលាសំណាក់សាធារណៈ បណ្ណាការសិល្បៈ របស់រដ្ឋសម្រាប់សេវាសាធារណៈ ដែលរដ្ឋជាម្ចាស់កិច្ចការ។ ប៉ុន្តែការសាងសង់ទាំងនេះ តម្រូវឱ្យជូនដំណឹងអំពីគម្រោងសាងសង់ទៅអាជ្ញាធរមូលដ្ឋាន។ [8]

ស្របជាមួយគ្នានោះដែរ តាមអនុក្រឹត្យលេខ២២៤ ស្តីពីលិខិតអនុញ្ញាតសាងសង់ក៏មានករណីលើកលែងមួយចំនួនដែរ។ សំណង់ដែលមិនទាមទារឱ្យលិខិតអនុញ្ញាតសាងសង់មានដូចជា៖

➢ សំណង់អគារផ្ទាល់ដីដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាង ឬស្មើ១២ម៉ែត្រក្រឡា និងមានកម្ពស់ទាបជាង ឬស្មើ ៥ម៉ែត្រ

➢ លំនៅឋានធ្វើពីឈើ ផ្ទះថ្មក្រោម-ឈើលើ ផ្ទះតៀមធ្វើពីឈើ ឬថ្មនៅទីជនបទ ឬស្រែចម្ការ ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាង ឬស្មើ១០០ ម៉ែត្រក្រឡា និងមានកម្ពស់ទាបជាង ឬស្មើ៩ម៉ែត្រ (ត្រូវមិននៅក្នុងតំបន់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌ តំបន់អភិរក្ស ឬតំបន់ការពារ)

---

[7] ***បបនីយភណ្ឌ*** សំដៅដល់គ្រឿងផ្គុំឧបករណ៍ សម្ភារៈបរិក្ខារដែលតម្កល់ទុកវត្ថុឬផលិតផលគ្រឿងឆេះដែលអាចបង្កអគ្គិសភ័យផ្សេងៗ ជាយថាហេតុ និងដែលត្រូវទុកដាក់ឱ្យបានល្អ។

[8] មាត្រា៣ នៃអនុក្រឹត្យលេខ៨៦ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតិសាងសង់ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧

- សំណង់មិនមែនបេតុងដែលសាងសង់ផ្ទាល់ដី សម្រាប់ប្រើប្រាស់បណ្ដោះអាសន្នមានជាអាទិ៍ បង្គោល ដងទង់ វេទិកា រោង តូប ឬគ្រឿងផ្គុំដទៃទៀតសម្រាប់ប្រារព្ធពិធីផ្សេងៗ
- សំណង់ក្នុងវត្តអារាមដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាង ឬស្មើ២០ ម៉ែត្រក្រឡា និងមានកម្ពស់ទាបជាង ឬស្មើ១២ម៉ែត្រ
- សំណង់របងដែលមិនធ្វើអំពីថ្ម ឬបេតុង
- ការងារសាងសង់ក្នុងស្ថានភាពអាសន្ន ឬគ្រោះមហន្តរាយ ដើម្បីជួយសង្គ្រោះ ឬការពារអាយុជីវិត ឬបង្ការមិនឱ្យមានការប៉ះពាល់ ឬខូចខាតធ្ងន់ធ្ងរដល់សុខភាព ឬទ្រព្យសម្បត្តិក្នុងភាពអាសន្ន ចំពោះការងារសំណង់ប្រភេទទាំងនេះ មុននឹងសាងសង់ ម្ចាស់សំណង់គ្រាន់តែជូនដំណឹងជាលាយលក្ខណ៍អក្សរទៅមេឃុំ ឬចៅសង្កាត់ដែលសំណង់នោះ ស្ថិតនៅតែប៉ុណ្ណោះ។ ក្រៅពីប្រភេទការងារសាងសង់ខាងលើ ម្ចាស់សំណង់ទាំងអស់ ត្រូវស្នើសុំលិខិតអនុញ្ញាតសាងសង់ពីអាជ្ញាធរមានសមត្ថកិច្ច នៅរដ្ឋបាលស្រុកខណ្ឌ ឬរដ្ឋបាលរាជធានី ខេត្ត ឬក្រសួង ទៅតាមប្រភេទ និងទំហំនៃផ្ទៃក្រឡានៃគម្រោងសាងសង់នោះ។

គួរបញ្ជាក់ផងដែរថា ការចេញលិខិតអនុញ្ញាតសាងសង់ គឺជាសមត្ថកិច្ចរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់។ ប៉ុន្តែអនុលោមតាមលិខិតលេខ ១០៦៦ ចុះថ្ងៃទី ០២ ខែឧសភា ឆ្នាំ២០១៨ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ និង លិខិតលេខ ១៤៧២ ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ២០១៨ របស់ក្រសួងមហាផ្ទៃ រដ្ឋបាលក្រុង ស្រុក ខណ្ឌដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្តនីមួយៗ អាចចេញលិខិតអនុញ្ញាត សាងសង់លំនៅឋានដែលមានផ្ទៃក្រឡាសំណង់សរុបមិនលើសពី ៥០០ម$^២$ និងមានកម្ពស់មិនលើសពី ៤ជាន់ រួមទាំងជាន់ផ្ទាល់ដី (E0 E១ E២ E៣)។[៩]

គោលការណ៍ថ្មីបានកំណត់ថា សំណង់រដ្ឋ ចាំបាច់ត្រូវមានការត្រួតពិនិត្យដោយក្រុមការងារជំនាញរបស់ក្រសួងដែនដីជាមុនសិន មុននឹងផ្តល់លិខិតអនុញ្ញាតឱ្យសាងសង់សំណង់នោះ ហើយសំណង់ឯកជន ចាំបាច់ត្រូវមានការត្រួតពិនិត្យដោយក្រុមហ៊ុនឯកជន និងអ្នកមានវិជ្ជាជីវៈជាមុនសិន មុននឹងត្រូវផ្តល់លិខិតអនុញ្ញាតឱ្យសាងសង់សំណង់នោះ។ ក្រុមហ៊ុន និងអ្នកមានវិជ្ជាជីវៈ អាចត្រួតពិនិត្យសំណង់ឯកជនបាន លុះត្រាតែទទួលបានអាជ្ញាបណ្ណពីក្រសួងដែនដី។ គោលការណ៍ថ្មីនេះ នឹងត្រូវអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២២ តទៅ។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានចេញគោលការណ៍ថ្មីមួយ ដើម្បីពង្រឹងវិស័យសំណង់នៅកម្ពុជា នោះគឺការត្រួតពិនិត្យជាមុនសិន មុននឹងចេញលិខិតអនុញ្ញាតឱ្យសំណង់ណាមួយ ចាប់ផ្តើមដំណើរការសាងសង់។ ប៉ុន្តែ ចំពោះការសាងសង់សំណង់ ជាពិសេសសំណង់ជាផ្ទះរបស់ប្រជាពលរដ្ឋ ដែលមានផ្ទៃតូច

---

[៩] មាត្រា៥ នៃអនុក្រឹត្យលេខ២២៤ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០

ជាង៥០០ម៉ែត្រការ៉េ មិនតម្រូវឱ្យមានការត្រួតពិនិត្យជាមុននោះទេ។ ដើម្បីពង្រឹងចំណុច៤យ៉ាងក្នុងវិស័យសំណង់ដែលកំពុងរីកដុះដាលខ្លាំង រួមមាន សោភ័ណភាព សុវត្ថិភាព គុណភាព និងរបៀបរៀបរយសាធារណៈ។ វិស័យសំណង់មានការរីកដុះដាលកាន់តែខ្លាំងការគ្រប់គ្រងលើវិស័យនេះ គឺតម្រូវឱ្យមានភាពហ្មត់ចត់កាន់តែខ្លាំង។ ការសាងសង់សំណង់ ដែលមានផ្ទៃធំជាង៥០០ម៉ែត្រការ៉េ ដល់ ៣០០០ម៉ែត្រការ៉េ ត្រូវសុំការអនុញ្ញាតនៅថ្នាក់រាជធានី ខេត្ត។ សំណង់អាគារពាណិជ្ជកម្មនានា ដែលមានទំហំធំជាង ៣,០០០ម៉ែត្រការ៉េ ចាំបាច់ត្រូវមានលិខិតអនុញ្ញាតពីក្រសួង។ ការសាងសង់ត្រូវចាប់ផ្តើមក្នុងរយៈពេលមួយឆ្នាំ បន្ទាប់ពីពេលដែលការអនុញ្ញាតិត្រូវបានប្រកាស។ រាល់ការពន្យារពេលសាងសង់អាចធ្វើទៅបាន លុះត្រាតែមានសំណុំឯកសារសុំពន្យារពេល។ វិញ្ញាបនបត្រត្រូវ ផ្តល់ជូនបន្ទាប់ពីការងារសាងសង់ត្រូវបានបញ្ចប់។ សំណង់លំនៅដ្ឋានដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាង ឬស្មើ៥០០(ប្រាំរយ)ម៉ែត្រក្រឡា និងមានកម្ពស់ទាបជាង៤ជាន់រួមទាំងជាន់ផ្ទាល់ដី និងគ្មានជាន់ក្រោមដី។ ការងារសាងសង់សំណង់លំនៅឋានសារឡើងវិញជាថ្មី ការងារសាងសង់បន្ថែម ឬការងារកែប្រែសំណង់លំនៅដ្ឋានដែលមានស្រាប់ ដែលមានផ្ទៃក្រឡាកម្រាលសំណង់ចាស់បូកផ្ទៃក្រឡាសំណង់ថ្មីសរុបលើសពីទំហំផ្ទៃក្រឡាកម្រាលាសំណង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ និងតិចជាងឬស្មើ៥០០(ប្រាំរយ)ម៉ែត្រក្រឡា។ ជាមួយគ្នានោះផងដែរ របងថ្ម ឬបេតុងដែលមានកម្ពស់ទាបជាងឬស្មើ៣(បី) ម៉ែត្រ នោះអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់និងភូមិបាលនៃរដ្ឋបាលក្រុង ខណ្ឌជាសេនាធិការមានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតអនុញ្ញាតរុះរើ ចំពោះសំណង់ការងារដូចខាងលើ។[10]

### ១.២.២. នីតិវិធីនៃការស្នើសុំសាងសង់

ដើម្បីដោះស្រាយ និងឆ្លើយតបនឹងបញ្ហាប្រឈមនាពេលបច្ចុប្បន្ន ក៏ដូចជាអនាគតសម្រាប់វិស័យសំណង់គួសបញ្ជាក់ថា ការអភិវឌ្ឍស្ថាប័ន ជាពិសេស ការគ្រប់គ្រងសំណង់ ការពង្រឹងអាជីវកម្មសំណង់ការជំរុញវិនិយោគក្នុងវិស័យសំណង់ ការកសាងច្បាប់បទប្បញ្ញត្តិពាក់ព័ន្ធ ការកំណត់ស្តង់ដារសំណង់ និងការពន្លឿនរយៈពេលចេញលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើក-បិទការដ្ឋានសាងសង់ព្រមទាំងការផ្តល់វិញ្ញាបនបត្រប្រកបអាជីវកម្មសំណង់ជូនប្រជាពលរដ្ឋ និងវិនិយោគិន គឺជាកត្តាសំខាន់ចាំបាច់ និងបន្ទាន់។ មកដល់បច្ចុប្បន្ននេះអាជ្ញាធរគ្រប់ជាន់ថ្នាក់បាននឹងកំពុងអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ដែលជាមូលដ្ឋានសម្រាប់គ្រប់គ្រងការសាងសង់ទាំងក្នុងអំឡុងពេលសាងសង់ និងក្រោយពេលសាងសង់រួមមានច្បាប់ស្តីពីការរៀបចំដែនដី

[10] មាត្រា៤ នៃអនុក្រឹត្យលេខ២២៤ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០

នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ឆ្នាំ១៩៩៧ ប្រកាសអន្តរក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងពាក់ព័ន្ធមួយចំនួន ប្រកាស និងសេចក្តីណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ រួមទាំងលិខិតណែនាំរបស់ថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិជាច្រើនទៀត ។

**ក.ការស្នើសុំលិខិតអនុញ្ញាតសាងសង់**

ការសាងសង់សំណង់មួយឡើង លុះត្រាតែមានការអនុញ្ញាតដោយកម្មសិទ្ធិករនៃដី និងអ្នកដែលបានកាន់កាប់ដីស្របច្បាប់យល់ព្រមឱ្យមានការសាងសង់។ ការងារសាងសង់ មិនអាចអនុញ្ញាតលើដីដែលកំពុងមានវិវាទអំពីសិទ្ធិនៃការកាន់កាប់បានឡើយ។ លិខិតអនុញ្ញាតសាងសង់ គឺជាលិខិតមួយដែលមានអត្ថប្រយោជន៍យ៉ាងខ្លាំងសម្រាប់ការសាងសង់ ហើយវាក៏ជាលិខិតបទដ្ឋានគតិយុត្តមួយដែលបង្ហាញពីភាពស្របច្បាប់នៃការងារសាងសង់សំណង់ផងដែរ។ គោលគំនិតនៃការ ចេញលិខិតអនុញ្ញាតសាងសង់នេះ គឺដើម្បីធានាសុខុមាលភាពនៃសំណង់ និង សុវត្ថិភាពសាធារណៈ ព្រមទាំងដើម្បីការពារដីធ្លីសាធារណៈចាំបាច់ សម្រាប់ធានាដល់ដំណើរការរៀបចំទីក្រុងឱ្យបានល្អប្រសើរ។

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវធ្វើជាភាសាខ្មែរ និងត្រូវមានភ្ជាប់ឯកសារបញ្ជាក់អំពីកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់ស្របច្បាប់នៃដីដែលសំណង់តាំងនៅ សលាកបត្រក្បាលដី គម្រោងប្លង់ស្ថាបត្យកម្ម និងឯកសារបច្ចេកទេសផ្សេងៗទៀតដែលសម្រាប់បម្រើឱ្យការងារសាងសង់។

បែបបទ និងបរិបទនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ បែបបទ និងបរិបទនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយអភិបាលនៃគណៈអភិបាលរាជធានីខេត្ត ក្រុង ស្រុកខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្រោយពីការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[11]

**ខ. ប្លង់ស្ថាបត្យកម្ម**

ស្ថាបត្យកម្មសំដៅដល់សិល្បៈ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យានៃការបង្កើតរចនាសម្ព័ន្ធអគារ និងការសាងសង់ទាំងក្នុង និងក្រៅសំណង់ផ្សេងៗ ស្របតាមលក្ខណៈបច្ចេកទេស និងតាមសោភណភាពដែលបានគ្រោងទុកដោយឆ្លុះបញ្ចាំងពីអត្តសញ្ញាណជាតិ សង្គម និងការការពារបរិស្ថាន។[12] គម្រោងប្លង់ស្ថាបត្យកម្មត្រូវសិក្សា និង

[11] មាត្រា២១ នៃអនុក្រឹត្យលេខ២២៤ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០

[12] មាត្រា៤ នៃព្រះរាជក្រឹត្យ នស/រកត/១២១១/១១២៤ ស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១

ចុះហត្ថលេខាដោយរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ឬហត្ថលេខារបស់អ្នកវិជ្ជាជីវៈជាស្ថាបត្យករ និងនាយកបច្ចេកទេស ព្រមទាំងបោះត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[13]

ប៉ុន្តែចំពោះសំណង់ ដែលសាងសង់នៅតាមដងផ្លូវសាធារណៈវិញ គឺត្រូវដាក់ឱ្យប្រើប្រាស់ប្លង់ស្ថាបត្យកម្មតាមចិញ្ចើមផ្លូវ ផ្លូវថ្មើជើង និងគន្លងផ្លូវទោចក្រយានសម្រាប់សាធារណជន និងជនពិការ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។[14] ប្លង់ស្ថាបត្យកម្មចិញ្ចើមផ្លូវ ផ្លូវថ្មើជើង និងគន្លងផ្លូវទោចក្រយាន សម្រាប់សាធារណជន និងជនពិការ ត្រូវបានអនុវត្តសម្រាប់ផ្លូវរាជធានី ផ្លូវក្រុង និងផ្លូវទីប្រជុំជននានាក្នុងខេត្ត ដើម្បីធានាសោភណភាពសាធារណៈ និងការធ្វើចរាចរណ៍ប្រកបដោយសុវត្ថិភាព សុខុមាលភាព និងភាពងាយស្រួលដល់សាធារណជន និងជនពិការ។[15]

### គ. ការស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់

ការចាប់ផ្តើមដំណើរការសាងសង់សំណង់ថ្មី ការងារកែប្រែ ការងារដំឡើង និងការងាររុះរើត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ជាមុនសិនស្របតាមលិខិតអនុញ្ញាតសាងសង់ ឬរុះរើសំណង់នោះ។ ការដ្ឋានសំណង់ដែលបានចាប់ផ្តើមដំណើរការ ប៉ុន្តែបានផ្អាកសកម្មភាពទៅវិញ លើសពី១(មួយ)ឆ្នាំ ត្រូវមានលិខិតបន្តសុពលភាពលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ មុននឹងបន្តដំណើរការសាងសង់ ឬរុះរើ។[16]

គម្រោងប្លង់គ្រឿងផ្គុំ និងគម្រោងប្លង់បច្ចេកទេសដទៃទៀតត្រូវសិក្សា និងចុះហត្ថលេខាដោយរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ឬហត្ថលេខារបស់អ្នកវិជ្ជាជីវៈជាវិស្វករនិងនាយកបច្ចេកទេស ព្រមទាំងបោះត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់ ដែលមានអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

[13] វិធានទី១ នៃចំណុចទី១ នៃសេចក្តីណែនាំលេខ០០២ ដនស/សណន ស្តីពីការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០

[14] ប្រការ១ នៃសេចក្តីសម្រេចលេខ០៣៩ សសរ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់ស្ថាបត្យកម្មចិញ្ចើមផ្លូវ ផ្លូវថ្មើជើង និងគន្លងផ្លូវ ទោចក្រយានសម្រាប់សាធារណៈជន និងជនពិការ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨

[15] ប្រការ២ នៃសេចក្តីសម្រេចលេខ០៣៩ សសរ ស្តីពីការដាក់ឱ្យប្រើប្រាស់ប្លង់ស្ថាបត្យកម្មចិញ្ចើមផ្លូវ ផ្លូវថ្មើជើង និងគន្លងផ្លូវ ទោចក្រយានសម្រាប់សាធារណៈជន និងជនពិការ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨

[16] មាត្រា៣៧ នៃអនុក្រឹត្យលេខ២២៤ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០

➢ គម្រោងប្លង់គ្រឿងផ្គុំសំណង់ និងគម្រោងប្លង់បច្ចេកទេសដទៃទៀត ត្រូវមានការបញ្ជាក់អនុលោមភាពតាមបទដ្ឋានបច្ចេកទេសសំណង់ ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលទទួលស្គាល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

➢ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ត្រូវមានបញ្ជាក់អំពីអត្តសញ្ញាណរបស់អ្នកសាងសង់ វិស្វករប្រចាំការដ្ឋាន វិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន និងគម្រោងប្លង់រៀបចំការដ្ឋានសំណង់ដែលមានហត្ថលេខារបស់នាយកបច្ចេកទេស។[17]ការងារសាងសង់សំណង់ថ្មីត្រូវបានចាត់ទុកថាបានចាប់ផ្តើមដំណើរការ នៅពេលដែលការងារដីឬការងារគ្រឹះដំបូងត្រូវបានអនុវត្ត។ ការងារកែប្រែត្រូវបានចាត់ទុកថាបានចាប់ផ្តើមកាលណាផ្នែកណាមួយនៃសំណង់ ឬបរិក្ខារសំណង់ឬផលិតផលសំណង់ ឬផលិតផលសំណង់ត្រូវបានផ្លាស់ប្តូរ។ ការងារដំឡើងត្រូវបានចាត់ទុកថាបានចាប់ផ្តើម កាលណាផ្នែកណាមួយនៃសំណង់ ឬផលិតផលសំណង់ត្រូវបានភ្ជាប់ទៅនឹងសំណង់។ ក្នុងករណីអាជ្ញាធរមានសមត្ថកិច្ចមិនសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ឬរុះរើក្នុងរយៈពេលដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ម្ចាស់សំណើរអាចដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ចាប់ពីថ្ងៃផុតកំណត់នោះ។[18]

សុំណុំឯកសារស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់សម្រាប់ការងារសាងសង់ ត្រូវមានភ្ជាប់លិខិតអនុញ្ញាតសាងសង់ គម្រោងប្លង់គ្រឿងផ្គុំសំណង់ ឯកសារសិក្សាភូគព្ភសាស្ត្រ សៀវភៅបន្ទុកនៃការងារសាងសង់ កិច្ចសន្យាម៉ៅការសាងសង់ ឯកសារបច្ចេកទេសផ្សេងទៀតសម្រាប់បម្រើឱ្យការងារសាងសង់ និងវិញ្ញាបនបត្រធានារ៉ាប់រង ឬឯកសារបញ្ជាក់អំពីការចុះកិច្ចសន្យាធានារ៉ាបរងភារៈទទួលខុសត្រូវការដ្ឋាន ជាមួយក្រុមហ៊ុនធានារ៉ាប់រង។ ក្នុងករណីសំណង់ត្រូវបានអនុញ្ញាតឱ្យសាងសង់ ឬរុះរើដោយតុល្យភាពសំណុំឯកសារស្នើសុំលិខិតអនុញ្ញាត បើកការដ្ឋានសំណង់សម្រាប់ការងារសាងសង់ ឬរុះរើត្រូវមានភ្ជាប់បង្កាន់ដៃទទួលពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ឬរុះរើ និងឯកសារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ បន្ថែមពីលើនេះទៀតត្រូវបានរាប់បញ្ចូលជាឯកសារបច្ចេកទេស លិខិតឯកភាពជាគោលការណ៍របស់ក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិតាមការកំណត់របស់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។[19]

- **រយៈពេលនៃការចេញលិខិតអនុញ្ញាតបើកការដ្ឋាន**

រយៈពេលសម្រាប់សម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ត្រូវកំណត់ដូខាងក្រោមៈ

---

[17] ចំណុចទី២នៃសេចក្តីណែនាំលេខ០០២ ដនស/សណន ស្តីពីការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់ចុះថ្ងៃទី១០ខែមករាឆ្នាំ២០២០

[18] មាត្រា៣៨ នៃអនុក្រឹត្យលេខ២២៤ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០

[19] មាត្រា៣ នៃអនុក្រឹត្យលេខ២២៤ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០

- យ៉ាងយូរ២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ដោយច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ផ្ដល់ដោយអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។
- យ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។
- យ៉ាងយូរ ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ដោយការិយាល័យច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ផ្ដល់ដោយអភិបាលនៃគណៈភិបាលក្រុង ស្រុកខណ្ឌ។[20]

- **សុពលភាពនៃលិខិតអនុញ្ញាតបើកការដ្ឋានសំណង់**

លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ អស់សុពលភាពក្នុងករណីណាមួយដូចខាងក្រោម៖

- ការដ្ឋានសំណង់មិនបានចាប់ដំណើរការក្នុងរយៈពេល១(មួយ)ឆ្នាំគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតបើកការដ្ឋានសំណង់នោះ
- ការដ្ឋានសំណង់បានផ្អាកដំណើរការរយៈពេលលើសពី១(មួយ)ឆ្នាំ
- លិខិតអនុញ្ញាតសាងសង់ ឬរុះរើអស់សុពលភាពត្រូវបាននិរាករណ៍ ឬប្រកាសមោឃភាពដោយអាជ្ញាធរមានសមត្ថកិច្ចឬដោយតុលាការ។
- លិខិតអនុញ្ញាតបើកការដ្ឋានសំណង់អាចបន្តសុពលភាពបានតែមួយដងគត់
- លក្ខខណ្ឌនៃការបន្តសុពលភាពលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ត្រូវបានធ្វើតាមរយៈយន្តការច្រកចេញចូលតែមួយ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃមុនថ្ងៃផុតសុពលភាពលិខិតអនុញ្ញាតបើកការដ្ឋានសំណង់។

គ្មានការកែប្រែគម្រោងប្លង់ស្ថាបត្យកម្ម គម្រោងប្លង់គ្រឿងផ្គុំសំណង់ ឬគម្រោងប្លង់រុះរើដើមនៃលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់។[21]

ចំពោះការរៀបចំការដ្ឋាន គឺមន្ត្រីត្រួតពិនិត្យត្រូវចុះវាស់វែង និងបោះបង្គោលព្រំកំណត់ទីតាំងដែលត្រូវសាងសង់ស្របតាមគម្រោងប្លង់ស្ថាបត្យកម្ម ដែលទទួលបានការយល់ព្រមតាមរយៈលិខិតអនុញ្ញាតសាងសង់។ ការដ្ឋានសំណង់ត្រូវមានផ្ទាំងព័ត៌មានអំពីគម្រោងសាងសង់នៅពីមុខការដ្ឋានសំណង់ ជាអាទិ៍ឈ្មោះគម្រោង

---

[20] មាត្រា៤០ នៃអនុក្រឹត្យលេខ២២៤ អនក្រ.បក ស្ដីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០

[21] មាត្រា៤១ នៃអនុក្រឹត្យលេខ២២៤ អនក្រ.បក ស្ដីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០

សាងសង់ ឈ្មោះក្រុមហ៊ុនសាងសង់ ឈ្មោះមេក្រុមជាង ឈ្មោះម្ចាស់សំណង់ ឈ្មោះរបស់វិស្វករប្រចាំការដ្ឋាន និងលេខទូរស័ព្ទទំនាក់ទំនង លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋាន រូបភាពនេត្រាទស្សន៍នៃគម្រោងសាងសង់ និងអាសយដ្ឋាន ទីតាំងសំណង់។ ប្រតិបត្តិការតាមវិធានសុវត្ថិភាពដូចមានកំណត់ក្នុងប្រកាសលេខ ៣២ ប្រក/សណ ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០១ ស្ដីពីការគ្រប់គ្រងការដ្ឋានសំណង់ និងសៀវភៅណែនាំអំពីសុវត្ថិភាពក្នុងការដ្ឋានសំណង់(២០១៨) របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[22]

### ឃ. លិខិតបញ្ជាក់ពីដំណើរការសាងសង់

បន្ទាប់ពីទទួលបាននូវលិខិតអនុញ្ញាតសាងសង់ និងការត្រួតពិនិត្យអំពីប្លង់ស្ថាបត្យកម្មជាបន្តបន្ទាប់មកនៅតាមការដ្ឋាននីមួយៗត្រូវតែបញ្ជាក់អំពីដំណើរការការសាងសង់នៅក្នុងការដ្ឋានរបស់ខ្លួន។ និតិវិធី និងដំណើរការនៃការសាងសង់៖

- មានតែក្រុមហ៊ុនសាងសង់ ដែលមានអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ទើបអាចទទួលម៉ៅការសាងសង់បាន។ ក្រុមហ៊ុនសាងសង់អាចចុះកិច្ចសន្យាបន្តដើម្បីប្រគល់ការងារក្រោមការទទួលខុសត្រូវរបស់ក្រុមហ៊ុននោះ។ វិស្វករប្រចាំការដ្ឋានត្រូវចាត់តាំងដោយក្រុមហ៊ុនសាងសង់។
- ក្រុមជាងដែលមានវិញ្ញាបនបត្រក្រុមជាងសំណង់ ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានីខេត្តអាចទទួលម៉ៅការសាងសង់សំណង់ត្រូវស្ថិតក្រោមសមត្ថកិច្ចអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌការងាររបស់ក្រុមជាងសំណង់ ត្រូវស្ថិតក្រោមការទទួលខុសត្រូវទាំងស្រុងរបស់វិស្វករប្រចាំការដ្ឋានយ៉ាងតិច ០១(មួយ)រូប ដែលមានអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងដែលបានចុះកិច្ចសន្យាជាមួយម្ចាស់សំណង់។
- គ្រប់ការដ្ឋានសំណង់ ត្រូវមានសៀវភៅតាមដានការងារសាងសង់ដើម្បីកត់ត្រាអំពីការងារសាងសង់ ឬរុះរើជាប្រចាំ និងត្រូវដាក់ជូនមន្ត្រីត្រួតពិនិត្យសំណង់រាល់ពេលចុះត្រួតពិនិត្យ។
- អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់មន្ត្រីត្រួតពិនិត្យឱ្យចុះបំពេញការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ជាប្រចាំ។ មន្ត្រីត្រួតពិនិត្យសំណង់ មានមន្ត្រីជំនាញនៃអគ្គនាយកដ្ឋានសំណង់ មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត និងការិយាល័យនគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុកខណ្ឌ។

---

[22] ចំណុចទី៣ នៃសេចក្តីណែនាំលេខ០០២ ដនស/សណនស្តីពីការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០

- ក្រុមហ៊ុនសាងសង់ ឬវិស្វករប្រចាំការដ្ឋាន ត្រូវជូនដំណឹងមកមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីចុះត្រួតពិនិត្យលើការងារសាងសង់តាមដំណាក់កាលដូចខាងក្រោមៈ
    - ក្នុងពេលកំណត់ទីតាំងសាងសង់
    - ក្នុងពេលអនុវត្តការងារគ្រឹះ
    - ក្នុងពេលអនុវត្តការងារសសរជាន់ផ្ទាល់ដី
    - ក្នុងពេលអនុវត្តការងារគ្រឿងផ្គុំបន្តបន្ទាប់ទៀត។
- រាល់ពេលចុះពិនិត្យការដ្ឋាន មន្ត្រីត្រួតពិនិត្យសំណង់ត្រូវចុះហត្ថលេខាលើសៀវភៅការងារតាមដានការងារសាងសង់ និងធ្វើកំណត់ហេតុត្រួតពិនិត្យសំណង់ដោយមានហត្ថលេខារបស់មន្ត្រីត្រួតពិនិត្យសំណង់ និងវិស្វករប្រចាំការដ្ឋាន និងស្នាមមេដៃរបស់ម្ចាស់សំណង់ និងអ្នកពាក់ព័ន្ធ។
- ក្នុងករណីពិនិត្យឃើញថា ការងារសាងសង់ ឬរុះរើមិនអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់ គម្រោងប្លង់ស្ថាបត្យកម្មដែលបានអនុញ្ញាតរួចរាល់ និងបទប្បញ្ញត្តិដទៃទៀត អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការផ្អាក កែតម្រូវ បញ្ឈប់ តម្រូវឱ្យរុះរើ ឬវិធានការចាំបាច់ផ្សេងទៀត។
- អគ្គនាយកដ្ឋានសំណង់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីខេត្ត ការិយាល័យនគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុកខណ្ឌ ត្រូវចងក្រង និងរក្សារាល់កំណត់ហេតុរបាយការណ៍ត្រួតពិនិត្យសំណង់ រូបថត និងឯកសារពាក់ព័ន្ធផ្សេងទៀតតាមការដ្ឋានសំណង់នីមួយ ទាំងជាឯកសាររឹង និងឯកសារជាអេឡិចត្រូនិកសម្រាប់ប្រើប្រាស់ក្នុងករណីចាំបាច់។[23]

**ង. ការប្រើប្រាស់សំណង់**

ការប្រើប្រាស់សំណង់ ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ ត្រូវអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ចតាមរយៈវិញ្ញាបនបត្រប្រើប្រាស់សំណង់។ ម្ចាស់សំណង់ត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ មុននឹងប្រើប្រាស់ ឬដាក់ឱ្យប្រើប្រាស់សំណង់នោះ។ រាល់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ត្រូវមានការត្រួតពិនិត្យ និងបញ្ជាក់អនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ដោយអ្នកត្រួតពិនិត្យ និងបញ្ជាក់ដែលមានអាជ្ញាបណ្ណ ឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបដែនដីន គរូបនីយកម្ម និងសំណង់មុននឹងអាជ្ញាធរមានសមត្ថកិច្ចអនុញ្ញាតឱ្យចូលប្រើប្រាស់សំណង់។[24]

---

[23] ចំណុចទី៤នៃសេចក្តីណែនាំលេខ០០២ ដនស/សណនស្តីពីការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់ ចុះថ្ងៃទី១០ខែមករាឆ្នាំ២០២០

[24] មាត្រា៨៤ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

- **លក្ខខណ្ឌនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់**

អាជ្ញាធរមានសមត្ថកិច្ច អាចអនុញ្ញាតឱ្យចូលប្រើប្រាស់សំណង់ក្នុងរយៈពេលណាមួយជាបណ្តោះអាសន្នបាន ចំពោះសំណង់ទាំងមូល ឬផ្នែកណាមួយនៃគម្រោងសាងសង់ ក្នុងករណីដែលសំណង់ទាំងមូលឬផ្នែកណាមួយនៃគម្រោងសាងសង់នោះអាចប្រើប្រាស់បានដោយសុវត្ថិភាព។[25] លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

លក្ខខណ្ឌនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ មានដូចខាងក្រោម៖

- សំណង់ត្រូវសាងសង់ ជួលជុល ឬកែប្រែនៅលើដីដែលបានចុះបញ្ជីដោយរដ្ឋបាលសុរិយោដី ឬដីដែលកាន់កាប់ដោយស្របច្បាប់ ស្របតាមប្លង់សុរិយោដីប្លង់លម្អិតនគរូបនីយកម្ម ផែនការប្រើប្រាស់ដី ប្លង់គោលប្រើប្រាស់ដី ឬប្លង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ
- ការងារសាងសង់ ការងារជួសជុល ការងារកែប្រែ ឬការងាររុះរើបានចប់រួចរាល់ដោយអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន
- សំណង់មានគ្រឿងផ្គុំអាចទ្រទ្រង់បន្ទុកបានប្រកបដោយសុវត្ថិភាពទៅតាមមុខងារប្រើប្រាស់សំណង់
- សំណង់មានសុវត្ថិអគ្គិភ័យ អនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការ និងការបន្លត់អគ្គិភ័យ
- សំណង់មានប្រព័ន្ធមេកានិក អគ្គិសនី និងទឹកអាចប្រើប្រាស់បានប្រកបដោយសុវត្ថិភាព អនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន
- សំណង់ត្រូវបានសាងសង់ ជួសជុល ឬកែប្រែដោយប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលអាចធានាគុណភាពសំណង់ និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់ អនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ឬស្តង់ដារកម្ពុជា។[26]

ម្ចាស់សំណង់អាចដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្តោះអាសន្ន ដើម្បីអាចប្រើប្រាស់ផ្នែកនៃសំណង់ដែលបានសាងសង់រួច។ បុគ្គលដែលបានទទួលវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្តោះអាសន្នមានតព្វកិច្ចរៀបចំដំឡើងរបាំងឬមធ្យោបាយផ្សេងទៀត សម្រាប់ខណ្ឌផ្នែកនៃសំណង់ដែលត្រូវបានអនុញ្ញាតឱ្យចូលប្រើប្រាស់ពីផ្នែកនៃសំណង់ដែលមិនទាន់សាងសង់រួចដើម្បីធានាសុវត្ថិភាពក្នុងការប្រើប្រាស់សំណង់។

---

[25] មាត្រា៤៥ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[26] មាត្រា១២ នៃអនុក្រឹត្យលេខ ២២៦ អនក្រ.បក ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

វិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្ដោះអាសន្ន មានសុពលភាពត្រឹមថ្ងៃដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ត្រូវបានផ្ដល់ជូនសម្រាប់សំណង់ទាំងមូល។[27]

លក្ខខណ្ឌនៃការផ្ដល់វិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្ដោះអាសន្ន មានដូចខាងក្រោមៈ

- សំណង់ត្រូវសាងសង់ ជួលជុល ឬកែប្រែនៅលើដីដែលបានចុះបញ្ជីដោយរដ្ឋបាលសុរិយោដីឬដីដែលកាន់កាប់ដោយស្របច្បាប់ ស្របតាមប្លង់សុរិយោដីប្លង់លម្អិតនគរូបនីយកម្ម ផែនការប្រើប្រាស់ដី ប្លង់គោលប្រើប្រាស់ដី ឬប្លង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ
- គ្រឿងផ្គុំសំណង់សំខាន់ៗមានជាអាទិ៍គ្រឹះ សសរ ធ្នឹម កម្រាលខណ្ឌ ជញ្ជាំងទ្របន្ទុកនៃសំណង់ទាំងមូលត្រូវបានសាងសង់ ជួលជុល ឬកែប្រែរួចនិងមានសុវត្ថិភាព
- ការងារសាងសង់ ការងារជួសជុល ឬការងារកែប្រែផ្នែកនៃសំណង់ដែលជាកម្មវត្ថុនៃពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្ដោះអាសន្នបានចប់រួចរាល់ ដោយអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន
- ផ្នែកនៃសំណង់ ដែលជាកម្មវត្ថុនៃពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្ដោះអាសន្នមានសុវត្ថិភាពអគ្គិភ័យអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការ និងការពន្លត់អគ្គិភ័យ
- ផ្នែកនៃសំណង់ ដែលជាកម្មវត្ថុនៃពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្ដោះអាសន្នមានប្រព័ន្ធមេកានិក អគ្គិសនី និងទឹកអាចប្រើប្រាស់បានប្រកបដោយសុវត្ថិភាពអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមាន
- ផ្នែកនៃសំណង់ដែលជាកម្មវត្ថុនៃពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្ដោះអាសន្នត្រូវបានសាងសង់ពីសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ ដែលអាចធានាគុណភាពសំណង់និងសុវត្ថិភាពសំណង់របស់អ្នកប្រើប្រាស់អនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ឬស្តង់ដារកម្ពុជា
- ការប្រើប្រាស់ផ្នែកនៃសំណង់ដែលជាកម្មវត្ថុនៃពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់បណ្ដោះអាសន្នអាចអនុញ្ញាតឱ្យការងារសាងសង់ផ្នែកផ្សេងទៀត នៃសំណង់បន្តដំណើរការបានដោយសុវត្ថិភាព។[28]

---

[27] មាត្រា១០ នៃអនុក្រឹត្យលេខ ២២៦ អនក្រ.បក ស្ដីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្ដល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

[28] មាត្រា១៣ នៃអនុក្រឹត្យលេខ ២២៦ អនក្រ.បក ស្ដីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្ដល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

សំណង់ ដែលប្រើប្រាស់ក្នុងគោលដៅក្រៅពីលំនៅដ្ឋានតម្រូវឱ្យមានការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពក្នុងរយៈពេលយ៉ាងយូរ៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។ ការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពនេះត្រូវបន្តអនុវត្តជាទៀងទាត់រផងរាល់៥(ប្រាំ)ឆ្នាំម្តងយ៉ាងយូរ។ សំណង់ដែលប្រើប្រាស់ក្នុងគោលដៅលំនៅដ្ឋានតម្រូវឱ្យមានការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពក្នុងរយៈពេលយ៉ាងយូរ១០ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។ ការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពនេះត្រូវបន្តអនុវត្តជាទៀងទាត់រៀងរាល់១០(ដប់)ឆ្នាំម្តងយ៉ាងយូរ។ ការត្រួតពិនិត្យនិងការចេញសេចក្តីបញ្ជាក់អំពីគុណភាពប្រសិទ្ធភាពនៃប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យនៃសំណង់ត្រូវធ្វើឡើងសម្រាប់រយៈពេល២ (ពីរ) ឆ្នាំម្តង។ បរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់ ត្រូវមានការត្រួតពិនិត្យរៀងរាល់១(មួយ) ឆ្នាំម្តង។ ប្រភេទបរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់។ ម្ចាស់សំណង់ ឬអ្នកគ្រប់គ្រងសំណង់មានកាតព្វកិច្ចប្រគល់លទ្ធផលនៃការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ជូនអាជ្ញាធរមានសមត្ថកិច្ចក្នុងរយៈពេល១(មួយ)ខែ ក្រោយថ្ងៃផុតកំណត់រយៈពេលដែលតម្រូវឱ្យអនុវត្តការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់។[29]

- **លក្ខខណ្ឌនៃការប្តូរមុខងារប្រើប្រាស់សំណង់**

ការស្នើសុំប្តូរមុខងារប្រើប្រាស់សំណង់ ត្រូវធ្វើឡើងដោយម្ចាស់សំណង់។ អាជ្ញាធរមានសមត្ថកិច្ចអនុញ្ញាតឱ្យប្តូរមុខងារប្រើប្រាស់សំណង់ដោយផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មី។ ក្នុងករណីការប្តូរមុខងារប្រើប្រាស់សំណង់តម្រូវឱ្យមានការជួសជុល ការកែប្រែ ការដំឡើងបរិក្ខារសំណង់ឬផលិតផលសំណង់ ឬការរុះរើផ្នែកនៃសំណង់ដែលប៉ះពាល់សោភណភាពខាងក្រៅ រចនាសម្ព័ន្ធទ្រទ្រង់បន្ទុក ឬដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈម្ចាស់សំណង់ត្រូវស្នើសុំលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើជាមុន និងត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់ថ្មីក្រោយការងារជួសជុលការងារកែប្រែ ការងារដំឡើង ឬការងាររុះរើនោះត្រូវបានបញ្ចប់។

លក្ខខណ្ឌនៃការប្តូរមុខងារប្រើប្រាស់សំណង់ មានដូចខាងក្រោមៈ

- សំណង់មានគ្រឿងផ្គុំអាចទ្រទ្រង់បន្ទុកបានប្រកបដោយសុវត្ថិភាពទៅតាមមុខងារប្រើប្រាស់ថ្មីរបស់សំណង់
- ការងារជួសជុល ការងារកែប្រែ ការងារដំឡើង ឬការងាររុះរើសម្រាប់បម្រើមុខងារប្រើប្រាស់ថ្មីបានចប់រួចរាល់ដោយអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន
- សំណង់មានសុវត្ថិភាពអគ្គិភ័យចំពោះមុខងារប្រើប្រាស់ថ្មី អនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការនិងការពន្លត់អគ្គិភ័យ

[29] មាត្រា៤៧ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

❖ សំណង់មានប្រព័ន្ធមេកានិក អគ្គិសនី និងទឹកអាចប្រើប្រាស់បានប្រកបដោយសុវត្ថិភាពអនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានការងារជួសជុល ការងារកែប្រែ ឬការងារដំឡើងសម្រាប់បម្រើមុខងារប្រើប្រាស់ថ្មីដោយប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលអាចធានាគុណភាពសំណង់ និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់ អនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ឬស្តង់ដារកម្ពុជា។[30]

### ១.២.៣. អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់

ដើម្បីកំណត់ប្រភេទនិងកម្រិតនៃអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ ការបញ្ចប់សុពលភាព ការព្យួរ និងការដកហូតអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ ព្រមទាំងលក្ខខណ្ឌនៃការអនុវត្តការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់៖

- ធានាគុណភាព សន្តិសុខ សុវត្ថិភាពសំណង់ ការពារទ្រព្យសម្បត្តិនិងសុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន
- ធានាការងារសិក្សាគម្រោងប្លង់ ការងារសាងសង់ និងការងាររុះរើអនុលោមតាមបទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសសំណង់
- ធានាគណនេយ្យភាពនិងប្រសិទ្ធភាពក្នុងប្រកបវិជ្ជាជីវៈ និងការប្រកបអាជីវកម្មក្នុងវិស័យសំណង់
- បង្កើនជំនឿទុកចិត្តរបស់សាធារណជនលើវិស័យសំណង់
- ជំរុញការវិនិយោគនៅក្នុងវិស័យសំណង់ និងទីផ្សារអចលនទ្រព្យប្រកបដោយប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចនិងសង្គម។[31]

**ក.ប្រភេទនៃអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់**

អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ មាន៤ប្រភេទដូចខាងក្រោម៖

១. អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ទូទៅ

២. អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ផ្នែកស្ថាបត្យកម្ម

៣. អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ផ្នែកគ្រឿងបង្គុំសំណង់

---

[30] មាត្រា១៩ នៃអនុក្រឹត្យលេខ ២២៦ អនក្រ.បក ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

[31] មាត្រា១ នៃអនុក្រឹត្យលេខ ២២៥ អនក្រ.បក ស្តីពីលក្ខខណ្ឌនិងនិតិវិធីនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងទី៣០ ខែធ្នូ ឆ្នាំ២០២០

៤. អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ផ្នែកមេកានិច អគ្គិសនី និងទឹក។[32]

**ខ. លក្ខខណ្ឌនិងសុពលភាពនៃការផ្តល់អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់**

❖ **លក្ខខណ្ឌ**

ចំពោះអាជ្ញាបណ្ណត្រួតពិនិត្យសំណង់ទូទៅ មាន២(ពីរ)កម្រិតដូចខាងក្រោម៖

១. អាជ្ញាបណ្ណត្រួតពិនិត្យសំណង់ទូទៅកម្រិត១ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់សម្រាប់សំណង់គ្រប់ប្រភេទ។

២. អាជ្ញាបណ្ណត្រួតពិនិត្យសំណង់ទូទៅកម្រិត២ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់ ដែលសម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ។[33]

ដោយឡែកអាជ្ញាបណ្ណពិនិត្យនិងបញ្ជាក់ផ្នែកស្ថាបត្យកម្មមាន ៣(បី)កម្រិតដូចខាងក្រោម៖

- អាជ្ញាបណ្ណពិនិត្យ និងបញ្ជាក់ផ្នែកស្ថាបត្យកម្មកម្រិត១ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់សម្រាប់គម្រោងប្លង់ស្ថាបត្យកម្ម និងសម្រាប់ការងារសាងសង់ ឬរុះរើផ្នែកស្ថាបត្យកម្មសម្រាប់សំណង់គ្រប់ប្រភេទសម្រាប់គម្រោងប្លង់ស្ថាបត្យកម្ម និងសម្រាប់ការងារសាងសង់ ឬរុះរើផ្នែកស្ថាបត្យកម្មនៃសំណង់ ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ។
- អាជ្ញាបណ្ណពិនិត្យ និងបញ្ជាក់ផ្នែកស្ថាបត្យកម្មកម្រិត២ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់សម្រាប់គម្រោងប្លង់ស្ថាបត្យកម្ម និងសម្រាប់ការងារសាងសង់ ឬរុះរើផ្នែកស្ថាបត្យកម្មនៃសំណង់ ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ។
- អាជ្ញាបណ្ណពិនិត្យ និងបញ្ជាក់ផ្នែកស្ថាបត្យកម្មកម្រិត៣ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់សម្រាប់គម្រោងប្លង់ស្ថាបត្យកម្មនិងសម្រាប់ការងារសាងសង់ ឬរុះរើផ្នែក

[32] មាត្រា៥ នៃអនុក្រឹត្យលេខ ២២៥ អនក្រ.បក ស្តីពីលក្ខខណ្ឌនិងនិតិវិធីនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

[33] មាត្រា៦ នៃអនុក្រឹត្យលេខ ២២៥ អនក្រ.បក ស្តីពីលក្ខខណ្ឌនិងនិតិវិធីនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

ស្ថាបត្យកម្មនៃសំណង់ ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។[34]

បន្ថែមពីលើនេះទៀតអាជ្ញាបណ្ណពិនិត្យ និងបញ្ជាក់ផ្នែកគ្រឿងផ្គុំសំណង់មាន៣កម្រិតដូចខាងក្រោមផងដែរៈ

- ❖ អាជ្ញាបណ្ណពិនិត្យ និងបញ្ជាក់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត១ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់សម្រាប់គ្រឿងផ្គុំសំណង់ គម្រោងប្លង់គ្រឿងផ្គុំសំណង់ និងការងារសាងសង់ ឬរុះរើផ្នែកគ្រឿងផ្គុំសំណង់សម្រាប់សំណង់គ្រប់ប្រភេទ។
- ❖ អាជ្ញាបណ្ណពិនិត្យ និងបញ្ជាក់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត២ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់សម្រាប់គ្រឿងផ្គុំសំណង់ គម្រោងប្លង់គ្រឿងផ្គុំសំណង់ និងការងារសាងសង់ ឬរុះរើផ្នែកគ្រឿងផ្គុំសំណង់សម្រាប់សំណង់ ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- ❖ អាជ្ញាបណ្ណពិនិត្យ និងបញ្ជាក់ផ្នែកគ្រឿងផ្គុំសំណង់កម្រិត៣ សម្រាប់ផ្តល់ជូនអ្នកវិជ្ជាជីវៈដែលអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់សម្រាប់គ្រឿងផ្គុំសំណង់ គម្រោងប្លង់គ្រឿងផ្គុំសំណង់ និងការងារសាងសង់ឬរុះរើផ្នែកគ្រឿងផ្គុំសំណង់សម្រាប់សំណង់ ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃ គណៈអភិបាលក្រុង ស្រុក ខណ្ឌ។[35]

ចំពោះអាជ្ញាបណ្ណពិនិត្យ និងបញ្ជាក់សំណង់ផ្នែកមេកានិច អគ្គិសនី និងទឹកក៏បានចែកជា៣(បី)កម្រិតដូចគ្នាផងដែរៈ

- អាជ្ញាបណ្ណពិនិត្យ និងបញ្ជាក់សំណង់ផ្នែកមេកានិច អគ្គិសនីនិងទឹក កម្រិត១ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់សម្រាប់ គម្រោងប្លង់ប្រព័ន្ធមេកានិច អគ្គិសនី ទឹក និងការងារសាងសង់ ឬរុះរើផ្នែកមេកានិច អគ្គិសនី និងទឹកសម្រាប់សំណង់គ្រប់ប្រភេទ។
- អាជ្ញាបណ្ណពិនិត្យ និងបញ្ជាក់សំណង់ផ្នែកមេកានិច អគ្គិសនី និងទឹក កម្រិត២ សម្រាប់ផ្តល់ជូនក្រុមហ៊ុនដែលអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់សម្រាប់ប្រព័ន្ធមេកានិច អគ្គិសនី និងទឹក និងការងារសាងសង់ ឬរុះរើផ្នែកមេកានិច អគ្គិសនី និងទឹកសម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

---

[34] មាត្រា៧ នៃអនុក្រឹត្យលេខ ២២៥ អនក្រ.បក ស្តីពីលក្ខខណ្ឌនិងនិតិវិធីនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

[35] មាត្រា៨ នៃអនុក្រឹត្យលេខ ២២៥ អនក្រ.បក ស្តីពីលក្ខខណ្ឌនិងនិតិវិធីនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

- អាជ្ញាបណ្ណពិនិត្យ និងបញ្ជាក់សំណង់ផ្នែកមេកានិច អគ្គិសនី និងទឹក កម្រិត៣ សម្រាប់ផ្តល់ជូនអ្នកវិជ្ជាជីវៈតាមមុខជំនាញផ្នែកមេកានិក អគ្គិសនី និងទឹក ដើម្បីអនុវត្តការងារត្រួតពិនិត្យ និងបញ្ជាក់សំណង់សម្រាប់ គម្រោងប្លង់ប្រព័ន្ធមេកានិច អគ្គិសនី និងទឹក និងការងារសាងសង់ឬរុះរើផ្នែកមេកានិច អគ្គិសនី និងទឹក សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។[36]

❖ **សុពលភាព**

អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ អាចចេញបានតែមួយដងគត់ លើកលែងករណីដែលអាជ្ញាបណ្ណដែលបានបាត់បង់ រហែក ឬខូច ឬមានការប្តូរប្រធានក្រុមហ៊ុនឬនាយកបច្ចេកទេស។ ក្នុងករណីនេះអ្នកកាន់អាជ្ញាបណ្ណ ត្រូវដាក់ពាក្យស្នើសុំសន្លឹកអាជ្ញាបណ្ណថ្មីមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[37]

អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ មានសុពលភាព៣(បី)ឆ្នាំ គិតចាប់ពីថ្ងៃចេញអាជ្ញាបណ្ណ និងអាចបន្តជាថ្មីបាន។ ការដាក់ពាក្យស្នើសុំសុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវធ្វើនៅក្នុងរយៈពេលយ៉ាង៣០(សាមសិប)ថ្ងៃមុនកាលបរិច្ឆេទផុតសុពលភាព។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រេចបញ្ចប់សុពលភាពអាជ្ញាបណ្ណដោយប្រកាស។ ក្នុងករណីនេះ អាជ្ញាបណ្ណថ្មីត្រូវមានការបញ្ជាក់អំពីកាលបរិច្ឆេទនៃការផ្តល់អាជ្ញាបណ្ណលើកដំបូង។ ក្នុងរយៈពេលនៃការពិនិត្យសម្រេចលើពាក្យស្នើសុំសុពលភាព អាជ្ញាបណ្ណចាស់នៅបន្តសុពលភាពរហូតដល់ថ្ងៃដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់សម្រេចលើពាក្យស្នើសុំនោះ។ អ្នកកាន់អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលផុតសុពលភាព អាចបន្តអនុវត្តកាតព្វកិច្ចនៃកិច្ចសន្យាផ្តល់សេវាកម្មត្រួតពិនិត្យ និងបញ្ជាក់សំណង់ ដែលត្រូវបានបង្កើតឡើងនៅក្នុងកំឡុងពេលដែលអាជ្ញាបណ្ណនោះមានសុពលភាព ប៉ុន្តែមិនអាចបង្កើតកិច្ចសន្យាផ្តល់សេវាកម្មថ្មីឡើយ។[38]

អ្នកកាន់កាប់អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ អាចឈប់ប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មដោយស្ម័គ្រចិត្តមុនកាលបរិច្ឆេទផុតសុពលភាពអាជ្ញាបណ្ណ។ ក្នុងករណីនេះ អ្នកកាន់កាប់អាជ្ញាបណ្ណត្រូវបញ្ជាក់អះអាង

[36] មាត្រា៩ នៃអនុក្រឹត្យលេខ ២២៥ អនក្រ.បក ស្តីពីលក្ខខណ្ឌនិងនិតិវិធីនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ ២០២០

[37] មាត្រា២២ នៃអនុក្រឹត្យលេខ ២២៥ អនក្រ.បក ស្តីពីលក្ខខណ្ឌនិងនិតិវិធីនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

[38] មាត្រា២៣ នៃអនុក្រឹត្យលេខ ២២៥ អនក្រ.បកស្តីពីលក្ខខណ្ឌនិងនិតិវិធីនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

ជាលាយលក្ខណ៍អក្សរថាបានអនុវត្តចប់សព្វគ្រប់នូវកាតព្វកិច្ចទាំងឡាយដែលបានបង្កើតឡើងដោយកិច្ចសន្យាសេវាកម្មត្រួតពិនិត្យនិងបញ្ជាក់សំណង់។

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រេចបញ្ចប់សុពលភាពអាជ្ញាបណ្ណដោយប្រកាស។ ការបញ្ចប់សុពលភាពអាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ មិនធ្វើឱ្យអ្នកស្នើសុំរួចផុតពីការទទួលខុសត្រូវក្នុងការខូចខាតដែលបង្កឡើងដល់អតិថិជន ឬអ្នកដទៃដោយសារវិការៈនៃការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់របស់ខ្លួនឡើយ។[39]

## ១.៣. ការបង្កើតមន្ទីរពិសោធន៍សំណង់ និងការត្រួតពិនិត្យផលិតផលសំណង់

### ១.៣.១. ការបង្កើតមន្ទីរពិសោធន៍គណៈវិស្វករកម្ពុជា

#### ក. គោលបំណង

មន្ទីរពិសោធន៍សំណង់ត្រូវបានបង្កើតឡើងក្នុងគោលបំណងសំខាន់ៗដូចខាងក្រោម៖

- ផ្ដល់ឱ្យគណៈវិស្វករកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រង ត្រួតពិនិត្យ វិភាគតាមដាន និងធ្វើកោសល្យវិច័យ លើការប្រកបវិជ្ជាជីវៈវិស្វកម្មនៅព្រះរាជាណាចក្រកម្ពុជា។
- សហការបណ្ដុះបណ្ដាលបំប៉នវិជ្ជាជីវៈវិស្វកម្មជាក់ស្ដែង ដល់វិស្វករចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីអភិវឌ្ឍសមត្ថភាពក្នុងការប្រតិបត្តិវិជ្ជាជីវៈវិស្វកម្មគ្រប់មុខជំនាញទាំងទ្រឹស្ដីទាំងបទពិសោធ ឱ្យមានលក្ខណៈសម្បត្តិតាមស្តង់ដារកំណត់ ឆ្លើយតបបានទៅនឹងតម្រូវការទីផ្សារពលកម្មក្នុងស្រុក តំបន់ និងអន្តរជាតិ។
- បង្កលក្ខណៈងាយស្រួលដល់គណៈវិស្វករកម្ពុជា ដើម្បីធ្វើការសិក្សា វិភាគ វាយតម្លៃគុណភាពសម្ភារៈបរិក្ខារសម្រាប់ប្រើប្រាស់ក្នុងវិស័យវិស្វកម្ម។
- តាមដានការងារអនុវត្តរបស់វិស្វករអាជីព ដើម្បីការណែនាំផ្នែកបច្ចេកទេសក្នុងការងារវិស្វកម្ម ដើម្បីធានានូវក្រមសីលធម៌វិជ្ជាជីវៈគុណភាព សោភណភាព និងការសន្សំសំចៃ។
- សហការជាមួយដៃគូអភិវឌ្ឍ ឬក្រុមហ៊ុនឯកជននានា ដើម្បីឱ្យមន្ទីរពិសោធន៍គណៈវិស្វករកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការផ្តល់សេវា និងអភិវឌ្ឍខ្លួន។[40]

---

[39] មាត្រា២៤ នៃអនុក្រឹត្យលេខ ២២៥ អនក្រ.បកស្ដីពីលក្ខខណ្ឌនិងនិតិវិធីនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

[40] មាត្រា២ នៃព្រះរាជក្រឹត្យលេខ០៦៣ អនក្រ.បក ស្ដីពីការបង្កើតមន្ទីរពិសោធន៍គណៈវិស្វករកម្ពុជា ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩

**ខ.តួនាទី និងភារកិច្ច**

មានតួនាទីនិងភារៈកិច្ចដូចខាងក្រោម៖

- ធ្វើការសិក្សាស្រាវជ្រាវបច្ចេកទេសថ្មីៗតាមសម័យនិយម លើមុខជំនាញវិស្វកម្ម ព្រមទាំងចូលរួមសហការកសាងបទដ្ឋានបច្ចេកទេសនានាពាក់ព័ន្ធវិជ្ជាជីវៈវិស្វកម្ម ដើម្បីធ្វើការផ្សព្វផ្សាយដល់វិស្វករសម្រាប់អនុវត្តទូទាំងប្រទេស
- កំណត់ពីស្តង់ដារនៃគុណភាពប្រភេទសម្ភារៈបរិក្ខារសម្រាប់ប្រើប្រាស់ក្នុងវិស័យវិស្វកម្ម
- សហការជាមួយមន្ទីរពិសោធន៍ដែលមានស្រាប់ នៅតាមក្រសួង មន្ទីរ សហគ្រាស គ្រឹះស្ថានឧត្តមសិក្សានានា ដើម្បីទទួលបាននូវស្តង់ដារបទដ្ឋានបច្ចេកទេសជាតិមួយសម្រាប់ផ្សព្វផ្សាយ និងអនុវត្ត
- ធ្វើការណែនាំ ផ្តល់យោបល់ និងផ្តល់ជំនួយបច្ចេកទេស កោសលវិច័យ ពិនិត្យកំហុសឆ្គងក្នុងវិស័យវិស្វកម្មដល់វិស្វករចុះបញ្ជី
- សហការជាមួយដៃគូអភិវឌ្ឍនិងក្រុមហ៊ុនឯកជន ដើម្បីឱ្យមន្ទីរពិសោធន៍គណៈវិស្វករកម្ពុជាមានសមត្ថភាពពេញលក្ខណៈសម្បត្តិក្នុងការផ្តល់សេវា និងបណ្តុះបណ្តាលបង្កើនសមត្ថភាពជំនាញវិជ្ជាជីវៈវិស្វកម្ម ដល់វិស្វករចុះបញ្ជី
- ទទួលកម្មសិក្សាការីអ្នកបច្ចេកទេស សម្រាប់បណ្តុះបណ្តាលឱមានវិជ្ជាជីវៈជំនាញពិតប្រាកដ
- រៀបចំឯកសារបច្ចេកទេស ដោយប្រមូលទិន្នន័យដែលទទួលបាន ក្នុងពេលបំពេញបេសកកម្ម និងតួនាទីភារកិច្ចរបស់ខ្លួន។[41]

**១.៣.២. ការបង្កើតមន្ទីរពិសោធន៍សំណង់**

មន្ទីរពិសោធន៍សំណង់ក្នុងគោលដៅអាជីវកម្មត្រូវមានអាជ្ញាបណ្ណ ដែលផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំ-ដែនដី នគរូបនីយកម្ម និងសំណង់។ ការបង្កើតមន្ទីរពិសោធន៍សំណង់ក្នុងគោលដៅសិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាលត្រូវមានលិខិតអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតលិខិតអនុញ្ញាតបង្កើតមន្ទីរពិសោធន៍សំណង់ក្នុងគោលដៅសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាល ត្រូវកំណត់ដោយអនុក្រឹត្យ។[42]

[41] មាត្រា៣ នៃព្រះរាជក្រឹត្យលេខ០៦៣ អនក្រ.បក ស្តីពីការបង្កើតមន្ទីរពិសោធន៍គណៈវិស្វករកម្ពុជា ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០៩

[42] មាត្រា២៥ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

# ជំពូកទី២
# នីតិវិធីគ្រប់គ្រងគ្រោះថ្នាក់នៃការសាងសង់នៅកម្ពុជា

# ជំពូកទី២
# នីតិវិធីគ្រប់គ្រងគ្រោះថ្នាក់នៃការសាងសង់នៅកម្ពុជា

## ២.១.ការត្រួតពិនិត្យការងារសាងសង់ និងរុះរើសំណង់

ការត្រួតពិនិត្យ ការវិភាគ ការផ្ទៀងផ្ទាត់ និងការបញ្ជាក់លើប្រតិបត្តិការការងារសាងសង់ ឬរុះរើអំពីភាពស្របតាមគម្រោងប្លង់ និងភាពអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានដទៃទៀត ដើម្បីជាមូលដ្ឋានសម្រាប់អាជ្ញាធរមានសមត្ថកិច្ចផ្តល់ការអនុញ្ញាតឱ្យប្រើប្រាស់សំណង់។

### ២.១.១. ការត្រួតពិនិត្យផលិតផលសំណង់

សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលចាំបាច់សម្រាប់ធានាគុណភាពសំណង់ និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ត្រូវមានការបញ្ជាក់ទទួលស្គាល់ ឬការបញ្ជាក់អនុលោមភាពដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តាមបទប្បញ្ញត្តិបច្ចេកទេសំណង់ ឬតាមស្តង់ដារកម្ពុជា ដែលបានអនុម័តដោយក្រុមប្រឹក្សាស្តង់ដារជាតិ ដោយត្រូវមានបិទឬបោះពុម្ពសញ្ញាស្តង់ដារកម្ពុជា និងត្រូវមានអាជ្ញាបណ្ណប្រើសញ្ញាស្តង់ដារកម្ពុជា។

បែបបទ និងនីតិវិធីនៃការបញ្ជាក់ទទួលស្គាល់ឬការបញ្ជាក់អនុលោមភាព និងប្រភេទនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលចាំបាច់សម្រាប់ធានាគុណភាពសំណង់ និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[43]

ការផលិត ការចែកចាយ ការនាំចូល ការដាក់លក់ ការផ្គត់ផ្គង់ ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ដែលគ្មានបិទសញ្ញាស្តង់ដារកម្ពុជា ឬគ្មានការបញ្ជាក់ទទួលស្គាល់ ឬគ្មានការបញ្ជាក់អនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវហាមឃាត់ក្នុងករណីសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់នោះតម្រូវឱ្យមានបិទសញ្ញាស្តង់ដារកម្ពុជា ឬការបញ្ជាក់ទទួលស្គាល់ ឬការបញ្ជាក់ពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។ ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ និងផលិតផលសំណង់ដែលមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវហាមឃាត់។[44] បរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់តម្រូវឱ្យមានការត្រួតពិនិត្យរៀងរាល់១(មួយ)ឆ្នាំម្តង។ ប្រភេទបរិក្ខារ

[43] មាត្រា២២ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[44] មាត្រា២៣ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

សំណង់ ដែលងាយបង្កគ្រោះថ្នាក់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[45]

ផលិតករនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដល់អ្នកដទៃដែលបង្កឡើងដោយវិការៈនៃផលិតផលរបស់ខ្លួន លើកលែងតែផលិតករនោះអាចបង្ហាញភស្តុតាងណាមួយដូចខាងក្រោម៖

- នៅខណៈដែលសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ ត្រូវបានដាក់លក់ ឬចែកចាយ ចំណេះដឹងផ្នែកវិទ្យាសាស្ត្រនិងបច្ចេកទេសពុំអាចរកឃើញវិការៈដែលបង្កឱ្យមានការខូចខាត។
- សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ត្រូវបានផលិតឡើងដោយអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសតម្រូវ។[46]

### ២.១.២. ការត្រួតពិនិត្យការងារសាងសង់

ការត្រួតពិនិត្យ ការងារសំណង់ គឺជាការត្រួតពិនិត្យ ការវិភាគ ការគណនា លើគម្រោងប្លង់ ទៅតាមសេចក្តីណែនាំបច្ចេកទេស ដើម្បីធានាសុវត្ថិភាព សុខុមាលភាពក្នុងការសាងសង់ ឬរុះរើ និងក្នុងការប្រើប្រាស់សំណង់។

សំណង់ និងការងារសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យ និងបញ្ជាក់សំណង់រួមមាន៖

- គម្រោងប្លង់ប្រើប្រាស់សម្រាប់ការងារសាងសង់ ឬរុះរើ មុនអាជ្ញាធរមានសមត្ថកិច្ច ឬមន្ត្រីមានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតពាក់ព័ន្ធ
- ការងារសាងសង់ ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាត
- សំណង់ដែលត្រូវបានសាងសង់ថ្មី ជួសជុល កែប្រែ ឬប្តូរមុខងារប្រើប្រាស់សំណង់ដែលតម្រូវឱ្យមានវិញ្ញាបនបត្រប្រើប្រាស់សំណង់
- សំណង់ និងបរិក្ខារសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពទៀងទាត់
- សំណង់ដែលបណ្តាលឱ្យមានហានិភ័យដល់អាយុជីវិតមនុស្ស ទ្រព្យសម្បត្តិ ឬការប៉ះពាល់ដល់សន្តិសុខ ឬសណ្តាប់ធ្នាប់សាធារណៈ។

ការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ អាចត្រូវបានធ្វើឡើងដោយអ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់ឯកជនដែលទទួលបានអាជ្ញាបណ្ណពីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់។ អាជ្ញាបណ្ណ និងត្រួតពិនិត្យសំណង់មាន ៤ប្រភេទ គឺ៖

[45] វាក្យខណ្ឌ៤ មាត្រា៨៧ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[46] មាត្រា៨១ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

- អាជ្ញាបណ្ណបញ្ជាក់ និងត្រួតពិនិត្យសំណង់ទូទៅ
- អាជ្ញាបណ្ណបញ្ជាក់ និងត្រួតពិនិត្យសំណង់ស្ថាបត្យកម្ម
- អាជ្ញាបណ្ណបញ្ជាក់ និងត្រួតពិនិត្យគ្រឿងបង្គុំសំណង់
- អាជ្ញាបណ្ណបញ្ជាក់ និងត្រួតពិនិត្យសំណង់ផ្នែកមេកានិច អគ្គិសនី និងទឹក

អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់ប្រភេទនីមួយៗត្រូវបានបែងចែកទៅតាមកម្រិតផ្សេងដែលកំណត់បានពីវិសាលភាពនៃការត្រួតពិនិត្យ និងបញ្ជាក់សំណង់របស់អ្នកកាន់អាជ្ញាបណ្ណ។ នៅពេលដំណើរការការដ្ឋាន រាល់ការងារសាងសង់ឬរុះរើតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានការត្រួតពិនិត្យ និងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ អ្នកត្រួតពិនិត្យ និងបញ្ជាក់ការងារសាងសង់ ឬរុះរើត្រូវធ្វើរបាយការណ៍ និងចេញលិខិតបញ្ជាក់ពីអនុលោមភាពនៃការងារតាមគម្រោងប្លង់ដែលបានយល់ព្រមដោយអាជ្ញាធរមានសមត្ថកិច្ច និងតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។[47] លក្ខខណ្ឌ និងនីតិវិធីនៃការគ្រប់គ្រង និងត្រួតពិនិត្យការងារសាងសង់ ឬរុះរើត្រូវកំណត់ដោយអនុក្រឹត្យ។[48]

**២.១.២.១. ការត្រួតពិនិត្យការសាងសង់សំណង់ថ្មី**

ការងារសាងសង់ដែលចាប់ផ្តើមពីការងារដី ឬការងារគ្រឹះ ការងារគ្រឿងបង្គុំ ការងារជញ្ជាំង ការងារដំឡើងរហូតដល់ការងារបង្ហើយដើម្បីបង្កើតសំណង់ថ្មីមួយ។

ការត្រួតពិនិត្យ និងបញ្ជាក់សំណង់ថ្មី ការងារជួសជុល ការងារកែប្រែ ឬការងាររុះរើ អាចធ្វើឡើងតាមការស្ម័គ្រចិត្តចំពោះសំណង់ដូចតទៅ៖

- សំណង់សាសនាសម្រាប់ដាក់ឱ្យប្រើប្រាស់ដោយសាធារណជនដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានីខេត្ត។
- សំណង់គ្រប់ប្រភេទ ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

ចំពោះសំណង់សាសនាសម្រាប់ដាក់ឱ្យប្រើប្រាស់ដោយសាធារណជន ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ពុំមានការត្រួតពិនិត្យ និងបញ្ជាក់ការងារសាងសង់សំណង់ថ្មី ការងារជួសជុល ការងារកែប្រែ ឬការងាររុះរើដោយក្រុមហ៊ុនត្រួតពិនិត្យនិងបញ្ជាក់សំណង់ទេ មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវទទួលបន្ទុកត្រួតពិនិត្យលក្ខណៈបច្ចេកទេសនៃការងារ

---

[47] មាត្រា៤១ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[48] មាត្រា៤២ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

សាងសង់ ឬរុះរើនោះ។ ចំពោះសំណង់គ្រប់ប្រភេទ ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ពុំមានការត្រួតពិនិត្យ និងបញ្ជាក់ការងារសាងសង់សំណង់ថ្មី ការងារជួលជុល ការងារកែប្រែ ឬការងាររុះរើដោយអ្នកវិជ្ជាជីវៈ ឬក្រុមហ៊ុនត្រួតពិនិត្យ និងបញ្ជាក់សំណង់ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកត្រួតពិនិត្យលក្ខណៈបច្ចេកទេសនៃការងារសាងសង់សំណង់ថ្មី ការងារជួសជុល ការងារកែប្រែ ឬការងាររុះរើនោះ។

អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់សំណង់ថ្មី មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ត្រួតពិនិត្យ និងបញ្ជាក់ការងារសាងសង់សំណង់សមស្របតាមប្លង់ស្ថាបត្យកម្មនិងគម្រោងប្លង់គ្រឿងផ្គុំសំណង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ច និងមន្ត្រីមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត
- ត្រួតពិនិត្យការងារសាងសង់ឱ្យអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ស្តង់ដារកម្ពុជា និងបទប្បញ្ញត្តិជាធរមានដទៃទៀត
- ត្រួតពិនិត្យការដ្ឋានសំណង់ឱ្យដំណើរការដោយគោរពតាមលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំពាក់ព័ន្ធ មានជាអាទិ៍ សុវត្ថិភាព បរិស្ថានអនាម័យ សន្តិសុខ សណ្តាប់ធ្នាប់នៅការដ្ឋានសំណង់
- បញ្ជាក់ថាសំណង់ដែលបានសាងសង់មានគុណភាពនិងសុវត្ថិភាពក្នុងការប្រើប្រាស់។[49]

អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់សំណង់ថ្មី ត្រូវអនុវត្តលើការងារដូចខាងក្រោម៖

- ការងារសាងសង់ផ្នែកនគរូបនីយកម្ម មានជាអាទិ៍ ផ្លាកម្លាត កម្ពស់សំណង់ សន្ទស្សន៍ប្រើប្រាស់ដី ផលធៀបក្រឡាផ្ទៃបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ ការប្រើប្រាស់លំហសាធារណៈ និងផ្ទៃបៃតង ចំណតយានយន្តក្រៅអគារ។
- ការងារសាងសង់គ្រឿងផ្គុំផ្នែកខាងក្រោមមានជាអាទិ៍ ការងារគ្រឹះ ការងារគម្រូបសសរគ្រឹះ ការងារជញ្ជាំងទប់ដី ការងារទប់ជញ្ជាំង ការងារធ្នឹមក្រវ៉ាត់ការងារសសរតឿ គ្រឿងផ្គុំផ្នែកខាងលើ មានជាអាទិ៍ ការងារធ្នឹម ការងារសសរ ការងារកម្រាលខណ្ឌ ការងារជញ្ជាំងទ្របន្ទុក ការងារជណ្តើរ ការងារដំបូល និងការងារពុម្ព មានជាអាទិ៍ ការងាររៀបពុម្ព ការងាររន្ទា ការងារជន្ទល ការងារដែកពង្រឹង។
- ការងារសាងសង់ផ្នែកស្ថាបត្យកម្ម មានជាអាទិ៍ ដំបូល ទ្វារ បង្អួចជណ្តើរ កម្ពស់ ច្រកចេញចូល លំហខ្យល់ចេញចូល ពន្លឺ ចំណតយានយន្តក្នុងអគារ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួល

[49] ប្រការ១៧ នៃប្រកាសលេខ១២៦ ដនស/ប្រ.ក/នី.ក ស្តីពីបែបបទនៃការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ និងរុះរើផ្នែកស្ថាបត្យកម្ម និងផ្នែកគ្រឿងផ្គុំសំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១

សម្រាប់ជនមានពិការភាព មុខងារសមាសភាគសំណង់ ភ្លើងសញ្ញាអាកាសចរលើដំបូលអគារ និងឧបករណ៍ការពាររន្ទះ។

- ការងារសាងសង់ផ្នែកប្រព័ន្ធទឹកកខ្វក់និងប្រព័ន្ធទឹកភ្លៀង មានជាអាទិ៍ បណ្តាញលូបង្ហូរទឹកកខ្វក់ បណ្តាញលូបង្ហូរទឹកភ្លៀង អាងសិបទិច អាងប្រព្រឹត្តកម្មទឹកកខ្វក់ ទទឹកភ្លៀង អាងស្តុកទឹកភ្លៀង អាងប្រព្រឹត្តកម្មសម្អាតសំណល់រាវ។
- ការងារសាងសង់ផ្នែកសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់។[50]

**២.១.១.២. ការត្រួតពិនិត្យបច្ចេកទេសសំណង់**

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវអនុវត្តបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានដទៃទៀតនៅក្នុងការអនុវត្តការងាររបស់ខ្លួន។[51] ក្នុងករណីពុំមានបទប្បញ្ញត្តិបច្ចេកទេសសំណង់ សម្រាប់ការងារសំណង់ណាមួយ អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវអនុវត្តបទដ្ឋានបច្ចេកទេសណាមួយ ដែលមានការទទួលស្គាល់កម្រិតអន្តរជាតិ ឬកម្រិតតាមតំបន់ តាមការជ្រើសរើសរបស់អ្នកសិក្សាគម្រោងប្លង់ អ្នកសាងសង់ ឬមន្ទីរពិសោធន៍សំណង់នឹងត្រូវត្រួតពិនិត្យ និងបញ្ជាក់លើផ្នែកសំណង់ត្រូវអះអាងអំពីចំណេះដឹងរបស់ខ្លួនក្នុងការអនុវត្តបទដ្ឋាននោះនៅក្នុងរបាយការណ៍ស្តីពីការត្រួតពិនិត្យនិងបញ្ជាក់សំណង់។ ការអនុវត្តបទដ្ឋានបច្ចេកទេសសំណង់ ត្រូវស្របតាមលក្ខខណ្ឌសេដ្ឋកិច្ច សង្គម ភូមិសាស្ត្រ អាកាសធាតុ បរិស្ថាន បច្ចេកវិទ្យា និងវិទ្យាសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា។[52] រាល់សំណង់ត្រូវមានគ្រឿងផ្គុំដែលអាចទ្រទ្រង់បន្ទុកបានប្រកបដោយសុវត្ថិភាពទៅតាមមុខងារប្រើប្រាស់របស់សំណង់ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសសំណង់។ ចំណាត់ថ្នាក់ ប្រភេទ និងទំហំសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យ និងបញ្ជាក់អំពីសុវត្ថិភាពគ្រឿងផ្គុំ ត្រូវពិនិត្យដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[53]

---

[50] ប្រការ១៨ នៃប្រកាសលេខ១២៦ ដនស/ប្រ.ក/នី.ក ស្តីពីបែបបទនៃការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ និងរុះរើផ្នែកស្ថាបត្យកម្ម និងផ្នែកគ្រឿងផ្គុំសំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១

[51] ប្រការ៣៣ នៃប្រកាសលេខ១២៦ ដនស/ប្រ.ក/នី.ក ស្តីពីបែបបទនៃការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ និងរុះរើផ្នែកស្ថាបត្យកម្ម និងផ្នែកគ្រឿងផ្គុំសំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១

[52] ប្រការ៣៤ នៃប្រកាសលេខ១២៦ ដនស/ប្រ.ក/នី.ក ស្តីពីបែបបទនៃការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ និងរុះរើផ្នែកស្ថាបត្យកម្ម និងផ្នែកគ្រឿងផ្គុំសំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១

[53] មាត្រា៧ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ ២០១៩

## ២.១.៣. ការត្រួតពិនិត្យការជួសជុល កែប្រែ

### ២.១.៣.១. ការត្រួតពិនិត្យនិងបញ្ជាក់ការងារជួសជុល

ការងារជួសជុលផ្នែកណាមួយនៃសំណង់ ឬការជួសជុលទាំងស្រុងដែលមានការខូចខាតដោយប្រការណាមួយ រួមទាំងការប្តូរចំណែកចាស់ទ្រុឌទ្រោមដែលអាចបង្កនូវគ្រោះថ្នាក់ជាយថាហេតុ និងការកែលម្អការបំពាក់សម្ភារៈបរិក្ខារផ្នែកផ្សេងទៀតនៅខាងក្នុងដោយរក្សាសោភណភាព ទ្រង់ទ្រាយដើម និងមិនប៉ះពាល់ដល់គ្រឿងផ្គុំសំណង់៖

**ក. ការចេញលិខិតអនុញ្ញាតសាងសង់**

ការចេញលិខិតអនុញ្ញាតជួសជុល ត្រូវចេញដោយអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីរាជធានី ខេត្ត ឬការិយាល័យ រៀបចំដែនដី នគរូបនីយកម្ម សំណង់និងភូមិបាលក្រុង ស្រុក ខណ្ឌ ស្របតាមសមត្ថកិច្ចរៀងៗខ្លួន។ ចំពោះអគារដែលបានសាងសង់ក្នុងចន្លោះឆ្នាំ១៩៩៨ ការស្នើសុំជួសជុលអគារទាំងនោះមិនតម្រូវឱ្យមានលិខិតអនុញ្ញាតជួសជុលទេ។ ដោយឡែកចំពោះអគារដែលបានសាងសង់ក្នុងចន្លោះឆ្នាំ១៩៩៨ ដល់មុនពេលចេញប្រកាសនេះ ហើយគ្មានលិខិតអនុញ្ញាតសាងសង់និងគ្មានទំនាស់ ស្ថាប័នមានសមត្ថកិច្ចអាចចេញលិខិតអនុញ្ញាតជួលជុលជូនម្ចាស់សំណង់បាន ដោយម្ចាស់សំណង់ត្រូវធ្វើកិច្ចសន្យាធានា និងទទួលខុសត្រូវលើគុណភាពសំណង់ សុវត្ថិភាពអ្នកជិតខាង និងសណ្តាប់ធ្នាប់សាធារណៈ។[54] ចំពោះសំណង់អគារដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងស្ថាប័ននានាមុនពេលជួសជុលម្ចាស់សំណង់ ត្រូវស្នើសុំលិខិតអនុញ្ញាតជួសជុលពីក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីរាជធានី ខេត្ត ឬការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ស្រុកខណ្ឌ លើកលែងតែសំណង់ដែលមានចែង លើកលែងក្នុងប្រការនេះ ឬសំណង់អគារណាដែលមានលិខិតបទដ្ឋានគតិយុត្តកំណត់ដោយឡែក។[55]

សេចក្តីជូនដំណឹងស្តីពីការស្នើសុំជួសជុល ត្រូវផ្សព្វផ្សាយជាសាធារណៈក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំដោយបិទផ្សាយនៅកន្លែងគ្រោងធ្វើការជួសជុល។ ក្នុងករណីចាំបាច់បន្ទាន់ ការជួសជុលអាចប្រព្រឹត្តទៅបានមុនផុតកំណត់រយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃសេចក្តីជូនដំណឹងខាងលើដោយយោងទៅលើការវាយតម្លៃរបស់ស្ថាប័នមានសមត្ថកិច្ច។ សេចក្តីជូនដំណឹងខាងលើត្រូវធ្វើឡើងដោយ

---

[54] ប្រការ៦ នៃប្រកាសលេខ០៧៤ ប្រក/អសណ ស្តីពីការអនុញ្ញាតជួសជុលសំណង់អគារ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣

[55] ប្រការ៧ នៃប្រកាសលេខ០៧៤ ប្រក/អសណ ស្តីពីការអនុញ្ញាតជួសជុលសំណង់អគារ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬមន្ទីររៀបចំដែនដី នគរូនីយកម្ម សំណង់និងសុរិយោដី រាជធានី ខេត្ត ឬការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល ក្រុងស្រុក ខណ្ឌស្របតាមសមត្ថកិច្ច សម្រេចលើលិខិតអនុញ្ញាតជួលជុលរៀងៗខ្លួន។[56]

ស្ថានប័នមានសមត្ថិកិច្ចមានសិទ្ធិត្រួតពិនិត្យតាមដានការដ្ឋានជួសជុល និងឯកសារពាក់ព័ន្ធនឹងការជួលជុលបានគ្រប់ពេលវេលា។ បើពិនិត្យឃើញថា ការជួសជុលមិនស្របតាមលិខិតអនុញ្ញាតជួសជុល និងមិនត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេសជំនាញ ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុងស្រុក ខណ្ឌ ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត ឬអគ្គនាយកដ្ឋានសំណង់ត្រូវផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរឱ្យម្ចាស់សំណង់ធ្វើការកែតម្រូវ ជាបន្ទាន់ឱ្យស្របតាមលិខិតអនុញ្ញាតជួសជុល និងតាមបទដ្ឋានបច្ចេកទេសជំនាញ។ ក្នុងករណីដែលម្ចាស់សំណង់មិនព្រមធ្វើតាមការណែនាំនេះ ស្ថាប័នមានសមត្ថកិច្ចជំនាញមានសិទ្ធិបញ្ឈប់ការជួសជុល ឬចេញលិខិតផ្អាកការដ្ឋាន និងឱ្យម្ចាស់សំណង់ធ្វើការកែតម្រូវជាលើកទីពីរឱ្យបានត្រឹមត្រូវក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលលិខិតណែនាំជាផ្លូវការ។ ប្រសិនបើម្ចាស់សំណង់ នៅតែរឹងរូសមិនព្រមអនុវត្តទៅតាមការណែនាំខាងលើនេះ មន្ត្រីជំនាញមានសិទ្ធិស្នើសុំអន្តរាគមន៍ពីអាជ្ញាធរមានសមត្ថកិច្ច ដើម្បីជួយដល់ការអនុវត្តន៍ឱ្យមានប្រសទ្ធិភាព។[57]

**ខ. ការហាមឃាត់សកម្មភាពពេលកំពុងជួសជុល**

សំណង់ដែលត្រូវហាមឃាត់ជួសជុលរួមមានដូចខាងក្រោម៖

- ការដាក់តាំងគរសម្ភារៈសំណង់លើផ្លូវសាធារណៈ
- ការតាំងការដ្ឋានលយលើចិញ្ចើមផ្លូវសាធារណៈលើសពីពីរភាគបីនៃចិញ្ចើមកផ្លូវ
- ការបង្ហូរទឹក និងការចោលកាកសំណល់ពីការដ្ឋានសំណង់មកផ្លូវ និងទីសាធារណៈ
- ម្ចាស់ការដ្ឋានសំណង់ត្រូវធ្វើរបងហ៊ុមព័ទ្ធការដ្ឋានសំណង់ក្នុងរយៈពេលដំណើរការជួសជុល រុះរើសម្អាតការដ្ឋានជួសជុល និងយកចេញនូវសម្ភារៈបរិក្ខារគ្រឿងចក្រ និងកាកសំណល់ពីការដ្ឋានជួសជុលក្នុងរយៈពេលយ៉ាងយូរពីរសប្តាហ៍ក្រោយពេលចប់ការងារជួលជុល។[58]

ក្នុងដំណើរការជួសជុល ម្ចាសសំណង់ និងអ្នកពាក់ព័ន្ធត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និងវិវាទផ្សេងៗ ដែលបណ្តាលមកពីការធ្វេសប្រហែស ឬការជួសជុលមិនត្រូវតាមបទដ្ឋានបច្ចេកទេសំណង់។[59] ចំពោះសំណង់

[56] ប្រការ៨ នៃប្រកាសលេខ០៧៤ ប្រក/អសណ ស្តីពីការអនុញ្ញាតជួសជុលសំណង់អគារ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣

[57] ប្រការ១៦ នៃប្រកាសលេខ០៧៤ ប្រក/អសណ ស្តីពីការអនុញ្ញាតជួសជុលសំណង់អគារ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣

[58] ប្រការ១៧ នៃប្រកាសលេខ០៧៤ ប្រក/អសណ ស្តីពីការអនុញ្ញាតជួសជុលសំណង់អគារ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣

[59] ប្រការ១៨ នៃប្រកាសលេខ០៧៤ ប្រក/អសណ ស្តីពីការអនុញ្ញាតជួសជុលសំណង់អគារ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣

ចាស់អគារទ្រុឌទ្រោមមិនអាចស្នាក់នៅបាន និងអាចបង្កគ្រោះថ្នាក់ដោយប្រការណាមួយដែលមានការវាយតម្លៃច្បាស់លាស់ពីស្ថាប័នជំនាញ អាជ្ញាធរមានសមត្ថកិច្ចតាមសំណើរបស់ស្ថាប័នជំនាញត្រូវជូនដំណឹងដល់ម្ចាស់សំណង់ ឬកម្មសិទ្ធិករដែលស្នាក់នៅក្នុងអគារនោះដោយបង្ខំឱ្យធ្វើការរុះរើ ឬជួសជុលជាបន្ទាន់ដើម្បីធានាសុវត្ថិភាព និងជៀសវាងថ្នាក់ជាយថាហេតុ។ ការជួសជុលត្រូវធ្វើឱ្យស្របតាមបទដ្ឋានបច្ចេកទេសសំណង់។ ក្នុងករណីម្ចាស់សំណង់មិនព្រមជួសជុលតាមសេចក្តីជូនដំណឹងខាងលើចំនួន២(ពីរ)ដង ម្ចាស់សំណង់ត្រូវទទួលខុសត្រូវចំពោះការខូចខាត ឬគ្រោះថ្នាក់ទាំងឡាយដែលកើតឡើងដោយការជួសជុលសំណង់របស់ខ្លួន។ ក្នុងករណីនេះ ម្ចាស់សំណង់ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។[60]

### ២.១.៣.៤. ការត្រួតពិនិត្យនិងបញ្ជាក់ការកែប្រែ

ការកែប្រែ គឺសំដៅដល់ការផ្លាស់ប្តូរមុខងារទ្រង់ទ្រាយទាំងស្រុង ឬផ្នែកណាមួយនៃសំណង់។ អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងារកែប្រែ ត្រូវអនុវត្តលើការងារដូចខាងក្រោម៖

- ការងារកែប្រែផ្នែកនគរូបនីយកម្ម មានជាអាទិ៍ ផ្លាតម្លាតកម្ពស់សំណង់ សន្ទស្សន៍ប្រើប្រាស់ដី ផលធៀបក្រឡាផ្ទៃបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ ការប្រើប្រាស់លំហសាធារណៈ និងផ្ទៃបៃតងចំណតយានយន្តក្រៅអគារ។
- ការងារកែប្រែផ្នែកគ្រឿងផ្គុំសំណង់ មានជាអាទិ៍ គ្រឿងផ្គុំផ្នែកខាងក្រោម គ្រឿងផ្គុំផ្នែកខាងលើ និងពុម្ព។
- ការងារកែប្រែផ្នែកប្រព័ន្ធទឹកកខ្វក់ និងប្រព័ន្ធទឹកភ្លៀង មានជាអាទិ៍ បណ្តាញលូបង្ហូរទឹកកខ្វក់ បណ្តាញលូបង្ហូរទឹកភ្លៀង អាងសិបទិច អាងប្រព្រឹត្តិកម្មទឹកកខ្វក់ ទទឹកភ្លៀង អាងស្តុកទឹកភ្លៀង អាងប្រព្រឹត្តិកម្មសម្អាតសំណល់រាវ។
- ការងារកែប្រែផ្នែកស្ថាបត្យកម្ម មានជាអាទិ៍ ដំបូល ទ្វារបង្អួច ជណ្តើរ កម្ពស់ ច្រកចេញចូល លំហខ្យល់ចេញចូល ពន្លឺ ចំណតយានយន្តក្នុងអគារ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តបង្កលក្ខណៈងាយស្រួលដល់ជនពិការភាព មុខងារសមាសភាពសំណង់ ភ្លើងសញ្ញាអាកាសចរលើដំបូលអគារ ឧបករណ៍ការពាររន្ទះ
- ការងារកែប្រែសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់។[61]

[60] ប្រការ២០ នៃប្រកាសលេខ០៧៤ ប្រក/អសណ ស្តីពីការអនុញ្ញាតជួសជុលសំណង់អគារ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៣

[61] ប្រការ២២ នៃប្រកាសលេខ១២៦ ដនស/ប្រ.ក/នី.ក ស្តីពីបែបបទនៃការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ និងរុះរើផ្នែកស្ថាបត្យកម្មនិងផ្នែកគ្រឿងផ្គុំសំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១

### ២.១.៤. ការត្រួតពិនិត្យការរុះរើសំណង់

គម្រោងប្លង់រុះរើ ត្រូវសិក្សានិងចុះហត្ថលេខាដោយរូបវន្តបុគ្គលសិក្សាគម្រោងប្លង់ ឬហត្ថលេខារបស់អ្នកវិជ្ជាជីវៈជាវិស្វករ និងនាយកបច្ចេកទេសព្រមទាំងបោះត្រារបស់ក្រុមហ៊ុនសិក្សាគម្រោងប្លង់ ដែលមានអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[62]

#### ២.១.៤.១. ការត្រួតពិនិត្យការរុះរើដោយផ្នែក

ការរុះរើដោយផ្នែកដែលជាការដោះដូរ ឬដកចេញនូវចំណែកណាមួយនៃសំណង់ ឬការងាររុះរើទាំងស្រុងដែលជាការដកចេញសំណង់ទាំងមូល ឬការងារវាយកម្ទេចសំណង់ទាំងមូលទាំងនៅលើដី ទាំងនៅក្រោមដី លើកលែងតែគ្រឹះនៃសំណង់ដែលអាចរក្សាទុក។

អ្នកត្រួតពិនិត្យ និងបញ្ជាក់ការងាររុះរើដោយផ្នែក ត្រូវអនុវត្តលើការងារដូចខាងក្រោម៖

- ការងាររុះរើផ្នែកសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់។
- ការងាររុះរើផ្នែកស្ថាបត្យកម្ម។
- ការងាររុះរើផ្នែកគ្រឿងផ្គុំសំណង់មានដូចជាគ្រឿងផ្គុំផ្នែកខាងក្រោមគ្រឿងផ្គុំផ្នែកខាងលើនិងការងារពុម្ព។[63]

#### ២.១.៤.២. ការត្រួតពិនិត្យការរុះរើទាំងស្រុង

អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងាររុះរើទាំងស្រុងមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ត្រួតពិនិត្យការងាររុះរើឱ្យស្របតាមគម្រោងប្លង់សម្រាប់ការងាររុះរើដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ច និងមន្ត្រីមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត
- ត្រួតពិនិត្យការងាររុះរើឱ្យអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស និងបទប្បញ្ញត្តិជាធរមានដទៃទៀត
- ត្រួតពិនិត្យការដ្ឋានសំណង់ឱ្យដំណើរការដោយគោរពតាមលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំពាក់ព័ន្ធមានជាអាទិ៍ សុវត្ថិភាព បរិស្ថាន អនាម័យ សន្តិសុខសណ្តាប់ធ្នាប់នៅការដ្ឋានសំណង់។[64]

អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងាររុះរើទាំងស្រុង ត្រូវអនុវត្តលើការងារដូចជា៖

- ការងាររុះរើផ្នែកសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់។

---

[62] ចំណុចទី១ កថាខណ្ឌទី២ នៃសេចក្តីណែនាំលេខ០០២ ដនស/សណន ស្តីពីការពង្រឹងគុណភាពនិសុវត្ថិភាពសំណង់ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០

[63] ប្រការ២៦ នៃប្រកាសលេខ១២៦ ដនស/ប្រ.ក/នី.ក ស្តីពីបែបបទនៃការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ និងរុះរើផ្នែកស្ថាបត្យកម្មនិងផ្នែកគ្រឿងផ្គុំសំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១

[64] ប្រការ២៣ នៃប្រកាសលេខ១២៦ ដនស/ប្រ.ក/នី.ក ស្តីពីបែបបទនៃការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ និងរុះរើផ្នែកស្ថាបត្យកម្មនិងផ្នែកគ្រឿងផ្គុំសំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១

- ការងារអុះអើផ្នែកគ្រឿងផ្គុំសំណង់ មានដូចជា គ្រឿងផ្គុំផ្នែកខាងលើ និងគ្រឿងផ្គុំផ្នែកខាងក្រោម។[65]

## ២.២. ការគ្រប់គ្រងដំណើរការសាងសង់

### ២.២.១. ការគ្រប់គ្រងគម្រោងប្លង់

រាល់គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ ឬអុះអើត្រូវចុះហត្ថលេខាទទួលខុសត្រូវដោយអ្នកសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[66] រាល់គ្រប់ប្រភេទ លើកលែងតែសំណង់សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារ និងសេវាសម្រាប់ជនពិការភាពជាអាទិ៍ ផ្លូវនិងជម្រាលសម្រាប់ផ្លាស់ទី ឧបការណ៍ធ្នាក់ដៃ ជណ្តើរយន្ត បន្ទាប់អនាម័យ ចំណតយានយន្ត ពិសេសសម្រាប់ជនពិការ និងផ្លាកសញ្ញានានា។ អនុលោមភាពនៃគម្រោងប្លង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិរៀបចំដែនដី និងនគរូបនីយកម្ម ត្រូវបញ្ជាក់ដោយអ្នកត្រួតពិនិត្យ និងបញ្ជាក់ដែលមានអាជ្ញាបណ្ណ ឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គម្រោងប្លង់ សាងសង់ ឬអុះអើដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានការបញ្ជាក់ពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ដោយត្រួតពិនិត្យ និងបញ្ជាក់ដែលមានអាជ្ញាបណ្ណ ឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[67]

### ២.២.២. ការគ្រប់គ្រងការងារសាងសង់ និងអុះអើ

រាល់ការងារសាងសង់ ឬអុះអើត្រូវអនុវត្តដោយអ្នកសាងសង់ដែលមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ឬលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋបាលរាជធានី ខេត្ត។ អ្នកសាងសង់មិនតម្រូវឱ្យមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋបាលរាជធានី ខេត្ត លុះត្រាតែអ្នកសាងសង់នោះបានបំពេញគ្រប់លក្ខខណ្ឌដូចខាងក្រោម៖

- ជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់
- សាងសង់ ឬអុះអើសំណង់ដែលជាលំនៅឋានផ្ទាល់ខ្លួន
- សាងសង់ ឬអុះអើសំណង់តាមជំនាញវិជ្ជាជីវៈរបស់ខ្លួន។[68]

---

[65] ប្រការ២៥ នៃប្រកាសលេខ១២៦ ដនស/ប្រ.ក/នី.ក ស្តីពីបែបបទនៃការងារត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ និងអុះអើផ្នែកស្ថាបត្យកម្មនិងផ្នែកគ្រឿងផ្គុំសំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១

[66] មាត្រា៣២ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[67] មាត្រា៣៣ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[68] មាត្រា៣៦ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

រាល់ការងារសាងសង់ ឬរុះរើត្រូវអនុវត្តស្របតាម៖

- គម្រោងប្លង់
- បទប្បញ្ញត្តិបច្ចេកទេសសំណង់
- បទប្បញ្ញត្តិជាធរមានដទៃទៀត។

រាល់ការងារសាងសង់ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាត ត្រូវអនុវត្តគម្រោងប្លង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត។[69]

### ២.២.៣. ការកំណត់កម្រិតនៃស្ថានភាពគ្រោះថ្នាក់

សភាពគ្រោះថ្នាក់នៃសំណង់ មាន២ប្រភេទ រួមមានប្រភេទសំណង់គ្រោះថ្នាក់អាចកើតឡើងភ្លាមៗ និងប្រភេទគ្រោះថ្នាក់មិនអាចកើតឡើងភ្លាមៗ។ ការចាត់កម្រិតគ្រោះថ្នាក់សំណង់ ត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងគោលការណ៍ណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[70]

សំណង់ដែលមានសភាពគ្រោះថ្នាក់មានដូចខាងក្រោម៖

- ➢ សំណង់ដែលមានគ្រឿងផ្គុំសំណង់ មិនអាចទ្រទ្រង់បន្ទុកបានប្រកបដោយសុវត្ថិភាព ទៅតាមមុខងារប្រើប្រាស់
- ➢ សំណង់ដែលគ្មានសុវត្ថិភាពអគ្គិភ័យ អនុលោមតាមបទដ្ឋានបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការនិងការពន្លត់អគ្គិភ័យ
- ➢ សំណង់ដែលត្រូវបានសាងសង់ពីសម្ភារៈសំណង់ បរិក្ខារសំណង់ ដែលមិនអាចធានាគុណភាពសំណង់ និងសុវត្ថិភាពឬសុខភាពរបស់អ្នកប្រើប្រាស់ ឬសាធារណជន អនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ឬស្តង់ដារកម្ពុជា
- ➢ សំណង់ដែលងាយរងគ្រោះថ្នាក់ដោយកត្តាខាងក្រៅដែកបង្កឡើងដោយមនុស្សឬធម្មជាតិមាន ជាអាទិ៍ ការបាក់ដី ការធ្លាក់ថ្ម ទឹកជំនន់ អគ្គិភ័យ
- ➢ សំណង់ដែលមានកត្តាប៉ះពាល់ធ្ងន់ធ្ងរដល់សុខភាពអ្នកប្រើប្រាស់ ឬសាធារណជនមានជាអាទិ៍កង្វះអនាម័យ កង្វះខ្យល់ កង្វះពន្លឺ សំណើម ការជ្រាបទឹក ការពុកផុយ។[71]

---

[69] មាត្រា៣៧ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[70] ប្រការ៤ នៃប្រកាសលេខ០៤៧ ដនស/ប្រ.ក/នី.ក ស្តីពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់ ចុះថ្ងៃទី០១ កុម្ភៈ ឆ្នាំ២០២២

[71] មាត្រា៣១ នៃអនុក្រឹត្យលេខ២២៦ អនក្រ.បក ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

**២.២.៣.១. គ្រោះថ្នាក់អាចកើតឡើងភ្លាមៗ**

ក្នុងករណីពិនិត្យឃើញថាគ្រោះថ្នាក់អាចកើតឡើងភ្លាមៗមន្ត្រីត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ត្រូវរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធជាបន្ទាន់តាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន។ អាជ្ញាធរមានសមត្ថកិច្ច ទទួលបានបណ្ដឹងឬព័ត៌មានអំពីសំណង់ដែលមានសភាពគ្រោះថ្នាក់ អាជ្ញាធរមានសមត្ថកិច្ចត្រូវសម្រេចធ្វើការត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់នោះ។ អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់តាំងមន្ត្រីត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់ ដើម្បីចុះត្រួតពិនិត្យវាយតម្លៃ និងធ្វើការសន្និដ្ឋានអំពីការចាត់កម្រិតគ្រោះថ្នាក់របស់សំណង់ជាបន្ទាន់។[72]

**២.២.៣.២. គ្រោះថ្នាក់មិនអាចកើតឡើងភ្លាមៗ**

ក្នុងករណីគ្រោះថ្នាក់មិនអាចកើតឡើងភ្លាមៗ អាជ្ញាធរមានសមត្ថកិច្ច ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និង/ឬ អ្នកជួលសំណង់អំពីវិធានការបញ្ចៀសគ្រោះថ្នាក់។[73]

វិធានការបញ្ចៀសគ្រោះថ្នាក់ដែលមិនអាចកើតឡើងភ្លាមៗ មានជាអាទិ៍៖

- តម្រូវឱ្យម្ចាស់សំណង់ជួសជុល កែប្រែ ឬរុះរើ សំណង់ឬផ្នែកណាមួយនៃសំណង់
- តម្រូវឱ្យម្ចាស់សំណង់រកអ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់ ដើម្បីសិក្សារកវិធីសាស្ត្របញ្ចៀសគ្រោះថ្នាក់
- តម្រូវឱ្យម្ចាស់សំណង់ចាត់ចែងអនុវត្តតាមការផ្ដល់យោបល់បច្ចេកទេសរបស់អ្នកត្រួតពិនិត្យ និងបញ្ជាក់សំណង់
- តម្រូវឱ្យម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និង/ឬ អ្នកជួលសំណង់ ចាត់វិធានការចាំបាច់នានា ដើម្បីធានាសុវត្ថិភាព និងទ្រព្យសម្បត្តិរបស់អតិថិជន អ្នកប្រើប្រាស់សំណង់ និងអ្នកជិតខាង
- បិទផ្សាយលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់នៅទីតាំងសំណង់។

រាល់ការចំណាយដើម្បីអនុវត្តវិធានការបញ្ចៀសគ្រោះថ្នាក់ ជាបន្ទុករបស់ម្ចាស់សំណង់។

## ២.៣. ការទទួលខុសត្រូវ និងវិធានការបញ្ចៀសគ្រោះថ្នាក់ការសាងសង់

### ២.៣.១. ស្ថាប័ន និងបុគ្គលដែលពាក់ព័ន្ធ

ការទទួលខុសត្រូវនៃស្ថាប័នថ្នាក់ជាតិនៅក្នុងវិស័យសំណង់ដើម្បីទទួលបានប្រសិទ្ធភាព និងមានមុខងារច្បាស់លាស់គឺមានការចូលរួមពីគណៈកម្មការអន្តរក្រសួង ដែលមានសមាសភាពចម្រុះមកពីក្រសួងនានា ប៉ុន្តែ

[72] ប្រការ៥ នៃប្រកាសលេខ០៤៧ ដនស/ប្រក/នីក ស្ដីពីកម្រិតនៃសភាពគ្រោះថ្នាក់ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២

[73] ប្រការ១២ នៃប្រកាសលេខ០៤៧ ដនស/ប្រក/នីក ស្ដីពីកម្រិតនៃសភាពគ្រោះថ្នាក់ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២

ក្រសួងនិងស្ថាប័នដែលមានភារកិច្ចចាំបាច់បំផុតនោះគឺ ក្រសួងមហាផ្ទៃ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ ជាមួយគ្នានោះផងដែរ ក្រៅពីស្ថាប័នធំៗថ្នាក់ជាតិទាំង២នេះ ក៏មានអ្នកពាក់ព័ន្ធជាច្រើនទៀត ដែលមានភារកិច្ចទទួលខុសត្រូវនៅក្នុងវិស័យនេះ។ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានស្នើសុំ ស្ថាប័នពាក់ព័ន្ធទាំងអស់ក្នុងវិស័យសំណង់រួមគ្នាចូលរួមលើកកម្ពស់សុវត្ថិភាពការងារក្នុងវិស័យសំណង់។

**២.៣.១.១. ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ច ត្រួតពិនិត្យតាមដានរាល់សំណង់ ទាំងឡាយណាដែលមានសភាពគ្រោះថ្នាក់ដើម្បីចាត់វិធានការចាំបាច់នានា ក្នុងការធានាសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ មានសមត្ថកិច្ចគ្រប់គ្រងការប្រើប្រាស់សំណង់គ្រប់ប្រភេទ។ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាអាជ្ញាធរមានសមត្ថកិច្ចក្នុងការ ផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ និងការប្តូរមុខងារប្រើប្រាស់សំណង់ទៅតាមបញ្ញត្តិ ស្តីពីសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់។[74] ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរ ឬការដកហូតអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈ ឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាចប្រគល់ ឬធ្វើប្រតិភូកម្មសមត្ថកិច្ចដូចមានចែងជូនដល់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។[75]

**២.៣.១.២. ក្រសួងមហាផ្ទៃ**

ការត្រួតពិនិត្យការដ្ឋានសំណង់បានរកឃើញថាសំណង់អាគារមួយចំនួនដែលត្រូវបានសាងសង់រួចរាល់ និងខ្លះទៀតកំពុងសាងសង់ មិនបានគិតគូរពីប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យនោះទេ ។ អគ្គស្នងការនគរបាល ជាតិ និងមជ្ឈមណ្ឌលជាតិ ត្រួតពិនិត្យគុណភាពប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ បានដាក់ឱ្យដំណើរការច្បាប់ស្តីអំពី ប្រព័ន្ធសុវត្ថិភាពអគ្គីភ័យថ្មី ក្នុងគោលបំណងការពារអ្នករស់នៅក្នុងអគារ និងទ្រព្យសម្បត្តិ តាមរយៈការកំណត់ ស្តង់ដារបច្ចេកទេស។

ក្រសួងមហាផ្ទៃមានសមត្ថកិច្ចៈ

- ត្រួតពិនិត្យប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យលើរាល់សំណង់ និងគោលដៅឱ្យបានត្រឹមត្រូវស្របតាម បទដ្ឋានបច្ចេកទេស

[74] មាត្រា៤,មាត្រា៥ នៃអនុក្រឹត្យលេខ ២២៦ អនក្រ.បក ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើ ប្រាស់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

[75] មាត្រា៩១ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

➢ ត្រួតពិនិត្យឧបករណ៍ សម្ភារៈ បរិក្ខារសម្រាប់បំពាក់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ
➢ បញ្ជាក់ទទួលស្គាល់លើគំនូរប្លង់ប្រព័ន្ធបង្ការ និងអគ្គិភ័យ។

ការចេញលិខិតផ្អាកសកម្មភាពបណ្ដោះអាសន្នដល់ផ្នែកណាមួយនៃសំណង់ និងគោលដៅ ដែលខ្វះលក្ខខណ្ឌ និងវិធានការបង្ការ និងពន្លត់អគ្គិភ័យ។[76] ជាមួយគ្នានោះផងដែរ ក្រសួងមហាផ្ទៃមានសមត្ថកិច្ចដាក់ចេញនូវគោលការណ៍ វិធានការ ការបណ្ដុះបណ្ដាល ការហ្វឹកហាត់ជំនាញអំពីការបង្ការ និងការពន្លត់អគ្គិភ័យ។[77] ចំពោះតម្រូវការត្រួតពិនិត្យលើប្លង់ប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យ រាល់សំណង់ និងគោលដៅដែលជាមូលដ្ឋានកងទ័ព ឬគោលដៅរក្សាការសម្ងាត់ទាក់ទងនឹងសន្តិសុខជាតិ ឬក្នុងស្ថានទូត ស្ថានកុងស៊ុល ស្ថានតំណាងបរទេស និវេសដ្ឋាន ឬស្ថានតំណាងអង្គការអន្តរជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាមីពាក់ព័ន្ធ។ ក្នុងករណីមានសំណើពីក្រសួងសាមីពាក់ព័ន្ធ អង្គភាពបង្ការ និងអគ្គិភ័យនៃក្រសួងមហាផ្ទៃ អាចជួយគាំទ្រលើផ្នែកបច្ចេកទេសបាន។ [78]

ក្រសួងមហាផ្ទៃធ្វើប្រតិភូកម្មអំណាចដល់អគ្គស្នងការដ្ឋាននគរបាលជាតិ និងស្នងការដ្ឋាននគរបាលរាជធានី- ខេត្ត ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យលើប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យរាលសំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ។[79] ក្រសួងមហាកផ្ទៃ អាចសហការជាមួយក្រសួង ស្ថាប័ន និងដៃគូជំនាញផ្នែកបច្ចេកទេសប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ សំដៅលើកកម្ពស់វិជ្ជាជីវៈ និងបច្ចេកទេសនៃការត្រួតពិនិត្យប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ។[80] មន្ត្រីនគរបាលបង្ការ និងពន្លត់អគ្គិសភ័យដែលចុះត្រួតពិនិត្យលើសំណង់ និងគោលដៅត្រូវបង្ហាញបណ្ណសម្គាល់ខ្លួន សញ្ញាសម្គាល់ និងលិខិតបញ្ជាបេសកកម្មជូនម្ចាស់សំណង់ ឬជនដែលខ្លួនត្រូវទំនាក់ទំនង និងត្រូវសមានកំណត់ហេតុត្រឹមត្រូវច្បាស់លាស់។[81]

---

[76] មាត្រា៥ នៃអនុក្រឹត្យលេខ៨២ អនក្រ.បក ស្តីពីចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១៨

[77] មាត្រា៧ នៃច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ ឆ្នាំ ២០១៣

[78] មាត្រា៦ នៃអនុក្រឹត្យលេខ៨២ អនក្រ.បក ស្តីពីចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១៨

[79] មាត្រា៧ នៃអនុក្រឹត្យលេខ៨២ អនក្រ.បក ស្តីពីចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១៨

[80] មាត្រា៨ នៃអនុក្រឹត្យលេខ៨២ អនក្រ.បក ស្តីពីចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១៨

[81] មាត្រា៩ នៃអនុក្រឹត្យលេខ៨២ អនក្រ.បក ស្តីពីចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១៨

### ២.៣.១.៣. អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។ ក្រមសីលធម៌សម្រាប់អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។[82]

បុគ្គលដែលមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ ឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជា និងមានវិញ្ញាបនបត្រធានារ៉ាប់រង ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មរបស់ខ្លួន។ កម្មវត្ថុនៃធានារ៉ាប់រងសំដៅធានាការបំពេញកាតព្វកិច្ចដែលបានចែងក្នុងកិច្ចសន្យារវាងអ្នកប្រកបវិជ្ជាជីវៈ ឬអ្នកប្រកបអាជីវកម្ម និងអតិថិជនរបស់ខ្លួន។ ចំនួនទឹកប្រាក់អប្បបរមា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈ ឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។[83]

អ្នកម៉ៅការសាងសង់ ឬរុះរើត្រូវមានការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានចំពោះការងារសាងសង់ ឬរុះរើដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើ ដើម្បីផ្តល់សំណងដល់ការខូចខាត ការបាត់បង់ទ្រព្យសម្បត្តិ ការមានរបួស ការមានពិការភាព ឬការបាត់បង់ជីវិត ដែលបង្កឡើងដោយការងារនោះដល់អ្នកដែលប្រតិបត្តិការងារ និងតតិយជន។ អាជ្ញាធរមានសមត្ថកិច្ចត្រូវធានាថាអ្នកម៉ៅការសាងសង់បានចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងណាមួយរួចហើយ មុននឹងអនុញ្ញាតឱ្យបើកការដ្ឋាន។[84]

ក្នុងករណីអ្នកម៉ៅការសាងសង់ចុះកិច្ចសន្យាម៉ៅការសាងសង់ ឬរុះរើបន្ត កាតព្វកិច្ចចុះកិច្ចសន្យាធានារ៉ាប់រងភារៈកិច្ចទទួលខុសត្រូវការដ្ឋាន គឺជាបន្ទុករបស់របស់អ្នកម៉ៅការសាងសង់ ឬរុះរើនោះ។ ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានត្រូវគ្របដណ្តប់លើប្រតិបត្តិការការងាររបស់អ្នកម៉ៅការសាងសង់ ឬរុះរើបន្តទាំងអស់។ ក្នុងករណីម្ចាស់សំណង់ចុះកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើជាមួយអ្នកម៉ៅការសាងសង់ ឬរុះរើច្រើនសម្រាប់ប្រតិបត្តិការការងារសាងសង់ ឬរុះរើសំណង់តែមួយ អ្នកម៉ៅការសាងសង់ ឬរុះរើទាំងអស់ត្រូវចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានរៀងៗខ្លួន។[85]

ជាមួយគ្នានោះផងដែរ ប្រធានការដ្ឋាន ឬអ្នកម៉ៅការត្រូវទទួលខុសត្រូវក្នុងការកំណត់រាល់សុវត្ថិភាពនៅការដ្ឋាន និងត្រូវរក្សានូវប្រព័ន្ធគ្រប់គ្រងដ៏ត្រឹមត្រូវដើម្បីធានាឱ្យបាននូវសុវត្ថិភាពដល់កម្មករ និងសាធារណជន

[82] មាត្រា១៣ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[83] មាត្រា១៩ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[84] មាត្រា៧២ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[85] មាត្រា៧៣ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០២៩

ដែលនៅក្នុង កៀរ ឬដើរឆ្លងកាត់។ ការទទួលខុសត្រូវទាំងនេះរួមមាន ការបង្កើតឡើងនូវប្រព័ន្ធ និងបែបបទទាំងឡាយមុនពេលចាប់លផ្ដើមការងារក្នុងការដ្ឋានដូចជា៖

- ការរៀបចំបទបញ្ជា ឬលក្ខខណ្ឌមុននឹងចូលក្នុងការដ្ឋាន
- ការអប់រំ ណែនាំអំពីគោលការណ៍សុវត្ថិភាពការដ្ឋាន
- ការរៀបចំឱ្យមានអ្នកគ្រប់គ្រងផ្នែកសុវត្ថិភាពក្នុងការដ្ឋាន ហើយអ្នកគ្រប់គ្រងនេះត្រូវទទួលការបណ្តុះបណ្តាលផ្នែកសុវត្ថិភាពឱ្យបានត្រឹមត្រូវច្បាស់លាស់
- ការដាក់ស្លាក់សញ្ញា និងកំណត់សម្គាល់អំពីសុវត្ថិភាព និងគ្រោះថ្នាក់
- សន្តិសុខក្នុង និងក្រៅការដ្ឋាន
- ការរៀបចំបាយការណ៍ ការចុះឈ្មោះ និងការបំពេញបែបបទផ្សេងៗរបស់អ្នកចូលធ្វើការក្នុងការដ្ឋាន
- ការរៀបចំឱ្យមានការប្រឹក្សាអំពីសុខភាព និងសុវត្ថិភាព។[86]

**២.៣.១.៤. ម្ចាស់សំណង់**

ម្ចាស់សំណង់ សំដៅដល់កម្មសិទ្ធិករនៃសំណង់ ឬអ្នកអភិវឌ្ឍអចលនវត្ថុ ដែលគ្រោងឬបានសាងសង់នៅលើដីរបស់ខ្លួនផ្ទាល់នៅលើដីរបស់អ្នកដទៃដោយមានការអនុញ្ញាតពីម្ចាស់ដី ឬអ្នកជួលអចិន្ត្រៃយ៍ដែលបានសាងសង់លើដីរបស់អ្នកឱ្យជួលអចិន្ត្រៃយ៍។[87] ម្ចាស់សំណង់ និងអ្នកគ្រប់គ្រងសំណង់មានកាតព្វកិច្ចរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច និងអនុវត្តន៍តាមវិធានការបញ្ចៀសគ្រោះថ្នាក់ទាំងឡាយដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។

ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួលសំណង់ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងការខូចខាតកើតឡើងដល់អ្នកដទៃ ក្នុងករណីដែលការប្រើប្រាស់ឬការគ្រប់គ្រងសំណង់នោះមានវិការៈ។ កម្មសិទ្ធិករនៃសំណង់ដែលស្ថិតក្នុងបញ្ជីសំណង់ ដែលមានសភាពគ្រោះថ្នាក់របស់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់និងសាធារណជន។ ម្ចាស់សំណង់ និងអ្នកគ្រប់គ្រងសំណង់ដែលស្ថិតក្នុងបញ្ជីសំណង់មានគ្រោះថ្នាក់ មានកាតព្វកិច្ចរាយការណ៍អំពីស្ថានភាព និងការប្រែប្រួលនៃសំណង់ជូនអាជ្ញាធរមានសមត្ថកិច្ច។

---

[86] សៀវភៅការណែនាំអំពីសុវត្ថិភាពក្នុងការដ្ឋានសំណង់,ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បោះពុម្ពឆ្នាំ២០២០ចំណុចទី៥ ទំព័រទី៨

[87] ប្រការ៣ ចំណុច៦នៃប្រកាសលេខ ០១៣ ដនស/ប្រក/នីក ស្តីពីបែបបទ និងបរិបថនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ថ្ងៃទី២២ មករា ២០២២

ក្នុងករណីចាំបាច់ដើម្បីបញ្ចៀសគ្រោះថ្នាក់ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបន្ទាន់មានជាអាទិ៍ ការជូនដំណឹងជាសាធារណៈ ការតម្រូវឱ្យជួសជុល ឬកែប្រែសំណង់ ការកម្រិតការប្រើប្រាស់ ការហាមប្រើប្រាស់ ការហ៊ុមព័ទ្ធសំណង់ ការហាមចូល ការកំណត់បរិវេណសុវត្ថិភាព ការជម្លៀស និងការតម្រូវឱ្យរុះរើសំណង់ទាំងមូល ឬមួយផ្នែកទៅតាមកម្រិតហានិភ័យនៃគ្រោះថ្នាក់ដោយរាល់ចំណាយជាបន្ទុករបស់ម្ចាស់សំណង់។ ក្នុងករណីម្ចាស់សំណង់មិនធ្វើការរុះរើសំណង់តាមការតម្រូវរបស់អាជ្ញាធរមនាសមត្ថកិច្ច អាជ្ញាធរមានសមត្ថកិច្ចអាចធ្វើការរុះរើសំណង់នោះដោយផ្ទាល់ រាល់ការចំណាយជាបន្ទុករបស់ម្ចាស់សំណង់។[88] ម្ចាស់សំណង់ ឬម្ចាស់គោលដៅ ត្រូវមានគំនូរប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ និងមានការបញ្ជាក់ទទួលស្គាល់ពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត មុនដំណើរការសាងសង់។ គំរូប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យត្រូវបានសិក្សា និងគូរដោយអ្នកជំនាញមានវិជ្ជាជីវៈ និងមានការទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ច។ ម្ចាស់សំណង់ ឬម្ចាស់គោលដៅចាំបាច់ត្រូវទទួលបានលិខិតបញ្ជាក់បញ្ចប់ការរៀបចំប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិសភ័យទទួនលពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត។ បែបបទ និងនីតិវិធីនៃការស្នើសុំរបស់ម្ចាស់សំណង់ និងម្ចាស់គោលដៅ ដូចមានចែងនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[89] ម្ចាស់សំណង់ឬម្ចាស់គោលដៅមុនការរុះរើ និងជួសជុល កែតម្រូវទៅលើប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យត្រូវស្នើសុំលិខិតអនុញ្ញាតពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត។[90]

### ២.៣.១.៥. មន្ត្រីអធិការកិច្ចសំណង់

មន្ត្រីអធិការកិច្ចសំណង់ទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសដូចមានចែងក្នុងច្បាប់ស្តីពីសំណង់ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

មន្ត្រីអធិការកិច្ចសំណង់មានភារកិច្ច និងសិទ្ធិដូចខាងក្រោមៈ

- ត្រួតពិនិត្យ បញ្ឈប់ ចាត់វិធានការបណ្តោះអាសន្ន និងពិន័យអន្តរការណ៍ចំពោះបទល្មើសសំណង់ដែលមានចែងក្នុងច្បាប់

[88] មាត្រា៣២ នៃអនុក្រឹត្យលេខ ២២៦ អនក្រ.បក ស្តីពីលក្ខខណ្ឌនិងនីតិវិធីការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

[89] មាត្រា១៦ នៃអនុក្រឹត្យលេខ៨៧ អ.ន.ក្រ/បក ស្តីពីចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១៨

[90] មាត្រា១៧ នៃអនុក្រឹត្យលេខ៨៧ អ.ន.ក្រ/បក ស្តីពីចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ចុះថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ២០១៨

❖ ដកហូតជាបណ្ដោះអាសន្ននូវលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណពាក់ព័ន្ធក្នុងករណីដែលអ្នកកាន់កាប់លិខិតអនុញ្ញាត ឬអាជ្ញាបណ្ណនោះប្រព្រឹត្តល្មើសនឹងច្បាប់

❖ ចាប់យកវត្ថុតាងនិងកសាងសំណុំរឿងនៃបទល្មើសសំណង់

❖ ចាត់វិធានការផ្សេងទៀតនៅក្នុងក្របខណ្ឌនៃការអនុវត្តច្បាប់។

បែបបទ និងនីតិវិធីនៃការធ្វើអធិការកិច្ចសំណង់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[91] មន្ត្រីអធិការកិច្ចសំណង់អាចស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដូចមានចែងក្នុងច្បាប់។ ក្នុងករណីបទល្មើសជាក់ស្ដែង ឬមិនមានលិខិតអនុញ្ញាតសាងសង់ ឬរុះរើ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវផ្ដល់ព័ត៌មានជាបន្ទាន់ដល់មន្ត្រីអធិការកិច្ចសំណង់មានសមត្ថកិច្ចដែលនៅជិតបំផុត ដើម្បីចាត់ការតាមនីតិវិធី។[92] ការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចសំណង់។

**២.៣.១.៦. មេជាងសំណង់**

អនុលោមតាមប្រកាសលេខ ៧៥ ប្រក/ជនស ចុះថ្ងៃទី ០២ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ស្ដីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់ និងដើម្បីគ្រប់គ្រងឱ្យមានប្រសិទ្ធភាពការងារសាងសង់ ដែលអនុវត្តដោយក្រុមជាងសំណង់នៅតាមបណ្ដាខេត្ត ក្រុង ដែលបច្ចុប្បន្នក្រុមជាងសំណង់ទាំងនេះប្រកបអាជីវកម្មសាងសង់តាមទ្រង់ទ្រាយអាជីវកម្មតូច និងមិនទាន់មានច្បាប់អនុញ្ញាត ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អំពីគោលការណ៍ដូចតទៅ៖[93]

**ក.សិទ្ធិរបស់ក្រុមមេជាង**

ការប្រកបអាជីវកម្មរបស់ក្រុមជាងសំណង់ ត្រូវបានប្រគល់សិទ្ធិឱ្យអនុវត្តការងារតាមការកំណត់ និងមុខជំនាញដូចខាងក្រោម ហើយដែលមានទំហំបច្ចេកទេសមិនលើសពីកម្រិតកំណត់ដូចតទៅ៖

- ផ្ទៃក្រឡាសំណង់សរុប ៨០ម៉ែត្រទ្វេគុណ
- ផ្ទៃក្រឡាសំណង់ ដែលត្រូវសង់ថ្មីបន្ត ឬពង្រីកបន្ថែម ត្រូវបូកបញ្ចូលនឹងផ្ទៃក្រឡាសំណង់ចាស់មានស្រាប់
- ផ្ទៃក្រឡាសំណង់ត្រូវគិតបញ្ចូលគ្នា ចំពោះសំណង់ដែលមានគ្រឿងផ្គុំជាប់គ្នា ទោះបីមានកម្មសិទ្ធិដោយឡែកពីគ្នា ឬពេលវេលានៃការអនុញ្ញាតឱ្យសាងសង់ខុសគ្នាក៏ដោយ

---

[91] មាត្រា៥៩ នៃច្បាប់ស្ដីពីសំណង់ ឆ្នាំ២០១៩

[92] មាត្រា៦១ នៃច្បាប់ស្ដីពីសំណង់ ឆ្នាំ២០១៩

[93] កថាខណ្ឌ១ នៃសារាចរណែនាំលេខ ០០១ ដ.ន.ស/អ.ស.ណ ស្ដីពីការគ្រប់គ្រងក្រុមជាងសំណង់ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០

- កម្ពស់អគារមួយជាន់(ជាន់ផ្ទាល់ដី)
- អគារពុំមានគ្រឿមលក្ខណៈសង់បន្ថែមច្រើនជាន់
- សំណង់អគារពុំស្ថិតនៅតំបន់ដីបាក់ស្រុត តំបន់ដីមានកម្រិតទ្រខ្សោយ
- ធ្នឹមកម្រាល ធ្នឹមទ្រផ្សេងៗ មានប្រវែង ៤ម៉ែត្រ ហ្វ្រេមគ្រោងដំបូលមានប្រវែង ៨ម៉ែត្រ ធ្នឹមលយមានប្រវែង ១.៥០ម៉ែត្រ
- អាងកប់ដី ដែលមានចំណុះ ១០ម៉ែត្រត្រីគុណ អាងទឹកខ្ពស់ពីដី ៤ម៉ែត្រ ដែលមានចំណុះ ៨ម៉ែត្រត្រីគុណ អាងកម្ពស់ ២.៥ម៉ែត្រ គិតពីនីវ៉ូដីត្រង់ជើងរបង
- សំណង់ជាលំនៅឋានរបស់ប្រជាពលរដ្ឋធ្វើពីឈើ (ដោយមិនគិតពីផ្ទៃក្រឡា និងកម្ពស់នៃសំណង់)
- ម៉ៅការបន្ត ការងារជួលជុល និងសាងសង់ពី សហគ្រាស ក្រុមហ៊ុនសាងសង់នានា ដែលមានលិខិតអនុញ្ញាតប្រកបអជីវកម្មពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដោយមានការទទួលខុសត្រូវលើលក្ខណៈបច្ចេកទេសពីសហគ្រាស ក្រុមហ៊ុនសាងសង់នោះ
- ក្រុមជាងសំណង់កាលណាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចសុំតម្លើងឋានៈប្រភេទ ជាសហគ្រាស ក្រុមហ៊ុន សាងសង់បាន ដោយត្រូវធ្វើបែបបទស្នើសុំមកក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីពិនិត្យសម្រេច។[94]

ជាមួយគ្នានោះផងដែរ មន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ខេត្ត ក្រុង ក៏មានសមត្ថកិច្ចចំពោះក្រុមជាងផងដែរ ហើយភារកិច្ចទាំងនោះមានដូចជា៖

- ❖ ចេញលិខិតអនុញ្ញាប្រកបអាជីវកម្មឱ្យក្រុមជាងសំណង់
- ❖ ចេញលិខិតបិទ ផ្អាក អាជីវកម្ម ក្រុមហ៊ុនរួមទាំងក្រុមជាង និងក្រុមជាងតាមមុខជំនាញ ដែលធ្វើអាជីវកម្មក្នុងមូលដ្ឋានរបស់ខ្លួន
- ❖ តាមដាន ត្រួតពិនិត្យ គ្រប់គ្រងសកម្មភាពអាជីវកម្ម
- ❖ ត្រូវផ្អាក ឬបិទសកម្មភាពអាជីវកម្មរបស់ក្រុមជាងសំណង់ណា ដែលប្រកបអាជីវកម្មជួសជុល និងសាងសង់ គ្មានលិខិតអនុញ្ញាតពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ឬក្នុងករណីដែលក្រុមជាងសំណង់នោះមិនគោរពតាមការកំណត់ ឬការណែនាំបទប្បញ្ញត្តិផ្សេងៗពីក្រសួងស្ថាប័ន និងមន្ទីរខេត្ត ក្រុងមានសមត្ថកិច្ច។

[94] ចំណុចទី១ នៃសារាចរណែនាំលេខ ០០១ ដ.ន.ស/អ.ស.ណ ស្តីពីការគ្រប់គ្រងក្រុមជាងសំណង់ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០

**ខ. លក្ខខណ្ឌសុំប្រកបអាជីវកម្មរបស់ក្រុមជាងសំណង់**

- ប្រធានក្រុមជាងសំណង់ ដែលជាមេជាងសំណង់ត្រូវមានសញ្ញាតិខ្មែរ
- ប្រធានក្រុមជាងសំណង់ត្រូវមកដាក់ពាក្យសុំប្រកបអាជីវកម្មដោយខ្លួនឯងផ្ទាល់
- នាមករណ៍របស់ក្រុមជាងមិនអនុញ្ញាតឱ្យប្រើពាក្យថា សហគ្រាស ឬក្រុមហ៊ុនឡើយ
- ក្រុមជាងសំណង់ត្រូវបង់ពន្ធអាករផ្សេងៗស្របតាមសេចក្តីប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិញ្ញវត្ថុ
- ក្រុមហ៊ុនជាងសំណង់ ត្រូវតំកល់ទុករបាយការណ៍សកម្មភាពការងារប្រចាំឆ្នាំរបស់ខ្លួននៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងសុរិយោដី ខេត្ត ក្រុងតាមការណែនាំរបស់មន្ទីររៀបចំ ដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង
- ក្នុងករណីមានការផ្លាស់ប្តូរអាសយដ្ឋាន ឬប្រធានក្រុមជាងសំណង់ ត្រូវជូនដំណឹងមកមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង យ៉ាងយូរ២សប្តាហ៍។[95]

**គ. សុពលភាព នៃលិខិតអនុញ្ញាតប្រកបអាជីវកម្ម**

លិខិតអនុញ្ញាតប្រកបអាជីវកម្ម ដល់ក្រុមជាងសំណង់ មានសុពលភាពបីឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាត ហើយក្នុងរយៈពេល៣០ថ្ងៃមុនកំណត់សុពលភាពក្រុមជាងសំណង់ ត្រូវដាក់ពាក្យសុំលិខិតអនុញ្ញាតជាថ្មីពីមន្ទីរ រៀបចំដែនដី នគរូបណនីយកម្ម សំណង់ និងសុរិយោដី ខេត្ត ក្រុង ដោយភ្ជាប់មកជាមួយនូវ លិខិតអនុញ្ញាតចាស់ និងបង្កាន់ដៃបង់ពន្ធអាករជាថ្មី។[96]

## ២.៣.២.វិធានការបញ្ចៀសគ្រោះថ្នាក់ការសាងសង់

អង្គភាពមានសមត្ថកិច្ចមានភារកិច្ចត្រួតពិនិត្យ និងតាមដានរាល់សំណង់ដែលត្រូវបានចុះបញ្ជីសំណង់ដែលមានសភាពគ្រោះថ្នាក់ និងលើកសំណើជូនអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចេញវិធានការបញ្ចៀសគ្រោះថ្នាក់ ឬដកចេញពីបញ្ជីសំណង់ដែលមានសភាពគ្រោះថ្នាក់។

### ២.៣.២.១. ការបញ្ចៀសការសាងសង់ និងប្រើប្រាស់សំណង់ដែលត្រូវហាមឃាត់

ស្របតាមការណែនាំស្តីពីការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានដាក់ចេញនូវបទបញ្ញត្តិ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធ ដើម្បីពង្រឹងដល់ការអនុវត្តច្បាប់ស្តីពីសំណង់ឱ្យកាន់តែមានប្រសិទ្ធភាព មិនតែប៉ុណ្ណោះគឺដើម្បីជំរុញដល់ការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ឱ្យមានការប្រុងប្រយ័ត្នខ្ពស់។ បទបញ្ញត្តិទាំងនោះមានចែងដូចតទៅៈ

[95] ចំណុចទី៣ នៃសារាចរណែនាំលេខ ០០១ ដ.ន.ស/អ.ស.ណ ស្តីពីការគ្រប់គ្រងក្រុមជាងសំណង់ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០

[96] ចំណុចទី៥ នៃសារាចរណែនាំលេខ ០០១ ដ.ន.ស/អ.ស.ណ ស្តីពីការគ្រប់គ្រងក្រុមជាងសំណង់ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០

- ហាមដាច់ខាតការសាងសង់សំណង់ដែលគ្មានលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ និងលិខិតអនុញ្ញាតបើកការដ្ឋានសំណង់។
- ហាមដាច់ខាតអនុវត្តការងារសាងសង់ឬរុះរើ ដោយអ្នកសាងសង់ដែលគ្មានអាជ្ញាបណ្ណ ឬវិញ្ញាបនបត្របញ្ជាក់ការអនុញ្ញាតឱ្យប្រកបអាជីវកម្មផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ហាមដាច់ខាតការដ្ឋានសំណង់ដែលដំណើរការការសាងសង់ ឬរុះរើដោយគ្មានវិស្វករប្រចាំការដ្ឋានជាអ្នកទទួលខុសត្រូវ
- ហាមដាច់ខាតការស្នាក់នៅក្នុងអគារដែលកំពុងសាងសង់ ទោះជាលក្ខណៈបណ្តោះអាសន្នក៏ដោយ និងហាមដាច់ខាតអ្នកគ្មានភារកិច្ចចូលក្នុងការដ្ឋានសំណង់។
- ហាមការប្រើប្រាស់សំណង់គ្រប់ប្រភេទ ដោយគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ឬលិខិតបិទការដ្ឋានផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ច។[97]

បន្ថែមពីលើនេះទៀតនៅក្នុងអនុក្រឹត្យលេខ ២២៦ អនក្រ.បក ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ បានបញ្ជាក់អំពីលក្ខណៈនៃសំណង់ដែលមិនត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ ដោយត្រូវហាមឃាត់ការចាត់ចែងការធ្វើចរន្តការនានាពាក់ព័ន្ធនឹងសំណង់ ការប្រើប្រាស់ក្នុងគោលដៅក្រៅពីលំនៅដ្ឋាន ឬការផ្សព្វផ្សាយពាណិជ្ជកម្ម ចំពោះសំណង់ដូចខាងក្រោម៖

- សំណង់ដែលគ្មានវិញ្ញាបណ្ណបត្រប្រើប្រាស់សំណង់
- សំណង់ដែលម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ ឬអ្នកជួលសំណង់មិនបានអនុវត្តវិធានការបញ្ចៀសគ្រោះថ្នាក់របស់អាជ្ញាធរមានសមត្ថកិច្ច
- សំណង់ដែលវិញ្ញាបនបត្រសំណង់ត្រូវបានព្យួរ ឬដកហូត។

អាជ្ញាធរមានសមត្ថកិច្ច ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ ឬអ្នកជួលសំណង់ ស្តីអំពីការហាមឃាត់ដោយបញ្ជាក់ពីមូលហេតុ និងការតម្រូវនានា ដើម្បីធានាសុវត្ថិភាពម្ចាស់សំណង់ អ្នកប្រើប្រាស់ និងសាធារណជន។[98]

[97] ចំណុចទី១ នៃសេចក្តីណែនាំលេខ ០០២ជនស/សណន ស្តីពីការពង្រឹងគុណភាពនិងសុវត្ថិភាពសំណង់ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២០

[98] មាត្រា៤៥ នៃអនុក្រឹត្យលេខ ២២៦ អនក្រ.បក ស្តីពីលក្ខខណ្ឌនិងនីតិវិធីការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

**២.៣.២.២. ការត្រួតពិនិត្យគុណភាពប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ**

អគ្គស្នងការនគរបាលជាតិ និងមជ្ឈមណ្ឌលជាតិ ត្រួតពិនិត្យគុណភាពប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ បានដាក់ឱ្យដំណើរការច្បាប់ស្តីអំពីប្រព័ន្ធសុវត្ថិភាពអគ្គីភ័យថ្មី ក្នុងគោលបំណងការពារអ្នករស់នៅក្នុងអគារ និងទ្រព្យសម្បត្តិ តាមរយៈការកំណត់ស្តង់ដារបច្ចេកទេស។ គ្រប់ទីប្រជុំជនត្រូវមានប្លង់គោលតម្កល់ទុកនៅអង្គភាពនគរបាលបង្ការ និងពន្លត់អគ្គិភ័យ។ រាល់សំណង់ត្រូវធានាឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យមុនដំណើរការសាងសង់។ ចំណាត់ថ្នាក់សំណង់ និងគោលដៅ ដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[99]

ការត្រួតពិនិត្យ និងការចេញសេចក្តីបញ្ជាក់អំពីគុណភាព ប្រសិទ្ធភាពនៃប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យដល់គោលដៅត្រូវត្រួតពិនិត្យធ្វើឡើងសម្រាប់រយៈពេល ២ឆ្នាំម្តង។ ក្នុងករណីចាំបាច់ម្ចាស់គោលដៅ អាចលើកសំណើសុំឱ្យត្រួតពិនិត្យមុនកាលកំណត់បាន។ បែបបទ និងនីតិវិធីនៃការត្រួតការចេញសេចក្តីបញ្ជាក់អំពីគុណភាព ប្រសិទ្ធភាពនៃប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[100]

ច្បាប់នេះ មិនត្រូវបានអនុវត្តចំពោះការរចនាប្រព័ន្ធបង្ការអគ្គិភ័យសម្រាប់អគារ និងសំណង់ដែលជាអគារឧស្សាហកម្ម (ឃ្លាំង) សម្រាប់រំសេវ ជាតិផ្ទុះ ឬអគារឧស្សាហកម្ម (ឃ្លាំង) សម្រាប់កាំជ្រួច និងផាវ។

**២.៣.២.៣. ការជូនដំណឹងរបស់មន្ត្រីសមត្ថកិច្ច**

អាជ្ញាធរមានសមត្ថកិច្ច ត្រូវកំណត់រយៈពេលសម្រាប់អនុវត្តវិធានការបញ្ចៀសគ្រោះថ្នាក់ដោយម្ចាស់សំណង់ទៅតាមកម្រិតនៃការប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ និងកម្រិតនៃហានិភ័យដែលសំណង់អាចបង្កដល់មនុស្ស និងទ្រព្យសម្បត្តិរបស់អ្នកជិតខាង និងសាធារណជន។

លិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់ ដោយម្ចាស់សំណង់ និងរយៈពេលសម្រាប់អនុវត្តសិទ្ធិតវ៉ារបស់ម្ចាស់សំណង់។

**២.៣.២.៤. ការកំណត់រយៈពេលនៃការអនុវត្តវិធានការ**

អាជ្ញាធរមានសមត្ថកិច្ចត្រូវកំណត់រយៈពេលសម្រាប់អនុវត្តសិទ្ធិតវ៉ារបស់ម្ចាស់សំណង់ទៅតាមប្រភេទ និងកម្រិតនៃសភាពគ្រោះថ្នាក់របស់សំណង់ ប៉ុន្តែរយៈពេលនេះមិនត្រូវយូរជាង៖

[99] មាត្រា១៨ នៃច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ ឆ្នាំ២០១៣

[100] មាត្រា១៩ នៃច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ ឆ្នាំ២០១៣

- ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់ សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែន នគរូបនីយកម្ម និងសំណង់។
- ៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់ សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាល គណៈនៃគណៈអភិបាលរាជធានីខេត្ត
- ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់ សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

**២.៣.២.៥. ការកំណត់ទោសបញ្ញត្តិ**

ទណ្ឌកម្មក្នុងច្បាប់ស្តីពីសំណង់មាន ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរ ឬការដកហូតអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈ ឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ការពិន័យអន្តរការណ៍ ការហាមឃាត់ការប្រកបវិជ្ជាជីវៈ ការបង្ខំឱ្យរុះរើ និង/ឬសាងសង់ឡើងវិញឱ្យដូចសភាពដើម ទោសពិន័យជាប្រាក់ និងទោសដាក់ពន្ធនាគារ។[101] ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យរំលត់បណ្តឹងអាជ្ញា។ ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍មន្ត្រីអធិការកិច្ចសំណង់អាចកសាងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការមានសមត្ថកិច្ច។ បទល្មើសដែលត្រូវផ្តន្ទាទោសពិន័យអន្តការណ៍ត្រូវកំណត់ដោយអនុក្រឹត្យ។ ចំពោះនីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ចំណូលដែលបានពីការពិន័យចំពោះអំពើល្មើស ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[102]អាជ្ញាធរមានសមត្ថកិច្ចអាចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ចំពោះសំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាត ឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់នេះចូលជាធរមានក្នុងករណីសំណង់នោះមិនបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់ និងសាធារណជនព្រមទាំងមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។ បែបបទ និងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។[103]

ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលជអាចតម្រូវឱ្យអ្នកវិជ្ជាជីវៈ ឬក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់តម្កល់ប្រាក់នៅធនាគារជាតិនៃកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈ ឬប្រកបអាជីវកម្មរបស់

[101] មាត្រា៩០ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[102] មាត្រា៩២ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

[103] មាត្រា១០៧ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

ខ្លួន។ អ្នកវិជ្ជាជីវៈ ឬក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ អាចដកប្រាក់តម្កល់វិញនៅពេលឈប់ប្រកបវិជ្ជាជីវៈ ឬប្រកបអាជីវកម្មនោះ និងនៅពេលអាជ្ញាបណ្ណផុតសុពលភាព ឬត្រូវបានដកហូតដោយអាជ្ញាធរមានសមត្ថកិច្ច។ អ្នកទទួលសេវាពីអ្នកវិជ្ជាជីវៈ ឬក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ ដែលទទួលរងការខូចខាតមានឯកសិទ្ធិលំដាប់ទី២ បន្ទាប់ពីប្រាក់ឈ្នួលរបស់កម្មករនិយោជិត ចំពោះប្រាក់តម្កល់ដូចមានចែងក្នុងកថាខណ្ឌនេះ។ [104]

[104] មាត្រា១០៩ នៃច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩

# សេចក្ដីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បច្ចុប្បន្ន ការអភិវឌ្ឍនៃវិស័យបច្ចេកវិទ្យាកាន់តែជឿនលឿនតម្រូវការ ជំនាញស្របទៅតាមនិន្នាការនេះក៏មានកាន់តែច្រើនឡើងផងដែរ ទន្ទឹមនឹងគ្នានោះគឺត្រូវទាមទារឱ្យវិស័យរដ្ឋ និងឯកជនពួតដៃគ្នាដើម្បីអភិវឌ្ឍបន្ថែមទៀតទៅលើវិស័យសំណង់ ក្នុងនោះកម្លាំងពលកម្មជំនាញប្រកបដោយគុណភាព គឺជាឆ្អឹងខ្នងដ៏សំខាន់សម្រាប់ការអភិវឌ្ឍវិស័យសំណង់នៅកម្ពុជា ដើម្បីឈានទៅរក្សាកំណើនសេដ្ឋកិច្ចជាតិ។ ជាមួយគ្នានោះផងដែរ កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ក៏ទាមទារឱ្យមានការចូលរួមចំណែកពីវិស័យឯកជន ដែលជាដៃគូមិនអាចខ្វះបានក្នុងការអភិវឌ្ឍជំនាញនៅកម្ពុជា។ ការរួមចំណែកដល់ការអភិវឌ្ឍវិស័យសំណង់នៅកម្ពុជាស្ថាប័នពាក់ព័ន្ធរួមមានកម្មករសំណង់ អ្នកជំនាញស្ថាបត្យកម្ម វិស្វកម្ម វិស្វករសំណង់ស៊ីវិល វិស្វករផ្នែកអគ្គិសនី វិស្វករផ្នែកប្រព័ន្ធទឹក បុគ្គលិកផ្នែកអភិវឌ្ឍន៍ពាណិជ្ជកម្ម និងអ្នកគ្រប់គ្រងអគារជាដើម។ បើទោះបីជាកម្លាំងពលកម្មជំនាញក្នុងវិស័យសំណង់កម្ពុជាមានការរីកចម្រើនជាងមុនក្តី កម្លាំងពលកម្មដែលមានជំនាញប្រកបដោយគុណភាព នៅតែមិនទាន់អាចឆ្លើយតបបានគ្រប់គ្រាន់តាមតម្រូវការដែលកំពុងកើនឡើងយ៉ាងគំហុកនៅឡើយទេ។ ភាពរីកចម្រើននៃវិស័យសំណង់ បានបង្កើតការងារជាច្រើនជូនដល់ប្រជាពលរដ្ឋ ជាពិសេសយុវជនកម្ពុជា។ វិស័យមួយនេះក៏បានជួយកាត់បន្ថយលំហូរចេញរបស់យុវជនទៅធ្វើការនៅក្រៅប្រទេសផងដែរ។ ម្យ៉ាងវិញទៀតកាលណាបើមានការរីកចម្រើនខ្លាំងនោះ បញ្ហាគ្រោះថ្នាក់នៅក្នុងវិស័យសំណង់ក៏មានច្រើន ដែលតម្រូវឱ្យមានការចូលរួមការពារពីគ្រប់ស្ថាប័នពាក់ព័ន្ធ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រហូតដល់ប្រជាពលរដ្ឋដែលជាម្ចាស់សំណង់ផងដែរ។ ការអនុវត្តបទដ្ឋានសុវត្ថិភាពនៅតាមការដ្ឋានសំណង់នីមួយៗ ត្រូវតែធានាឱ្យមានប្រសិទ្ធភាពការយកទីតាំងការដ្ឋានសំណង់ធ្វើជាកន្លែងស្នាក់នៅផង និងសាងសង់ផងគឺជាហានិភ័យសម្រាប់ជីវិតមនុស្សជាពិសេសកម្មករសំណង់ និងក្រុមគ្រួសារ។ អ្នកទទួលខុសត្រូវសាងសង់ និងម្ចាស់សំណង់មិនត្រូវឱ្យរួចផុតពីបទព្រហ្មទណ្ឌដោយគ្រាន់តែចេញសំណង់ដល់ជនរងគ្រោះនោះឡើយ។ សុវត្ថិភាព គឺជាកត្តាចំបងនិងមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងការដ្ឋានសំណង់។ គ្រោះថ្នាក់ចៃដន្យអាចកើតឡើងនៅគ្រប់ពេល ប្រសិនបើកម្មករខ្វះការប្រុងប្រយ័ត្ន ឬខ្វះចំណេះដឹងទាក់ទងនឹងសុវត្ថិភាពសំណង់ ។

ដូច្នេះដើម្បីបញ្ចៀស និងគ្រប់គ្រងគ្រោះថ្នាក់ផ្សេងៗ ដែលអាចកើតឡើងជាយថាហេតុ នៅតាមការដ្ឋានសំណង់ និងដែលអាចបង្កផលប៉ះពាល់ដល់សុខភាព អាយុជីវិត និងផែនការនៃគម្រោងសាងសង់ គឺតម្រូវឱ្យគ្រប់ប្រតិបត្តិករពាក់ព័ន្ធទាំងអស់ យកចិត្តទុកដាក់ខ្ពស់អំពីសុវត្ថិភាព និងសុខភាព នៅក្នុងអំឡុងពេលបំពេញការងារនៅតាមការដ្ឋានសំណង់ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយពីវិធានការច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា មានភាពចាំបាច់សម្រាប់កម្មករ និយោជិតក្រុមហ៊ុនសិក្សាគម្រោងប្លង់ ក្រុមហ៊ុនសាងសង់ និងអ្នកពាក់ព័ន្ធក្នុងវិស័យសាងសង់។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការស្រាវជ្រាវនិងបានបកស្រាយនូវប្រធានបទទាក់ទងនឹង «**នីតិវិធីគ្រប់គ្រងគ្រោះថ្នាក់នៃការសាងសង់នៅកម្ពុជា**» និងដោយសង្កេតឃើញថា ការការពារ និងការយល់ដឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់សំណង់ ព្រមទាំងភាពចំបាច់នៃការជំរុញនូវការអនុវត្តច្បាប់ស្តីពីសំណង់ឱ្យកាន់តែមានប្រសិទ្ធភាពគឺពិតជាមានសារៈសំខាន់សម្រាប់ជីវភាពរស់នៅ និងការអភិវឌ្ឍក្នុងវិស័យសំណង់ នាងខ្ញុំមានជាអនុសាសន៍ចំនួន១០ចំណុច ដើម្បីជាគន្លឹះក្នុងការកែលម្អបន្ថែម។ ម៉្យាងវិញទៀត ចំពោះជីវភាពរស់នៅប្រចាំថ្ងៃ រួមទាំងក្នុងការងារទូទៅ យើងពិនិត្យឃើញថា ការយល់ដឹងអំពីគុណភាព សុវត្ថិភាពសំណង់ និងគ្រោះថ្នាក់នៃការសាងសង់ខុសបច្ចេកទេស នៅមានកម្រិតនៅឡើយ។ បន្ថែមពីលើនេះទៀត ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធពុំទាន់យល់ច្បាស់អំពីសិទ្ធ និងកាតព្វកិច្ចរបស់ខ្លួននៅក្នុងការសាងសង់ ព្រមទាំងគម្រោងសំណង់ដែលកំពុងប្រតិបត្តការ។ ចំណុចខ្វះខាតទាំងនេះគឺជាហេតុនៃការបង្កឱ្យមានការកើតឡើងគ្រោះថ្នាក់ក្នុងការសាងសង់ ជាក់ស្តែងការបាក់រលំអគារ ការស្រុតអគារ បង្កើតជាភយន្តរាយដល់អាយុជីវិតមនុស្សជាច្រើន។ ការអភិវឌ្ឍន៍ទីក្រុង ត្រូវតែគិតដល់បរិស្ថាន សុខមាលភាព និងសុវត្ថិភាពសារធារណៈដែលទាំងនេះជាតួនាទីរបស់រដ្ឋ។ ការបំពានលើបម្រាម ឬសេចក្តីណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ច គឺជាការល្មើសច្បាប់ដែលត្រូវតែផ្តន្ទាទោសយ៉ាងតឹងរឹង អ្នកសមគំនិត និងអ្នកប្រព្រឹត្តត្រូវទទួលទោសដូចគ្នា។

១. ក្រសួងពាក់ព័ន្ធជាពិសេសក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងមហាផ្ទៃ ត្រូវកំណត់ច្បាប់ ឬវិធានការ រៀបចំឱ្យមានឧបករណ៍សម្រាប់ត្រួតពិនិត្យសុវត្ថិភាពការងារក្នុងវិស័យសំណង់ ឱ្យបានគ្រប់គ្រាន់ ដើម្បីធានាសុវត្ថិភាពរបស់អ្នកសាងសង់ និងអ្នកប្រើប្រាស់ផងដែរ។

២. រៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីសុវត្ថិភាពការងារក្នុងវិស័យសំណង់ អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ និងដល់មេជាង ព្រមទាំងកម្មករសំណង់។

៣. ជាមួយគ្នានោះផងដែរ គួរតែបង្កើតវគ្គបណ្តុះបណ្តាលដល់កម្មករក្នុងវិស័យសំណង់ឱ្យបានញឹកញាប់ ដើម្បីជាការរួមចំណែកជួយលើកកម្ពស់ជំនាញរបស់មេជាងសំណង់កម្ពុជាក៏ដូចជាគុណភាពវិស័យសំណង់នៅកម្ពុជាផងដែរ។

៤. កម្រិតទោសព្រហ្មទណ្ឌចំពោះបុគ្គល ឬស្ថាប័នដែលល្មើសនឹងបទបញ្ញតិ ដែលបានចែងនៅក្នុងច្បាប់សំណង់ និងច្បាប់នានាដែលពាក់ព័ន្ធ

៥. ពង្រឹងការអនុវត្តច្បាប់របស់មន្ត្រីមានសមត្ថកិច្ច ចំពោះការត្រួតពិនិត្យតាមការដ្ឋាននីមួយៗមានការត្រួតពិនិត្យ វាយតម្លៃពីស្ថាប័នជំនាញ ដើម្បីឱ្យប្រាកដថាគម្រោងសាងសង់នីមួយៗមានច្បាប់អនុញ្ញាត និងមានគុណភាពតាមស្តង់ដារសុវត្ថិភាព។

៦. ជំរុញការចូលរួមរបស់ប្រជាពលរដ្ឋ និងសាធារណៈ ព្រោះមជ្ឈដ្ឋានទាំងពីរនេះត្រូវទទួលរងផលប៉ះពាល់ផ្ទាល់ពីគ្រោះថ្នាក់សំណង់ដែលកើតឡើង។

៧. ជំរុញអោយមានការចុះធ្វើអធិការកិច្ចការងារជាប្រចាំឱ្យមានប្រសិទ្ធភាព និងតម្លាភាព ដើម្បីពិនិត្យមើលអំពីលក្ខខណ្ឌសុវត្ថិភាព និងបទដ្ឋានការងាររបស់កម្មករសំណង់នៅទូទាំងប្រទេសកម្ពុជា។

៨. បញ្ឈប់ជាបន្ទាន់នូវសកម្មភាពម៉ៅការបន្តដែលគ្មានអាជ្ញាបណ្ណ និងធានាការអនុវត្តបទដ្ឋានសុវត្ថិភាពគ្រប់ការដ្ឋានសំណង់។

៩. ផ្តន្ទាទោសទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ចំពោះអ្នកសមគំនិត ត្រូវទទួលទោសដូចអ្នកប្រព្រឹត្តផ្ទាល់ដែរ។ អាជ្ញាធរមានសមត្ថកិច្ចត្រូវតែទទួលខុសត្រូវទទួលខុសត្រូវលើគ្រោះថ្នាក់ទទួលទោសដូចអ្នកប្រព្រឹត្តផ្ទាល់ដែរ។

១០. ករណីមានគ្រោះថ្នាក់ធ្ងន់ធ្ងរ គឺក្រសួងអាចនឹងបញ្ជាឱ្យបិទការដ្ឋានតែម្តង។

នាងខ្ញុំជឿជាក់ថា សំណូមពរទាំងដប់ចំណុចខាងលើរបស់នាងខ្ញុំនឹងអាចជួយដល់ការងារគ្រប់គ្រងសំណង់នៅព្រះរាជាណាចក្រកម្ពុជាកាន់តែល្អប្រសើរឡើង និងកាន់តែមានប្រសិទ្ធិភាពដើម្បីឆ្លើយតបយ៉ាងទាន់ពេល ស្របទៅនឹងការរីកចម្រើនយ៉ាងខ្លាំងក្លានាពេលបច្ចុប្បន្ននឹងនាពេលអនាគតលើវិស័យសំណង់នេះ។ នាងខ្ញុំក៏សង្ឃឹមយ៉ាងមុតមាំ ថាយោបល់ខាងលើនឹងត្រូវបានយកទៅពិនិត្យ និងពិភាក្សាដោយអាជ្ញាធរពាក់ព័ន្ធផងដែរ៕

# ឯកសារយោង

## ឯកសារយោង

### ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ច្បាប់ស្តីពីសំណង់ ឆ្នាំ២០១៩
- ច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៩
- ច្បាប់ស្តីពីការរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឆ្នាំ១៩៩៤
- ព្រះរាជក្រឹត្យស្តីពីការបង្កើតមន្ទីរពិសោធន៍គណៈវិស្វករកម្ពុជា
- អនុក្រឹត្យលេខ ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់
- អនុក្រឹត្យលេខ ២២៦ អនក្រ/បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់
- អនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ
- ព្រះរាជក្រឹត្យលេខ ០៣ ន.ស/រ.ក.ត/១២១១/១១២៤ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈស្ថាបត្យករកម្ពុជា
- អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- អនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- ប្រកាសលេខ ០៤៧ ដនស/ប្រក/នី.ក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់
- ប្រកាសលេខ ១០៩ ដ.ន.ស/ ប.ក./ នី.ក. ចុះថ្ងៃទី២២ ខែវិច្ឆកា ឆ្នាំ២០២១ ស្តីពីបែបបទនៃការងារត្រួតពិនិត្យ និងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្ម និងគម្រោងប្លង់ គ្រឿងផ្គុំសំណង់
- ប្រកាសលេខ ១២៦ ដ.ន.ស./ ប.ក./ នី/ក. ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីបទនៃ ការងារត្រួតពិនិត្យ និងបញ្ជាក់ការងារសាងសង់ និងរុះរើផ្នែកស្ថាបត្យកម្ម និងផ្នែកគ្រឿងផ្គុំសំណង់
- ប្រកាសលេខ ១៧៧ ដនស/ប្រក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន
- ប្រកាសលេខ ០៧៤ ប្រក/អសណ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ ២០១៣ ស្តីពីការអនុញ្ញាតជួសជុលសំណង់អគារ
- ប្រកាសលេខ ១៩២ ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ ២០០៧ ស្តីពីការគ្រប់គ្រងរូបវន្តបុគ្គលគម្រោងប្លង់

- ប្រកាសលេខ ៣២ ប្រក/សហ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១ ស្តីពីការគ្រប់គ្រងការដ្ឋានសំណង់
- ប្រកាសលេខ ៧៦ ប្រក/ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និង សុរិយោដី រាជធានី-ខេត្ត និងតួនាទី ភារកិច្ចរបស់បណ្ដាលការិយាល័យក្រោមឱវាទ
- ប្រកាសលេខ ៧៥ ប្រក/ដនស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៩ ស្តីពីការគ្រប់គ្រងសហគ្រាស និងក្រុមហ៊ុនសិក្សាគម្រោងប្លង់ និងសាងសង់
- សេចក្តីណែនាំលេខ ០០២ ដនស/សណន ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០២០ ស្តីអំពីការពង្រឹងគុណភាព និងសុវត្ថិភាពសំណង់
- សេចក្តីសម្រេចលេខ ០០៥ សសរ ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០២០ ស្តីពីការចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់
- សេចក្តីជូនដំណឹងលេខ ៩៤៨ សជណ ចុះថ្ងៃទី ០៥ កក្កដា ២០១៩ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ១៩៨៣ ដនស/អរប ចុះថ្ងៃទី ២៧ មិថុនា ២០១៩ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- សេចក្តីណែនាំលេខ ០០៣ ដនស/សណន ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការអនុវត្តប្រកាសអន្តរក្រសួងស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈកិច្ចទទួលខុសត្រូវការដ្ឋាន
- សារាចរណែនាំលេខ ០០១ ដនស/អសណ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការគ្រប់គ្រងក្រុមជាងសំណង់
- សារាចរណែនាំលេខ ០០២ ដនស/អសណ ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការចុះបញ្ជី អាជីវកម្មសិក្សាគម្រោងប្លង់ និងសាងសង់របស់សហគ្រាស ក្រុមហ៊ុន និងរូបវន្តបុគ្គលបរទេស

## ២. ប្រភពសៀវភៅ

- សៀវភៅនីតិនគរូបនីយវិទ្យា, បណ្ឌិត អ៊ុន សកក្កដា , បោះពុម្ពឆ្នាំ២០១៩
- សៀវភៅណែនាំស្តីពីសុវត្ថិភាពក្នុងការដ្ឋានសំណង់, ក្រសួងរៀបចំដែនដី នគររូបនីយកម្ម និងសំណង់, បោះពុម្ពឆ្នាំ២០២០

## ៣. ប្រភពពីគេហទំព័រ

- គេហទំព័រ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ https://www.mlmupc.gov.kh/
- គេហទំព័រ https://opendevelopmentcambodia.net/km/topics/construction/
- គេហទំព័រ https://www.rfi.fr/km/Cambodia/building-collapse-in-SHV-22-06-2019

# បញ្ជីឧបសម្ព័ន្ធ

## ១. ឧបសម្ព័ន្ធរូបភាព

- ឧបសម្ព័ន្ធទី១៖ បណ្តុំរូបភាពសំណង់អគារដែលខុសពីលក្ខណៈបទដ្ឋានបច្ចេកទេ
- ឧបសម្ព័ន្ធទី២៖ បណ្តុំសំណង់អគារដែលសមស្របតាមបច្ចេកទេស
- ឧបសម្ព័ន្ធទី៣៖ បណ្តុំរូបភាពសំណង់អគារដួលរលំនៅខេត្តព្រះសីហនុនាថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩
- ឧបសម្ព័ន្ធទី៤៖ បណ្តុំរូបភាពសំណង់អគារដួលរលំនៅខេត្តកែប  នាថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០
- ឧបសម្ព័ន្ធទី៥៖ បណ្តុំរូបភាពគ្រោះថ្នាក់ដាច់ជណ្តើរយោងឡើងអគារកំពុងសាងសង់ក្នុងខេត្ត ព្រះសីហនុ នាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២
- ឧបសម្ព័ន្ធទី៦៖ បណ្តុំរូបភាពនៃគ្រោះថ្នាក់នៃការរលំដងសន្ទូចនៅការដ្ឋានសំណង់មួយក្រុងប៉ោយប៉ែត នាថ្ងៃទី១៣ ខែសីហា ២០២២
- ឧបសម្ព័ន្ធទី៧៖ អង្គការលេខក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ឧបសម្ព័ន្ធទី៨៖ រចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ
- ឧបសម្ព័ន្ធទី៩៖ ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់
- ឧបសម្ព័ន្ធទី១០៖ ពាក្យសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់
- ឧបសម្ព័ន្ធទី១១៖ អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់
- ឧបសម្ព័ន្ធទី១២៖ គំរូទម្រង់របាយការណ៍បញ្ជីត្រួតពិនិត្យគុណភាព និងសុវត្ថិភាពសំណង់
- ឧបសម្ព័ន្ធទី១៣៖ គំរូទម្រង់បញ្ជីសំណង់ដែលមានសភាពគ្រោះថ្នាក់
- ឧបសម្ព័ន្ធទី១៤៖ ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ពង្រីកបន្ថែម រុះរើ ជួសជុល
- ឧបសម្ព័ន្ធទី១៥៖ កិច្ចសន្យាសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុលជាប់ជញ្ជាំងអឡ្លសិទ្ធិ
- ឧបសម្ព័ន្ធទី១៦៖ កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន
- ឧបសម្ព័ន្ធទី១៧៖ កិច្ចសន្យារបស់ក្រុមហ៊ុន ឬក្រុមជាងសាងសង់
- ឧបសម្ព័ន្ធទី១៨៖ ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់
- ឧបសម្ព័ន្ធទី១៩៖ វិញ្ញាបនបត្រប្រើប្រាស់សំណង់(សម្រាប់សមត្ថកិច្ចរបស់ក្រសួង)

## ២. ឧបសម្ព័ន្ធគតិយុត្ត

- ឧបសម្ព័ន្ធទី១៖ ច្បាប់ស្តីពីសំណង់ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១៧/០១៩ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩
- ឧបសម្ព័ន្ធទី២៖ ច្បាប់ស្តីពីការបន្លត់អគ្គិភ័យប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម ០៦១៣/ ០០៧ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៣
- ឧបសម្ព័ន្ធទី៣៖ អនុក្រឹត្យលេខ ២២៤ អនក្រ.បក ស្តីពីលិខិតអនុញ្ញាតសាងសង់ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០
- ឧបសម្ព័ន្ធទី៤៖ អនុក្រឹត្យលេខ ៨៧ អនក្រ.បក ស្តីពីចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៨
- ឧបសម្ព័ន្ធទី៥៖ ប្រកាសលេខ ០៤៧ ដនស/ប្រ.ក/នី.ក ស្តីពីការបញ្ចៀសគ្រោះថ្នាក់សាងសង់ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២

# ឧបសម្ព័ន្ធរូបភាព

# ឧបសម្ព័ន្ធទី១

បណ្តុំរូបភាពសំណង់អគារដែលខុសពីលក្ខណៈបទដ្ឋានបច្ចេកទេស







## ឧបសម្ព័ន្ធទី២

សំណង់អគារដែលសមស្របតាមបច្ចេកទេស





# ឧបសម្ព័ន្ធទី៣

បណ្តុំរូបភាពសំណង់អគារដួលរលំនៅខេត្តព្រះសីហនុ  នាថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៩





# ឧបសម្ព័ន្ធទី៤

បណ្តុំរូបភាពសំណង់អគារដួលរលំនៅខេត្តកែប  នាថ្ងៃទី០៣ ខែមករា ឆ្នាំ២០២០





# ឧបសម្ព័ន្ធទី៥

បណ្ដុំរូបភាពគ្រោះថ្នាក់ដាច់ជណ្ដើរយោងឡើងអគារកំពុងសាងសង់ក្នុងខេត្តព្រះសីហនុនាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២២







# ឧបសម្ព័ន្ធទី៦

បណ្តុំរូបភាពនៃគ្រោះថ្នាក់នៃការរលំដងសន្ទូចនៅការដ្ឋានសំណង់មួយក្រុងប៉ោយប៉ែត

នាថ្ងៃទី១៣ សីហា ២០២០










# ឧបសម្ព័ន្ធ៧

អង្គការលេខក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់



# ឧបសម្ព័ន្ធ៨

រចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី-ខេត្ត និងការិយាល័យរៀបចំ
ដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក-ខណ្ឌ



# ឧបសម្ព័ន្ធទី៩

## ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
ច្រកចេញ - ចូលតែមួយ

**ពាក្យសុំលិខិតអនុញ្ញាតសាងសង់**

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ..................................................ភេទ........ឆ្នាំកំណើត.................សញ្ជាតិ............. មុខរបរ..............................បច្ចុប្បន្នស្នាក់នៅផ្ទះលេខ.........ផ្លូវលេខ........ក្រុមទី...........សង្កាត់................................ ខណ្ឌ.............................................រាជធានីភ្នំពេញ។

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ..................................................ភេទ........ឆ្នាំកំណើត.................សញ្ជាតិ............. មុខរបរ..............................បច្ចុប្បន្នស្នាក់នៅផ្ទះលេខ.........ផ្លូវលេខ........ក្រុមទី...........សង្កាត់................................ ខណ្ឌ.............................................រាជធានីភ្នំពេញ។

**សូមគោរពជូន**
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**តាមរយៈ** : - ចៅសង្កាត់.....................................................................................
- អភិបាលខណ្ឌ.....................................................................................
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ

**កម្មវត្ថុ** : សំណើសុំ............................................................ លើដីឡូត៍លេខ......................ផ្លូវលេខ................ ភូមិ.....................សង្កាត់..................................ខណ្ឌ..........................................រាជធានីភ្នំពេញ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំ សូមជម្រាបជូន ឯកឧត្តម មេត្តាជ្រាបថា:
.........................................................................................................................................

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើសូមឯកឧត្តម មេត្តាអនុញ្ញាតច្បាប់អោយដល់ខ្ញុំបាទ-នាងខ្ញុំ កាន់កាប់ ......................................................................................................ដោយអនុគ្រោះ ។

សូម ឯកឧត្តម មេត្តាទទួលនូវការគោរព ដ៏ខ្ពង់ខ្ពស់បំផុត អំពីខ្ញុំបាទ-នាងខ្ញុំ។

***សូមជូនភ្ជាប់មកជាមួយនូវ :***

- ច្បាប់ថតចំលងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ចំនួន.................ច្បាប់
- ប្លង់ស្ថាបត្យកម្ម ចំនួន.................ច្បាប់
- សលាកប័ត្រដីឡូត៍ ចំនួន.................ច្បាប់
- កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន ចំនួន.................ច្បាប់
- កិច្ចសន្យាសាងសង់ ចំនួន.................ច្បាប់
- ច្បាប់ថតចំលងអត្តសញ្ញាណប័ណ្ណ ចំនួន.................ច្បាប់

ភ្នំពេញ,ថ្ងៃទី.........ខែ.............ឆ្នាំ២០.....
**ស្នាមមេដៃស្តាំអ្នកស្នើសុំ**

លេខ:.....................
បានឃើញ និង បញ្ជូនមក
លោកអភិបាលខណ្ឌ.............................
"ដើម្បីពិនិត្យ និងជួយសម្រួលដោយក្តីអនុគ្រោះ"
ភ្នំពេញ, ថ្ងៃទី..........ខែ...............ឆ្នាំ២០.......
**ចៅសង្កាត់**..........................

លេខ:.....................
បានឃើញ និង បញ្ជូនមក
លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម
សំណង់ និងសុរិយោដីរាជធានីភ្នំពេញ។
"ដើម្បីពិនិត្យ និងជួយសម្រួលដោយក្តីអនុគ្រោះ"
ភ្នំពេញ, ថ្ងៃទី..........ខែ...............ឆ្នាំ២០.......
**អភិបាលខណ្ឌ**...........................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ





| ចំណុច | អាប់ស៊ីស | អរដោនេ |
|---|---|---|
| 1 | 488620.296 | 1270860.501 |
| 2 | 488640.337 | 1270825.394 |
| 3 | 488657.165 | 1270785.972 |
| 4 | 488620.045 | 1270761.806 |
| 5 | 488633.529 | 1270721.373 |
| 6 | 488581.482 | 1270700.518 |
| 7 | 488541.978 | 1270768.765 |
| 8 | 488558.081 | 1270794.508 |
| 9 | 488542.950 | 1270801.504 |

ដ ឃុំ ... ស្រុក

# ឧបសម្ព័ន្ធទី១០

ឧបសម្ព័ន្ធ៨នៃប្រកាសលេខ ០១៣ ដនសព/ប្រ.កនីក ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០២២ ស្តីពីបែបបទ និងបរិបទនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

***គំរូទម្រង់ពាក្យស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់***

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់**

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ ____________ ភេទ ______ អាយុ ______ ឆ្នាំ សញ្ជាតិ ____________

មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ ____________ ផុតកំណត់ ____________

ជាតំណាងស្របច្បាប់របស់ ______________________ (នាមករណ៍នីតិបុគ្គល)

មានទីស្នាក់ការ ផ្ទះ/អគារលេខ ______ ផ្លូវ ______ ភូមិ ______ ឃុំ/ សង្កាត់ ____________

ក្រុង/ស្រុក/ខណ្ឌ ________ រាជធានី/ ខេត្ត ________ អ៊ីមែល ________ លេខទូរស័ព្ទ ________

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**<u>កម្មវត្ថុ</u>៖** សំណើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់

**<u>យោង</u>៖** លិខិតអនុញ្ញាតសាងសង់លេខ ________ ថ្ងៃទី _____ ខែ ______ ឆ្នាំ២០ ___

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/ នាងខ្ញុំសូមគោរពជម្រាប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា ដោយមានការចាំបាច់ ខ្ញុំបាទ/ នាងខ្ញុំគោរពស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ខាងលើ។

សូមគោរពជូនភ្ជាប់ឯកសារកែប្រែនៃសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ ដូចខាងក្រោម (ករណីមានការកែប្រែ)៖

១- ______________________________________________

______________________________________________

២- ______________________________________________

______________________________________________

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាសម្រេចដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/ នាងខ្ញុំ។

ថ្ងៃ __________ ខែ ___ ឆ្នាំ______ ព.ស. ___

ធ្វើនៅ _______ ថ្ងៃទី_____ ខែ_____ ឆ្នាំ _______

ហត្ថលេខា គោត្តនាមនិងនាមរបស់ម្ចាស់សំណង់ ឬតំណាងស្របច្បាប់

និងត្រារបស់នីតិបុគ្គល

# ឧបសម្ព័ន្ធទី១១
# អាជ្ញាបណ្ណត្រួតពិនិត្យ និងបញ្ជាក់សំណង់



គំរូទម្រង់អាជ្ញាបណ្ណសម្រាប់ក្រុមហ៊ុន

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
Ministry of Land Management, Urban Planning and Construction
លេខ/N° ____________

**ព្រះរាជាណាចក្រកម្ពុជា**
Kingdom of Cambodia
**ជាតិ សាសនា ព្រះមហាក្សត្រ**
Nation Religion King

## អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់
## CONSTRUCTION CERTIFIER LICENCE

នាមករណ៍ក្រុមហ៊ុន ____________
Company Name ____________
បញ្ជីពាណិជ្ជកម្មលេខ ____________ ចុះថ្ងៃទី ____________
Company Registration N° ____________ Dated ____________
ទីស្នាក់ការ ____________
Head Office ____________
ប្រធានក្រុមហ៊ុន ____________
President/CEO ____________
នាយកបច្ចេកទេស ____________
Technical Director ____________

អាជ្ញាបណ្ណត្រួតពិនិត្យនិងបញ្ជាក់សំណង់ លេខ ____________
Construction Certifier Licence N° ____________
ថ្នាក់ ____________ កម្រិត ____________
Class ____________ Level ____________
កាលបរិច្ឆេទផ្ដល់អាជ្ញាបណ្ណដំបូង ____________
First Issue Date ____________
សុពលភាពត្រឹមថ្ងៃទី ____________
Valid until ____________
អ្នកកាន់អាជ្ញាបណ្ណត្រូវគោរពបទដ្ឋានគតិយុត្តជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។
The licensee shall observe and comply with relevant laws and regulations of the Kingdom of Cambodia.

រាជធានីភ្នំពេញ ថ្ងៃ ______ ខែ ______ ឆ្នាំ ______ ព.ស. ______ ត្រូវនឹងថ្ងៃទី ______ ខែ ______ ឆ្នាំ ______
Phnom Penh, ____________

**រដ្ឋមន្ត្រី** Minister

# ឧបសម្ព័ន្ធទី១២

ឧបសម្ព័ន្ធ១នៃប្រកាសលេខ ០៤៣ ជនស/ប្រ.ក.ស.ក ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០២២ ស្ដីពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់

*គំរូទម្រង់របាយការណ៍ស្ដីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ត្រាសញ្ញា

**ឈ្មោះស្ថាប័ន**

ឈ្មោះអង្គភាព

លេខ : ................

**សូមគោរពជូន**

______________________________

**កម្មវត្ថុ៖** របាយការណ៍ស្ដីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ____________ មានទីតាំងស្ថិតនៅលើដីឡូត៍លេខ ______ ផ្លូវលេខ _____ ក្រុមទី ____ ភូមិ ______ ឃុំ សង្កាត់ __________ ក្រុង ស្រុក ខណ្ឌ __________ រាជធានី ខេត្ត ______

**យោង៖**-ប្រកាសលេខ ______ ចុះថ្ងៃទី ____ ខែ _____ ឆ្នាំ២០២២ ស្ដីពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់

-យោងចំណារ ______________________________

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំមានកិត្តិយសសូមគោរពរាយការណ៍ជូន __________ មេត្តាជ្រាបថា នៅថ្ងៃទី ___ ខែ ____ ឆ្នាំ២០ ___ មន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ដឹកនាំដោយ ______________ បានចុះត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ នៅលើដីឡូត៍លេខ______ ផ្លូវលេខ_____ ក្រុមទី____ ភូមិ_______ ឃុំ សង្កាត់_________ ក្រុង ស្រុក ខណ្ឌ __________ រាជធានី ខេត្ត __________ ដែលមាន ____________ (ឯកសារបញ្ជាក់អំពីការកាន់កាប់ដីស្របច្បាប់) លេខ ___________ ចុះថ្ងៃទី _____ខែ____ ឆ្នាំ __ ទទួលបានលទ្ធផលដូចខាងក្រោម៖

**១. ព័ត៌មានទូទៅ**

– ម្ចាស់សំណង់ឈ្មោះ ___________ ភេទ ____ សញ្ជាតិ _____ ថ្ងៃខែឆ្នាំកំណើត _________
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ ______________
និងប្រពន្ធ/ប្ដីឈ្មោះ ____________ សញ្ជាតិ ______ ថ្ងៃខែឆ្នាំកំណើត ________
កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ ______________

មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ______ ផ្លូវ ______ ភូមិ _________ ឃុំ សង្កាត់ ____________
ក្រុង ស្រុក ខណ្ឌ ____________ រាជធានី ខេត្ត _____________ លេខទូរស័ព្ទ _____________

- **ម្ចាស់ដីឈ្មោះ** ______________________ (ក្នុងករណីម្ចាស់ដីមិនមែនជាម្ចាស់សំណង់) ភេទ ____
  សញ្ជាតិ __________ ថ្ងៃខែឆ្នាំកំណើត _______________ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/
  លិខិតឆ្លងដែនលេខ ______________________ និងប្រពន្ធ/ប្តីឈ្មោះ _______________
  សញ្ជាតិ ________ ថ្ងៃខែឆ្នាំកំណើត _________________ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/
  លិខិតឆ្លងដែនលេខ __________________________ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ______
  ផ្លូវ ________ ភូមិ ___________ ឃុំ សង្កាត់ ____________ ក្រុង ស្រុក ខណ្ឌ ___________
  រាជធានី ខេត្ត _____________ លេខទូរស័ព្ទ ______________
- **អ្នកគ្រប់គ្រងសំណង់ឈ្មោះ** _________________ ភេទ ____ សញ្ជាតិ ______ ថ្ងៃខែឆ្នាំកំណើត
  ________ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ/លិខិតឆ្លងដែនលេខ ________________
  និងប្រពន្ធ/ប្តីឈ្មោះ ________________ សញ្ជាតិ ________ ថ្ងៃខែឆ្នាំកំណើត ____________
  កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ _____________________________
  មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ______ ផ្លូវ ______ ភូមិ _________ ឃុំ សង្កាត់ ____________
  ក្រុង ស្រុក ខណ្ឌ ____________ រាជធានី ខេត្ត _____________ លេខទូរស័ព្ទ ____________
- **អ្នកផ្តល់សំណង់ឈ្មោះ** ____________ ភេទ ____ សញ្ជាតិ _______ ថ្ងៃខែឆ្នាំកំណើត ________
  កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ ____________________________
  និងប្រពន្ធ/ប្តីឈ្មោះ ________________ សញ្ជាតិ ________ ថ្ងៃខែឆ្នាំកំណើត ____________
  កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនលេខ ____________________________
  មានទីលំនៅបច្ចុប្បន្នផ្ទះលេខ ______ ផ្លូវ ______ ភូមិ _________ ឃុំ សង្កាត់ ____________
  ក្រុង ស្រុក ខណ្ឌ ____________ រាជធានី ខេត្ត _____________ លេខទូរស័ព្ទ ____________
- **អំពីកិច្ចសន្យា៖**
  - កិច្ចសន្យាផ្តល់សំណង់៖ ☐ គ្មាន ☐ មាន ចុះថ្ងៃទី ________ ខែ _______ ឆ្នាំ២០ ____
  - កិច្ចសន្យាម៉ៅការសាងសង់៖ ☐ គ្មាន ☐ មាន ចុះថ្ងៃទី ______ ខែ _____ ឆ្នាំ២០ ___

## ២. និត្តិភាពច្បាប់

- លិខិតអនុញ្ញាតសាងសង់ ☐ គ្មាន ☐ មាន លេខ _________ ចុះថ្ងៃទី ___ ខែ ___ ឆ្នាំ២០ ____
- លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ☐ គ្មាន ☐ មាន លេខ ____ ចុះថ្ងៃទី __ ខែ __ ឆ្នាំ២០ ____
- លិខិតបិទការដ្ឋានសំណង់លេខ ________________ ចុះថ្ងៃទី ______ ខែ ______ ឆ្នាំ២០ ____
- ឯកសារបញ្ជាក់អំពីការកាន់កាប់ដីស្របច្បាប់ លេខ __________ ចុះថ្ងៃទី ___ ខែ ___ ឆ្នាំ២០ ____
- សលាកបត្រក្បាលដីលេខ ___________________ ចុះថ្ងៃទី ______ ខែ ______ ឆ្នាំ២០ ____
- ទំហំដី ____________________ ម$^{២}$
- កិច្ចសន្យាម៉ៅការសាងសង់ ________________________________________________
- វិញ្ញាបនបត្រធានារ៉ាប់រង _________________________________________________

– លិខិតអនុញ្ញាតផ្សេងៗ ______________________________

៣. **និដ្ឋភាពបច្ចេកទេស**

**ក. ព័ត៌មានទូទៅ**

– ឈ្មោះសំណង់ __________________ មុខងារប្រើប្រាស់ ______________

ផ្ទៃអំពី ____________ ចំនួន ______ ជាន់ កម្ពស់ _______ ម៉ែត្រ ផ្ទៃក្រឡាកម្រាលសំណង់សរុប ____________ ម៉ែតក្រឡា

– បញ្ចប់ការងារសាងសង់នៅឆ្នាំ ______________________________

– ទីប្រឹក្សាគម្រោង ☐ គ្មាន ☐ មាន គោត្តនាមនិងនាម/ នាមករណ៍ ______________

– អ្នកសាងសង់ ☐ ក្រុមហ៊ុន ☐ ក្រុមជាង គោត្តនាមនិងនាម/ នាមករណ៍ ______________

☐ គ្មានអាជ្ញាបណ្ណ ☐ មានអាជ្ញាបណ្ណ លេខ __________ ចុះថ្ងៃទី ____ ខែ _____ ឆ្នាំ២០ ___

– អ្នកគ្រប់គ្រងការដ្ឋាន ☐ គ្មាន ☐ មាន ឈ្មោះ ______________________________

– អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ផ្នែកស្ថាបត្យកម្ម ☐ គ្មាន ☐ មាន គោត្តនាមនិងនាម/ នាមករណ៍ ______________________________

– អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ផ្នែកគ្រឿងផ្គុំសំណង់ ☐ គ្មាន ☐ មាន គោត្តនាមនិងនាម/ នាមករណ៍ ______________________________

**ខ. ការត្រួតពិនិត្យផ្នែកស្ថាបត្យកម្ម**

**ខ.១-** ប្លង់ស្ថាបត្យកម្ម ☐ គ្មាន ☐ មាន

- អ្នកសិក្សាគម្រោងប្លង់ ☐ គ្មាន ☐ មាន គោត្តនាមនិងនាម/ នាមករណ៍ ______________

  ☐ គ្មានអាជ្ញាបណ្ណ ☐ មានអាជ្ញាបណ្ណ លេខ ________ ចុះថ្ងៃទី ____ ខែ ____ ឆ្នាំ២០ __

- អ្នកត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់ស្ថាបត្យកម្ម ☐ គ្មាន ☐ មាន គោត្តនាមនិងនាម/ នាមករណ៍ ______________________________

**ខ.២-** ស្ថានភាពដែលពិនិត្យឃើញ

- ______________________________
- ______________________________

**គ. ការត្រួតពិនិត្យផ្នែកគ្រឿងផ្គុំសំណង់**

**គ.១-** ប្លង់គ្រឿងផ្គុំសំណង់ ☐ គ្មាន ☐ មាន

- អ្នកសិក្សាគម្រោងប្លង់ ☐ គ្មាន ☐ មាន គោត្តនាមនិងនាម/ នាមករណ៍ ______________

  ☐ គ្មានអាជ្ញាបណ្ណ ☐ មានអាជ្ញាបណ្ណ លេខ ________ ចុះថ្ងៃទី ____ ខែ ____ ឆ្នាំ២០ __

- អ្នកត្រួតពិនិត្យនិងបញ្ជាក់គម្រោងប្លង់គ្រឿងផ្គុំសំណង់ ☐ គ្មាន ☐ មាន គោត្តនាមនិងនាម/ នាមករណ៍ ______________________________

**គ.២-** ស្ថានភាពដែលពិនិត្យឃើញ

- ______________________________
- ______________________________

ឃ. ការត្រួតពិនិត្យផ្នែកសុវត្ថិភាពអគ្គិភ័យ

- ប្លង់ប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យ ☐ គ្មាន ☐ មាន អ្នកវិជ្ជាជីវៈឬក្រុមហ៊ុន ______________
- ______________________________
- ______________________________

ង. ការត្រួតពិនិត្យផ្នែកប្រព័ន្ធមេកានិក ប្រព័ន្ធអគ្គិសនី និងប្រព័ន្ធទឹក

- ប្លង់ប្រព័ន្ធមេកានិក ☐ គ្មាន ☐ មាន អ្នកវិជ្ជាជីវៈឬក្រុមហ៊ុន ______________
- ប្លង់ប្រព័ន្ធអគ្គិសនី ☐ គ្មាន ☐ មាន អ្នកវិជ្ជាជីវៈឬក្រុមហ៊ុន ______________
- ប្លង់ប្រព័ន្ធទឹក ☐ គ្មាន ☐ មាន អ្នកវិជ្ជាជីវៈឬក្រុមហ៊ុន ______________
- ______________________________
- ______________________________
- ______________________________

ច. កត្តាដែលធ្វើឱ្យប៉ះពាល់ដល់គុណភាពនិងសុវត្ថិភាពសំណង់

- ______________________________
- ______________________________
- ______________________________

## ៤. ការធ្វើតេស្តសំណង់

- ______________________________
- ______________________________
- ______________________________

## ៥. ចំណាត់ការរបស់អាជ្ញាធរមានសមត្ថកិច្ចនិងការអនុវត្តរបស់ម្ចាស់សំណង់

ក. ចំណាត់ការរបស់អាជ្ញាធរមានសមត្ថកិច្ច

- ______________________________
- ______________________________
- ______________________________

ខ. ការអនុវត្តរបស់ម្ចាស់សំណង់

- ______________________________
- ______________________________
- ______________________________

**៦. ឯកសារដែលម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួលសំណង់ បានប្រគល់ជូនមន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់**

**៧. សេចក្តីសន្និដ្ឋាន**

ក-ការវាយតម្លៃ

– ទិដ្ឋភាពច្បាប់

– ទិដ្ឋភាពបច្ចេកទេស

ខ-យោបល់របស់ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួលសំណង់

– ម្ចាស់សំណង់

– អ្នកគ្រប់គ្រងសំណង់

– អ្នកជួលសំណង់

គ-ការចូលរួមត្រួតពិនិត្យ ☐ គ្មាន ☐ មាន

–

–

–

ឃ-ប្រភេទនិងកម្រិតនៃសភាពគ្រោះថ្នាក់

– ប្រភេទ

– កម្រិត

ង-សំណើចាត់វិធានការ

–

–

–

៨. **ឯកសារភ្ជាប់**

ក- ទីតាំងសំណង់

- ប្លង់ទីតាំង (google map)
- ប្លង់ទីតាំងសំណង់ក្នុងដីឡូត៍។

ខ- រូបថតបង្ហាញសញ្ញាណគ្រោះថ្នាក់

គ- អត្តសញ្ញាណរបស់ម្ចាស់ដី ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និង/ឬអ្នកជួលសំណង់

សេចក្តីដូចបានគោរពរាយការណ៍ជូនខាងលើ សូម ____________________ មេត្តាពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់។

សូម ____________________ មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥

ថ្ងៃទី ខែ ឆ្នាំ២០

**អ្នកធ្វើរបាយការណ៍**

បានឃើញ និងសូមគោរពជូន

____________________ មេត្តាសម្រេចដ៏ខ្ពង់ខ្ពស់។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥

ថ្ងៃទី ខែ ឆ្នាំ២០

**ប្រធានក្រុមការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់**

បានឃើញ និងសូមគោរពជូន

____________________ មេត្តាសម្រេចដ៏ខ្ពង់ខ្ពស់។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥

ថ្ងៃទី ខែ ឆ្នាំ២០

**អគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់ ឬ**

**ប្រធានមន្ទីរ ដ.ន.ស.ស. រាជធានី ខេត្ត ឬ**

**ប្រធានការិយាល័យ ដ.ន.ស.ត. នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ**

# ឧបសម្ព័ន្ធទី១៣

ឧបសម្ព័ន្ធ២នៃប្រកាសលេខ ០៤៣ ជនសា/ប្រក/ន.ក ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០២២ ស្ដីពី
កម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់

*គំរូទម្រង់បញ្ជីសំណង់ដែលមានសភាពគ្រោះថ្នាក់*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រូបសញ្ញា

**ឈ្មោះស្ថាប័ន**
ឈ្មោះអង្គភាព
លេខ : ........

**បញ្ជីសំណង់ដែលមានសភាពគ្រោះថ្នាក់**

| ល.រ | លេខយោង | សំណង់ | ទីតាំង | មុខងារប្រើប្រាស់ | ម្ចាស់សំណង់ | អ្នកគ្រប់គ្រងសំណង់ | កម្រិតនៃសភាពគ្រោះថ្នាក់ | វិធានការ |
|---|---|---|---|---|---|---|---|---|
| ១ | | | | | | | | |
| ២ | | | | | | | | |
| ៣ | | | | | | | | |

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥
ថ្ងៃទី ខែ ឆ្នាំ២០
អ្នករៀបចំបញ្ជី

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥
ថ្ងៃទី ខែ ឆ្នាំ២០
**ប្រធានអង្គភាពមានសមត្ថកិច្ច**

**ឧបសម្ព័ន្ធទី១៤**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ពង្រីកបន្ថែម រុះរើ ជួសជុល

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................ភេទ..............អាយុ......ឆ្នាំជនជាតិ........... សញ្ជាតិ................មុខរបរ............................ទីលំនៅបច្ចុប្បន្នផ្ទះលេខ.............ផ្លូវ.........ភូមិ ............ឃុំ/សង្កាត់..........................ក្រុង/ស្រុក/ខណ្ឌ..............................រាជធានី/ខេត្ត........ កាន់អត្តសញ្ញាណប័ណ្ណលេខ.......................................លេខទូរស័ព្ទ...................................។

**សូមគោរពជូន**

**លោកអភិបាល នៃគណៈអភិបាល**..................................

**__តាមរយៈ__** ៖ ចៅសង្កាត់.........................................................................................

**__កម្មវត្ថុ__** ៖ សំណើសុំ........................................................លើដីឡូតិ៍.............ផ្លូវ.......... ភូមិ.................សង្កាត់..........................ខណ្ឌ................រាជធានី/ខេត្ត..........។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជម្រាប **លោកអភិបាល** មេត្តាជ្រាបថា៖ ខ្ញុំបាទនាងខ្ញុំមានបំណង..............................................................លើដីឡូតិ៍.............ផ្លូវ ................ភូមិ......................សង្កាត់...................................................ខណ្ឌចំការមន រាជធានីភ្នំពេញ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **លោកអភិបាល** មេត្តាពិនិត្យ និង អនុញ្ញាតិច្បាប់ឱ្យដល់ខ្ញុំបាទ នាងខ្ញុំដោយអនុគ្រោះ។

សូម **លោកអភិបាល** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ នាងខ្ញុំ។

*សូមជូនភ្ជាប់ជាមួយនូវ៖*

| | |
|---|---|
| -ច្បាប់ចម្លងប័ណ្ណសម្គាល់សិទ្ធកាន់កាប់អចនវត្ថុ | ចំនួន០៥ច្បាប់ |
| -ប្លង់ស្ថាបត្យកម្ម | ចំនួន០៥ច្បាប់ |
| -សលាកប័ត្រដីឡូត៍ | ចំនួន០៥ច្បាប់ |
| -កិច្ចសន្យាហ៊ុំព័ន្ធការដ្ឋាន | ចំនួន០៥ច្បាប់ |
| -កិច្ចសន្យាសាង់សង់ជាប់ជញ្ជាំងអឌ្ឍសិទ្ធិ<br>(ករណីសាងសង់ជាប់ជញ្ជាំងអឌ្ឍសិទ្ធិអ្នកជិតខាង) | ចំនួន០៥ច្បាប់ |
| -រូបថតបង្ហាញទីតាំង | ចំនួន០១ច្បាប់ |
| -ច្បាប់ចម្លងលិខិតបញ្ជាក់អត្តសញ្ញាណប័ណ្ណ | ចំនួន០៥ច្បាប់ |

.................,ថ្ងៃទី..........ខែ........ឆ្នាំ២០......

**ស្នាមមេដៃស្តាំ**

លេខ៖..........................

បានឃើញ និងបញ្ជូនមក

លោកអភិបាលខណ្ឌ..................មេត្តាពិនិត្យ និងសម្រេច។

..........................ថ្ងៃទី..........ខែ........ឆ្នាំ២០......

**មេឃុំ ចៅសង្កាត់**

# ឧបសម្ព័ន្ធទី១៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>កិច្ចសន្យាសាងសង់ពង្រីកបន្ថែម រុះរើ ជួសជុកជាប់ជញ្ជាំងអន្តរសិទ្ធិ</u>

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ..................................ភេទ..............អាយុ......ឆ្នាំជនជាតិ............ សញ្ជាតិ................មុខរបរ............................ទីលំនៅបច្ចុប្បន្នផ្ទះលេខ.............ផ្លូវ..........ភូមិ.... ឃុំ/សង្កាត់...........................ក្រុង/ស្រុក/ខណ្ឌ..............................រាជធានី/ខេត្ត...................... កាន់អត្តសញ្ញាណប័ណ្ណលេខ........................................លេខទូរស័ព្ទ.................................... ដែលមានព្រំដីឡូតិ៍ផ្នែកខាង................................................ ជាប់ជាមួយដីឡូតិ៍ដែលត្រូវសាង សង់លេខ...............................ក្រុមទី.........ផ្លូវ........ភូមិ...............សង្កាត់.............................. ខណ្ឌ............រាជធានី/ខេត្ត.............របស់លោក/លោកស្រី...................................................។

បានយល់ព្រមឱ្យលោក/លោកស្រី.......................................................................................... សាងសង់ជាប់ជញ្ជាំងរបស់ខ្ញុំបាទ-នាងខ្ញុំដោយសន្យាថានៅពេលដែលឈ្មោះ................................. ធ្វើការសាងសង់ បើសិនជាមានការប៉ះពារដោយប្រការណាមួយមកលើខាងខ្ញុំ................................. គឺឈ្មោះ...........................................ត្រូវទទួលខុសត្រូវទាំងស្រុងនូវរាល់ការខូចខាតនេះ។

ក្រែងពុំប្រាកដ យើងខ្ញុំសូមផ្តិតមេដៃស្តាំទុកជាភស្តុតាងស្រាប់។

..................ថ្ងៃទី..........ខែ........ឆ្នាំ២០...

**ស្នាមមេដៃស្តាំអ្នកសុំសាងសង់** **សាក្សី** **ស្នាមមេដៃស្តាំអ្នកអនុញ្ញាតឱ្យ**

លេខ:...........................................

បានឃើញ និងបញ្ជាក់ថា

ស្នាមមេដៃខាងលើនេះ ពិតជាស្នាមមេដៃរបស់ឈ្មោះ

...............................................................................និងឈ្មោះ

..................................................ពិតប្រាកដមែន។

.........................ថ្ងៃទី............ខែ....................ឆ្នាំ២០....

**ចៅសង្កាត់**

**ឧបសម្ព័ន្ធទី១៦**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>កិច្ចសន្យាហ៊ុំព័ទ្ធការដ្ឋាន</u>

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ....................................ភេទ...............អាយុ......ឆ្នាំជនជាតិ.................... សញ្ជាតិ.................មុខរបរ.............................ទីលំនៅបច្ចុប្បន្នផ្ទះលេខ.............ផ្លូវ.........ភូមិ.............ឃុំ/សង្កាត់............................ក្រុង/ស្រុក/ខណ្ឌ...............................រាជធានី/ខេត្ត.............................កាន់អត្តសញ្ញាណប័ណ្ណលេខ.........................................លេខទូរស័ព្ទ....................................។

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ....................................ភេទ...............អាយុ......ឆ្នាំជនជាតិ...........សញ្ជាតិ.................មុខរបរ.............................ទីលំនៅបច្ចុប្បន្នផ្ទះលេខ.............ផ្លូវ.........ភូមិ.............ឃុំ/សង្កាត់............................ក្រុង/ស្រុក/ខណ្ឌ...............................រាជធានី/ខេត្ត........កាន់អត្តសញ្ញាណប័ណ្ណលេខ.........................................លេខទូរស័ព្ទ....................................។

សូមធ្វើកិច្ចសន្យាជូនរដ្ឋអំណាចអំពីការដាក់សម្ភារៈសាងសង់ដែលមានទីតាំងលើដីឡូត៍លេខ........ផ្លូវ...................ភូមិ.................. សង្កាត់...........................ខណ្ឌ.......................រាជធានី/ខេត្ត......................... ដូចខាងខាងក្រោម៖

១-ធ្វើរបងហ៊ុំព័ទ្ធការដ្ឋានសាងសង់ ដាក់សម្ភារៈ និងធ្វើរបាំងឱ្យបានម៉ត់ចត់ពីក្រោមដល់លើដើម្បីការពារគ្រោះថ្នាក់ផ្សេងៗ។

២-រក្សាទុកចិញ្ចើមថ្នល់ឱ្យបានទូលាយ ស្មើនឹងពីរភាគបី សម្រាប់ឱ្យថ្មើរជើងធ្វើដំណើរទៅមកដោយសេរី។

៣-មិនយកទ្រូងផ្លូវធ្វើជាកន្លែងលាយស៊ីម៉ង់ត៍ ចាក់សំរាម កំទេចកំទីសម្ភារៈសំណង់ ណិងចាក់ថ្ម គ្រួស ខ្សាច់ ធ្វើឱ្យប៉ះពាល់ដល់អនាម័យសណ្ដាប់ធ្នាប់ដាច់ខាត។

៤-មិនបង្កទំនាស់ និងរំខានដល់អ្នកជិតខាងដែលជាប់ដីឡូត៍គ្នា។

ក្រែងពុំប្រាកដ ខ្ញុំបាទ/នាងខ្ញុំសូមផ្ដិតមេដៃស្ដាំទុកជាភស្តុតាង។

............ថ្ងៃទី...............ខែ....................ឆ្នាំ២០............

**ស្នាមមេដៃស្ដាំ**

**ឧបសម្ព័ន្ធទី១៧**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## កិច្ចសន្យារបស់ក្រុមហ៊ុន ឬក្រុមជាងសាងសង់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ....................................ភេទ.............អាយុ......ឆ្នាំជនជាតិ.............សញ្ជាតិ................ជាតំណាងក្រុមហ៊ុនសាងសង់ ឬក្រុមសាងសង់...........................................អាសយដ្ឋានបច្ចុប្បន្ន.....................................................................................................ទូរស័ព្ទលេខ........................................អត្តសញ្ញាណសញ្ជាតិខ្មែរលេខ...................................វិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់លេខ.................................ដែលចេញដោយ....................បានយល់ព្រមទទួលម៉ៅការ........................................របស់ឈ្មោះ........................................នៅដីឡូត៍លេខ.........................ផ្លូវ...................ក្រុមទី.............ភូមិ................សង្កាត់.............ខណ្ឌ.......................រាជធានី/ខេត្ត.................. ។

ខ្ញុំបាទ/នាងខ្ញុំសូមសន្យាថា៖

- គោរព និងអនុវត្តតាមការណែនាំរបស់ម្ចាស់សំណង់ និងស្របបទបញ្ញត្តិជាធរមាន
- អនុវត្តតាមប្លង់គ្រឿងផ្គុំសំណង់ និងប្លង់ស្ថាបត្យកម្មដែលបានអនុញ្ញាត
- ទទួលខុសត្រូវលើការងារបច្ចេកទេសសាងសង់ លើគុណភាព និងសុវត្ថិភាពសំណង់ ដែលសហគ្រាស ក្រុមហ៊ុនសាងសង់ ឬក្រុមជាងសំណង់បានអនុវត្ត។

ចំការមន ថ្ងៃទី...............ខែ....................ឆ្នាំ

២០............

ក្រុមហ៊ុនសាងសង់ ឬក្រុមជាងសំណង់

**ប្រធាន**

**បានឃើញ និងឯកភាព**

**ម្ចាស់សំណង់**

**<u>សូមជូនភ្ជាប់៖</u>**

- វិញ្ញាបនបត្រប្រកបអាជីវកម្មសាងសង់ ចំនួន ០១ច្បាប់

# ឧបសម្ព័ន្ធទី១៨
# ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

*ឧបសម្ព័ន្ធទី១ នៃប្រកាសលេខ.០៧៧.ដនស/ប្រក.ចុះថ្ងៃទី...០៦.....ខែ..ធ្នូ.........ឆ្នាំ២០១៩....ស្តីពីបែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់ស្តីពីសំណង់ចូលជាធរមាន*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

***គំរូទម្រង់***
*សម្រាប់សមត្ថកិច្ចរបស់ក្រសួង*

**<u>ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់</u>**

ខ្ញុំបាទ/ នាងខ្ញុំឈ្មោះ......................... ភេទ...... សញ្ជាតិ.......... ថ្ងៃខែឆ្នាំកំណើត................ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ....................... និងប្រពន្ធ/ប្តីឈ្មោះ.................. សញ្ជាតិ........ថ្ងៃខែឆ្នាំកំណើត............ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/ លិខិតឆ្លងដែនលេខ................ មានទីលំនៅបច្ចុប្បន្នផ្ទះលេខ.......ផ្លូវ........ភូមិ...........ឃុំ/ សង្កាត់................ ក្រុង/ ស្រុក/ ខណ្ឌ.............. រាជធានី/ ខេត្ត................ តំណាងឱ្យក្រុមហ៊ុន.............................. ចុះបញ្ជីលេខ............. ចុះថ្ងៃទី.... ខែ........ឆ្នាំ......... ទីស្នាក់ការស្ថិតនៅអគារលេខ.................. ភូមិ...............ឃុំ/ សង្កាត់..................... ក្រុង/ ស្រុក/ ខណ្ឌ.................រាជធានី/ ខេត្ត......................។

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**តាមរយៈ**÷ -ប្រធានច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-អគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់

**កម្មវត្ថុ** ÷ សំណើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាអនុញ្ញាតផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ដល់ខ្ញុំបាទ/ នាងខ្ញុំ ដែលបានសាងសង់រួចរាល់ កាលពីថ្ងៃទី....ខែ......ឆ្នាំ........ ជាប្រភេទសំណង់........................ សាងសង់អំពី................ កំពស់............ ម៉ែត្រ ស្មើនឹង..........ជាន់ ផ្ទៃក្រឡាសំណង់សរុប.....................ម$^{២}$ មានទីតាំងស្ថិតនៅលើដីឡូត៍លេខ............... ផ្លូវលេខ............. ភូមិ............... ឃុំ/ សង្កាត់...................... ក្រុង/ ស្រុក/ ខណ្ឌ............... រាជធានី/ ខេត្ត.................។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាពិនិត្យនិងសម្រេចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដល់ខ្ញុំបាទ/ នាងខ្ញុំ ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ/ នាងខ្ញុំ។

<u>*សូមគោរពជូនភ្ជាប់ជាមួយនូវ÷*</u>

១. ច្បាប់ចម្លងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនរបស់ម្ចាស់សំណង់ ឬអ្នកតំណាង ចំនួន ០៣ ច្បាប់

២. ច្បាប់ចម្លងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម និងលក្ខន្តិកៈក្រុមហ៊ុន (ករណីក្រុមហ៊ុន) ចំនួន ០៣ ច្បាប់

៣. លិខិតប្រគល់សិទ្ធិរបស់ក្រុមហ៊ុន (ករណីក្រុមហ៊ុន) ចំនួន ០៣ ច្បាប់

| | |
|---|---|
| ៤. ច្បាប់ចម្លងឯកសារបញ្ជាក់ការកាន់កាប់ដីដោយស្របច្បាប់ | ចំនួន ០៣ ច្បាប់ |
| ៥. សលាកបត្រក្បាលដីផ្តល់ដោយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត | ចំនួន ០៣ ច្បាប់ |
| ៦. សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែង | ចំនួន ០៣ ច្បាប់ |
| ៧. របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់(បើមាន) | ចំនួន ០៣ ច្បាប់ |
| ៨. ច្បាប់ចម្លងកិច្ចសន្យាម៉ៅការសាងសង់(បើមាន) | ចំនួន ០៣ ច្បាប់ |
| ៩. ច្បាប់ចម្លងឯកសារពាក់ព័ន្ធអ្នកម៉ៅការសាងសង់(បើមាន) | ចំនួន ០៣ ច្បាប់ |
| ១០. ច្បាប់ចម្លងរបាយការណ៍សិក្សាពិសោធន៍ដីនិងសំភារៈសំណង់(បើមាន) | ចំនួន ០៣ ច្បាប់ |
| ១១. ច្បាប់ចម្លងលិខិតអនុញ្ញាតសាងសង់ (បើមាន) | ចំនួន ០៣ ច្បាប់ |
| ១២. ច្បាប់ចម្លងលិខិតអនុញ្ញាតបើកការដ្ឋាន (បើមាន) | ចំនួន ០៣ ច្បាប់ |

ថ្ងៃ.................... ខែ.......... ឆ្នាំ.................... ព.ស. .........
ធ្វើនៅ............. ថ្ងៃទី...... ខែ.......... ឆ្នាំ.........

**ហត្ថលេខា ឬស្នាមមេដៃស្តាំអ្នកស្នើសុំ**

**__សម្គាល់:__** រាល់ឯកសារថតចម្លង ត្រូវធ្វើនីត្យានុកូលកម្ម នៅអាជ្ញាធរមានសមត្ថកិច្ច ឬមន្ទីរសារការី។

# ឧបសម្ព័ន្ធទី១៩
# អាជ្ញាបណ្ណប្រើប្រាស់សំណង់



ឧបសម្ព័ន្ធទី ២ នៃប្រកាសលេខ........ចុះថ្ងៃទី.......ខែ.......ឆ្នាំ២០១៥
ស្តីពីនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចរាល់

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
MINISTRY OF LAND MANAGEMENT, URBAN PLANNING AND CONSTRUCTION
លេខ/N°: ....................................

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

## វិញ្ញាបនបត្រប្រើប្រាស់សំណង់
## CERTIFICATE OF OCCUPANCY

- សំណង់អំពី.................... កម្ពស់.................. ម៉ែត្រ ស្មើនឹង.................. ជាន់ ផ្ទៃក្រឡាកម្រាលសំណង់សរុប.............................. ម²
CONSTRUCTION BUILT OF...........; HEIGHT.................M, ....................STORIES, TOTAL AREA ................................................ M²
- ទីតាំងសំណង់÷ ក្បាលដីលេខ.................. ផ្លូវ............ ភូមិ.................. ឃុំ/សង្កាត់................. ក្រុង/ស្រុក/ខណ្ឌ................. រាជធានី/ខេត្ត.................
LOCATION: LAND TITLE N°:........, ST.:.........VILLAGE:........., COMMUNE/SANGKAT:.............., KRONG/SROK/KHAN:..............., CAPITAL/PROVINCE:..............
- ម្ចាស់សំណង់÷................................................................ -មុខងារប្រើប្រាស់សំណង់ ..............................................................
OWNER: ............................................................................ USE OF THE CONSTRUCTION: ..................................................
- ថ្ងៃចាប់ផ្តើមសាងសង់..................... ថ្ងៃបញ្ចប់ការសាងសង់......................... -សម្រង់ប្លង់តាមការសាងសង់ជាក់ស្តែងលេខ.................. ចុះថ្ងៃទី..... ខែ........ ឆ្នាំ...........
CONSTRUCTION DATE: STARTED:.....................; COMPLETED:.................. AS BUILT DRAWING N°...................DATED:..............................
- របាយការណ៍ត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ចុះថ្ងៃទី............ ខែ................ ឆ្នាំ.......... អនុវត្តដោយ ..............................................
CONSTRUCTION QUALITY AND SAFETY INSPECTION REPORT DATED:............................ DONE BY:..................................................
សម្គាល់÷ នៅពេលមានការផ្លាស់ប្តូរមុខងារប្រើប្រាស់សំណង់ និង/ឬការកែប្រែគ្រឿងផ្គុំសំណង់ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ថ្មី។
REMARK: WHEN THERE IS A CHANGE OF THE USE OF THE CONSTRUCTION AND/OR A CHANGE OF THE CONSTRUCTION STRUCTURE, THE OWNER SHALL SUBMIT REQUEST FOR A NEW CERTIFICATE OF OCCUPANCY.

ថ្ងៃ.............................. ខែ............. ឆ្នាំ................ ព.ស. ..........

រាជធានីភ្នំពេញ ថ្ងៃទី ............ ខែ ............ ឆ្នាំ .............
PHNOM PENH, DATE ...............................................

ជ.រដ្ឋមន្ត្រី
FOR THE MINISTER

# ឧបសម្ព័ន្ធគតិយុត្ត

# ព្រះរាជក្រម

នស/រកម/១១១៩/០១៩

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីសំណង់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៧ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៩ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់
# ស្តីពី
# សំណង់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះមានគោលបំណងធានា៖

- គុណភាព សន្តិសុខ សុវត្ថិភាពសំណង់ ការពារទ្រព្យសម្បត្តិនិងសុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន
- សោភណភាពនិងបរិស្ថានល្អសម្រាប់ការរស់នៅប្រកបដោយចីរភាព សំដៅលើកកម្ពស់សុខុមាលភាពសាធារណៈ
- គណនេយ្យភាពនិងប្រសិទ្ធភាពក្នុងការប្រកបការងារនិងការប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់
- ការបង្កើនការជឿទុកចិត្តរបស់វិនិយោគិននៅក្នុងវិស័យសំណង់ និងជំរុញទីផ្សារអចលនទ្រព្យប្រកបដោយប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចនិងសង្គម។

**មាត្រា២ .-**

ច្បាប់នេះមានគោលដៅកំណត់គោលការណ៍ បទប្បញ្ញត្តិបច្ចេកទេសសំណង់ វិធាន និងនីតិវិធីក្នុងការគ្រប់គ្រងវិស័យសំណង់ក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣ .-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះវិស័យសំណង់នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែប្រភេទសំណង់ដែលកំណត់ក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៤ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះត្រូវបានកំណត់និយមន័យនៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥ .-**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងវិស័យសំណង់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អាចប្រគល់ឬធ្វើប្រតិភូកម្មសមត្ថកិច្ចគ្រប់គ្រងវិស័យសំណង់ដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ជំពូកទី៣
## គោលការណ៍

**មាត្រា៦ .-**

រាល់ការងារសំណង់ត្រូវគោរពគោលការណ៍៖

- ការពារផលប្រយោជន៍សាធារណៈនិងសិទ្ធិបុគ្គល
- ប្រសិទ្ធភាព ចីរភាព និងបរិយាបន្ន
- រៀបចំដែនដីនិងនគរូបនីយកម្ម
- អភិវឌ្ឍបៃតង ការពារធនធានធម្មជាតិ និងបរិស្ថាន
- រក្សានិងលើកកម្ពស់អត្តសញ្ញាណជាតិ។

## ជំពូកទី៤

## បទប្បញ្ញត្តិបច្ចេកទេសសំណង់

**មាត្រា៧ .-**

រាល់ការងារសំណង់ត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។

ការត្រួតពិនិត្យអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវអនុវត្តដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

លក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៨ .-**

រាល់សំណង់ត្រូវមានគ្រឿងផ្គុំដែលអាចទ្ររាល់បន្ទុកបានប្រកបដោយសុវត្ថិភាព ទៅតាមមុខងារប្រើប្រាស់របស់សំណង់ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសសំណង់។

ចំណាត់ថ្នាក់ ប្រភេទ និងទំហំសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់អំពីសុវត្ថិភាពគ្រឿងផ្គុំត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៩ .-**

រាល់សំណង់ត្រូវអនុលោមតាមបទប្បញ្ញត្តិសុវត្ថិភាពអគ្គិភ័យ ដូចមានកំណត់ក្នុងបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការបង្ការនិងការពន្លត់អគ្គិភ័យ។

ចំណាត់ថ្នាក់ ប្រភេទ និងទំហំសំណង់ដែលតម្រូវឱ្យមានការត្រួតពិនិត្យនិងបញ្ជាក់អំពីសុវត្ថិភាពអគ្គិភ័យលើសំណង់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១០ .-**

បទប្បញ្ញត្តិជាតិបច្ចេកទេសសំណង់ត្រូវដាក់ឱ្យប្រើប្រាស់ដោយអនុក្រឹត្យតាមសំណើរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់។

បទប្បញ្ញត្តិបច្ចេកទេសសំណង់ដទៃទៀតក្រៅពីបទប្បញ្ញត្តិជាតិបច្ចេកទេសសំណង់ ត្រូវដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលតម្រូវឱ្យអនុវត្តតាមស្តង់ដារណាមួយជាកំណត់ ត្រូវដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យ

ឧស្សាហកម្ម តាមសំណើរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងតាមការសម្រេចរបស់ក្រុមប្រឹក្សាស្តង់ដាជាតិ។

បទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដទៃទៀតដែលមិនទាន់ត្រូវបានកំណត់ជាស្តង់ដាកម្ពុជា ត្រូវដាក់ឱ្យប្រើប្រាស់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១១.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ ដែលមានរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ជាប្រធាននិងមានតំណាងក្រសួងស្ថាប័ននិងវិស័យឯកជនពាក់ព័ន្ធជាសមាជិក។

ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាជាតិបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៥
## ការគ្រប់គ្រងអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់

**មាត្រា១២.-**

រូបវន្តបុគ្គលដែលអាចបំពេញមុខងារជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ ត្រូវចុះបញ្ជីនៅគណៈវិជ្ជាជីវៈពាក់ព័ន្ធនីមួយៗនៃវិស័យសំណង់។

ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈវិជ្ជាជីវៈនីមួយៗពាក់ព័ន្ធនឹងវិស័យសំណង់ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

**មាត្រា១៣.-**

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។

ក្រមសីលធម៌សម្រាប់អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា១៤.-**

ការគ្រប់គ្រងអ្នកជំនាញក្នុងវិស័យសំណង់ផ្សេងទៀតដែលមិនទាន់បានបង្កើតគណៈវិជ្ជាជីវៈត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៦
## ការគ្រប់គ្រងការប្រកបវិជ្ជាជីវៈនិងការប្រកបអាជីវកម្មក្នុងវិស័យសំណង់

**មាត្រា១៥.-**

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ដែលអាចប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់ដោយឯករាជ្យបាន ត្រូវមានអាជ្ញាប័ណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ដែលបំពេញមុខងារជានាយកបច្ចេកទេសនៃក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ មិនតម្រូវឱ្យមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឡើយ។

នាយកបច្ចេកទេសនៃក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវបំពេញមុខងារដោយឯករាជ្យស្របតាមក្រមសីលធម៌វិជ្ជាជីវៈនិងបទប្បញ្ញត្តិបច្ចេកទេសជាធរមាន។

**មាត្រា១៦.-**

អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ត្រូវបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈ ក្នុងករណីណាមួយដូចខាងក្រោម៖

- លែងបំពេញលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការប្រកបវិជ្ជាជីវៈ
- បានប្រព្រឹត្តកំហុសវិជ្ជាជីវៈដែលនាំទៅដល់ការផ្អាកឬការដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈ
- មានបញ្ហាសុខភាពដែលអាចប៉ះពាល់ដល់ការប្រកបវិជ្ជាជីវៈ ដោយមានបញ្ជាក់ពីគ្រូពេទ្យជំនាញឬបានទទួលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅឬការប្រកាសការចាប់ផ្តើមហិត្តូបត្ថម្ភដោយតុលាការ
- បានទទួលការប្រកាសក្ស័យធនដោយតុលាការ
- ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ។

ការផ្អាកអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់មិនត្រូវលើសពី៦(ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃផ្អាកអាជ្ញាបណ្ណ។

នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់អាចត្រូវបានផ្តល់ឡើងវិញ ក្រោយរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃដកហូតអាជ្ញាបណ្ណ។

ក្នុងករណីបាត់បង់នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈដោយមូលហេតុត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ នីតិសម្បទាក្នុងការប្រកបវិជ្ជាជីវៈនេះ អាចត្រូវបានផ្តល់ឡើងវិញ បន្ទាប់ពីសាមីខ្លួនបានទទួលនីតិសម្បទាឡើងវិញស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា១៧.-**

រាល់ការប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬលិខិតអនុញ្ញាតរបស់រដ្ឋបាលរាជធានី ខេត្តទៅតាមប្រភេទអាជីវកម្ម។

**មាត្រា១៨.-**

ក្រុមហ៊ុនដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវបាត់បង់នីតិសម្បទាក្នុងការប្រកបអាជីវកម្មក្នុងករណីណាមួយដូចខាងក្រោម៖

- លែងបំពេញលក្ខខណ្ឌតម្រូវណាមួយដែលអនុញ្ញាតឱ្យក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណប្រកបអាជីវកម្ម
- ត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម
- ត្រូវបានតុលាការប្រកាសរំលាយឬប្រកាសមោឃភាព
- ត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ
- មានអភិបាលឬនាយកបច្ចេកទេសដែលបានទទួលការប្រកាសការចាប់ផ្ដើមអាណាព្យាបាលទូទៅឬការប្រកាសការចាប់ផ្ដើមហិតូបត្ថម្ភដោយតុលាការ លើកលែងតែអភិបាលឬនាយកបច្ចេកទេសនោះត្រូវបានប្ដូរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសដោយតុលាការ
- មានអភិបាលឬនាយកបច្ចេកទេសដែលត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ លើកលែងតែអភិបាលឬនាយកបច្ចេកទេសនោះត្រូវបានប្ដូរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃប្រកាសដោយតុលាការ
- មានអភិបាលឬនាយកបច្ចេកទេសដែលត្រូវបានផ្ដន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ លើកលែងតែអភិបាលឬនាយកបច្ចេកទេសនោះត្រូវបានប្ដូរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃមានសាលក្រមឬសាលដីកាស្ថាពរ។

ការផ្អាកអាជ្ញាបណ្ណប្រកបអាជីវកម្មក្នុងវិស័យសំណង់មិនត្រូវមានរយៈពេលលើសពី១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃផ្អាកអាជ្ញាបណ្ណ។

នីតិសម្បទាក្នុងការប្រកបអាជីវកម្មក្នុងវិស័យសំណង់អាចត្រូវបានផ្ដល់ឡើងវិញក្រោយរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃដកហូតអាជ្ញាបណ្ណ។

បុគ្គលឬអ្នកវិជ្ជាជីវៈដែលត្រូវបានតុលាការប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ អាចទទួលបាននីតិសម្បទាធ្វើជាអភិបាលឬនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ ក្រោយរយៈពេល៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃប្រកាសក្ស័យធនឬការជម្រះបញ្ជីតាមផ្លូវតុលាការ។

បុគ្គលឬអ្នកវិជ្ជាជីវៈដែលត្រូវបានផ្ដន្ទាទោសពីបទឧក្រិដ្ឋនៅក្នុងព្រះរាជាណាចក្រកម្ពុជាឬក្នុងប្រទេសណាមួយដែលខ្លួនធ្លាប់ស្នាក់នៅ អាចទទួលបាននីតិសម្បទាធ្វើជាអភិបាលឬនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ បន្ទាប់ពីសាមីខ្លួនបានទទួលនីតិសម្បទាឡើងវិញស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**មាត្រា១៩ .-**

បុគ្គលដែលមានអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ត្រូវចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងដែលធ្វើប្រតិបត្តិការនៅព្រះរាជាណាចក្រកម្ពុជានិងមានវិញ្ញាបនបត្រធានារ៉ាប់រង ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មរបស់ខ្លួន។

កម្មវត្ថុនៃកិច្ចសន្យាធានារ៉ាប់រង សំដៅធានាការបំពេញកាតព្វកិច្ចដែលបានចែងក្នុងកិច្ចសន្យារវាងអ្នកប្រកបវិជ្ជាជីវៈឬអ្នកប្រកបអាជីវកម្មនិងអតិថិជនរបស់ខ្លួន។

ចំនួនទឹកប្រាក់អប្បបរមាដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២០ .-**

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតអាជ្ញាបណ្ណប្រកបវិជ្ជាជីវៈនិងអាជ្ញាបណ្ណឬការអនុញ្ញាតផ្សេងទៀតឱ្យប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២១ .-**

ការស្នើសុំអាជ្ញាបណ្ណឬការអនុញ្ញាតផ្សេងទៀតដើម្បីប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវបង់កម្រៃសេវា។

កម្រៃសេវាអាជ្ញាបណ្ណនិងការអនុញ្ញាតផ្សេងទៀតដើម្បីប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

កម្រៃសេវាអាជ្ញាបណ្ណនិងការអនុញ្ញាតផ្សេងទៀតដើម្បីប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវបានជាប្រយោជន៍ដល់ថវិកាជាតិនិងថវិកាថ្នាក់ក្រោមជាតិ។

## ជំពូកទី៧

## ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ និងមន្ទីរពិសោធន៍សំណង់

**មាត្រា២២ .-**

សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលចាំបាច់សម្រាប់ធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ត្រូវមានការបញ្ជាក់ទទួលស្គាល់ឬការបញ្ជាក់អនុលោមភាពដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ឬតាមស្តង់ដាកម្ពុជាដែលអនុម័តដោយក្រុមប្រឹក្សាស្តង់ដាជាតិ ដោយត្រូវមានបិទឬបោះពុម្ពសញ្ញាស្តង់ដាកម្ពុជានិងត្រូវមានអាជ្ញាបណ្ណប្រើសញ្ញាស្តង់ដាកម្ពុជា។

បែបបទនិងនីតិវិធីនៃការបញ្ជាក់ទទួលស្គាល់ឬការបញ្ជាក់អនុលោមភាពនិងប្រភេទនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលចាំបាច់សម្រាប់ធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៣ .-**

ការផលិត ការចែកចាយ ការនាំចូល ការដាក់លក់ ការផ្គត់ផ្គង់ ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ដែលគ្មានបិទសញ្ញាស្តង់ដាកម្ពុជា ឬគ្មានការបញ្ជាក់ទទួលស្គាល់ ឬគ្មានការបញ្ជាក់អនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវហាមឃាត់ក្នុងករណីសម្ភារៈសំណង់ បរិក្ខារសំណង់

ឬផលិតផលសំណង់នោះ តម្រូវឱ្យមានបិទសញ្ញាស្តង់ដាកម្ពុជា ឬការបញ្ជាក់ទទួលស្គាល់ ឬការបញ្ជាក់ពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។

ការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ត្រូវហាមឃាត់។

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យអនុលោមភាពនៃការប្រើសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ស្របតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៤ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវរៀបចំឱ្យមានមន្ទីរពិសោធន៍ជាតិសំណង់។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់មន្ទីរពិសោធន៍ជាតិសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៥ .-**

មន្ទីរពិសោធន៍សំណង់ក្នុងគោលដៅអាជីវកម្មត្រូវមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ការបង្កើតមន្ទីរពិសោធន៍សំណង់ក្នុងគោលដៅសិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាលត្រូវមានលិខិតអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតលិខិតអនុញ្ញាតបង្កើតមន្ទីរពិសោធន៍សំណង់ក្នុងគោលដៅសិក្សា ស្រាវជ្រាវ និងបណ្តុះបណ្តាល ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី៨

## លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ

**មាត្រា២៦ .-**

រាល់ការងារសាងសង់ឬរុះរើត្រូវមានការអនុញ្ញាតជាមុនដោយអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា២៧ .-**

ការងារសាងសង់ឬរុះរើក្នុងស្ថានភាពអាសន្នឬគ្រោះមហន្តរាយដើម្បីជួយសង្គ្រោះឬការពារអាយុជីវិតឬបង្ការ មិនឱ្យមានការប៉ះពាល់ឬខូចខាតធ្ងន់ធ្ងរដល់សុខភាពឬទ្រព្យសម្បត្តិក្នុងភាពអាសន្ន មិនតម្រូវឱ្យមានលិខិតអនុញ្ញាតជាមុនឡើយ។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្នត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលត្រូវបានសាងសង់ក្នុងស្ថានភាពអាសន្នត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់តាមលក្ខខណ្ឌនិងនីតិវិធីជាធរមាន។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្នត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលបានរុះរើក្នុងភាពអាសន្នត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា២៨ .-**

រាល់ការងារសាងសង់ឬរុះរើដែលមិនតម្រូវឱ្យមានការអនុញ្ញាតមានដូចខាងក្រោម៖

- សំណង់ទំហំតូចដែលមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ
- លំនៅឋានធ្វើពីឈើ ផ្ទះថ្មក្រោមឈើលើ ផ្ទះគៀមធ្វើពីឈើឬថ្មនៅទីជនបទឬស្រែចម្ការ ដែលមិនប៉ះពាល់ដល់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌ តំបន់អភិរក្ស ឬតំបន់ការពារ
- សំណង់បម្រើដល់សន្តិសុខជាតិនិងការពារជាតិ។

ប្រភេទនិងទំហំនៃការងារសាងសង់ឬរុះរើដែលមិនតម្រូវឱ្យមានការអនុញ្ញាត ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា២៩ .-**

រាល់ការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់មិនតម្រូវឱ្យមានការអនុញ្ញាតឡើយ ក្នុងករណីដែលការងារនោះមិនប៉ះពាល់ដល់រចនាសម្ព័ន្ធទ្រទម្ងន់ សោភណភាពខាងក្រៅ ឬមុខងារប្រើប្រាស់ទាំងមូល ឬផ្នែកណាមួយនៃសំណង់ និងមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។ ក្នុងករណីនេះ ម្ចាស់សំណង់ត្រូវជូនដំណឹងជាមុនទៅអាជ្ញាធរមានសមត្ថកិច្ច។

ប្រភេទនិងទំហំការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់ដែលមិនតម្រូវឱ្យមានការអនុញ្ញាត ត្រូវកំណត់ដោយអនុក្រឹត្យ។

បែបបទនិងនីតិវិធីនៃការជូនដំណឹងជាមុនអំពីការងារជួសជុល កែប្រែ ឬបំពាក់បរិក្ខារសំណង់ដែលមិនតម្រូវឱ្យមានការអនុញ្ញាត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣០ .-**

លក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣១ .-**

លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើមិននាំឱ្យបុគ្គលដែលទទួលបានលិខិតអនុញ្ញាតនោះរួចផុតពីកាតព្វកិច្ចនិងការទទួលខុសត្រូវ តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀតឡើយ។

ការអនុវត្តការងារសាងសង់ឬរុះរើចំពោះសំណង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតមិននាំឱ្យម្ចាស់សំណង់រួចផុតពីកាតព្វកិច្ចនិងការទទួលខុសត្រូវតាមច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀតឡើយ។

## ជំពូកទី៩
## ការគ្រប់គ្រងគម្រោងប្លង់

**មាត្រា៣២ .-**

រាល់គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើត្រូវចុះហត្ថលេខាទទួលខុសត្រូវដោយអ្នកសិក្សាគម្រោងប្លង់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្ដល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៣ .-**

រាល់គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើត្រូវអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម។

គម្រោងប្លង់ដែលប្រើប្រាស់សម្រាប់ការងារសាងសង់ឬរុះរើសំណង់គ្រប់ប្រភេទ លើកលែងតែសំណង់សម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធ បរិក្ខារ និងសេវាសម្រាប់ជនមានពិការភាព ជាអាទិ៍ ផ្លូវនិងជម្រាលសម្រាប់ផ្លាស់ទី ឧបករណ៍ផ្ទាក់ដៃ ជណ្ដើរយន្ត បន្ទប់អនាម័យ ចំណតយានយន្តពិសេសសម្រាប់ជនពិការ និងផ្លាកសញ្ញានានា។

អនុលោមភាពនៃគម្រោងប្លង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម ត្រូវបញ្ជាក់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្ដល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

គម្រោងប្លង់សាងសង់ឬរុះរើសំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានការបញ្ជាក់ពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្ដល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៤ .-**

ម្ចាស់សំណង់ត្រូវធានាថាការងារសាងសង់ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវបានអនុវត្តត្រឹមត្រូវតាមគម្រោងប្លង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត។

មុនការអនុវត្តការងារសាងសង់ឬរុះរើ អាជ្ញាធរមានសមត្ថកិច្ចអាចអនុញ្ញាតឱ្យកែសម្រួលគម្រោងប្លង់ដែលបានទទួលការយល់ព្រមរួចហើយ។

ការអនុញ្ញាតកែសម្រួលគម្រោងប្លង់ត្រូវធ្វើឡើងតាមរយៈលិខិតអនុញ្ញាតកែសម្រួលគម្រោងប្លង់។

លក្ខខណ្ឌនិងនីតិវិធីនៃការអនុញ្ញាតកែសម្រួលគម្រោងប្លង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៣៥ .-**

រាល់ស្នាដៃរបស់អ្នកសិក្សាគម្រោងប្លង់ដែលមានលក្ខណៈដើមទាំងមូលឬដោយផ្នែកដែលបានទទួលការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាតសាងសង់ ត្រូវបានការពារពីការលួចចម្លងស្របតាមបទប្បញ្ញត្តិជាធរមាន។

គម្រោងប្លង់មួយមិនអាចយកទៅអនុវត្តនៅទីតាំងផ្សេងទៀតដោយគ្មានការអនុញ្ញាតពីអ្នកសិក្សាដែលបានចុះហត្ថលេខាលើគម្រោងប្លង់នោះនិងម្ចាស់សំណង់បានឡើយ។

រាល់ការអនុវត្តគម្រោងប្លង់ដែលមានតម្លៃពិសេសផ្នែកស្ថាបត្យកម្មនៅទីតាំងផ្សេងទៀតត្រូវបានហាមឃាត់។ គម្រោងប្លង់ដែលមានតម្លៃពិសេសផ្នែកស្ថាបត្យកម្មត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី១០

## ការគ្រប់គ្រងការងារសាងសង់ឬរះវើ

### មាត្រា៣៦ .-

រាល់ការងារសាងសង់ឬរះរើត្រូវអនុវត្តដោយអ្នកសាងសង់ដែលមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋបាលរាជធានី ខេត្ត។

អ្នកសាងសង់មិនតម្រូវឱ្យមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋបាលរាជធានី ខេត្ត លុះត្រាតែអ្នកសាងសង់នោះបានបំពេញគ្រប់លក្ខខណ្ឌដូចខាងក្រោម៖

- ជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់
- សាងសង់ឬរះរើសំណង់ដែលជាលំនៅឋានផ្ទាល់ខ្លួន និង
- សាងសង់ឬរះរើសំណង់តាមជំនាញវិជ្ជាជីវៈរបស់ខ្លួន។

### មាត្រា៣៧ .-

រាល់ការងារសាងសង់ឬរះរើត្រូវអនុវត្តស្របតាម៖

- គម្រោងប្លង់
- បទប្បញ្ញត្តិបច្ចេកទេសសំណង់
- បទប្បញ្ញត្តិជាធរមានដទៃទៀត។

រាល់ការងារសាងសង់ឬរះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាត ត្រូវអនុវត្តតាមគម្រោងប្លង់ដែលទទួលបានការយល់ព្រមពីអាជ្ញាធរមានសមត្ថកិច្ចតាមរយៈលិខិតអនុញ្ញាត។

### មាត្រា៣៨ .-

រាល់ការងារសាងសង់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ជាមុន។

លក្ខខណ្ឌនិងនីតិវិធីនៃការចេញលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

### មាត្រា៣៩ .-

អ្នកសាងសង់ត្រូវធានាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថាននៅការដ្ឋានសំណង់របស់ខ្លួន។

**មាត្រា៤០ ._**

ម្ចាស់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារសាងសង់ឬរុះរើជូនអាជ្ញាធរមានសមត្ថកិច្ច។

របាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារសាងសង់ឬរុះរើត្រូវរៀបចំដោយអ្នកសាងសង់និងមានការឯកភាពពីម្ចាស់សំណង់។

បែបបទនិងនីតិវិធីនៃការផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពនៃការងារសាងសង់ឬរុះរើ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៤១ ._**

នៅពេលដំណើរការការដ្ឋាន រាល់ការងារសាងសង់ឬរុះរើដែលតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវមានការត្រួតពិនិត្យដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អ្នកត្រួតពិនិត្យនិងបញ្ជាក់ការងារសាងសង់ឬរុះរើត្រូវធ្វើរបាយការណ៍និងចេញលិខិតបញ្ជាក់ពីអនុលោមភាពនៃការងារតាមគម្រោងប្លង់ដែលបានយល់ព្រមដោយអាជ្ញាធរមានសមត្ថកិច្ចនិងតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់។

**មាត្រា៤២ ._**

ក្នុងករណីចាំបាច់ដើម្បីធានាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ អាជ្ញាធរមានសមត្ថកិច្ចអាចចាត់តាំងមន្ត្រីត្រួតពិនិត្យសំណង់ដើម្បីត្រួតពិនិត្យការងារសាងសង់ឬរុះរើ។

ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ បុគ្គលដែលពាក់ព័ន្ធការងារសាងសង់ រាប់បញ្ចូលទាំងអ្នកអភិវឌ្ឍអចលនវត្ថុ អ្នកសាងសង់ និងអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ត្រូវផ្តល់កិច្ចសហការដល់មន្ត្រីត្រួតពិនិត្យសំណង់។

អាជ្ញាធរមានសមត្ថកិច្ចអាចសម្រេចផ្អាក កែតម្រូវ បញ្ឈប់ តម្រូវឱ្យរុះរើ ឬចាត់វិធានការចាំបាច់ផ្សេងទៀត ក្នុងករណី រកឃើញថាការងារសាងសង់ឬរុះរើមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមាន ដទៃទៀត។

**មាត្រា៤៣ ._**

លក្ខខណ្ឌនិងនីតិវិធីនៃការគ្រប់គ្រងនិងត្រួតពិនិត្យការងារសាងសង់ឬរុះរើត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី១១

## ការប្រើប្រាស់សំណង់

**មាត្រា៤៤ ._**

ការប្រើប្រាស់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ត្រូវអនុញ្ញាតដោយអាជ្ញាធរមានសមត្ថកិច្ចតាមរយៈវិញ្ញាបនបត្រប្រើប្រាស់សំណង់។

ម្ចាស់សំណង់ត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់ មុននឹងប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់សំណង់នោះ។

រាល់សំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ត្រូវមានការត្រួតពិនិត្យនិងបញ្ជាក់អនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលមានអាជ្ញាបណ្ណឬការអនុញ្ញាតផ្ដល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មុននឹងអាជ្ញាធរមានសមត្ថកិច្ចអនុញ្ញាតឱ្យចូលប្រើប្រាស់សំណង់។

**មាត្រា៤៥ ._**

អាជ្ញាធរមានសមត្ថកិច្ចអាចអនុញ្ញាតឱ្យចូលប្រើប្រាស់សំណង់ក្នុងរយៈពេលណាមួយជាបណ្ដោះអាសន្នបាន ចំពោះសំណង់ទាំងមូលឬផ្នែកណាមួយនៃគម្រោងសាងសង់ ក្នុងករណីដែលសំណង់ទាំងមូលឬផ្នែកណាមួយនៃគម្រោងសាងសង់នោះអាចប្រើប្រាស់បានដោយសុវត្ថិភាព។

**មាត្រា៤៦ ._**

លក្ខខណ្ឌនិងនីតិវិធីនៃការផ្ដល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៤៧ ._**

សំណង់ដែលប្រើប្រាស់ក្នុងគោលដៅក្រៅពីលំនៅឋានតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពក្នុងរយៈពេលយ៉ាងយូរ៥(ប្រាំ)ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពនេះត្រូវបន្តអនុវត្តជាទៀងទាត់រៀងរាល់៥(ប្រាំ)ឆ្នាំម្ដងយ៉ាងយូរ។

សំណង់ដែលប្រើប្រាស់ក្នុងគោលដៅលំនៅឋានតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពក្នុងរយៈពេលយ៉ាងយូរ១០(ដប់)ឆ្នាំ គិតចាប់ពីថ្ងៃចេញវិញ្ញាបនបត្រប្រើប្រាស់សំណង់។ ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពនេះត្រូវបន្តអនុវត្តជាទៀងទាត់ក្នុងរយៈពេលរៀងរាល់១០(ដប់)ឆ្នាំម្ដងយ៉ាងយូរ។

ការត្រួតពិនិត្យនិងការចេញសេចក្ដីបញ្ជាក់អំពីគុណភាព ប្រសិទ្ធភាពនៃប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យនៃសំណង់ត្រូវធ្វើឡើងសម្រាប់រយៈពេល២(ពីរ)ឆ្នាំម្ដង។

បរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់តម្រូវឱ្យមានការត្រួតពិនិត្យរៀងរាល់១(មួយ)ឆ្នាំម្ដង។ ប្រភេទបរិក្ខារសំណង់ដែលងាយបង្កគ្រោះថ្នាក់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ម្ចាស់សំណង់ឬអ្នកគ្រប់គ្រងសំណង់មានកាតព្វកិច្ចប្រគល់លទ្ធផលនៃការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ជូនអាជ្ញាធរមានសមត្ថកិច្ចក្នុងរយៈពេល១(មួយ)ខែក្រោយថ្ងៃផុតកំណត់រយៈពេលដែលតម្រូវឱ្យអនុវត្តការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៤៨ .-**

អាជ្ញាធរមានសមត្ថកិច្ចអាចតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ក្នុងករណីមានហានិភ័យចំពោះជីវិតមនុស្ស ទ្រព្យសម្បត្តិ ឬការប៉ះពាល់ដល់សន្តិសុខឬសណ្តាប់ធ្នាប់សាធារណៈ។

**មាត្រា៤៩ .-**

ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវអនុវត្តដោយមន្ត្រីត្រួតពិនិត្យសំណង់ ឬដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដែលមានអាជ្ញាបណ្ណផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រាល់ចំណាយសម្រាប់ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ជាបន្ទុករបស់ម្ចាស់សំណង់។

ចំពោះអគារសហកម្មសិទ្ធិ ម្ចាស់នៃចំណែកឯកជនទាំងអស់ត្រូវទទួលបន្ទុករួមគ្នាលើរាល់ចំណាយសម្រាប់ការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ស្របតាមសមាមាត្រទៅនឹងទំហំនៃចំណែកឯកជន។

**មាត្រា៥០ .-**

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី១២

## សំណង់ដែលមានសភាពគ្រោះថ្នាក់

**មាត្រា៥១ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានភារកិច្ចត្រួតពិនិត្យ តាមដានរាល់សំណង់ ទាំងឡាយណាដែលមានសភាពគ្រោះថ្នាក់ដើម្បីចាត់វិធានការចាំបាច់នានាក្នុងការធានាសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។

**មាត្រា៥២ .-**

ចំពោះសំណង់ដែលមានសភាពគ្រោះថ្នាក់ ម្ចាស់សំណង់និងអ្នកគ្រប់គ្រងសំណង់មានកាតព្វកិច្ចរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចនិងអនុវត្តតាមវិធានការបញ្ចៀសគ្រោះថ្នាក់ទាំងឡាយដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។

ក្នុងករណីចាំបាច់ដើម្បីបញ្ចៀសគ្រោះថ្នាក់ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបន្ទាន់ជាអាទិ៍ ហ៊ុំព័ទ្ធ ហាមចូល ហាមប្រើប្រាស់ និងតម្រូវឱ្យរុះរើសំណង់។

រាល់ការចំណាយក្នុងការបញ្ចៀសគ្រោះថ្នាក់ជាបន្ទុករបស់ម្ចាស់សំណង់។

**មាត្រា៥៣ .-**

កម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី១៣
## សំណង់ដែលសាងសង់ឬរុះរើដោយគ្មានឬខុសពីលិខិតអនុញ្ញាត

**មាត្រា៥៤ .-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការបញ្ឈប់ការងារសាងសង់ឬរុះរើដែលគ្មានលិខិតអនុញ្ញាត ក្នុងករណីការសាងសង់ឬរុះរើនោះតម្រូវឱ្យមានលិខិតអនុញ្ញាត។

**មាត្រា៥៥ .-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការផ្អាកការងារសាងសង់ឬរុះរើដែលបានធ្វើឡើងខុសពីលិខិតអនុញ្ញាត និងតម្រូវឱ្យម្ចាស់សំណង់កែតម្រូវឱ្យស្របតាមលិខិតអនុញ្ញាត។

**មាត្រា៥៦ .-**

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការកែសម្រួលឬរុះរើរាល់សំណង់ដែលសាងសង់ដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាត ក្នុងករណីការសាងសង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាត។

អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់វិធានការហាមឃាត់រាល់ការប្រើប្រាស់ ការប្រកបអាជីវកម្ម ការចាត់ចែង និងការធ្វើចរន្តការទាទាញពាក់ព័ន្ធនឹងសំណង់គ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាត ក្នុងករណីការសាងសង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាត។

## ជំពូកទី១៤
## អធិការកិច្ចសំណង់

**មាត្រា៥៧ .-**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់តែងតាំងមន្ត្រីអធិការកិច្ចសំណង់ ដើម្បីចុះតាមដាន អង្កេត ស្រាវជ្រាវ ត្រួតពិនិត្យ ប្រមូលភស្តុតាង និងជំរុញការអនុវត្តច្បាប់នេះ។

មន្ត្រីអធិការកិច្ចសំណង់ទទួលនីតិសម្បទាជានគរបាលយុត្តិធម៌ឱ្យពិនិត្យបទល្មើសដូចមានចែងក្នុងច្បាប់នេះស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ។

បែបបទនិងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៥៨ .-**

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចសំណង់ត្រូវស្លៀកពាក់ឯកសណ្ឋាន មានសញ្ញាសម្គាល់ និងលិខិតបញ្ជាបេសកកម្ម។

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីអធិការកិច្ចសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

**មាត្រា៥៩ .-**

មន្ត្រីអធិការកិច្ចសំណង់មានភារកិច្ចនិងសិទ្ធិដូចខាងក្រោម៖

- ត្រួតពិនិត្យ បញ្ឈប់ ចាត់វិធានការបណ្តោះអាសន្ន និងពិន័យអន្តរការណ៍ចំពោះបទល្មើសសំណង់ដែលមានចែងក្នុងច្បាប់នេះ
- ដកហូតជាបណ្តោះអាសន្ននូវលិខិតអនុញ្ញាតឬអាជ្ញាបណ្ណពាក់ព័ន្ធក្នុងករណីដែលអ្នកកាន់កាប់លិខិតអនុញ្ញាតឬអាជ្ញាបណ្ណនោះប្រព្រឹត្តល្មើសនឹងច្បាប់នេះ
- ចាប់យកវត្ថុតាងនិងកសាងសំណុំរឿងនៃបទល្មើសសំណង់
- ចាត់វិធានការផ្សេងទៀតនៅក្នុងក្របខណ្ឌនៃការអនុវត្តច្បាប់នេះ។

បែបបទនិងនីតិវិធីនៃការធ្វើអធិការកិច្ចសំណង់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៦០ .-**

មន្ត្រីអធិការកិច្ចសំណង់អាចចូលទៅក្នុងការដ្ឋានសំណង់គ្រប់ពេលវេលាក្នុងពេលការដ្ឋានកំពុងដំណើរការ ឬក្នុងអគារនៅក្នុងម៉ោងធ្វើការដើម្បីបំពេញភារកិច្ចរបស់ខ្លួន។

**មាត្រា៦១ .-**

រាល់ប្រតិបត្តិការអធិការកិច្ចសំណង់ក្នុងការពិនិត្យបទល្មើសត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

មន្ត្រីអធិការកិច្ចសំណង់អាចស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដូចមានចែងក្នុងច្បាប់នេះ។

ក្នុងករណីបទល្មើសជាក់ស្តែងឬមិនមានលិខិតអនុញ្ញាតសាងសង់ឬរុះរើ អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធត្រូវផ្តល់ព័ត៌មានជាបន្ទាន់ដល់មន្ត្រីអធិការកិច្ចសំណង់មានសមត្ថកិច្ចដែលនៅជិតបំផុត ដើម្បីចាត់ការតាមនីតិវិធី។

## ជំពូកទី១៥
## វិសមិតភាព

**មាត្រា៦២ .-**

មន្ត្រីរាជការដែលមានសមត្ថកិច្ចត្រួតពិនិត្យនិង/ឬសម្រេចលើគម្រោងប្លង់មិនអាចជាអ្នកសិក្សាគម្រោងប្លង់ឬអ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់ដែលខ្លួនបានសិក្សាឬត្រួតពិនិត្យនិងបញ្ជាក់បានឡើយ។

**មាត្រា៦៣ .-**

មន្ត្រីអធិការកិច្ចសំណង់ មន្ត្រីត្រួតពិនិត្យសំណង់ និងអ្នកត្រួតពិនិត្យនិងបញ្ជាក់ មិនអាចជាម្ចាស់សំណង់ ឬជាសហព័ទ្ធ ឬជាញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង៣(បី)ថ្នាក់ ឬញាតិពន្ធក្នុង៣(បី)ថ្នាក់របស់ម្ចាស់សំណង់ ឬជាអ្នកដែលមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធនឹងគម្រោងសាងសង់បានឡើយ។

**មាត្រា៦៤ .-**

ការបំពេញមុខងារជាអ្នកសិក្សាគម្រោងប្លង់មានវិសមិតភាពជាមួយនឹងការបំពេញមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់របស់ខ្លួន។

**មាត្រា៦៥ .-**

ការបំពេញមុខងារជាអ្នកសាងសង់មានវិសមិតភាពជាមួយនឹងការបំពេញមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់លើការងារសាងសង់របស់ខ្លួន។

**មាត្រា៦៦ .-**

អ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់ឬការងារសាងសង់មិនអាចជាសហព័ទ្ធ ឬញាតិលោហិតផ្ទាល់ ឬសាខាញាតិលោហិតក្នុង៣ (បី) ថ្នាក់របស់ម្ចាស់សំណង់បានឡើយ។

សមាជិកភាគហ៊ុននៃក្រុមហ៊ុនដែលជាម្ចាស់សំណង់ បុគ្គលិកក្រុមហ៊ុនដែលជាម្ចាស់សំណង់ ឬអ្នកដែលមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុពាក់ព័ន្ធនឹងគម្រោងសាងសង់ មិនអាចបំពេញមុខងារជាអ្នកត្រួតពិនិត្យនិងបញ្ជាក់លើគម្រោងប្លង់ឬការងារសាងសង់សំណង់នោះបានឡើយ។

## ជំពូកទី១៦
## កិច្ចសន្យាម៉ៅការសាងសង់ឬរុះរើ

**មាត្រា៦៧ .-**

កិច្ចសន្យាម៉ៅការសាងសង់ឬរុះរើត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងត្រូវមានចែងខអប្បបរមាដូចខាងក្រោម៖

- អត្តសញ្ញាណរបស់ភាគីនៃកិច្ចសន្យា
- ទីតាំង ទំហំ និងប្រភេទការងារ
- តម្លៃនៃកិច្ចសន្យានិងកាលបរិច្ឆេទនិងរបៀបនៃការទូទាត់
- ការធានារបស់ភាគីនៃកិច្ចសន្យាចំពោះការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា
- លក្ខខណ្ឌបច្ចេកទេសនិងលក្ខខណ្ឌសុវត្ថិភាពនៃការងារ
- លក្ខខណ្ឌពាក់ព័ន្ធនឹងការផ្គត់ផ្គង់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬឧបករណ៍និងគ្រឿងចក្រសម្រាប់បម្រើឱ្យការងារសាងសង់ឬរុះរើនិងសម្រាប់បំពាក់លើសំណង់
- លក្ខខណ្ឌនៃការកែប្រែនិងរំលាយកិច្ចសន្យា
- ការធានារ៉ាប់រងឬបញ្ញត្តិផ្សេងទៀតពាក់ព័ន្ធនឹងការទទួលខុសត្រូវចំពោះការខូចខាតដែលបង្កឡើងដោយការងារ
- ការអះអាងអំពីអនុលោមភាពនៃគម្រោងប្លង់ដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើតាមបទប្បញ្ញត្តិជាធរមាន
- កាលបរិច្ឆេទចាប់ផ្តើមនិងបញ្ចប់ការងារនិងកាលបរិច្ឆេទប្រគល់ទទួល

- លក្ខខណ្ឌពាក់ព័ន្ធនឹងករណីប្រធានសក្តិ
- ការដោះស្រាយវិវាទពាក់ព័ន្ធនឹងកិច្ចសន្យា។

**មាត្រា៦៨ .-**

ចំពោះកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើសំណង់លំនៅឋានឯកជន ខដែលរំលោភបំពានត្រូវទុកជាមោឃៈ។

ខដែលរំលោភបំពាននៅក្នុងកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើសំណង់លំនៅឋានឯកជន មានដូចខាងក្រោម៖

១- ខដែលតម្រូវឱ្យម្ចាស់សំណង់ផ្តល់អាណត្តិឱ្យអ្នកម៉ៅការស្វែងរកកម្ចីចាំបាច់សម្រាប់ផ្តល់ហិរញ្ញប្បទានដល់ការសាងសង់។

២- ខដែលតម្រូវឱ្យម្ចាស់សំណង់ធ្វើការទូទាត់តម្លៃនៃកិច្ចសន្យាទាំងស្រុងជាមុនដើម្បីឱ្យអ្នកម៉ៅការប្រគល់សំណង់មកម្ចាស់សំណង់។

៣- ខដែលហាមឃាត់ម្ចាស់សំណង់ឬតំណាងមិនឱ្យចូលពិនិត្យក្នុងការដ្ឋាន មុនការទូទាត់តម្លៃនៃកិច្ចសន្យាក្នុងដំណាក់កាលនីមួយៗនិងមុនការប្រគល់ទទួល។

៤- ខដែលតម្រូវឱ្យអ្នកម៉ៅការអនុវត្តការងារសាងសង់ឬរុះរើ តាមលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ ដែលលក្ខខណ្ឌបច្ចេកទេសមានការប្រែប្រួលធ្ងន់ធ្ងរខុសពីលក្ខខណ្ឌបច្ចេកទេសនៃគម្រោងសាងសង់ ជួសជុល ឬរុះរើដែលជាកម្មវត្ថុនៃកិច្ចសន្យា។

៥- ខដែលដោះបន្ទុកអ្នកម៉ៅការពីកាតព្វកិច្ចអនុវត្តការងារពេញលេញតាមពេលកំណត់ក្នុងកិច្ចសន្យាដោយទទួលស្គាល់មូលហេតុនៃការយឺតយ៉ាវផ្សេងៗ លើកលែងតែមូលហេតុប្រធានសក្តិនិងមូលហេតុដែលបង្កដោយម្ចាស់សំណង់ផ្ទាល់។

**មាត្រា៦៩ .-**

ភាគីនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើអាចដាក់លក្ខខណ្ឌបង្អង់លើកាតព្វកិច្ចឬសិទ្ធិដែលកើតឡើងដោយកិច្ចសន្យា ដូចខាងក្រោម៖

១- លទ្ធកម្មដីឬសិទ្ធិប្រត្យក្សដែលអនុញ្ញាតឱ្យសាងសង់ ក្នុងករណីដែលម្ចាស់សំណង់ទទួលបានការសន្យាលក់។

២- ការទទួលបានលិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ ឬការអនុញ្ញាតផ្សេងទៀតរបស់អាជ្ញាធរមានសមត្ថកិច្ច។ ក្នុងករណីនេះ ម្ចាស់សំណង់ត្រូវបញ្ជាក់កាលបរិច្ឆេទដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតឱ្យបានច្បាស់លាស់។

៣- ការទទួលបានកម្ចីដើម្បីធ្វើហិរញ្ញប្បទានដល់ការងារសាងសង់ឬរុះរើ។

៤- ការទទួលបាននូវការធានារ៉ាប់រងចំពោះការខូចខាតបង្កដោយការងារសាងសង់ឬរុះរើ។

៥- ការទទួលបាននូវការធានាការផ្គត់ផ្គង់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់សម្រាប់ការដ្ឋានសំណង់។

**មាត្រា៧០.-**

ករណីយកិច្ចសម្រេចការងារដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើដោយគ្មានវិការៈមានដូចខាងក្រោម៖

១- ការងារសាងសង់ត្រូវបានអនុវត្តស្របតាមលិខិតអនុញ្ញាត បទប្បញ្ញត្តិបច្ចេកទេសសំណង់ បទប្បញ្ញត្តិ និងសេចក្តីណែនាំជាធរមានដទៃទៀត។

២- ការងារសាងសង់ត្រូវបានអនុវត្តដោយប្រើវិធីសាស្ត្រសមស្របនិងប្រកបដោយសមត្ថភាពជំនាញ។

៣- សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់សម្រាប់ផ្គត់ផ្គង់ដល់ការងារត្រូវសមស្របតាមមុខងារប្រើប្រាស់អនុលោមតាមគម្រោងប្លង់និងមានគុណភាពត្រឹមត្រូវតាមបទប្បញ្ញត្តិបច្ចេកទេស។

៤- សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់សម្រាប់ផ្គត់ផ្គង់ដល់ការងារត្រូវតែជាសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ថ្មី លើកលែងតែមានការកំណត់ផ្សេងនៅក្នុងកិច្ចសន្យា។

**មាត្រា៧១.-**

រយៈពេលនៃការធានាចំពោះវិការៈនៃការងារដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ គិតចាប់ពីថ្ងៃប្រគល់ទទួលសំណង់ ត្រូវបានកំណត់ដូចខាងក្រោម៖

ក- ១០(ដប់)ឆ្នាំយ៉ាងតិច ចំពោះគ្រឿងផ្គុំសំណង់ធ្វើពីបេតុងសរសៃដែក បេតុងដែក ឬដែក។

ខ- ៥(ប្រាំ)ឆ្នាំយ៉ាងតិច ចំពោះជញ្ជាំងខាងក្រៅ បង្អួច ទ្វារ និងដំបូលអគារ។

គ- ២(ពីរ)ឆ្នាំយ៉ាងតិច ចំពោះការងារផ្នែកអគ្គិសនី ទឹក មេកានិក និងការងារពាក់ព័ន្ធផ្សេងទៀត។

គូភាគីនៃកិច្ចសន្យាម៉ៅការសាងសង់អាចព្រមព្រៀងគ្នាកំណត់រយៈពេលនៃការធានាចំពោះវិការៈនៃការងារវែងជាងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ។

ការកំណត់រយៈពេលនៃការធានាចំពោះវិការៈនៃការងារខ្លីជាងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ត្រូវចាត់ទុកជាមោឃៈ។

## ជំពូកទី១៧

## ការធានារ៉ាប់រង

**មាត្រា៧២.-**

អ្នកម៉ៅការសាងសង់ឬរុះរើត្រូវមានការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានចំពោះការងារសាងសង់ឬរុះរើដែលជាកម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើ ដើម្បីផ្តល់សំណងដល់ការខូចខាត ការបាត់បង់ទ្រព្យសម្បត្តិ ការមានរបួស ការមានពិការភាព ឬការបាត់បង់ជីវិត ដែលបង្កឡើងដោយការងារនោះដល់អ្នកដែលប្រតិបត្តិការងារនិងតតិយជន។

អាជ្ញាធរមានសមត្ថកិច្ចត្រូវធានាថាអ្នកម៉ៅការសាងសង់បានចុះកិច្ចសន្យាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រងណាមួយរួចហើយ មុននឹងអនុញ្ញាតឱ្យបើកការដ្ឋាន។

**មាត្រា៧៣ ._**

ក្នុងករណីអ្នកម៉ៅការសាងសង់ចុះកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើបន្ត កាតព្វកិច្ចចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានគឺជាបន្ទុករបស់អ្នកម៉ៅការសាងសង់ឬរុះរើនោះ។ ការធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានត្រូវគ្របដណ្តប់លើប្រតិបត្តិការការងាររបស់អ្នកម៉ៅការសាងសង់ឬរុះរើបន្តទាំងអស់។

ក្នុងករណីម្ចាស់សំណង់ចុះកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើជាមួយអ្នកម៉ៅការសាងសង់ឬរុះរើច្រើនសម្រាប់ប្រតិបត្តិការការងារសាងសង់ឬរុះរើសំណង់តែមួយ អ្នកម៉ៅការសាងសង់ឬរុះរើទាំងអស់ត្រូវចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានរៀងៗខ្លួន។

**មាត្រា៧៤ ._**

ក្នុងករណីប្រតិបត្តិការការងារសាងសង់ឬរុះរើរបស់គម្រោងអភិវឌ្ឍអចលនវត្ថុ អ្នកអភិវឌ្ឍអចលនវត្ថុត្រូវចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋានជាមួយក្រុមហ៊ុនធានារ៉ាប់រងដោយផ្ទាល់។

**មាត្រា៧៥ ._**

ប្រភេទនិងទំហំសំណង់ដែលតម្រូវឱ្យមានការធានារ៉ាប់រងចំពោះការងារសាងសង់ឬរុះរើ ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី១៨

## ការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធនឹងសំណង់

**មាត្រា៧៦ ._**

អ្នកសិក្សាគម្រោងប្លង់ត្រូវទទួលខុសត្រូវក្នុងការសងនូវការខូចខាតដែលកើតមានឡើងដល់អ្នកដទៃប្រសិនបើគម្រោងប្លង់នៃសំណង់នោះមានវិការៈ លើកលែងតែករណីដែលអ្នកសិក្សាគម្រោងប្លង់អាចបង្ហាញភស្តុតាងថាគម្រោងប្លង់របស់ខ្លួនបានអនុលោមតាមបទប្បញ្ញត្តិតម្រូវជាធរមាន។

**មាត្រា៧៧ ._**

នៅក្នុងពេលអនុវត្តការងារសាងសង់ឬរុះរើ ម្ចាស់សំណង់និងអ្នកសាងសង់ឬរុះរើត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ក្នុងករណីដែលការងារសាងសង់ឬរុះរើ ឬការងារគ្រប់គ្រងការដ្ឋានសំណង់នោះមានវិការៈ។

**មាត្រា៧៨ ._**

អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ដោយសារវិការៈនៃការងារត្រួតពិនិត្យនិងបញ្ជាក់របស់ខ្លួន។

**មាត្រា៧៩ ._**

ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និងអ្នកជួលសំណង់ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពក្នុងការសងការខូចខាតដែលកើតមានឡើងដល់អ្នកដទៃ ក្នុងករណីដែលការប្រើប្រាស់ឬការគ្រប់គ្រងសំណង់នោះមានវិការៈ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា៨០ ._**

សិទ្ធិទាមទារសំណងនៃការខូចខាតបង្កឡើងដោយវិការៈនៃការសិក្សាគម្រោងប្លង់ ការសាងសង់ឬរុះរើ ឬការគ្រប់គ្រងការដ្ឋានសំណង់ ការត្រួតពិនិត្យនិងបញ្ជាក់សំណង់ ការប្រើប្រាស់សំណង់ និងការគ្រប់គ្រងសំណង់ ត្រូវរលត់ដោយអាជ្ញាយុកាល ប្រសិនបើ៖

- រយៈពេល៣(បី)ឆ្នាំបានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះឬអ្នកតំណាងដែលច្បាប់បានកំណត់របស់ជនរងគ្រោះនោះបានដឹងថាអាចទាមទារសំណងការខូចខាត ឬ
- រយៈពេល១០(ដប់)ឆ្នាំបានកន្លងហួស បន្ទាប់ពីការខូចខាតបានកើតឡើង។

**មាត្រា៨១ ._**

ផលិតករនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវទទួលខុសត្រូវក្នុងការសងការខូចខាតដល់អ្នកដទៃដែលបង្កឡើងដោយវិការៈនៃផលិតផលរបស់ខ្លួន លើកលែងតែផលិតករនោះអាចបង្ហាញភស្តុតាងណាមួយដូចខាងក្រោម៖

១. នៅខណៈដែលសម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ត្រូវបានដាក់លក់ឬចែកចាយ ចំណេះដឹងផ្នែកវិទ្យាសាស្ត្រនិងបច្ចេកទេសពុំអាចរកឃើញវិការៈដែលបង្កឱ្យមានការខូចខាត។
២. សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ត្រូវបានផលិតឡើងដោយអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសតម្រូវ។

**មាត្រា៨២ ._**

សិទ្ធិទាមទារសំណងនៃការខូចខាតបង្កឡើងដោយវិការៈនៃសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវរលត់ដោយអាជ្ញាយុកាល ប្រសិនបើ៖

១. រយៈពេល៣(បី)ឆ្នាំបានកន្លងហួស បន្ទាប់ពីពេលដែលជនរងគ្រោះឬអ្នកតំណាងស្របច្បាប់បានដឹងថាអាចទាមទារសំណងការខូចខាត ឬ
២. រយៈពេល១០(ដប់)ឆ្នាំបានកន្លងហួស បន្ទាប់ពីសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ត្រូវបានប្រគល់លើកដំបូងដោយផលិតករ។ ក្នុងករណីសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់មានសារធាតុបង្កឱ្យមានការប៉ះពាល់ដល់សុខភាពមនុស្ស រយៈពេលនេះត្រូវបន្ថែម២០(ម្ភៃ)ឆ្នាំទៀត។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ជំពូកទី១៩
## ការដោះស្រាយវិវាទក្នុងវិស័យសំណង់
### ផ្នែកទី១
### ការប្តឹងតវ៉ាក្នុងវិស័យសំណង់

**មាត្រា៨៣ .-**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ មានសិទ្ធិតវ៉ាជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ ទៅអាជ្ញាធរមានសមត្ថកិច្ចដែលបានចេញសេចក្តីសម្រេចនោះ ឬទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

អាជ្ញាធរមានសមត្ថកិច្ចដែលទទួលបណ្តឹងត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរលើបណ្តឹងតវ៉ាដោយបញ្ជាក់អំពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង។

ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចទទួលបណ្តឹង មិនសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងរយៈពេល៦០ (ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង។

បុគ្គលដែលមិនសុខចិត្តចំពោះសេចក្តីសម្រេចលើបណ្តឹងតវ៉ាមានសិទ្ធិប្តឹងទៅតុលាការក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅតុលាការក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃគិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

**មាត្រា៨៤ .-**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងវិស័យសំណង់ ត្រូវប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ ទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាមុន មុននឹងប្តឹងទៅតុលាការ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង។

ក្នុងករណីបុគ្គលណាមួយមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បុគ្គលនោះមានសិទ្ធិប្តឹងតវ៉ាទៅតុលាការតាមនីតិវិធីក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ។

**មាត្រា៨៥ .-**

បុគ្គលដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចសំណង់អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីវិធានការនោះ ឬអាចប្តឹងទៅតុលាការតាមនីតិវិធីជាធរមានក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីវិធានការនោះ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវចេញសេចក្តីសម្រេចលើបណ្តឹងតវ៉ាដោយបញ្ជាក់អំពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលបានបណ្តឹងតវ៉ា។

ក្នុងករណីបុគ្គលណាមួយមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បុគ្គលនោះមានសិទ្ធិប្តឹងតវ៉ាទៅតុលាការតាមនីតិវិធីក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរគិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងអំពីសេចក្តីសម្រេចនោះ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់មិនសម្រេចលើបណ្តឹងតវ៉ាក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់បណ្តឹងអាចប្តឹងទៅតុលាការក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

## ផ្នែកទី២

## ការដោះស្រាយវិវាទពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិបុគ្គលក្នុងវិស័យសំណង់ និងកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើ

**មាត្រា៨៦ .-**

បុគ្គលដែលរងការខូចខាតឬមានការបារម្ភជាក់ស្តែងថានឹងរងការខូចខាតដោយសារការអនុវត្តសិទ្ធិឬកាតព្វកិច្ចរបស់បុគ្គលណាម្នាក់ក្នុងវិស័យសំណង់ អាចធ្វើសំណើទៅគណៈកម្មការដោះស្រាយវិវាទសំណង់ដើម្បីធ្វើការសម្រុះសម្រួល មុននឹងប្តឹងទៅតុលាការ។

សំណើសុំសម្រុះសម្រួលត្រូវធ្វើជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃគិតចាប់ពីថ្ងៃទទួលរងផលប៉ះពាល់។

គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវធ្វើការសម្រុះសម្រួលជាមួយភាគីនៃវិវាទក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។

ក្នុងករណីគណៈកម្មការដោះស្រាយវិវាទសំណង់សម្រេចបដិសេធសំណើសុំសម្រុះសម្រួល គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណើ។ ក្នុងករណីនេះម្ចាស់សំណើមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន។

ក្នុងករណីគណៈកម្មការដោះស្រាយវិវាទសំណង់មិនអនុវត្តនីតិវិធីសម្រុះសម្រួលក្នុងរយៈពេលដូចមានកំណត់ក្នុងកថាខណ្ឌខាងលើ ម្ចាស់សំណើមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន។

ក្នុងករណីភាគីវិវាទពុំអាចព្រមព្រៀងគ្នាជាឯកច្ឆ័ន្ទដើម្បីបញ្ចប់វិវាទតាមការសម្រុះសម្រួលរបស់គណៈកម្មការដោះស្រាយវិវាទសំណង់ ម្ចាស់សំណើមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន គិតចាប់ពីថ្ងៃផុតរយៈពេលកំណត់។

**មាត្រា៨៧.-**

ភាគីឬគូភាគីនៃកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើអាចធ្វើសំណើមកគណៈកម្មការដោះស្រាយវិវាទសំណង់ ដើម្បីសម្រុះសម្រួលនិងដោះស្រាយវិវាទពាក់ព័ន្ធនឹងការអនុវត្តកិច្ចសន្យាម៉ៅការសាងសង់ឬរុះរើនោះ។

សំណើសុំការសម្រុះសម្រួលត្រូវធ្វើជាលាយលក្ខណ៍អក្សរក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលវិវាទបានកើតឡើង។

គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវធ្វើការសម្រុះសម្រួលជាមួយគូភាគីនៃវិវាទនិងចេញសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរដោយបញ្ជាក់អំពីមូលហេតុក្នុងរយៈពេល៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលសំណើសុំការសម្រុះសម្រួល។

ភាគីនៃវិវាទអាចសម្រេចចិត្តឈប់ទទួលយកការសម្រុះសម្រួលនិងដោះស្រាយវិវាទរបស់គណៈកម្មការដោះស្រាយវិវាទសំណង់នៅគ្រប់ដំណាក់កាលនៃការសម្រុះសម្រួល ប៉ុន្តែភាគីនៃវិវាទត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគណៈកម្មការដោះស្រាយវិវាទសំណង់អំពីការឈប់ទទួលយកការសម្រុះសម្រួលនិងដោះស្រាយវិវាទរបស់គណៈកម្មការដោះស្រាយវិវាទសំណង់ មុននឹងប្តឹងទៅតុលាការ។

**មាត្រា៨៨.-**

អាជ្ញាយុកាលនៃការរំលត់សិទ្ធិលើបំណុលត្រូវផ្អាក ក្នុងករណីមានសំណើសុំសម្រុះសម្រួលទៅគណៈកម្មការដោះស្រាយវិវាទសំណង់។

**មាត្រា៨៩.-**

គណៈកម្មការដោះស្រាយវិវាទសំណង់មានរចនាសម្ព័ន្ធដូចតទៅ៖

១- គណៈកម្មការដោះស្រាយវិវាទសំណង់ថ្នាក់ជាតិ

២- គណៈកម្មការដោះស្រាយវិវាទសំណង់ថ្នាក់រាជធានី ខេត្ត

៣- គណៈកម្មការដោះស្រាយវិវាទសំណង់ថ្នាក់ក្រុង ស្រុក ខណ្ឌ។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការដោះស្រាយវិវាទសំណង់ត្រូវកំណត់ដោយអនុក្រឹត្យ។

## ជំពូកទី២០
## ទោសប្បញ្ញត្តិ

**មាត្រា៩០ .-**

ទណ្ឌកម្មក្នុងច្បាប់នេះរួមមាន ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរឬការដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ការពិន័យអន្តរការណ៍ ការហាមឃាត់ការប្រកបវិជ្ជាជីវៈ ការបង្ខំឱ្យរុះរើនិង/ឬសាងសង់ឡើងវិញឱ្យដូចសភាពដើម ទោសពិន័យជាប្រាក់និងទោសដាក់ពន្ធនាគារ។

**មាត្រា៩១ .-**

ការព្រមានជាលាយលក្ខណ៍អក្សរ ការព្យួរឬការដកហូតអាជ្ញាបណ្ណឬលិខិតអនុញ្ញាតប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ជាសមត្ថកិច្ចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់អាចប្រគល់ឬធ្វើប្រតិភូកម្មសមត្ថកិច្ចដូចមានចែងក្នុងមាត្រានេះជូនដល់អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**មាត្រា៩២ .-**

ការពិន័យអន្តរការណ៍ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចសំណង់។

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យរំលត់បណ្តឹងអាជ្ញា។

ក្នុងករណីជនល្មើសមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចសំណង់អាចកសាងសំណុំរឿងនៃបទល្មើសបញ្ជូនទៅតុលាការមានសមត្ថកិច្ច។

បទល្មើសដែលត្រូវផ្តន្ទាទោសពិន័យអន្តរការណ៍ត្រូវកំណត់ដោយអនុក្រឹត្យ។

នីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ចំណូលដែលបានពីការពិន័យចំពោះអំពើល្មើស ដូចមានចែងនៅក្នុងបទប្បញ្ញត្តិនៃច្បាប់នេះត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

រាជរដ្ឋាភិបាលអាចសម្រេចផ្តល់រង្វាន់លើកទឹកចិត្តដល់មន្ត្រីដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសក្នុងវិស័យសំណង់។

**មាត្រា៩៣ .-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៥ ០០០ ០០០(ប្រាំលាន)រៀលទៅ២០ ០០០ ០០០(ម្ភៃលាន)រៀលចំពោះជនណាដែលមិនមែនជាវិស្វករ ស្ថាបត្យករ និងអ្នកជំនាញផ្សេងទៀតក្នុងវិស័យសំណង់ដែលបំពេញមុខងារជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ទ្វេដង ក្នុងករណីនៅតែប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេល១(មួយ)ឆ្នាំ។

**មាត្រា៩៤ .-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៤ ០០០ ០០០(បួនលាន)រៀលទៅ១០ ០០០ ០០០(ដប់លាន)រៀល ចំពោះវិស្វករ ស្ថាបត្យករ និងអ្នកជំនាញផ្សេងទៀតដែលបំពេញមុខងារជាអ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់ដោយមិនបានចុះបញ្ជីនៅគណៈវិជ្ជាជីវៈ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ១(មួយ)ឆ្នាំ និងត្រូវពិន័យជាប្រាក់ទ្វេដង ក្នុងករណីនៅតែប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេល១(មួយ)ឆ្នាំ។

**មាត្រា៩៥ .-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលប្រកបវិជ្ជាជីវៈក្នុងវិស័យសំណង់ដោយឯករាជ្យដោយគ្មានអាជ្ញាបណ្ណ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ទ្វេដង ក្នុងករណីនៅតែប្រព្រឹត្តបទល្មើសដដែលក្នុងរយៈពេល១(មួយ)ឆ្នាំ។

**មាត្រា៩៦ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី១០ ០០០ ០០០(ដប់លាន)រៀលទៅ២០ ០០០ ០០០(ម្ភៃលាន)រៀល ចំពោះជនណាដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ដោយគ្មានលិខិតអនុញ្ញាត ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា៩៧ .-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលប្រឆាំងនឹងសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ចឱ្យផ្អាក កែតម្រូវ បញ្ឈប់ ឬរុះរើសំណង់ ឬហាមប្រើប្រាស់សំណង់។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែទៅ៣(បី)ខែ និងពិន័យជាប្រាក់ទ្វេដង ចំពោះជនណាដែលប្រឆាំងនឹងសេចក្តីសម្រេចជាលើកទីពីររបស់អាជ្ញាធរមានសមត្ថកិច្ចឱ្យផ្អាក កែតម្រូវ បញ្ឈប់ ឬរុះរើសំណង់ ឬហាមប្រើប្រាស់សំណង់។

**មាត្រា៩៨ .-**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន)រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលបានប្រើឬបំពាក់ក្នុងការសាងសង់នូវសម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ចាំបាច់សម្រាប់ធានាគុណភាពសំណង់និងសុវត្ថិភាពរបស់អ្នកប្រើប្រាស់សំណង់ ដែលមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ឬមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសម្រាប់សម្ភារៈសំណង់ បរិក្ខារសំណង់ និងផលិតផលសំណង់ដែលតម្រូវឱ្យអនុវត្តតាមស្តង់ដារណាមួយជាក់លាក់ ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា៩៩ ..**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន) រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះអ្នកសិក្សាគម្រោងប្លង់ណាដែលបានសិក្សាគម្រោងប្លង់ ដោយមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ហើយការអនុវត្តតាមគម្រោងប្លង់នោះបណ្តាលឱ្យ មានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០០ ..**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន) រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះអ្នកសាងសង់ដែលបានសាងសង់ឬរុះរើមិនអនុលោម តាមគម្រោងប្លង់និងតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាព ដល់អ្នកដទៃ។

**មាត្រា១០១ ..**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៣០ ០០០ ០០០(សាមសិប លាន)រៀលទៅ៦០ ០០០ ០០០(ហុកសិបលាន)រៀល ចំពោះអ្នកត្រួតពិនិត្យនិងបញ្ជាក់ដែលបានបញ្ជាក់លើ គម្រោងប្លង់ឬការងារសាងសង់ឬរុះរើថាត្រឹមត្រូវ ដែលតាមជាក់ស្តែង គម្រោងប្លង់ឬការងារសាងសង់ឬរុះរើ នោះមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និង/ឬតាមគម្រោងប្លង់ដែលបានអនុញ្ញាត ហើយ បណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូចសុខភាពដល់អ្នកដទៃ។

**មាត្រា១០២ ..**

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ឆ្នាំទៅ៣(បី)ឆ្នាំ និងពិន័យជាប្រាក់ពី២០ ០០០ ០០០(ម្ភៃលាន) រៀលទៅ៤០ ០០០ ០០០(សែសិបលាន)រៀល ចំពោះជនណាដែលប្រើប្រាស់ឬដាក់ឱ្យប្រើប្រាស់ក្នុងគោលដៅ អាជីវកម្មនូវសំណង់ដែលគ្មានវិញ្ញាបនបត្រប្រើប្រាស់សំណង់ ហើយបណ្តាលឱ្យមានរបួសឬបណ្តាលឱ្យខូច សុខភាពដល់អ្នកដទៃ។

**មាត្រា១០៣ ..**

អំពើល្មើសដែលមានចែងក្នុងមាត្រា៩៥ មាត្រា៩៦ មាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ និងមាត្រា១០២នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥(ប្រាំ)ឆ្នាំទៅ១០(ដប់)ឆ្នាំ កាលបើ អំពើនេះបណ្តាលឱ្យមានការកាត់អវយវៈឬនាំឱ្យមានពិការភាពជាអចិន្ត្រៃយ៍ដល់ជនរងគ្រោះ។

អំពើល្មើសដែលមានចែងក្នុងមាត្រា៩៥ មាត្រា៩៦ មាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ និងមាត្រា១០២នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ)ឆ្នាំទៅ១៥(ដប់ប្រាំ)ឆ្នាំ កាលបើអំពើនេះបណ្តាលឱ្យមានមនុស្សស្លាប់។

**មាត្រា១០៤ .-**

ត្រូវផ្តន្ទាទោសដូចមាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ មាត្រា១០២ និងមាត្រា១០៣ នៃច្បាប់នេះ កាលបើអំពើល្មើសដូចមានចែងក្នុងមាត្រាទាំងនោះ ប្រព្រឹត្តដោយនាយកបច្ចេកទេសនៃក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់។

**មាត្រា១០៥ .-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៤០ ០០០ ០០០(សែសិបលាន)រៀលទៅ៨០ ០០០ ០០០(ប៉ែតសិបលាន)រៀល ចំពោះនីតិបុគ្គលណាដែលប្រកបអាជីវកម្មក្នុងវិស័យសំណង់ដោយគ្មានអាជ្ញាបណ្ណ។

នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០១ មាត្រា១០២ និងមាត្រា១០៣នៃច្បាប់នេះ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៦០ ០០០ ០០០(ហុកសិបលាន)រៀលទៅ១០០ ០០០ ០០០ (មួយរយលាន)រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើនដូចតទៅនេះ៖

១- ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០(ការរំលាយនីតិបុគ្គលនិងការជម្រះបញ្ជីនៃនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ។

២- ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា១៧១(ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ)នៃក្រមព្រហ្មទណ្ឌ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយឬច្រើន តាមបែបបទកំណត់ដោយមាត្រា១៧២(ការហាមឃាត់ចំពោះការធ្វើសកម្មភាព)នៃក្រមព្រហ្មទណ្ឌ។

៤- ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ តាមបែបបទកំណត់ដោយមាត្រា១៧៣(ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ)នៃក្រមព្រហ្មទណ្ឌ។

៥- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា១៨០(ការបិទផ្សាយសេចក្តីសម្រេច)នៃក្រមព្រហ្មទណ្ឌ។

៦- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរឬការផ្សាយតាមគ្រប់មធ្យោបាយតាមបែបបទកំណត់ដោយមាត្រា១៨១(ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍)នៃក្រមព្រហ្មទណ្ឌ។

## ជំពូកទី២១

## អន្តរប្បញ្ញត្តិ

**មាត្រា១០៦ .-**

ក្នុងរយៈពេល២(ពីរ)ឆ្នាំ ក្រោយច្បាប់នេះចូលជាធរមាន ម្ចាស់សំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់នេះចូលជាធរមាន ត្រូវមកដាក់ពាក្យស្នើសុំ

វិញ្ញាបនបត្រប្រើប្រាស់សំណង់របស់ខ្លួនពីអាជ្ញាធរមានសមត្ថកិច្ច ក្នុងករណីសំណង់នោះតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់។

ក្នុងរយៈពេលកំណត់ខាងលើ រាល់ទោសប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងវិស័យសំណង់ត្រូវបន្តអនុវត្តចំពោះសំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់នេះចូលជាធរមាន។

**មាត្រា១០៧.-**

អាជ្ញាធរមានសមត្ថកិច្ចអាចផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ចំពោះសំណង់ដែលបានសាងសង់រួចដោយគ្មានលិខិតអនុញ្ញាតឬសាងសង់ខុសពីលិខិតអនុញ្ញាតមុនច្បាប់នេះចូលជាធរមាន ក្នុងករណីសំណង់នោះមិនបង្កគ្រោះថ្នាក់ដល់អ្នកប្រើប្រាស់និងសាធារណជន និងមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។

បែបបទនិងនីតិវិធីនៃការផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ដែលបានសាងសង់រួចមុនច្បាប់នេះចូលជាធរមាន ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១០៨.-**

ក្រោយច្បាប់នេះចូលជាធរមានក្នុងរយៈពេល២(ពីរ)ឆ្នាំ មន្ទីរពិសោធន៍សំណង់ដែលបាននិងកំពុងប្រតិបត្តិការឬប្រកបអាជីវកម្មត្រូវស្នើសុំលិខិតអនុញ្ញាតឬអាជ្ញាបណ្ណប្រកបអាជីវកម្មស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ។

**មាត្រា១០៩.-**

ក្នុងករណីចាំបាច់ រាជរដ្ឋាភិបាលអាចតម្រូវឱ្យអ្នកវិជ្ជាជីវៈឬក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់តម្កល់ប្រាក់នៅធនាគារជាតិនៃកម្ពុជា ដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មរបស់ខ្លួន។ អ្នកវិជ្ជាជីវៈឬក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់អាចដកយកប្រាក់តម្កល់វិញនៅពេលឈប់ប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មនោះ និងនៅពេលអាជ្ញាបណ្ណផុតសុពលភាពឬត្រូវបានដកហូតដោយអាជ្ញាធរមានសមត្ថកិច្ច។

អ្នកទទួលសេវាពីអ្នកវិជ្ជាជីវៈឬក្រុមហ៊ុនប្រកបអាជីវកម្មក្នុងវិស័យសំណង់ ដែលទទួលរងការខូចខាតមានឯកសិទ្ធិលំដាប់ទី២បន្ទាប់ពីប្រាក់ឈ្នួលរបស់កម្មករនិយោជិត ចំពោះប្រាក់តម្កល់ដូចមានចែងក្នុងកថាខណ្ឌខាងលើ។

លក្ខខណ្ឌនិងនីតិវិធីនៃការតម្កល់ប្រាក់ ការដកប្រាក់តម្កល់ និងចំនួនទឹកប្រាក់អប្បបរមាដែលត្រូវតម្កល់នៅធនាគារជាតិនៃកម្ពុជា ទៅតាមប្រភេទនៃអាជ្ញាបណ្ណដើម្បីធានាការទទួលខុសត្រូវក្នុងការប្រកបវិជ្ជាជីវៈឬប្រកបអាជីវកម្មក្នុងវិស័យសំណង់ ត្រូវកំណត់ដោយអនុក្រឹត្យ។

ROYAUME DU CAMBODGE • LE MINISTERE DU PALAIS ROYAL

## ជំពូកទី២២

## អវសានបញ្ញត្តិ

**មាត្រា១១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

**មាត្រា១១១.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

ថ្ងៃ សៅរ៍ ៦កើត ខែ កត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១៩

នស.១១១៩.០១៦

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**

# ឧបសម្ព័ន្ធនៃច្បាប់ស្តីពីសំណង់

## សទ្ទានុក្រម

១- **ការងារសំណង់**(construction work) សំដៅដល់ការងារសិក្សាគម្រោងប្លង់ ការងារវាស់វែង ការងារសាងសង់(building work) ការងាររុះរើ ការងារគ្រប់គ្រងការដ្ឋាន ការងារត្រួតពិនិត្យនិងបញ្ជាក់ ការងារសិក្សាពិសោធ ការងារគ្រប់គ្រងគម្រោងសាងសង់ ឬការងារត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

២- **ការងារសិក្សាគម្រោងប្លង់**(design work) សំដៅដល់ការងារគូរប្លង់ ការងារសិក្សាស្រាវជ្រាវនិងវិភាគទិន្នន័យសម្រាប់ការងារស្ថាបត្យកម្មនិងវិស្វកម្ម ការងារផែនការ ការងាររៀបចំបញ្ជីប៉ាន់តម្លៃ ការងាររៀបចំសេចក្តីណែនាំបច្ចេកទេស និងការងារគូរប្លង់លម្អិត។

៣- **ការងារវាស់វែង**(surveying work) សំដៅដល់ការសិក្សានិងវិភាគទិន្នន័យនិងព័ត៌មានដែលបានពីការវាស់ ការស្ទង់ ការធ្វើថានលេខា និងការសង្កេត សម្រាប់បម្រើដល់ការធ្វើផែនការ ការសិក្សាគម្រោងប្លង់ និងការងារសាងសង់។

៤- **ការងារសាងសង់**(building work) សំដៅដល់ការងារដី ការងារសាងសង់សំណង់ថ្មី ការងារជួសជុល ការងារកែប្រែ និងការដំឡើង។

៥- **ការងារជួសជុល**(repair work) សំដៅដល់ការជួសជុលផ្នែកណាមួយនៃសំណង់ឬការជួសជុលទាំងស្រុងដែលមានការខូចខាតដោយប្រការណាមួយ រួមទាំងការផ្លាស់ប្តូរចំណែកចាស់ទ្រុឌទ្រោមដែលអាចបង្កនូវគ្រោះថ្នាក់ជាយថាហេតុ និងការកែលម្អ ការបំពាក់សម្ភារៈបរិក្ខារផ្នែកផ្សេងទៀតនៅខាងក្នុងដោយរក្សាសោភណភាព ទ្រង់ទ្រាយដើម និងមិនប៉ះពាល់ដល់គ្រឿងផ្គុំសំណង់។

៦- **ការងារកែប្រែ**(modification work) សំដៅដល់ការផ្លាស់ប្តូរមុខងារទ្រង់ទ្រាយទាំងស្រុងឬផ្នែកណាមួយនៃសំណង់។

៧- **ការងាររុះរើ**(demolition work) សំដៅដល់ការងារដោះឬដកចេញនូវចំណែកណាមួយ ឬដកចេញសំណង់ទាំងមូល ឬការងារវាយកម្ទេចសំណង់។

៨- **ការងារត្រួតពិនិត្យនិងបញ្ជាក់**(certification work) សំដៅដល់ការត្រួតពិនិត្យ ការវិភាគ និងការបញ្ជាក់ លើគម្រោងប្លង់ ការគណនា សេចក្តីណែនាំបច្ចេកទេសសម្រាប់ការងារសាងសង់ឬរុះរើ និងប្រតិបត្តិការការងារសាងសង់ឬរុះរើ អំពីអនុលោមភាពតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងបទប្បញ្ញត្តិជាធរមានដទៃទៀត ដើម្បីធានាសុវត្ថិភាព សុខុមាលភាពក្នុងការសាងសង់ឬរុះរើ និងក្នុងការប្រើប្រាស់សំណង់។

៩- **ការងារសិក្សាពិសោធ**(testing work) សំដៅដល់ការសិក្សា ការវិភាគ និងការងារគណនាផ្នែកភូគព្ភសាស្ត្រ ផ្នែកគ្រឿងផ្គុំសំណង់ ផ្នែកឧបករណ៍និងគ្រឿងចក្រសំណង់ និងផ្នែកសម្ភារៈ បរិក្ខារ និងផលិតផលសំណង់។

១០- **ការងារគ្រប់គ្រងគម្រោងសាងសង់**(construction project management) សំដៅដល់ការងារដែលអ្នកគ្រប់គ្រងគម្រោងសាងសង់អនុវត្តក្នុងនាមម្ចាស់សំណង់ ដើម្បីធានាឱ្យគម្រោងសាងសង់ឬរុះរើដំណើរការទៅប្រកបដោយប្រសិទ្ធភាពលើពេលវេលា តម្លៃ គុណភាព និងសុវត្ថិភាព។

**១១- ការដកហូត**(revocation) សំដៅដល់ការសម្រេចនិរាករអាជ្ញាបណ្ណឬលិខិតអនុញ្ញាតក្នុងវិស័យសំណង់ដោយអាជ្ញាធរឬមន្ត្រីមានសមត្ថកិច្ច។

**១២- កិច្ចសន្យាម៉ៅការសាងសង់**(construction contract) សំដៅដល់កិច្ចសន្យារវាងម្ចាស់សំណង់និងអ្នកសាងសង់ និងកិច្ចសន្យារវាងអ្នកសាងសង់និងអ្នកម៉ៅការសាងសង់ឬរុះរើបន្តដើម្បីអនុវត្តការងារសាងសង់ឬរុះរើ។

**១៣- គម្រោងប្លង់**(design document) សំដៅដល់ឯកសារបច្ចេកទេសសម្រាប់បម្រើដល់ការងារសំណង់មានជាអាទិ៍ ប្លង់ស្ថាបត្យកម្ម ប្លង់គ្រឿងផ្គុំសំណង់ ប្លង់ប្រព័ន្ធមេកានិក ប្លង់ប្រព័ន្ធអគ្គិសនី ប្លង់ប្រព័ន្ធទឹកស្អាត ទឹកកខ្វក់ ប្លង់ប្រព័ន្ធសុវត្ថិភាពអគ្គិភ័យ ឬប្លង់ ឯកសារ និងសេចក្តីណែនាំបច្ចេកទេសដទៃទៀត សម្រាប់ការងារសាងសង់ឬរុះរើនិងការប្រើប្រាស់សំណង់។

**១៤- តម្លៃនៃកិច្ចសន្យា**(contract fee) សំដៅដល់កម្រៃឬតម្លៃផ្សេងទៀតដែលម្ចាស់សំណង់ត្រូវបង់ជូនអ្នកសាងសង់តាមការកំណត់ក្នុងកិច្ចសន្យាសាងសង់។

**១៥- ប្រធានសក្តិ**(force majeure) សំដៅដល់ព្រឹត្តិការណ៍ដែលកើតឡើងក្រៅឆន្ទៈ មិនអាចប៉ាន់ស្មានជាមុន និងមិនអាចជម្នះបាន។

**១៦- បទប្បញ្ញត្តិបច្ចេកទេសសំណង់**(building technical regulations) សំដៅដល់បទដ្ឋានបច្ចេកទេស លក្ខខណ្ឌបច្ចេកទេស វិធានបច្ចេកទេសដែលមានលក្ខណៈបញ្ញា សម្រាប់អនុវត្តការងារសំណង់ដែលត្រូវបានអនុម័តដោយស្ថាប័នមានសមត្ថកិច្ច។

**១៧- បទប្បញ្ញត្តិរៀបចំដែនដីនិងនគរូបនីយកម្ម**(spatial and urban regulations) សំដៅដល់បទប្បញ្ញត្តិដែលមានចែងក្នុងបទដ្ឋានគតិយុត្តរៀបចំដែនដីនិងនគរូបនីយកម្ម ផែនការរៀបចំដែនដី ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម។

**១៨- បន្ទុក**(load) សំដៅដល់ទម្ងន់ សំពាធ ឬកម្លាំងទាំងឡាយដែលសង្កត់ឬមានឥទ្ធិពលលើគ្រឿងផ្គុំសំណង់។

**១៩- បរិក្ខារសំណង់**(construction equipment) សំដៅដល់បរិក្ខារដែលត្រូវបានផ្គុំ បង្កើត ឬផលិតឡើងដើម្បីប្រើប្រាស់ឬបំពាក់ភ្ជាប់នឹងសំណង់ដើម្បីបង្កើនគុណភាព ផាសុកភាព និងភាពងាយស្រួលនៃការប្រើប្រាស់សំណង់ មានជាអាទិ៍ អំពូលភ្លើង ខ្សែភ្លើង ខ្សែអុបទិក ឡាវ៉ាបូ រ៉ូប៊ីណេ ធើងងូតទឹក ម៉ាស៊ីនត្រជាក់ ជណ្តើរយន្ត ទុយោ។

**២០- ផលិតផលសំណង់**(construction product) សំដៅដល់ផលិតផលសម្រេចឬពាក់កណ្តាលសម្រេចដែលកើតចេញពីការបង្កើតឬការផលិតដោយប្រើប្រាស់សម្ភារៈសំណង់និងសម្រាប់យកទៅប្រើជាគ្រឿងផ្គុំសំណង់ មានជាអាទិ៍ ក្បឿង ឥដ្ឋ បាយអរ បេតុង សសរ ជញ្ជាំង ជហ្វា កម្រាលបេតុង បំពង់លូបេតុង ម្នាងសិលា ស៊ីម៉ងត៍ សី ស្វាតបត ក្រដាសជញ្ជាំង ថ្នាំលាប ជ័រស្អិតការ៉ូ។

**២១- ផលិតករ**(producer) សំដៅដល់អ្នកផលិត អ្នកនាំចូល ឬបុគ្គលដែលបានដាក់សញ្ញាណនៃនាមករណ៍របស់ខ្លួនជាផលិតករឬជាអ្នកលក់។

**២២- ម្ចាស់សំណង់**(construction owner) សំដៅដល់កម្មសិទ្ធិករនៃសំណង់ឬអ្នកអភិវឌ្ឍអចលនវត្ថុដែលបានសាងសង់នៅលើដីរបស់ខ្លួនផ្ទាល់ឬនៅលើដីរបស់អ្នកដទៃដោយមានការអនុញ្ញាតពីម្ចាស់ដី ឬអ្នកជួលអចិន្ត្រៃយ៍ដែលបានសាងសង់លើដីរបស់អ្នកឱ្យជួលអចិន្ត្រៃយ៍។

**២៣- មន្ត្រីត្រួតពិនិត្យសំណង់**(construction controller) សំដៅដល់មន្ត្រីជំនាញដែលត្រូវបានចាត់តាំងដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចុះត្រួតពិនិត្យការងារសាងសង់ឬរុះរើនិងត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

**២៤- វិការៈ**(defect) សំដៅដល់ការប្រែប្រួលចាកពីភាពប្រក្រតី។

**២៥- វិញ្ញាបនបត្រប្រើប្រាស់សំណង់**(occupancy certificate) សំដៅដល់លិខិតអនុញ្ញាតផ្ដល់ដោយអាជ្ញាធរមានសមត្ថកិច្ចដល់ម្ចាស់សំណង់ ដើម្បីប្រើប្រាស់ ជួល ឬធ្វើអាជីវកម្មលើសំណង់នោះបាន។

**២៦- សំណង់ដែលមានសភាពគ្រោះថ្នាក់**(dangerous building) សំដៅដល់សំណង់ឬផ្នែកណាមួយនៃសំណង់ ឬសម្ភារៈសំណង់ បរិក្ខារដែលបំពាក់លើសំណង់ ដែលអាចបង្កគ្រោះថ្នាក់ដល់សំណង់ជិតខាង ដល់អាយុជីវិត រាងកាយ សុខភាពរបស់អ្នកប្រើប្រាស់សំណង់ អ្នកជិតខាង និងសាធារណជន។

**២៧- សំណង់**(construction) សំដៅដល់ដំណើរការនៃការងារសំណង់ ដល់អគារ គ្រឿងផ្គុំ ស្ថាបត្យការ្យទាំងឡាយដែលមានលក្ខណៈជាអចិន្ត្រៃយ៍ឬបណ្ដោះអាសន្ន ធ្វើឡើងដោយប្រើប្រាស់សម្ភារៈសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់។

**២៨- សម្ភារៈសំណង់**(construction material) សំដៅដល់វត្ថុធាតុដើមសម្រាប់ធ្វើការលាយ ផ្សំ ផ្គុំ ឬប្រើប្រាស់ជាគ្រឿងផ្គុំសំណង់ បរិក្ខារសំណង់ ឬផលិតផលសំណង់ មានជាអាទិ៍ ខ្សាច់ ថ្ម ក្រួស ស៊ីម៉ងត៍ ដែក កញ្ចក់ ជីឥដ្ឋ សេរ៉ាមិក ឈើ។

**២៩- អ្នកសាងសង់**(builder) សំដៅដល់អ្នកទទួលម៉ៅការសាងសង់ឬរុះរើ អ្នកសាងសង់ឬរុះរើតាមជំនាញ ឬក្រុមជាងសំណង់។

**៣០- អ្នកអភិវឌ្ឍអចលនវត្ថុ**(real estate developer) សំដៅដល់ពាណិជ្ជករ វិនិយោគិន ឬក្រុមហ៊ុនដែលប្រកបអាជីវកម្មសាងសង់សំណង់សម្រាប់លក់ដើម្បីស្វែងរកផលចំណេញ។

**៣១- អាជ្ញាធរមានសមត្ថកិច្ច**(competent authority) សំដៅដល់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**៣២- អ្នកវិជ្ជាជីវៈក្នុងវិស័យសំណង់**(construction professional) សំដៅដល់ស្ថាបត្យករឬវិស្វករដែលបានចុះបញ្ជីនៅគណៈស្ថាបត្យករកម្ពុជាឬគណៈវិស្វករកម្ពុជា ឬអ្នកជំនាញដែលបានចុះបញ្ជីនៅគណៈវិជ្ជាជីវៈពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យសំណង់។

**៣៣- អ្នកជំនាញក្នុងវិស័យសំណង់**(tradesperson) សំដៅដល់អ្នកបច្ចេកទេសសំណង់(កម្មករជំនាញ/ជាង) ដែលបានទទួលការបណ្ដុះបណ្ដាលដោយសាលាបច្ចេកទេសជំនាញពាក់ព័ន្ធឬដែលមានជំនាញនិងបទពិសោធក្នុងការអនុវត្តការងារសាងសង់ឬអ្នកជំនាញក្នុងវិស័យសំណង់ដែលពុំទាន់មានបង្កើតគណៈវិជ្ជាជីវៈ។

៣៤ **អ្នកគ្រប់គ្រងសំណង់**(building manager) សំដៅដល់អ្នកដែលបានទទួលអាណត្តិឬសិទ្ធិគ្រប់គ្រងសំណង់ពីម្ចាស់សំណង់ក្នុងរយៈពេលកំណត់។

# ព្រះរាជក្រម

នស/រកម/០៦១៣/០០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំរដ្ឋសភាលើកទី៩ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ នាសម័យប្រជុំវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

# ច្បាប់

# ស្តីពី

# ការបង្ការ និងការពន្លត់អគ្គិភ័យ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងលើកកម្ពស់ការបង្ការនិងការពន្លត់អគ្គិភ័យ សំដៅការពារអាយុជីវិត ទ្រព្យសម្បត្តិ បរិស្ថាន សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅកំណត់អំពីការទទួលខុសត្រូវរបស់ជនគ្រប់រូប និងអំពីលក្ខខណ្ឌវិធាន-ការនានាដើម្បីបង្ការនិងពន្លត់អគ្គិភ័យ ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពគ្របដណ្តប់លើរាល់សកម្មភាពបង្ការនិងពន្លត់អគ្គិភ័យ ក្នុងព្រះរាជា-ណាចក្រកម្ពុជា ។

**មាត្រា ៤.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះមាននិយមន័យដូចខាងក្រោម ៖

- **អគ្គិភ័យ** សំដៅដល់ករណីមានភ្លើងឆេះមិនអាចគ្រប់គ្រងបានដែលអាចបង្កមហន្តរាយដល់អាយុជីវិត ទ្រព្យសម្បត្តិ និងបរិស្ថាន ។
- **ការបង្ការអគ្គិភ័យ** សំដៅដល់ការរៀបចំអនុវត្តនូវលក្ខខណ្ឌ និងវិធានការនានាដើម្បីធានាសុវត្ថិភាព មិនឲ្យមានអគ្គិភ័យកើតឡើង ។
- **ប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យ** សំដៅដល់ការបំពាក់ឧបករណ៍បច្ចេកទេសក្នុងនិង/ឬក្រៅគោលដៅ និងវិធានការនានាដើម្បីបង្ការទប់ស្កាត់ ពន្លត់អគ្គិភ័យ និងសង្គ្រោះ ។
- **មធ្យោបាយ** សំដៅដល់យានយន្ត ឧបករណ៍ សម្ភារៈ បរិក្ខារដែលប្រើប្រាស់សម្រាប់បង្ការនិងពន្លត់អគ្គិភ័យ ។
- **ទីកន្លែងងាយឆេះឬងាយផ្ទុះឆេះ** សំដៅដល់ទីកន្លែងដែលមានស្តុក ប្រើប្រាស់សារធាតុងាយឆេះឬងាយផ្ទុះឆេះ ។
- **សារធាតុងាយឆេះឬងាយផ្ទុះឆេះ** សំដៅដល់សារធាតុរាវ រឹង ឧស្ម័ន គីមី ទំនិញ ឬវត្ថុធាតុដើមដែលងាយឆេះឬងាយផ្ទុះឆេះ ។
- **ការពន្លត់អគ្គិភ័យ** សំដៅដល់ការពន្លត់អគ្គិភ័យនិងទប់ស្កាត់ការឆេះរាលដាលដោយប្រើប្រាស់កម្លាំង ប្រើប្រាស់មធ្យោបាយពន្លត់អគ្គិភ័យ និងប្រើប្រាស់គ្រប់វិធានការផ្សេងៗទៀត ។

- តំបន់ពន្លត់អគ្គិភ័យ សំដៅដល់ទីកន្លែងកំពុងឆេះឬប្រឈមនឹងការឆេះដែលសមត្ថកិច្ចកំពុងប្រតិបត្តិការពន្លត់អគ្គិភ័យ ។
- គោលដៅ សំដៅដល់ទីកន្លែងនានានិងមធ្យោបាយដឹកជញ្ជូនទាំងឡាយដែលអាចមានអគ្គិភ័យកើតឡើង ។

**មាត្រា ៥.-**

រាល់អំពើដែលអាចបង្កឲ្យមានអគ្គិភ័យកើតឡើងត្រូវហាមឃាត់ ។

**មាត្រា ៦.-**

ជនគ្រប់រូបដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានករណីយកិច្ចចូលរួមក្នុងសកម្មភាពបង្ការនិងពន្លត់អគ្គិភ័យ ។

## ជំពូកទី ២
## សមត្ថកិច្ច

**មាត្រា ៧.-**

ក្រសួងមហាផ្ទៃមានសមត្ថកិច្ចក្នុងការស្នើនិងដាក់ចេញនូវគោលការណ៍ វិធានការ ការបណ្តុះបណ្តាល ការហ្វឹកហាត់ជំនាញអំពីការបង្ការនិងការពន្លត់អគ្គិភ័យ ។

**មាត្រា ៨.-**

អ្នកទទួលខុសត្រូវតាមគោលដៅនានា ត្រូវទទួលខុសត្រូវដោយផ្ទាល់ក្នុងកិច្ចប្រតិបត្តិការបង្ការនិងពន្លត់អគ្គិភ័យ ។

អង្គភាពនគរបាលបង្ការនិងពន្លត់អគ្គិភ័យ ត្រូវឆ្លើយតបតាមសំណើឬអន្តរាគមន៍ជាបន្ទាន់ដល់គ្រប់គោលដៅដែលមានអគ្គិភ័យកើតឡើង ។

លក្ខខណ្ឌនិងវិធានការនានាស្តីពីការបង្ការនិងការពន្លត់អគ្គិភ័យតាមគោលដៅ និងការបង្ការអគ្គិភ័យនៅតាមលំនៅឋានរបស់ជនគ្រប់រូប ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៩.-**

កិច្ចប្រតិបត្តិការបង្ការនិងពន្លត់អគ្គិភ័យ ការត្រួតពិនិត្យ ការបញ្ជាក់ទទួលស្គាល់ប្រព័ន្ធបង្ការអគ្គិភ័យលើគោលដៅ ការផ្អាកសកម្មភាពបណ្តោះអាសន្នដល់គោលដៅ ឬសកម្មភាពណាដែលខ្វះលក្ខខណ្ឌនិងវិធានការបង្ការនិងពន្លត់អគ្គិភ័យ ការពិនិត្យអង្កេតកន្លែងកើតហេតុ ការធ្វើកោសល្យវិច័យ ចំណុះឲ្យសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃដែលមានអគ្គស្នងការដ្ឋាននគរបាលជាតិជាសេនាធិការ ។

### មាត្រា ១០.-

អ្នកទទួលខុសត្រូវតាមគោលដៅនានា ត្រូវចូលរួមជួយសង្គ្រោះនិងពន្លត់អគ្គិភ័យដែលកើតមានឡើងនៅជិតគោលដៅរបស់ខ្លួន លើកលែងតែនៅក្នុងមូលដ្ឋានកងទ័ពឬគោលដៅក្រោការសម្ងាត់ទាក់ទងនឹងសន្តិសុខជាតិ ឬក្នុងស្ថានទូត ស្ថានកុងស៊ុល ស្ថានតំណាងបរទេស និវេសនដ្ឋាន ឬស្ថានតំណាងអង្គការអន្តរជាតិ ដែលត្រូវមានសំណូមពរសុំជំនួយ ។

### មាត្រា ១១.-

គ្រប់គោលដៅ គ្រប់ប្រព័ន្ធឃោសនាត្រូវមានកម្មវិធីផ្សព្វផ្សាយអប់រំនិងលើកកម្ពស់ការយល់ដឹងអំពីវិធានការបង្ការនិងពន្លត់អគ្គិភ័យ ។

### មាត្រា ១២.-

កិច្ចសហប្រតិបត្តិការជួយពន្លត់អគ្គិភ័យនិង/ឬសំណើសុំជំនួយពន្លត់អគ្គិភ័យជាមួយបណ្ដាប្រទេស និងអង្គការអន្តរជាតិនានា ជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលដែលមានក្រសួងមហាផ្ទៃជាសេនាធិការ ។

### មាត្រា ១៣.-

ថ្ងៃទី២២ ខែកុម្ភៈរៀងរាល់ឆ្នាំ ត្រូវបានកំណត់ជាថ្ងៃប្រារព្ធទិវាជាតិបង្ការនិងពន្លត់អគ្គិភ័យ ។

## ជំពូកទី ៣
## ការបង្ការអគ្គិភ័យ

### មាត្រា ១៤.-

ការស្តុកទុក ការដឹកជញ្ជូន ការគ្រប់គ្រង ការលក់ ការប្រើប្រាស់សារធាតុងាយឆេះ ងាយផ្ទុះឆេះប្រភពភ្លើង និងប្រភពកំដៅ ដែលអាចបង្កឲ្យមានអគ្គិភ័យត្រូវអនុវត្តតាមលក្ខខណ្ឌនិងវិធានការនានាស្ដីពីការបង្ការនិងការពន្លត់អគ្គិភ័យ ដែលត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រោយមានការឯកភាពពីអាជ្ញាធរជំនាញពាក់ព័ន្ធ ។

### មាត្រា ១៥.-

អ្នកផលិត អ្នកធ្វើពាណិជ្ជកម្ម និងអ្នកដឹកជញ្ជូនប្រេងឥន្ធនៈ សារធាតុងាយឆេះឬងាយផ្ទុះឆេះត្រូវមានវិញ្ញាបនបត្របញ្ជាក់អំពីការហ្វឹកហ្វឺនជំនាញបង្ការនិងពន្លត់អគ្គិភ័យ ។ ការហ្វឹកហ្វឺនអំពីជំនាញបង្ការនិងពន្លត់អគ្គិភ័យ និងការផ្ដល់វិញ្ញាបនបត្របញ្ជាក់ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ១៦.–**

ការដាក់លក់រាយប្រេងឥន្ធនៈឬឧស្ម័នចំហេះរបស់ប្រជាពលរដ្ឋ ដើម្បីបម្រើជីវភាពប្រចាំថ្ងៃ ត្រូវអនុវត្តតាមលក្ខខណ្ឌនិងវិធានការនានា ស្តីពីការបង្ការនិងការពន្លត់អគ្គិភ័យដូចមានចែងនៅក្នុងមាត្រា ១៤ នៃច្បាប់នេះ ។

**មាត្រា ១៧.–**

គោលដៅស្តុក ផលិតកែច្នៃប្រេងឥន្ធនៈ កែច្នៃសារធាតុងាយឆេះឬងាយផ្ទុះឆេះ ត្រូវស្ថិតនៅទីតាំងដែលធានាមិនបង្កហានិភ័យដល់ទីប្រជុំជន។ ចំពោះគោលដៅទាំងឡាយណាដែលមានការអនុញ្ញាតរួចហើយ ត្រូវអនុវត្តតាមលក្ខខណ្ឌនិងវិធានការនានាស្តីពីការបង្ការនិងការពន្លត់អគ្គិភ័យដូចមានចែងនៅក្នុងមាត្រា ១៤ នៃច្បាប់នេះ ។

**មាត្រា ១៨.–**

គ្រប់ទីប្រជុំជនត្រូវមានប្លង់គោលតម្កល់ទុកនៅអង្គភាពនគរបាលបង្ការនិងពន្លត់អគ្គិភ័យ ។

រាល់សំណង់ត្រូវធានាឲ្យមានប្លង់ប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យមុនដំណើរការសាងសង់ ។

ចំណាត់ថ្នាក់សំណង់និងគោលដៅ ដែលតម្រូវឲ្យមានប្លង់ប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា ១៩.–**

ការត្រួតពិនិត្យនិងការចេញសេចក្តីបញ្ជាក់អំពីគុណភាព ប្រសិទ្ធភាពនៃប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យ ដល់គោលដៅត្រូវធ្វើឡើងសម្រាប់រយៈពេល ២ឆ្នាំម្តង ។ ក្នុងករណីចាំបាច់ ម្ចាស់គោលដៅអាចលើកសំណើសុំឲ្យត្រួតពិនិត្យមុនកាលកំណត់បាន ។

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យ ការចេញសេចក្តីបញ្ជាក់អំពីគុណភាព ប្រសិទ្ធភាពនៃប្រព័ន្ធបង្ការនិងពន្លត់អគ្គិភ័យ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ២០.–**

នៅគ្រប់ការរៀបចំពិធីធំៗដែលប្រមូលផ្តុំមនុស្សច្រើនកុះករ អ្នករៀបចំ ឬអ្នកគ្រប់គ្រង ឬអ្នកទទួលខុសត្រូវពិធី ត្រូវសហការជាមួយអង្គភាពនគរបាលបង្ការនិងពន្លត់អគ្គិភ័យ ដើម្បីធ្វើផែនការបង្ការពន្លត់អគ្គិភ័យនិងជម្លៀសមនុស្សចេញក្នុងករណីមានអគ្គិភ័យកើតឡើង ។

## ជំពូកទី ៤
## ការពន្លត់អគ្គិភ័យ

**មាត្រា ២១.-**

ក្នុងករណីមានអគ្គិភ័យកើតឡើង មន្ត្រីបញ្ជាដឹកនាំនគរបាលពន្លត់អគ្គិភ័យមានសិទ្ធិ ៖

- កំណត់តំបន់ប្រតិបត្តិការពន្លត់អគ្គិភ័យនិងតំបន់ហាមឃាត់ការចេញចូលឆ្លងកាត់ និងសហការការពារ សន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- ប្រមូលកម្លាំងប្រជាពលរដ្ឋដែលមានអាយុចាប់ពី ១៨ឆ្នាំឡើង និងមធ្យោបាយនានាដើម្បីជួយសង្គ្រោះជីវិតមនុស្ស ទ្រព្យសម្បត្តិ និងជួយពន្លត់អគ្គិភ័យ ។

**មាត្រា ២២.-**

នៅពេលដែលមានអគ្គិភ័យកើតឡើង មន្ត្រីដឹកនាំនគរបាលប្រតិបត្តិការពន្លត់អគ្គិភ័យត្រូវចាត់វិធានការគ្រប់បែបយ៉ាងដើម្បីពន្លត់អគ្គិភ័យ សំដៅជួយសង្គ្រោះជីវិតមនុស្សនិងទ្រព្យសម្បត្តិជាបន្ទាន់ ។

**មាត្រា ២៣.-**

ជនណាដែលបានដឹងព័ត៌មានអំពីអគ្គិភ័យឬបានឃើញអគ្គិភ័យកើតឡើងឬបម្រុងនឹងកើតឡើង ត្រូវផ្តល់ដំណឹងជាបន្ទាន់ដល់សមត្ថកិច្ចឬនគរបាលបង្ការនិងពន្លត់អគ្គិភ័យដែលនៅជិតបំផុត ដើម្បីចាត់វិធានការដោះស្រាយឲ្យបានទាន់ពេលវេលា ។

នៅពេលដែលមានអគ្គិភ័យកើតឡើង ហើយពុំទាន់មានវត្តមាននគរបាលបង្ការនិងពន្លត់អគ្គិភ័យ អ្នកទទួលខុសត្រូវតាមគោលដៅឬអាជ្ញាធរមានសមត្ថកិច្ចនៅនឹងកន្លែង ត្រូវចាត់វិធានការជាបន្ទាន់ដើម្បីជួយសង្គ្រោះជីវិតមនុស្ស ទ្រព្យសម្បត្តិ និងពន្លត់អគ្គិភ័យ ។

ក្រសួង ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធនានានៅពេលទទួលបានសំណូមពរសុំជួយអន្តរាគមន៍ ត្រូវឆ្លើយតបជាបន្ទាន់ ។

## ជំពូកទី ៥
## ការគាំពារ

**មាត្រា ២៤.-**

ចំពោះភ្នាក់ងារនគរបាលបង្ការនិងពន្លត់អគ្គិភ័យ ឬជនណាដែលពលីជីវិតឬរងរបួស ប៉ះពាល់សុខភាព ឬពិការមួយជីវិតក្នុងពេលប្រតិបត្តិការពន្លត់អគ្គិភ័យ រដ្ឋត្រូវទទួលខុសត្រូវដោះស្រាយគោលនយោបាយ ផ្តល់កិត្តិយស និងផ្តល់ការព្យាបាលដោយឥតគិតថ្លៃ ។

ការផ្តល់សំណងនៃការខូចខាតទ្រព្យសម្បត្តិ ដូចមានចែងក្នុងមាត្រា ២១ និងមាត្រា ២២ នៃច្បាប់នេះ ដោយថវិការបស់រដ្ឋ ។

**មាត្រា ២៥.-**

រដ្ឋទទួលខុសត្រូវដោះស្រាយទីកន្លែង ជម្រកស្នាក់នៅបណ្តោះអាសន្ន និងដោះស្រាយជីវភាព សង្គមដល់ជនរងគ្រោះដោយសារអគ្គិភ័យ ។

**មាត្រា ២៦.-**

រដ្ឋលើកទឹកចិត្តសប្បុរសជន អង្គការជាតិ អង្គការអន្តរជាតិក្នុងការជួយឧបត្ថម្ភ សង្គ្រោះដល់ជនរងគ្រោះដោយសារអគ្គិភ័យ ។

## ជំពូកទី ៦
## ទោសប្បញ្ញត្តិ

**មាត្រា ២៧.-**

មន្ត្រីសមត្ថកិច្ចអគ្គិភ័យដែលខ្វះការទទួលខុសត្រូវ មិនបំពេញភារកិច្ច ឬបំពេញភារកិច្ចដោយមិនត្រឹមត្រូវក្នុងការពន្លត់អគ្គិភ័យ បង្កឲ្យមានការខូចខាតធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់អ្នកដទៃត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦(ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ 000 000 (មួយលាន) រៀល ទៅ ៤ 000 000 (បួនលាន) រៀល ។

**មាត្រា ២៨.-**

អំពើរារាំង បង្កឧបសគ្គដោយចេតនា ដល់សកម្មភាពពន្លត់អគ្គិភ័យ បង្កឲ្យមានការខូចខាតធ្ងន់ធ្ងរដល់ទ្រព្យសម្បត្តិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ៤ 000 000 (បួនលាន) រៀល ទៅ ១០ 000 000 (ដប់លាន) រៀល ។

**មាត្រា ២៩.-**

អំពើផ្តល់ព័ត៌មានក្លែងឬអំពើបើកកកាយព័ត៌មានក្លែង ដើម្បីធ្វើឲ្យជឿថាអគ្គិភ័យនឹងកើតមានឬអគ្គិភ័យបានកើតមានឡើង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងពិន័យជាប្រាក់ពី ២ 000 000 (ពីរលាន) រៀល ទៅ ៤ 000 000 (បួនលាន) រៀល ។

**មាត្រា ៣០.-**

នីតិបុគ្គលអាចត្រូវបានប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌចំពោះអំពើបំផ្លិចបំផ្លាញ [illegible]ទ្រាម ឬធ្វើឲ្យខូចខាតទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិអ្នកដទៃដោយអានុភាពនៃអគ្គិភ័យ កាលបើអំពើនេះបណ្តាលមកពី ៖

១- ការធ្វេសប្រហែស ការមិនប្រុងប្រយ័ត្ន ឬការខ្ជីខ្ជា ។

២- ការរំលោភបំពានលើកាតព្វកិច្ចសន្តិសុខឬកាតព្វកិច្ចប្រុងប្រយ័ត្នដែលច្បាប់តម្រូវ ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ២០ ០០០ ០០០ (ម្ភៃលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយឬច្រើនដូចមានចែងក្នុងមាត្រា ២០៩ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៣១.-**

ក្រៅពីបទល្មើសដែលមានចែងក្នុងច្បាប់នេះ អំពើដែលជាបទល្មើសព្រហ្មទណ្ឌត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

## ជំពូកទី ៧
## អន្តរប្បញ្ញត្តិ

**មាត្រា ៣២.-**

បទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៨ និងពីមាត្រា ១៤ ដល់មាត្រា ១៩ ត្រូវចាប់អនុវត្តក្នុងរយៈពេល ១ (មួយ) ឆ្នាំ ក្រោយពេលច្បាប់នេះចូលជាធរមាន ។

## ជំពូកទី ៨
## អវសានប្បញ្ញត្តិ

**មាត្រា ៣៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៣

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

*នស.១៣០៦.៥៦៩*

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ

ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ហត្ថលេខា

ស ខេង

លេខ: ៥៦៦ ស.ណ

សំណៅចេញដោយមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៣

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

សយ សុខា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២២៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# លិខិតអនុញ្ញាតសាងសង់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ៧៦ អនក្រ.បក ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ៤២ អនក្រ.បក ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**សម្រេច**

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះកំណត់អំពីសមត្ថកិច្ច លក្ខខណ្ឌ និងនីតិវិធី ក្នុងការផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ក្នុងគោលបំណង ដើម្បី៖

- ធានាគុណភាព សុវត្ថិភាពសំណង់ ការពារទ្រព្យសម្បត្តិ និងសុខុមាលភាពរបស់ម្ចាស់សំណង់ អ្នកប្រើប្រាស់សំណង់ និងសាធារណជន
- ធានាការងារសាងសង់ឬរុះរើឱ្យត្រឹមត្រូវតាមបទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសសំណង់ ដើម្បីរក្សាសោភណភាព បរិស្ថានល្អ និងសណ្តាប់ធ្នាប់សាធារណៈ
- ការពារដីសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដទៃទៀត
- ធានាគុណភាពនិងភាពត្រឹមត្រូវនៃការរៀបចំដែនដីនិងនគរូបនីយកម្ម
- បង្ការនិងទប់ស្កាត់វិវាទក្នុងការងារសាងសង់ឬរុះរើ
- បង្កើនការជឿទុកចិត្តរបស់វិនិយោគិននៅក្នុងវិស័យសំណង់ និងជំរុញទីផ្សារអចលនទ្រព្យប្រកបដោយប្រសិទ្ធភាពផ្នែកសេដ្ឋកិច្ចនិងសង្គម។

**មាត្រា២.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះសំណង់គ្រប់ប្រភេទ លើកលែងតែប្រភេទសំណង់ដែលមានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា៣ ._**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

១. **ការងារដី** សំដៅដល់ការងារកែប្រែរចនាសម្ព័ន្ធដីដែលបម្រើដល់ការងារសាងសង់ មានជាអាទិ៍ ការងារឈូសឆាយដី ការងារជីកដី ការងារចាក់បំពេញដី ការងារបង្ហាប់ដី ការងារពង្រឹងគុណភាពដី។

២. **ការងារដំឡើង** សំដៅដល់ការងារដំឡើងផលិតផលសំណង់ឬការងារបំពាក់បរិក្ខារសំណង់ភ្ជាប់ទៅនឹងផ្នែកនៃសំណង់ មានជាអាទិ៍គ្រឿងផ្គុំសំណង់ ជញ្ជាំង ដំបូលនៃសំណង់សម្រាប់ការប្រើប្រាស់ជាបណ្តោះអាសន្នឬជាប់លាប់។

៣. **ការងារសាងសង់សំណង់ថ្មី** សំដៅដល់ការងារសាងសង់ដែលចាប់ផ្តើមពីការងារដីឬការងារគ្រឹះ ការងារគ្រឿងផ្គុំ ការងារជញ្ជាំង ការងារដំឡើងរហូតដល់ការងារបង្ហើយដើម្បីបង្កើតសំណង់ថ្មីមួយ។

៤. **គ្រឿងផ្គុំសំណង់** សំដៅដល់រចនាសម្ព័ន្ធរបស់សំណង់ មានជាអាទិ៍គ្រឹះ សសរ ធ្នឹម កម្រាលខណ្ឌ ជណ្តើរ ជញ្ជាំងទ្រទម្ងន់ គ្រឿងផ្គុំដំបូល និងគ្រឿងផ្គុំផ្សេងទៀតដែលមានមុខងារទ្រទម្ងន់។

៥. **ជញ្ជាំងទប់ដី** សំដៅដល់សំណង់ឬសិល្បការ្យ ដែលសាងសង់សម្រាប់ទប់ការរអិលដី ការបាក់ដី ឬសម្ពាធដីផ្សេងទៀតនិងដែលមិនមែនជាផ្នែកនៃហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ឬសំណង់ការងារទឹក។

៦. **ឋបនីយភណ្ឌ** សំដៅដល់គ្រឿងផ្គុំឬគ្រឿងឧបករណ៍ សម្ភារៈ បរិក្ខារដែលតម្កល់ទុកវត្ថុឬផលិតផលគ្រឿងឆេះដែលអាចបង្កអគ្គិភ័យផ្សេងៗជាយថាហេតុ និងដែលត្រូវទុកដាក់ឱ្យបានល្អ។

៧. **ផ្ទៃក្រឡាកម្រាលសំណង់** សំដៅដល់ផ្ទៃក្រឡាកម្រាលសំណង់ដែលធ្វើការសាងសង់។

៨. **មន្ត្រីមានសមត្ថកិច្ច** សំដៅដល់អគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

៩. **មុខងារសមាសភាគសំណង់** សំដៅដល់មុខងារទាំងឡាយនៃផ្នែកនីមួយៗរបស់សំណង់ដែលផ្សំគ្នាសម្រាប់បង្កើតមុខងារប្រើប្រាស់សំណង់។

១០. **យន្តការច្រកចេញចូលតែមួយ** សំដៅដល់ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត និងការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។

១១. **លិខិតបញ្ជាក់អនុលោមភាព** សំដៅដល់លិខិតចេញដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ដើម្បីបញ្ជាក់អំពីអនុលោមភាពនៃសំណង់ឬការងារសំណង់តាមបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងបទប្បញ្ញត្តិជាធរមានដទៃទៀត។

១២. **វិញ្ញាបនបត្រប្រើប្រាស់សំណង់** សំដៅដល់លិខិតអនុញ្ញាតផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចដល់ម្ចាស់សំណង់ដើម្បីប្រើប្រាស់ ជួល ឬធ្វើអាជីវកម្មលើសំណង់នោះបាន។

១៣. **សលាកបត្រក្បាលដី** សំដៅដល់ឯកសារផ្តល់ដោយរដ្ឋបាលសុរិយោដី ដែលមានបង្ហាញកម្មសិទ្ធិករនៃដី ទីតាំងនៃដី និយាមកាចំណុចព្រំដី និងទំហំនៃដី។

១៤. **សៀវភៅបន្ទុក** សំដៅដល់កម្រងឯកសារបច្ចេកទេសសម្រាប់បម្រើដល់ការអនុវត្តការងារសាងសង់ ឬរុះរើ មានជាអាទិ៍ផែនការការងារ សេចក្តីណែនាំបច្ចេកទេស វិធីសាស្ត្រ និងឯកសារបច្ចេកទេស ដទៃទៀត។

១៥. **សំណង់បេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រ** សំដៅដល់សំណង់ជាកេរដំណែលបន្សល់ទុកពីមនុស្ស ជំនាន់មុនដែលមានចរិតវិទ្យាសាស្ត្រ វប្បធម៌ ប្រវត្តិសាស្ត្រ បុរាណវិទ្យា សិល្បៈ សាសនា ដែលឆ្លុះ បញ្ចាំងពីដំណាក់កាលនៃការវិវត្តរបស់អរិយធម៌ និងដែលបានចុះបញ្ជីសារពើភណ្ឌ បេតិកភណ្ឌ ស្របតាមច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌។

១៦. **សំណង់មិនមែនអគារ** សំដៅដល់សំណង់ដែលសាងសង់ឡើងភ្ជាប់នឹងដីឬអចលនវត្ថុដទៃទៀត សម្រាប់ទ្រទ្រង់បន្ទុកដែលត្រូវបានសិក្សាឡើងមិនមែនសម្រាប់មនុស្សស្នាក់នៅឬប្រើប្រាស់ជានិរន្តរ៍ មានជាអាទិ៍បង្គោលអង់តែនទូរសព្ទ បង្គោលអង់តែនស្ថានីយវិទ្យុឬទូរទស្សន៍ សំណង់ពាក់ព័ន្ធ នឹងការគ្រប់គ្រងសកម្មភាពផ្នែកដោនស្ទ្រីម បង្គោលអគ្គិសនី ដងទង់ ប៉ម ខ្លោងទ្វារ អាងស្តុកទឹក ខ្ពស់ពីដី ស្តូប បដិមា កន្ត្រកវិល។

១៧. **សំណង់លំនៅឋាន** សំដៅដល់សំណង់ដែលមានមុខងារប្រើប្រាស់ជាទីលំនៅអចិន្ត្រៃយ៍។

១៨. **អគារ** សំដៅដល់សំណង់ដែលសាងសង់ឡើងភ្ជាប់នឹងដីសម្រាប់ទ្រទ្រង់បន្ទុកដែលត្រូវបានសិក្សា ឡើងសម្រាប់មនុស្សស្នាក់នៅឬប្រើប្រាស់ជានិរន្តរ៍ មានជាអាទិ៍សំណង់លំនៅឋាន សណ្ឋាគារ អគារការិយាល័យ មន្ទីរពេទ្យ អគារសិក្សា បណ្ណាល័យ រោងភាពយន្ត សារមន្ទីរ សាលមហោស្រព ផ្សារ រោងចក្រ ស្ថានីយអ្នកដំណើរ។

១៩. **អាជ្ញាធរមានសមត្ថកិច្ច** សំដៅដល់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

២០. **ឯកសារបច្ចេកទេស** សំដៅដល់គម្រោងប្លង់ស្ថាបត្យកម្ម គម្រោងប្លង់គ្រឿងផ្គុំសំណង់ គម្រោង ប្លង់រុះរើ គម្រោងប្លង់ប្រព័ន្ធមេកានិក អគ្គិសនី ឬទឹក លិខិតបញ្ជាក់អនុលោមភាព វិញ្ញាបនបត្រ ប្រើប្រាស់សំណង់ ឯកសារសិក្សាភូគព្ភសាស្ត្រ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម ឯកសារសិក្សាសមិទ្ធលទ្ធកម្ម សៀវភៅបន្ទុកនៃការងារសាងសង់ និងគម្រោង ប្លង់បច្ចេកទេសដទៃទៀត។

## ជំពូកទី២
## សមត្ថកិច្ច

**មាត្រា៤ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចគ្រប់គ្រងសំណង់គ្រប់ប្រភេទ។

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ និងលិខិតអនុញ្ញាតរុះរើចំពោះសំណង់ឬការងារ ដូចខាងក្រោម៖

- សំណង់ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបលើសពី៣ ០០០(បីពាន់)ម៉ែត្រក្រឡា
- ការងារសាងសង់ឡើងវិញជាថ្មី ការងារសាងសង់បន្ថែម ឬការងារកែប្រែសំណង់ដែលមានស្រាប់ ដែលមានផ្ទៃក្រឡាកម្រាលសំណង់ចាស់បូកផ្ទៃក្រឡាកម្រាលសំណង់ថ្មី សរុបលើសពី៣ ០០០ (បីពាន់)ម៉ែត្រក្រឡា
- អគារដែលមានកម្ពស់ខ្ពស់ជាង១១(ដប់មួយ)ជាន់ឡើងទៅរួមទាំងជាន់ផ្ទាល់ដី
- សំណង់ដែលមានជាន់ក្រោមដីក្នុងជម្រៅជ្រៅជាង៥(ប្រាំ)ម៉ែត្រ
- ជញ្ជាំងទប់ដីដែលមានកម្ពស់ខ្ពស់ជាង៥(ប្រាំ)ម៉ែត្រ
- ថបនីយភណ្ឌដែលអាចបង្កគ្រោះថ្នាក់ដោយអគ្គិភ័យដូចជាស្ថានីយឬដេប៉ូស្តុក លក់ ឬចែកចាយ ប្រេងឥន្ធនៈ ឧស្ម័ន ឬផលិតផលគេលសិលាដទៃទៀត ពោងឬស៊ីទែនស្តុកប្រេងឥន្ធនៈ ឧស្ម័ន សារធាតុងាយឆេះ ឬផលិតផលគេលសិលាដទៃទៀត និងរោងជាងដែលមានផលិតផលងាយឆេះ
- អាងតម្កល់ឬស្តុកទឹកដែលមានកម្ពស់ខ្ពស់ជាង១៥(ដប់ប្រាំ)ម៉ែត្រ ឬមានចំណុះលើសពី៥០(ហាសិប) ម៉ែត្រគុប
- សំណង់សម្រាប់បម្រើវិស័យកីឡា ទេសចរណ៍ និងវប្បធម៌ មានជាអាទិ៍ពហុកីឡដ្ឋាន ទីលានវាយកូនហ្គោល ទីលានកីឡាប្រណាំង សួនកម្សាន្ត អាងហែលទឹក សារមន្ទីរ សាលមហោស្រព សាលសន្និសីទ រោងភាពយន្ត
- សំណង់នៅក្នុងតំបន់ការពារបរិស្ថានធម្មជាតិ បេតិកភណ្ឌវប្បធម៌ ប្រវត្តិសាស្ត្រ ឬតំបន់ការពារផ្សេងទៀត
- អគារ ប៉ម ឬសំណង់នៅក្នុងស្ថានីយអ្នកដំណើរតាមរថយន្ត ស្ថានីយអយស្ម័យយាន កំពង់ផែ អាកាសយានដ្ឋាន និងស្ថានីយរ៉ាវីអគ្គិសនី ដែលមិនមែនជាផ្នែកនៃហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ឬផ្នែកនៃសំណង់ការងារទឹក
- សំណង់អគារ ប៉ម ឬខ្លោងទ្វារនៅតាមច្រកទ្វារអន្តរជាតិ
- បង្គោលអង់តែនទូរសព្ទនិងបង្គោលអង់តែនស្ថានីយវិទ្យុឬទូរទស្សន៍
- សំណង់មិនមែនអគារដទៃទៀតដែលមានកម្ពស់ខ្ពស់ជាង៣០(សាមសិប)ម៉ែត្រ។

**មាត្រា៥ .-**

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដោយមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្តជាសេនាធិការ មានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតអនុញ្ញាតរុះរើ ចំពោះសំណង់ឬការងារ ដូចខាងក្រោម៖

- សំណង់ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ៣ ០០០(បីពាន់)ម៉ែត្រក្រឡា និងមានកម្ពស់ទាបជាងឬស្មើ១១(ដប់មួយ)ជាន់រួមទាំងជាន់ផ្ទាល់ដី ដោយគ្មានឬមានជាន់ក្រោមដីក្នុង

ជម្រៅរាក់ជាងឬស្មើ៥(ប្រាំ)ម៉ែត្រ លើកលែងសំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

- ការងារសាងសង់ឡើងវិញជាថ្មី ការងារសាងសង់បន្ថែម ឬការងារកែប្រែសំណង់ដែលមានស្រាប់ ដែលមានផ្ទៃក្រឡាកម្រាលសំណង់ចាស់ បូកផ្ទៃក្រឡាកម្រាលសំណង់ថ្មីសរុបលើសពី៥០០(ប្រាំរយ) ម៉ែត្រក្រឡា និងតិចជាងឬស្មើ៣ ០០០(បីពាន់)ម៉ែត្រក្រឡា
- ជញ្ជាំងទប់ដីដែលមានកម្ពស់ទាបជាងឬស្មើ៥(ប្រាំ)ម៉ែត្រ
- របងថ្មឬបេតុងដែលមានកម្ពស់ខ្ពស់ជាង៣(បី)ម៉ែត្រ
- សំណង់មិនមែនអគារដទៃទៀតដែលមានកម្ពស់ទាបជាងឬស្មើ៣០(សាមសិប)ម៉ែត្រ។

**មាត្រា៦.-**

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដោយមានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ជាសេនាធិការ មានសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតអនុញ្ញាតរុះរើ ចំពោះសំណង់ឬការងារដូចខាងក្រោម៖

- សំណង់លំនៅឋានដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ៥០០(ប្រាំរយ)ម៉ែត្រក្រឡានិងមានកម្ពស់ទាបជាងឬស្មើ៤(បួន)ជាន់រួមទាំងជាន់ផ្ទាល់ដី និងគ្មានជាន់ក្រោមដី
- ការងារសាងសង់សំណង់លំនៅឋានឡើងវិញជាថ្មី ការងារសាងសង់បន្ថែម ឬការងារកែប្រែសំណង់លំនៅឋានដែលមានស្រាប់ ដែលមានផ្ទៃក្រឡាកម្រាលសំណង់ចាស់បូកផ្ទៃក្រឡាកម្រាលសំណង់ថ្មីសរុបលើសពីទំហំផ្ទៃក្រឡាកម្រាលសំណង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ និងតិចជាងឬស្មើ៥០០(ប្រាំរយ)ម៉ែត្រក្រឡា
- របងថ្មឬបេតុងដែលមានកម្ពស់ទាបជាងឬស្មើ៣(បី)ម៉ែត្រ។

**មាត្រា៧.-**

រាជរដ្ឋាភិបាលឬស្ថាប័នតំណាងដែលបានទទួលសិទ្ធិប្រទាន មានសមត្ថកិច្ចផ្តល់ការអនុញ្ញាតឱ្យសាងសង់ឬរុះរើ ចំពោះសំណង់ដូចខាងក្រោម៖

- សំណង់ដែលជាការសម្ងាត់របស់ជាតិ មានជាអាទិ៍សំណង់សម្រាប់បោះពុម្ពប្រាក់ក្រដាស តម្កល់ និងរក្សាទុករូបិយវត្ថុ
- សំណង់សម្រាប់បម្រើដល់សន្តិសុខជាតិនិងការការពារជាតិ មានជាអាទិ៍សំណង់លេណដ្ឋាន ឃ្លាំងស្តុកអាវុធនិងគ្រឿងយុទ្ធភណ្ឌ និងសំណង់បម្រើដល់ការប្រយុទ្ធ។

## ជំពូកទី៣

## គោលការណ៍ទូទៅនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ និងលិខិតអនុញ្ញាតបើកការដ្ឋានសំណង់

**មាត្រា៨ .-**

រាល់ការសាងសង់ឬរុះរើ ត្រូវមានលិខិតអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ច លើកលែងតែការងារមួយចំនួនដែលបានកំណត់នៅក្នុងអនុក្រឹត្យនេះ។

រាល់ចម្លើយបដិសេធរបស់អាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ច ចំពោះការស្នើសុំលិខិតអនុញ្ញាត ត្រូវធ្វើជាលាយលក្ខណ៍អក្សរនិងមានបញ្ជាក់អំពីមូលហេតុឱ្យបានច្បាស់លាស់។

ការមិនសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាត ក្នុងរយៈពេលដែលបានកំណត់ក្នុងអនុក្រឹត្យនេះ ត្រូវចាត់ទុកថាអាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ច បានផ្តល់ការអនុញ្ញាតដល់ម្ចាស់សំណើដោយតុណ្ហីភាព។

សិទ្ធិនិងកាតព្វកិច្ចដែលទទួលបានពីលិខិតអនុញ្ញាតដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវផ្ទេរទៅឱ្យកម្មសិទ្ធិករថ្មីឬអ្នកកាន់កាប់ថ្មីនៃសំណង់ នៅពេលមានការផ្ទេរកម្មសិទ្ធិនៃដីឬសិទ្ធិកាន់កាប់ដី និង/ឬការផ្ទេរកម្មសិទ្ធិនៃសំណង់ឬគម្រោងសាងសង់នោះត្រឹមត្រូវតាមគោលការណ៍និងនីតិវិធីជាធរមាន។

**មាត្រា៩ .-**

ក្នុងករណីអាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ចសម្រេចបដិសេធផ្តល់លិខិតអនុញ្ញាត អាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ចនោះ ត្រូវចេញលិខិតជូនដំណឹងនិងតម្រូវឱ្យម្ចាស់សំណើមកទទួលយកសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតរបស់ខ្លួនវិញ។

ក្នុងករណីម្ចាស់សំណើមិនមកទទួលយកសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតរបស់ខ្លួនក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង អាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ចអាចសម្រេចមិនរក្សាទុកសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតនោះបាន។

**មាត្រា១០ .-**

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ត្រូវយកទៅដាក់នៅ៖

១. ច្រកចេញចូលតែមួយនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់លិខិតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២. អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត សម្រាប់លិខិតផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

៣. ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់លិខិតផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

បង្កាន់ដៃទទួលពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត អាចផ្តល់ជូនម្ចាស់សំណើតែក្នុងករណីសំណុំឯកសារស្នើសុំនោះមានលក្ខណៈគ្រប់គ្រាន់។

ក្នុងករណី សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត មានលក្ខណៈមិនត្រឹមត្រូវ យន្តការច្រកចេញចូលតែមួយ ត្រូវស្នើជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណើឱ្យធ្វើការកែតម្រូវ។

កំលុងពេលនៃការកែតម្រូវសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត មិនត្រូវបានរាប់បញ្ចូលក្នុងបរិបថនៃការសម្រេចលើពាក្យស្នើសុំឡើយ។

**មាត្រា១១ .-**

អ្នកដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ត្រូវបង់កម្រៃសេវា។

កម្រៃសេវាពិនិត្យនិងផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ត្រូវបង់នៅពេលទទួលបង្កាន់ដៃទទួលពាក្យស្នើសុំនិងមិនអាចប្រគល់ជូនម្ចាស់សំណើវិញឡើយ ទោះក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចឬមន្ត្រីមានសមត្ថកិច្ចសម្រេចបដិសេធផ្តល់ការអនុញ្ញាតជូនម្ចាស់សំណើក៏ដោយ។

កម្រៃសេវាពិនិត្យនិងផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាតដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

កម្រៃសេវាពិនិត្យនិងផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាតដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១២ .-**

សំណុំឯកសារស្តីពីលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ត្រូវតម្កល់ទុករយៈពេលយ៉ាងតិច ១៥(ដប់ប្រាំ)ឆ្នាំនៅ៖

- អគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចំពោះលិខិតអនុញ្ញាតផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ចំពោះលិខិតអនុញ្ញាតផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចំពោះលិខិតអនុញ្ញាតផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

សំណុំឯកសារស្តីពីលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ និងលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ដែលគម្រោងប្លង់ស្ថាបត្យកម្មមានតម្លៃពិសេសផ្នែកស្ថាបត្យកម្ម ត្រូវតម្កល់ទុកជាអចិន្ត្រៃយ៍។

## ជំពូកទី៤

## លិខិតអនុញ្ញាតសាងសង់

**មាត្រា១៣ .-**

មានតែកម្មសិទ្ធិករនៃដីនិងអ្នកដែលបានកាន់កាប់ដីស្របច្បាប់ ទើបអាចអនុញ្ញាតឱ្យសាងសង់សំណង់នៅលើដីនោះបាន។

ការងារសាងសង់ មិនអាចអនុញ្ញាតនៅលើដីដែលកំពុងមានវិវាទអំពីសិទ្ធិកាន់កាប់បានឡើយ។

**មាត្រា១៤ .-**

ការងារសាងសង់ក្នុងស្ថានភាពអាសន្នឬគ្រោះមហន្តរាយដើម្បីជួយសង្គ្រោះឬការពារអាយុជីវិតឬបង្ការមិនឱ្យមានការប៉ះពាល់ឬខូចខាតធ្ងន់ធ្ងរដល់សុខភាពឬទ្រព្យសម្បត្តិក្នុងភាពអាសន្ន មិនតម្រូវឱ្យមានលិខិតអនុញ្ញាតជាមុនឡើយ ទោះបីការងារសាងសង់នោះអនុវត្តនៅលើដីដែលកំពុងមានវិវាទអំពីសិទ្ធិកាន់កាប់ក៏ដោយ។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ ក្រោយពីស្ថានភាពអាសន្នឬគ្រោះមហន្តរាយត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលត្រូវបានសាងសង់ក្នុងស្ថានភាពអាសន្នឬគ្រោះមហន្តរាយ ត្រូវស្នើសុំវិញ្ញាបនបត្រប្រើប្រាស់សំណង់តាមលក្ខខណ្ឌនិងនីតិវិធីជាធរមាន។

**មាត្រា១៥ .-**

សំណង់ដែលការងារសាងសង់មិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ មានដូចខាងក្រោម៖

- សំណង់អគារផ្ទាល់ដីដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ១២(ដប់ពីរ)ម៉ែត្រក្រឡា និងមានកម្ពស់ទាបជាងឬស្មើ៥(ប្រាំ)ម៉ែត្រ
- លំនៅឋានធ្វើពីឈើ ផ្ទះថ្មក្រោមឈើលើដោយមានកម្រាលខណ្ឌធ្វើពីឈើ ផ្ទះតៀមធ្វើពីឈើឬថ្មនៅទីជនបទឬស្រែចម្ការ ដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ១០០(មួយរយ)

ម៉ែត្រក្រឡា មានកម្ពស់ទាបជាងឬស្មើ៤(បួន)ម៉ែត្រ និងមិននៅក្នុងតំបន់រមណីយដ្ឋានទេសចរណ៍ តំបន់បេតិកភណ្ឌ តំបន់អភិរក្ស ឬតំបន់ការពារ

- សំណង់មិនមែនបេតុងដែលសាងសង់ផ្ទាល់ដីសម្រាប់ប្រើប្រាស់ជាបណ្ដោះអាសន្ន មានជាអាទិ៍ បង្គោល ដងទង់ វេទិកា រោង តូប ឬគ្រឿងផ្គុំដទៃទៀតសម្រាប់ប្រារព្ធពិធីផ្សេងៗ
- សំណង់នៅក្នុងបរិវេណវត្តអារាមនៃព្រះពុទ្ធសាសនាដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ២០(ម្ភៃ)ម៉ែត្រក្រឡានិងមានកម្ពស់ទាបជាងឬស្មើ១២(ដប់ពីរ)ម៉ែត្រ
- របងដែលមិនធ្វើអំពីថ្មឬបេតុង។

**មាត្រា១៦ .-**

ការងារកែប្រែដែលមិនប៉ះពាល់ដល់រចនាសម្ព័ន្ធទ្រទ្រង់ គ្រឿងផ្គុំសំណង់ និងសោភណភាពខាងក្រៅ និងមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្ដាប់ធ្នាប់សាធារណៈ មិនតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ឡើយ មានជាអាទិ៍៖

- ការប្ដូរពណ៌ផ្ទៃខាងក្នុង
- ការប្ដូរទ្រង់ទ្រាយផ្ទៃខាងក្នុងនៃសំណង់ ដូចជាបង្កាន់ដៃសុវត្ថិភាព ពិតានដែលមិនធ្វើពីបេតុង ដែក ជញ្ជាំងខណ្ឌបន្ទប់ដែលមិនទ្រទ្រង់
- ការប្ដូរមុខងារសមាសភាគសំណង់ដែលមិនបង្កើនបន្ទុកលើគ្រឿងផ្គុំសំណង់និងក្នុងគោលដៅមិនមែនអាជីវកម្ម។

**មាត្រា១៧ .-**

មុននឹងធ្វើការសាងសង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាត ម្ចាស់សំណង់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនទៅមេឃុំឬចៅសង្កាត់នៃទីតាំងដែលសំណង់នោះស្ថិតនៅ។

បែបបទនិងនីតិវិធីនៃការជូនដំណឹងជាមុនអំពីការងារសាងសង់ដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា១៨ .-**

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវធ្វើជាភាសាខ្មែរ និងត្រូវមានភ្ជាប់ឯកសារបញ្ជាក់អំពីកម្មសិទ្ធិឬសិទ្ធិកាន់កាប់ស្របច្បាប់នៃដីដែលសំណង់តាំងនៅ សលាកបត្រក្បាលដី គម្រោងប្លង់ស្ថាបត្យកម្ម និងឯកសារបច្ចេកទេសផ្សេងទៀតសម្រាប់បម្រើឱ្យការងារសាងសង់។

**មាត្រា១៩ .-**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ក្នុងរយៈពេលយ៉ាងយូរ៤៥(សែសិបប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលច្រកចេញចូលតែមួយ

នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចេញបង្កាន់ដៃទទួលពាក្យស្នើសុំនោះ។

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេលយ៉ាងយូរ២៥(ម្ភៃប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ចេញបង្កាន់ដៃទទួលពាក្យស្នើសុំនោះ។

អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ក្នុងរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ចេញបង្កាន់ដៃទទួលពាក្យស្នើសុំនោះ។

**មាត្រា២០ .-**

លិខិតអនុញ្ញាតសាងសង់ អស់សុពលភាពក្នុងករណីដែលការដ្ឋានសំណង់មិនបានចាប់ផ្តើមដំណើរការក្នុងរយៈពេល១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតសាងសង់នោះ។

ក្នុងករណីម្ចាស់សំណង់បានទទួលលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ រយៈពេលនៃសុពលភាពលិខិតអនុញ្ញាតសាងសង់ ត្រូវចាប់ផ្តើមរាប់ឡើងវិញគិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតបើកការដ្ឋានសំណង់នោះ។

អាជ្ញាធរមានសមត្ថកិច្ច អាចបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់បានតែមួយដងគត់។

លក្ខខណ្ឌនៃការបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់មានដូចខាងក្រោម៖

- ការស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ត្រូវបានធ្វើមកអាជ្ញាធរមានសមត្ថកិច្ចតាមរយៈយន្តការច្រកចេញចូលតែមួយ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃមុនថ្ងៃផុតសុពលភាពលិខិតអនុញ្ញាតសាងសង់
- គ្មានការកែប្រែគម្រោងប្លង់ស្ថាបត្យកម្មដើមនៃលិខិតអនុញ្ញាតសាងសង់
- មិនទាន់មានការចាប់ផ្តើមសាងសង់នៅការដ្ឋានសំណង់។

រយៈពេលសម្រាប់សម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់។

**មាត្រា២១ .-**

បែបបទនិងបរិបទនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បែបបទនិងបរិបទនៃការផ្តល់លិខិតអនុញ្ញាតសាងសង់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្រោយការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៥
## លិខិតអនុញ្ញាតជួសជុល

**មាត្រា២២ .-**

ការងារជួសជុលសំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ ត្រូវមានលិខិតអនុញ្ញាតជួសជុលជាមុន។

**មាត្រា២៣ .-**

ការងារជួសជុលដែលមិនប៉ះពាល់ដល់រចនាសម្ព័ន្ធទ្របន្ទុក គ្រឿងផ្គុំសំណង់ ទ្រង់ទ្រាយដើម និងសោភណភាពខាងក្រៅ និងមិនប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ មិនតម្រូវឱ្យមានលិខិតអនុញ្ញាតជួសជុលឡើយ មានជាអាទិ៍៖

- ការជួសជុលផ្នែកខាងក្នុងដែលមានការខូចខាត ឬការផ្លាស់ប្តូរចំណែកចាស់ទ្រុឌទ្រោមដែលអាចបង្កនូវគ្រោះថ្នាក់ជាយថាហេតុ
- ការកោសលាបនិង/ឬការបូកបន្ថែមផ្នែកខាងក្នុងអគារ
- ការកែលម្អនិង/ឬការប្តូរពិតានដែលមិនធ្វើពីបេតុងដែក
- ការកែលម្អនិង/ឬការប្តូរឬការបំពាក់បរិក្ខារនិងផលិតផលសំណង់នៅខាងក្នុង មានជាអាទិ៍ការ៉ូ ក្រដាសបិទជញ្ជាំង ជញ្ជាំងកញ្ចក់ សន្លឹកទ្វារ សន្លឹកបង្អួច ម៉ាស៊ីនត្រជាក់
- ការកែលម្អនិង/ឬការប្តូរឬការបំពាក់បរិក្ខារសំណង់ មានជាអាទិ៍បរិក្ខារបន្ទប់ទឹក គ្រឿងបន្លាស់ជណ្តើរយន្ត បណ្តាញខ្សែទូរគមនាគមន៍ និងបរិក្ខារអគ្គិសនី មានជាអាទិ៍ខ្សែភ្លើង ខ្សែអុបទិក អំពូលកង្ហារ។

**មាត្រា២៤ .-**

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតជួសជុល ត្រូវមានភ្ជាប់ឯកសារបញ្ជាក់អំពីកម្មសិទ្ធិលើសំណង់ លិខិតអនុញ្ញាតសាងសង់ គម្រោងប្លង់ស្ថាបត្យកម្ម គម្រោងប្លង់គ្រឿងផ្គុំសំណង់ វិញ្ញាបនបត្រប្រើប្រាស់សំណង់ និងឯកសារបច្ចេកទេសផ្សេងទៀតសម្រាប់បម្រើឱ្យការងារជួសជុល។

**មាត្រា២៥ .-**

រយៈពេលសម្រាប់សម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុល ត្រូវកំណត់ដូចខាងក្រោម៖

១. យ៉ាងយូរ២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតជួសជុលដោយច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតជួសជុលផ្តល់ដោយអគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២. យ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុលដោយអង្គភាពច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតជួសជុលផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

៣- យ៉ាងយូរ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុលដោយការិយាល័យច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតជួសជុលផ្ដល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

**មាត្រា២៦ .-**

លិខិតអនុញ្ញាតជួសជុលអស់សុពលភាពក្នុងករណីដែលការដ្ឋានសំណង់មិនបានចាប់ផ្ដើមដំណើរការក្នុងរយៈពេល១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតជួសជុលនោះ។

លិខិតអនុញ្ញាតជួសជុល អាចបន្តសុពលភាពបានតែមួយដងគត់។

លក្ខខណ្ឌនៃការបន្តសុពលភាពលិខិតអនុញ្ញាតជួសជុលមានដូចខាងក្រោម៖

- ការស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតជួសជុលត្រូវបានធ្វើ តាមរយៈយន្តការច្រកចេញចូលតែមួយ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃមុនថ្ងៃផុតសុពលភាពលិខិតអនុញ្ញាតជួសជុល
- គ្មានការកែប្រែគម្រោងប្លង់ស្ថាបត្យកម្មឬគម្រោងប្លង់គ្រឿងផ្គុំសំណង់ដើមនៃលិខិតអនុញ្ញាតជួសជុល
- មិនទាន់មានការចាប់ផ្ដើមជួសជុលនៅការដ្ឋានសំណង់។

ការងារជួសជុលត្រូវបានចាត់ទុកថាបានចាប់ផ្ដើម កាលណាការងារដំបូងត្រូវបានអនុវត្តចំពោះផ្នែកណាមួយនៃសំណង់។

ការដ្ឋានសំណង់ដែលបានចាប់ផ្ដើមដំណើរការជួសជុល ប៉ុន្តែបានផ្អាកសកម្មភាពទៅវិញលើសពី៦(ប្រាំមួយ)ខែ ត្រូវមានលិខិតបន្តសុពលភាពលិខិតអនុញ្ញាតជួសជុល មុននឹងបន្តដំណើរការជួសជុល។

រយៈពេលសម្រាប់សម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតជួសជុល ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះការស្នើសុំបន្តសុពលភាពនៃលិខិតអនុញ្ញាតជួសជុល។

**មាត្រា២៧ .-**

មុននឹងធ្វើការជួសជុលដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាត ម្ចាស់សំណង់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនទៅមេឃុំឬចៅសង្កាត់នៃទីតាំងដែលសំណង់នោះស្ថិតនៅ។

បែបបទនិងនីតិវិធីនៃការជូនដំណឹងជាមុនអំពីការងារជួសជុលដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា២៨ .-**

បែបបទនិងបរិបថនៃការផ្ដល់លិខិតអនុញ្ញាតជួសជុលដោយអគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។

បែបបទនិងបរិបថនៃការផ្ដល់លិខិតអនុញ្ញាតជួសជុលដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ក្រោយការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

# ជំពូកទី៦
## លិខិតអនុញ្ញាតរុះរើ

**មាត្រា២៩ .-**

ការងាររុះរើសំណង់ដែលតម្រូវឱ្យមានលិខិតអនុញ្ញាតសាងសង់ ត្រូវមានលិខិតអនុញ្ញាតរុះរើជាមុន។

**មាត្រា៣០ .-**

ការស្នើសុំលិខិតអនុញ្ញាតរុះរើ ត្រូវធ្វើដោយម្ចាស់សំណង់។

សំណង់ដែលកំពុងមានវិវាទអំពីកម្មសិទ្ធិ មិនអនុញ្ញាតឱ្យរុះរើឡើយ។

**មាត្រា៣១ .-**

ការងាររុះរើសំណង់ក្នុងស្ថានភាពអាសន្នឬគ្រោះមហន្តរាយដើម្បីជួយសង្គ្រោះឬការពារអាយុជីវិតឬបង្ការមិនឱ្យមានការប៉ះពាល់ឬខូចខាតធ្ងន់ធ្ងរដល់សុខភាពឬទ្រព្យសម្បត្តិក្នុងភាពអាសន្ន មិនតម្រូវឱ្យមានលិខិតអនុញ្ញាតជាមុនឡើយ ទោះបីសំណង់នោះកំពុងមានវិវាទអំពីកម្មសិទ្ធិក៏ដោយ។

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរក្រោយពីស្ថានភាពអាសន្នឬគ្រោះមហន្តរាយត្រូវបានបញ្ចប់ ម្ចាស់សំណង់ដែលបានរុះរើក្នុងភាពអាសន្នឬគ្រោះមហន្តរាយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអាជ្ញាធរមានសមត្ថកិច្ច។

**មាត្រា៣២ .-**

មុននឹងធ្វើការរុះរើដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាត ម្ចាស់សំណង់ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនទៅមេឃុំឬចៅសង្កាត់នៃទីតាំងដែលសំណង់នោះស្ថិតនៅ។

បែបបទនិងនីតិវិធីនៃការជូនដំណឹងជាមុនអំពីការងាររុះរើដែលមិនតម្រូវឱ្យមានលិខិតអនុញ្ញាតត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៣៣ .-**

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតរុះរើ ត្រូវមានភ្ជាប់ឯកសារបញ្ជាក់អំពីកម្មសិទ្ធិនៃសំណង់ គម្រោងប្លង់ស្ថាបត្យកម្ម គម្រោងប្លង់រុះរើ និងឯកសារបច្ចេកទេសផ្សេងទៀតសម្រាប់បម្រើឱ្យការងាររុះរើ។

**មាត្រា៣៤ .-**

បញ្ញត្តិស្ដីពីរយៈពេលនៃការសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះរយៈពេលនៃការសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតរុះរើ។

**មាត្រា៣៥ .-**

បញ្ញត្តិស្ដីពីលក្ខខណ្ឌសុពលភាព ការស្នើសុំបន្តសុពលភាព និងការអនុញ្ញាតឱ្យបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ ត្រូវយកមកអនុវត្តដូចគ្នាផងដែរចំពោះលក្ខខណ្ឌសុពលភាព ការស្នើសុំបន្តសុពលភាព និងការអនុញ្ញាតឱ្យបន្តសុពលភាពលិខិតអនុញ្ញាតរុះរើ។

ការបន្តសុពលភាពលិខិតអនុញ្ញាតរុះរើ មិនត្រូវមានការកែប្រែគម្រោងប្លង់រុះរើនៃសំណង់ដែលបាន កំណត់ក្នុងលិខិតអនុញ្ញាតរុះរើដើមឡើយ។

**មាត្រា៣៦ .-**

បែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតរុះរើដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បែបបទនិងបរិបថនៃការផ្តល់លិខិតអនុញ្ញាតរុះរើដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោយការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៧

## លិខិតអនុញ្ញាតបើកការដ្ឋានសំណង់

**មាត្រា៣៧ .-**

ការចាប់ផ្តើមដំណើរការការងារសាងសង់សំណង់ថ្មី ការងារកែប្រែ ការងារដំឡើង និងការងាររុះរើ ត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ជាមុនស្របតាមលិខិតអនុញ្ញាតសាងសង់ឬរុះរើសំណង់នោះ។

ការដ្ឋានសំណង់ដែលបានចាប់ផ្តើមដំណើរការ ប៉ុន្តែបានផ្អាកសកម្មភាពទៅវិញ លើសពី១(មួយ)ឆ្នាំ ត្រូវមានលិខិតបន្តសុពលភាពលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ មុននឹងបន្តដំណើរការសាងសង់ឬរុះរើ។

**មាត្រា៣៨ .-**

ការងារសាងសង់សំណង់ថ្មីត្រូវបានចាត់ទុកថាបានចាប់ផ្តើមដំណើរការ នៅពេលដែលការងារដីឬ ការងារគ្រឹះដំបូងត្រូវបានអនុវត្ត។ ការងារកែប្រែត្រូវបានចាត់ទុកថាបានចាប់ផ្តើម កាលណាផ្នែកណាមួយ នៃសំណង់ឬបរិក្ខារសំណង់ឬផលិតផលសំណង់ត្រូវបានផ្លាស់ប្តូរ។ ការងារដំឡើងត្រូវបានចាត់ទុកថាបាន ចាប់ផ្តើម កាលណាផ្នែកណាមួយនៃបរិក្ខារសំណង់ឬផលិតផលសំណង់ ត្រូវបានភ្ជាប់ទៅនឹងសំណង់។

ការងាររុះរើត្រូវបានចាត់ទុកថាបានចាប់ផ្តើមដំណើរការ នៅពេលដែលផ្នែកដំបូងនៃសំណង់ត្រូវ បានដកឬរើចេញ។

ក្នុងករណីអាជ្ញាធរមានសមត្ថកិច្ចមិនសម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ឬរុះរើក្នុង រយៈពេលដូចមានកំណត់ក្នុងអនុក្រឹត្យនេះ ម្ចាស់សំណើអាចដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋាន សំណង់ចាប់ពីថ្ងៃផុតរយៈពេលកំណត់នោះ។

**មាត្រា៣៩ .-**

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់សម្រាប់ការងារសាងសង់ ត្រូវមានភ្ជាប់ លិខិតអនុញ្ញាតសាងសង់ គម្រោងប្លង់គ្រឿងផ្គុំសំណង់ ឯកសារសិក្សាភូគព្ភសាស្ត្រ សៀវភៅបន្ទុកនៃការងារ

សាងសង់ កិច្ចសន្យាម៉ៅការសាងសង់ ឯកសារបច្ចេកទេសផ្សេងទៀតសម្រាប់បម្រើឱ្យការងារសាងសង់ និង វិញ្ញាបនបត្រធានារ៉ាប់រង ឬឯកសារបញ្ជាក់អំពីការចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន ជាមួយក្រុមហ៊ុនធានារ៉ាប់រង។

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់សម្រាប់ការងាររុះរើ ត្រូវមានភ្ជាប់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតរុះរើ គម្រោងប្លង់គ្រឿងផ្គុំសំណង់ គម្រោងប្លង់រុះរើ សៀវភៅបន្ទុកនៃការងាររុះរើ កិច្ចសន្យាម៉ៅការសាងសង់ ឯកសារបច្ចេកទេសផ្សេងទៀតសម្រាប់បម្រើឱ្យការងាររុះរើ និង វិញ្ញាបនបត្រធានារ៉ាប់រង ឬឯកសារបញ្ជាក់អំពីការចុះកិច្ចសន្យាធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន ជាមួយក្រុមហ៊ុនធានារ៉ាប់រង។

ក្នុងករណីសំណង់ត្រូវបានអនុញ្ញាតឱ្យសាងសង់ឬរុះរើដោយតុណ្ហីភាព សំណុំឯកសារស្នើសុំលិខិតអនុញ្ញាត បើកការដ្ឋានសំណង់សម្រាប់ការងារសាងសង់ឬរុះរើ ត្រូវមានភ្ជាប់បង្កាន់ដៃទទួលពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ឬរុះរើ និងឯកសារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។

ត្រូវបានរាប់បញ្ចូលជាឯកសារបច្ចេកទេស លិខិតឯកភាពជាគោលការណ៍របស់ក្រសួង ស្ថាប័ន ឬរដ្ឋបាលថ្នាក់ក្រោមជាតិតាមការកំណត់របស់ច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**មាត្រា៤០ .-**

រយៈពេលសម្រាប់សម្រេចលើពាក្យស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ត្រូវកំណត់ដូចខាងក្រោម៖

១. យ៉ាងយូរ២០(ម្ភៃ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ដោយច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ផ្តល់ដោយអគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

២. យ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ដោយអង្គភាពច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

៣. យ៉ាងយូរ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃចេញបង្កាន់ដៃទទួលពាក្យស្នើសុំលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ដោយការិយាល័យច្រកចេញចូលតែមួយ ចំពោះលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

**មាត្រា៤១ .-**

លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ អស់សុពលភាពក្នុងករណីណាមួយដូចខាងក្រោម៖

- ការដ្ឋានសំណង់មិនបានចាប់ផ្តើមដំណើរការក្នុងរយៈពេល១(មួយ)ឆ្នាំ គិតចាប់ពីថ្ងៃចេញលិខិតអនុញ្ញាតបើកការដ្ឋានសំណង់នោះ

- ការដ្ឋានសំណង់បានផ្អាកដំណើរការរយៈពេលលើសពី១(មួយ)ឆ្នាំ
- លិខិតអនុញ្ញាតសាងសង់ឬរុះរើអស់សុពលភាព ត្រូវបាននិរាករឬប្រកាសមោឃភាពដោយអាជ្ញាធរមានសមត្ថកិច្ចឬដោយតុលាការ។

លិខិតអនុញ្ញាតបើកការដ្ឋានសំណង់អាចបន្តសុពលភាពបានតែមួយដងគត់។

លក្ខខណ្ឌនៃការបន្តសុពលភាពលិខិតអនុញ្ញាតបើកការដ្ឋានសំណង់មានដូចខាងក្រោម៖

- ការស្នើសុំបន្តសុពលភាពលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ត្រូវបានធ្វើតាមរយៈយន្តការច្រកចេញចូលតែមួយ ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃមុនថ្ងៃផុតសុពលភាពលិខិតអនុញ្ញាតបើកការដ្ឋានសំណង់
- គ្មានការកែប្រែគម្រោងប្លង់ស្ថាបត្យកម្ម គម្រោងប្លង់គ្រឿងផ្គុំសំណង់ ឬគម្រោងប្លង់រុះរើដើមនៃលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតរុះរើ ឬលិខិតអនុញ្ញាតបើកការដ្ឋានសំណង់។

**មាត្រា៤២ .-**

បែបបទនិងបរិបទនៃការផ្តល់លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ដោយអគ្គនាយកនៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បែបបទនិងបរិបទនៃការផ្តល់លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោយការពិគ្រោះយោបល់ជាមួយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៨

## លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ឬលិខិតបន្តសុពលភាពលិខិតអនុញ្ញាត សម្រាប់គម្រោងអភិវឌ្ឍន៍អចលនវត្ថុ

**មាត្រា៤៣ .-**

ការផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ក្នុងគម្រោងអភិវឌ្ឍន៍អចលនវត្ថុ ត្រូវគោរពតាមលក្ខខណ្ឌនិងនីតិវិធីសម្រាប់សំណង់ទូទៅដែរ។

ការស្នើសុំលិខិតអនុញ្ញាតសាងសង់ក្នុងគម្រោងអភិវឌ្ឍន៍អចលនវត្ថុ ត្រូវមានលិខិតអនុញ្ញាតអភិវឌ្ឍដីផ្តល់ដោយអាជ្ញាធរមានសមត្ថកិច្ចជាមុន។

ការសាងសង់ក្នុងគម្រោងអភិវឌ្ឍន៍អចលនវត្ថុ អាចអនុញ្ញាតឱ្យធ្វើឡើងតាមដំណាក់កាលស្របតាមផែនការ ដូចមានកំណត់ក្នុងលិខិតអនុញ្ញាតអភិវឌ្ឍដី។

**មាត្រា៤៤ .-**

ការស្នើសុំលិខិតអនុញ្ញាតសាងសង់ដោយបំបែកជាគម្រោងតូចៗនៃគម្រោងអភិវឌ្ឍនៃបណ្តុំផ្ទះល្វែង ឬគម្រោងបណ្តុំលំនៅឋានក្នុងគោលដៅអាជីវកម្មដែលមានម្ចាស់សំណង់តែមួយ មានម្ចាស់ដីតែមួយ និងស្ថិតនៅលើក្បាលដីតែមួយ ត្រូវហាមឃាត់។

**មាត្រា៤៥ .-**

គម្រោងសាងសង់បណ្តុំផ្ទះល្វែង ឬបណ្តុំលំនៅឋានក្នុងគោលដៅអាជីវកម្មដែលស្ថិតនៅលើក្បាលដីតែមួយ ត្រូវមានលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ជាមុន មុននឹងអនុញ្ញាតឱ្យធ្វើការបំបែកក្បាលដី។

គម្រោងសាងសង់អគារសហកម្មសិទ្ធិក្នុងគោលដៅអាជីវកម្មដែលស្ថិតនៅលើក្បាលដីតែមួយ ត្រូវអនុវត្តការងារសាងសង់គ្រឿងឆ្អឹងសំណង់អគារទាំងមូលមួយរយភាគរយ និងបានរៀបចំខណ្ឌជញ្ជាំង ចំណែកឯកជនរួចរាល់តាមប្លង់អនុញ្ញាត មុននឹងអនុញ្ញាតឱ្យធ្វើការបំបែកជាចំណែកឯកជន។

## ជំពូកទី៩
## ការប្តឹងតវ៉ា

**មាត្រា៤៦ .-**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច ឬមន្ត្រីមានសមត្ថកិច្ចដូចមានចែងក្នុងអនុក្រឹត្យនេះ មានសិទ្ធិតវ៉ាទៅអាជ្ញាធរ ឬមន្ត្រីមានសមត្ថកិច្ចដែលបានចេញសេចក្តីសម្រេចនោះ ឬទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬទៅតុលាការតាមនីតិវិធីដូចមានចែងក្នុងច្បាប់ស្តីពីសំណង់និងបទប្បញ្ញត្តិដទៃទៀតជាធរមាន។

**មាត្រា៤៧ .-**

បុគ្គលដែលរងការខូចខាត ឬមានការបារម្ភជាក់ស្តែងថានឹងរងការខូចខាតដោយសារការអនុវត្តសិទ្ធិ ឬកាតព្វកិច្ចរបស់បុគ្គលណាម្នាក់ដូចមានកំណត់ក្នុងលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ និងលិខិតអនុញ្ញាតបើកការដ្ឋានសំណង់ អាចធ្វើសំណើទៅគណៈកម្មការដោះស្រាយវិវាទសំណង់ដើម្បីធ្វើការសម្រុះសម្រួលតាមនីតិវិធីជាធរមាន។

## ជំពូកទី១០
## ទណ្ឌកម្ម

**មាត្រា៤៨ .-**

បុគ្គលដែលក្លែងបន្លំឯកសារ ឬផ្តល់ព័ត៌មានមិនពិតដល់អាជ្ញាធរ ឬមន្ត្រីមានសមត្ថកិច្ចដើម្បីទទួលបានលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ឬលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ដូចមានចែងក្នុងអនុក្រឹត្យនេះ ឬក្លែងបន្លំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ឬលិខិតបន្ត

សុពលភាពលិខិតអនុញ្ញាត ដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ។

**មាត្រា៤៩ .-**

អ្នករាជការសាធារណៈមានសមត្ថកិច្ចដែលមិនទទួលពិនិត្យសំណុំឯកសារស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ឬលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ឬបដិសេធផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ឬលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ដោយគ្មានមូលហេតុត្រឹមត្រូវ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលដោយមិនទាន់គិតដល់ការទទួលខុសត្រូវព្រហ្មទណ្ឌ តាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី១១

## អន្តរប្បញ្ញត្តិ

**មាត្រា៥០ .-**

លិខិតបទដ្ឋាននិងគោលការណ៍ណែនាំរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ពាក់ព័ន្ធនឹងការផ្តល់លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ ឬលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ដែលអនុវត្តមុនអនុក្រឹត្យនេះចូលជាធរមានត្រូវមានអានុភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋាននិងគោលការណ៍ណែនាំថ្មីមកជំនួស។

លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ដែលបានផ្តល់ជូនម្ចាស់សំណង់មុនអនុក្រឹត្យនេះចូលជាធរមាន នៅបន្តសុពលភាពរហូតថ្ងៃផុតសុពលភាពលិខិតអនុញ្ញាតទាំងនោះ។

**មាត្រា៥១ .-**

ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតជួសជុល លិខិតអនុញ្ញាតរុះរើ លិខិតអនុញ្ញាតបើកការដ្ឋានសំណង់ និងលិខិតបន្តសុពលភាពលិខិតអនុញ្ញាត ដែលបានដាក់នៅយន្តការច្រកចេញចូលតែមួយមុនអនុក្រឹត្យនេះចូលជាធរមាន អាជ្ញាធរមានសមត្ថកិច្ចនិងមន្ត្រីមានសមត្ថកិច្ច ត្រូវបន្តដំណើរការពិនិត្យនិងសម្រេចរហូតដល់ចប់នីតិវិធី។ ក្នុងករណីនេះ អាជ្ញាធរមានសមត្ថកិច្ចនិងមន្ត្រីមានសមត្ថកិច្ចត្រូវអនុវត្តគោលការណ៍ឬលក្ខខណ្ឌទាំងឡាយដូចមានចែងក្នុងអនុក្រឹត្យនេះដែលផ្តល់ប្រយោជន៍ដល់ម្ចាស់សំណើ។

**មាត្រា៥២ .-**

សំណុំឯកសារស្នើសុំលិខិតអនុញ្ញាតជួសជុលសំណង់ដែលបានសាងសង់រួចមុនអនុក្រឹត្យនេះចូលជាធរមានដោយមានឬគ្មានលិខិតអនុញ្ញាតសាងសង់ ត្រូវភ្ជាប់លិខិតបិទការដ្ឋានសំណង់ ឬវិញ្ញាបនបត្រប្រើប្រាស់សំណង់ និងឯកសារបច្ចេកទេសផ្សេងទៀតដូចមានចែងក្នុងអនុក្រឹត្យនេះ។

## ជំពូកទី១២

## អវសានប្បញ្ញត្តិ

**មាត្រា៥៣ .-**

អនុក្រឹត្យលេខ៨៦ អនក្រ.បក. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥៤ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១ រោច ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៨៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ចំណាត់ថ្នាក់សំណង់ និងគោលដៅ ដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំដែនដីនគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០០៧ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យ

- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងពន្ធដារ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ._**

អនុក្រឹត្យនេះមានគោលបំណងកំណត់អំពីចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ដើម្បីការពារទប់ស្កាត់គ្រោះថ្នាក់អគ្គិភ័យ។

**មាត្រា២ ._**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីសមត្ថកិច្ចគ្រប់គ្រង ត្រួតពិនិត្យលើប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យនៃសំណង់ និងគោលដៅ ដើម្បីបង្ការ និងការពារអាយុជីវិត ទ្រព្យសម្បត្តិ បរិស្ថាន សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមពីគ្រោះថ្នាក់អគ្គិភ័យ។

**មាត្រា៣ ._**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើសំណង់ និងគោលដៅ ដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ ._**

វាក្យស័ព្ទសំខាន់ៗដែលមានប្រើក្នុងច្បាប់ស្តីពីការបង្ការ និងការពន្លត់អគ្គិភ័យត្រូវបានបន្ថែមក្នុងអនុក្រឹត្យនេះមាននិយមន័យដូចខាងក្រោម ៖

- អគ្គិភ័យ សំដៅដល់ករណីមានភ្លើងឆេះមិនអាចគ្រប់គ្រងបានដែលអាចបង្កមហន្តរាយដល់អាយុជីវិត ទ្រព្យសម្បត្តិ និងបរិស្ថាន។

- ការបង្ការអគ្គិភ័យ សំដៅដល់ការរៀបចំអនុវត្តនូវលក្ខខណ្ឌ និងវិធានការនានាដើម្បីធានាសុវត្ថិភាពមិនឱ្យមានអគ្គិភ័យកើតឡើង។

- ចំណាត់ថ្នាក់សំណង់ សំដៅដល់សំណង់ដែលត្រូវបានកំណត់ឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យដូចមានចែងក្នុងអនុក្រឹត្យនេះ។

- គោលដៅ សំដៅដល់ទីកន្លែងនានា និងមធ្យោបាយដឹកជញ្ជូនទាំងឡាយដែលអាចមានអគ្គិភ័យកើតឡើង។

- ប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ សំដៅដល់គំនូរទាំងឡាយដែលត្រូវបានកំណត់យ៉ាងច្បាស់ និងលម្អិតអំពីការបំពាក់ឧបករណ៍ សម្ភារៈ បរិក្ខារសម្រាប់ការបង្ការ និងការពន្លត់អគ្គិភ័យ។

- ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ សំដៅដល់ការបំពាក់ឧបករណ៍បច្ចេកទេសក្នុង និង/ឬក្រៅសំណង់ និងគោលដៅ និងវិធានការនានាដើម្បីបង្ការ ទប់ស្កាត់ ពន្លត់អគ្គិភ័យ និងសង្គ្រោះ។

- មធ្យោបាយ សំដៅដល់យានយន្ត ឧបករណ៍ សម្ភារៈ បរិក្ខារដែលប្រើប្រាស់សម្រាប់បង្ការ និងពន្លត់អគ្គិភ័យ។

## ជំពូកទី ២

## សមត្ថកិច្ចគ្រប់គ្រង និងត្រួតពិនិត្យ

**មាត្រា៥ .-**

ក្រសួងមហាផ្ទៃមានសមត្ថកិច្ច៖

- ត្រួតពិនិត្យប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យលើរាល់សំណង់ និងគោលដៅឱ្យបានត្រឹមត្រូវស្របតាមបទដ្ឋានបច្ចេកទេស

- ត្រួតពិនិត្យឧបករណ៍ សម្ភារៈ បរិក្ខារសម្រាប់បំពាក់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យឱ្យស្របតាមបទដ្ឋានបច្ចេកទេស

- ត្រួតពិនិត្យទីតាំងស្តុក ដាក់លក់ឧបករណ៍ សម្ភារៈ បរិក្ខាបង្ការ និងពន្លត់អគ្គិភ័យ

- បញ្ជាក់ទទួលស្គាល់លើគំនូរប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ

- ចេញលិខិតផ្អាកសកម្មភាពបណ្ដោះអាសន្នដល់ផ្នែកណាមួយនៃសំណង់ និងគោលដៅ ដែលខ្វះលក្ខខណ្ឌ និងវិធានការបង្ការ និងពន្លត់អគ្គិភ័យ។

**មាត្រា៦ .-**

ចំពោះតម្រូវការត្រួតពិនិត្យលើប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ រាល់សំណង់ និងគោលដៅដែលជាមូលដ្ឋានកងទ័ព ឬគោលដៅរក្សាការសម្ងាត់ទាក់ទងនឹងសន្តិសុខជាតិ ឬក្នុងស្ថានទូត ស្ថានកុងស៊ុល ស្ថានតំណាងបរទេស និវេសនដ្ឋាន ឬស្ថានតំណាងអង្គការអន្តរជាតិ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាមីពាក់ព័ន្ធ។ ក្នុងករណីមានសំណើពីក្រសួងសាមីពាក់ព័ន្ធ អង្គភាពបង្ការ និងពន្លត់អគ្គិភ័យនៃក្រសួងមហាផ្ទៃ អាចជួយគាំទ្រលើផ្នែកបច្ចេកទេសបាន។

**មាត្រា៧ .-**

ក្រសួងមហាផ្ទៃធ្វើប្រតិភូកម្មអំណាចដល់អគ្គស្នងការដ្ឋាននគរបាលជាតិ និងស្នងការដ្ឋាននគរបាលរាជធានីខេត្ត ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យលើប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យរាល់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យដូចមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យនេះ។

**មាត្រា៨ .-**

ក្រសួងមហាផ្ទៃ អាចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូជំនាញផ្នែកបច្ចេកទេសប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ សំដៅលើកកម្ពស់វិជ្ជាជីវៈ និងបច្ចេកទេសនៃការត្រួតពិនិត្យប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ។

**មាត្រា៩ .-**

មន្ត្រីនគរបាលបង្ការ និងពន្លត់អគ្គិភ័យដែលចុះត្រួតពិនិត្យលើសំណង់ និងគោលដៅ ត្រូវបង្ហាញបណ្ណសម្គាល់ខ្លួន សញ្ញាសម្គាល់ និងលិខិតបញ្ជាបេសកកម្ម ជូនម្ចាស់សំណង់ ឬជនដែលខ្លួនត្រូវទំនាក់ទំនង និងត្រូវមានកំណត់ហេតុត្រឹមត្រូវច្បាស់លាស់។

**មាត្រា១០ .-**

រយៈពេល និងកម្រៃសេវានៃការផ្ដល់លិខិតបញ្ជាក់ទទួលស្គាល់ប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បែបបទ និងនីតិវិធីក្នុងការបញ្ជាក់ទទួលស្គាល់ប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១១ .-**

អគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត មានសមត្ថកិច្ចចេញលិខិតព្រមាន និងពិន័យអន្តរការណ៍ចំពោះម្ចាស់សំណង់ និងម្ចាស់គោលដៅទាំងឡាយណាដែលបំពាក់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យមិនត្រឹមត្រូវស្របតាមបទដ្ឋានបច្ចេកទេស ឬមិនបានបំពាក់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យដូចមានកំណត់ក្នុងអនុក្រឹត្យនេះ។

## ជំពូកទី ៣

## ចំណាត់ថ្នាក់សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ

**មាត្រា១២ .-**

សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ត្រូវបានកំណត់ចំណាត់ថ្នាក់ដូចខាងក្រោម៖

ក-ចំណាត់ថ្នាក់ទី១ : សំណង់ ឬគោលដៅពាណិជ្ជកម្មទាក់ទងនឹងការផលិត ការលក់ ការកែច្នៃ ការស្តុកស្ថានីយប្រេង និងការប្រើប្រាស់ឧស្ម័នចំហេះ សារធាតុងាយឆេះ ងាយផ្ទុះ និងងាយផ្ទុះឆេះ។

ខ-ចំណាត់ថ្នាក់ទី២ : ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពរបស់រដ្ឋ គ្រឹះស្ថានសាធារណៈ និងឯកជន។

គ-ចំណាត់ថ្នាក់ទី៣ : សំណង់ ឬគោលដៅនៃទីប្រជុំជនដែលមានប្រជាជនរស់នៅច្រើនគុះករ អគារសហកម្មសិទ្ធិ បុរីលំនៅឋាន ឬលំនៅឋានមានលក្ខណៈបុរី បណ្ដុំអគារពាណិជ្ជកម្មធំៗ រោងភាពយន្ត រោងមហោស្រព សារមន្ទីរជាតិ បណ្ណសារជាតិ បណ្ណាល័យជាតិ ទីកន្លែងសប្បាយកម្សាន្ត ក្លិបកំសាន្ត ស្ថានីយវិទ្យុ ស្ថានីយទូរទស្សន៍ ស្ថានីយទូរគមនាគមន៍ ក្រុមហ៊ុនគោលដៅស្រាវជ្រាវវិទ្យាសាស្ត្រ អាកាសយានដ្ឋាន ស្ថានីយរថភ្លើង កំពង់ផែ យានដ្ឋាន និងចំណតយានយន្ត។

ឃ-ចំណាត់ថ្នាក់ទី៤ : សំណង់ ឬគោលដៅដែលស្ថិតនៅតំបន់ភ្នំ តំបន់ព្រៃ តំបន់អភិរក្ស រមណីយដ្ឋាន ស្ថានីយអគ្គិសនី វារីអគ្គិសនី រោងចក្រ សហគ្រាស ឧស្សាហកម្ម សិប្បកម្ម និងការដ្ឋានរ៉ែ។

ង-ចំណាត់ថ្នាក់ទី៥ : អគារពាណិជ្ជកម្មខ្នាតតូច និងផ្សារ។

**មាត្រា១៣ .-**

សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ស្ថិតក្រោមសមត្ថកិច្ចរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ៖

ក-សំណង់ និងគោលដៅទាំងឡាយណាដែលមានផ្ទៃក្រឡាកម្រាលចាប់ពី ៣.០០០(បីពាន់)ម៉ែត្រក្រឡា និង/ឬ មានកម្ពស់ចាប់ពី ៩(ប្រាំ)ជាន់ឡើង ដោយរាប់បញ្ចូលទាំងជាន់ក្រោមដី និង/ឬផ្ទុកចំនួនមនុស្សចាប់ពី ២០០(ពីររយ)នាក់ និង/ឬចំនួនបន្ទប់ចាប់ពី ២៥(ម្ភៃប្រាំ)បន្ទប់ និង/ឬចំណតរថយន្តចាប់ពី ១០០(មួយរយ)គ្រឿង។

ខ-ស្ថានីយប្រេងឥន្ធនៈ ដេប៉ូប្រេង ពោងស្តុកប្រេងឥន្ធនៈ ទីតាំងលក់ឧស្ម័នចំហេះ និងគោលដៅផលិត កែច្នៃសារធាតុងាយផ្ទុះ ងាយឆេះ និងងាយផ្ទុះឆេះគ្រប់ប្រភេទ ចំណុះចាប់ពី ១០.០០០(មួយម៉ឺន)លីត្រ និង/ឬ ៥.០០០ (ប្រាំពាន់)គីឡូក្រាមឡើង។

គ-សំណង់សំខាន់ៗក្នុងតំបន់ការពារបរិស្ថានធម្មជាតិ បេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ រមណីយដ្ឋាន ទេសចរណ៍ និងសាសនា។

**មាត្រា១៤ .-**

សំណង់ និងគោលដៅដែលតម្រូវឱ្យមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ស្ថិតក្រោមសមត្ថកិច្ចរបស់ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត៖

ក-សំណង់ និងគោលដៅទាំងឡាយណាដែលមានផ្ទៃក្រឡាកម្រាលក្រោម ៣.០០០(បីពាន់)ម៉ែត្រក្រឡា និង/ឬមានកម្ពស់ ៤(បួន)ជាន់ចុះ ដោយរាប់បញ្ចូលទាំងជាន់ក្រោមដី និង/ឬផ្ទុកចំនួនមនុស្សក្រោម ២០០(ពីររយ)នាក់ និង/ឬចំនួនបន្ទប់ក្រោម ២៥(ម្ភៃប្រាំ)បន្ទប់ និង/ឬចំណតរថយន្តក្រោម ១០០(មួយរយ)គ្រឿង

ខ-ស្ថានីយប្រេងឥន្ធនៈ ដេប៉ូប្រេង ពោងស្តុកប្រេងឥន្ធនៈ ទីតាំងលក់ឧស្ម័នចំហេះ និងគោលដៅផលិត កែច្នៃសារធាតុងាយផ្ទុះ ងាយឆេះ និងងាយផ្ទុះឆេះគ្រប់ប្រភេទ ចំណុះក្រោម ១០.០០០(មួយម៉ឺន)លីត្រ និង/ឬ ៥.០០០(ប្រាំពាន់)គីឡូក្រាម។

**មាត្រា១៥ .-**

ចំពោះសំណង់ និងគោលដៅដែលពាក់ព័ន្ធដល់រោងចក្រ សហគ្រាសធុនតូច មធ្យម និងសិប្បកម្មដែលបានចំណាត់ថ្នាក់ដូចខាងលើ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ។

ចំពោះការអនុញ្ញាត ឬបញ្ជាក់ប្លង់សុវត្ថិភាពបច្ចេកទេសឧស្សាហកម្ម និងសិប្បកម្ម ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រង រោងចក្រ និងសិប្បកម្ម។

## ជំពូកទី ៤

## ភារកិច្ចរបស់ម្ចាស់សំណង់ ឬម្ចាស់គោលដៅ

**មាត្រា១៦ .-**

ម្ចាស់សំណង់ ឬម្ចាស់គោលដៅ ត្រូវមានគំនូរប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ និងមានការបញ្ជាក់ទទួលស្គាល់ពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត មុនដំណើរការសាងសង់។

គំនូរប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យត្រូវបានសិក្សា និងគូរដោយអ្នកជំនាញមានវិជ្ជាជីវៈ និងមានការទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ច។

ម្ចាស់សំណង់ ឬម្ចាស់គោលដៅ ចាំបាច់ត្រូវទទួលបានលិខិតបញ្ជាក់បញ្ចប់ការរៀបចំប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យទទួលស្គាល់ពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត។

បែបបទ និងនីតិវិធីនៃការស្នើសុំរបស់ម្ចាស់សំណង់ និងម្ចាស់គោលដៅ ដូចមានចែងក្នុងមាត្រា១៦ នេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

**មាត្រា១៧ .-**

ម្ចាស់សំណង់ ឬម្ចាស់គោលដៅមុនការប្រើ និងជួសជុល កែតម្រូវទៅលើប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យត្រូវស្នើសុំលិខិតអនុញ្ញាតពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ដូចមានចែងក្នុងមាត្រា១៣ មាត្រា១៤ និងមាត្រា១៥ នៃអនុក្រឹត្យនេះ។

## ជំពូកទី ៥
## ទោសប្បញ្ញត្តិ

**មាត្រា១៨ .-**

នីតិវិធីនៃការពិន័យអន្តរការណ៍ ការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ពិន័យ និងការចាត់ចែងប្រាក់ចំណូលដែលបានមកពីការពិន័យចំពោះបទល្មើសដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

នីតិវិធីនៃការចាត់ចែងប្រាក់ពិន័យដែលបានមកពីការផ្តន្ទាទោសដោយតុលាការ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

**មាត្រា១៩ .-**

មន្ត្រីនគរបាលបង្ការ និងពន្លត់អគ្គិភ័យ រូបណាដែលធ្វេសប្រហែស ខកខាន ឬធ្វើជាភ្លេចភ្លាំង ខ្វះការទទួលខុសត្រូវ មិនបានបំពេញភារកិច្ចត្រឹមត្រូវ ដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មផ្នែករដ្ឋបាល។ ក្នុងករណីធ្ងន់ធ្ងរត្រូវទទួលទោសតាមច្បាប់ជាធរមាន។

**មាត្រា២០ .-**

នីតិបុគ្គល ឬរូបវន្តបុគ្គល ដែលជាម្ចាស់សំណង់ ឬម្ចាស់គោលដៅ មិនគោរពអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងអនុក្រឹត្យនេះត្រូវ៖

- ព្រមានជាលាយលក្ខណ៍អក្សរ
- ក្នុងករណីមិនអនុវត្តតាមការព្រមានជាលាយលក្ខណ៍អក្សរ ត្រូវពិន័យអន្តរការណ៍ជាប្រាក់មិនលើសពី ១០.០០០.០០០ (ដប់លាន)រៀល
- ក្នុងករណីនៅតែមិនព្រមអនុវត្ត ត្រូវប្តឹងទៅតុលាការសុំផ្អាកការសាងសង់ជាបណ្តោះអាសន្ន។

**មាត្រា២១ .-**

ម្ចាស់សំណង់ និងម្ចាស់គោលដៅ មិនបានអនុវត្តស្របតាមប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ដែលមានក្នុងគំនូរប្លង់សាងសង់រួម ត្រូវព្រមានជាលាយលក្ខណ៍អក្សរ។ ក្នុងករណីមិនអនុវត្តតាមការព្រមានជាលាយលក្ខណ៍អក្សរ ត្រូវពិន័យជាប្រាក់ ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ៥.០០០.០០០(ប្រាំលាន)រៀល និងតម្រូវឱ្យធ្វើការកែតម្រូវឱ្យស្របតាមប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យជាមុនសិន។

**មាត្រា២២ .-**

ម្ចាស់សំណង់ និងម្ចាស់គោលដៅដំណើរការសាងសង់គ្មានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ និងមិនមានការបញ្ជាក់ទទួលស្គាល់ពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ត្រូវផ្អាកសកម្មភាពជាបណ្តោះអាសន្ន និងត្រូវពិន័យជាប្រាក់មិនលើសពី ១០.០០០.០០០(ដប់លាន)រៀល។

ក្នុងករណីមិនរៀងចាល ត្រូវពិន័យជាប្រាក់ទ្វេដង។

**មាត្រា២៣ .-**

ម្ចាស់សំណង់ និងម្ចាស់គោលដៅដែលធ្វើការរុះរើ ជួសជុល ឬកែតម្រូវប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ មិនបានសុំការអនុញ្ញាតជាមុន ត្រូវព្រមានជាលាយលក្ខណ៍អក្សរ។ ក្នុងករណីមិនរៀងចាលត្រូវពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន)រៀល ទៅ ៥.០០០.០០០(ប្រាំលាន)រៀល។

**មាត្រា២៤ .-**

ការបង់ប្រាក់ពិន័យអន្តរការណ៍នាំឱ្យរលត់បណ្តឹងអាជ្ញា។

## ជំពូកទី ៦

## អន្តរប្បញ្ញត្តិ

**មាត្រា២៥ .-**

ក្នុងរយៈពេល ២៤ខែ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ម្ចាស់សំណង់ និងម្ចាស់គោលដៅដែលបានសាងសង់រួច ឬកំពុងដំណើរការសាងសង់ពុំមានប្លង់ប្រព័ន្ធបង្ការ និងពន្លត់អគ្គិភ័យ ត្រូវមកបំពេញបែបបទស្នើសុំលិខិតបញ្ជាក់ ពីអគ្គស្នងការដ្ឋាននគរបាលជាតិ ឬស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ស្របតាមអនុក្រឹត្យនេះ។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

**មាត្រា២៦ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវទទួលអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

*ថ្ងៃចន្ទ ១៣កើត ខែ[illegible] ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២*
*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ ធ្នូ ឆ្នាំ ២០១៨*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ២៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ០៤៧ ដនសណ/ប្រ.ក/នី.ក

# ប្រកាស

# ស្តីពី

# កម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសំណង់
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ
- បានឃើញអនុក្រឹត្យលេខ៣៩ អនក្រ.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបុរី
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា១៦ និងមាត្រា១៧នៃអនុក្រឹត្យលេខ១២៦ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩ ស្តីពីការគ្រប់គ្រងនិងប្រើប្រាស់អគារសហកម្មសិទ្ធិ



អាសយដ្ឋាន : ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

- បានឃើញអនុក្រឹត្យលេខ២២៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការត្រួតពិនិត្យនិងបញ្ជាក់សំណង់
- បានឃើញអនុក្រឹត្យលេខ២២៦ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលក្ខខណ្ឌនិងនីតិវិធីនៃការផ្តល់ ការព្យួរ និងការដកហូតវិញ្ញាបនបត្រប្រើប្រាស់សំណង់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១._**

ប្រកាសនេះ កំណត់អំពីកម្រិតនៃសភាពគ្រោះថ្នាក់ ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ និងនីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់ ក្នុងគោលបំណងដើម្បីៈ

- ធានាសុវត្ថិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ
- បង្ការគ្រោះថ្នាក់ដល់សំណង់ជិតខាង ដល់អាយុជីវិត រាងកាយ សុខភាពរបស់អ្នកប្រើប្រាស់សំណង់ អ្នកជិតខាង និងសាធារណជន
- បង្កើនការទទួលខុសត្រូវរបស់ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ អ្នកជួលសំណង់ និងអ្នកប្រើប្រាស់សំណង់ចំពោះគ្រោះថ្នាក់ដែលអាចកើតឡើងជាយថាហេតុពីសំណង់
- បង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងសំណង់ដោយអាជ្ញាធរមានសមត្ថកិច្ច។

**ប្រការ២._**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះសំណង់គ្រប់ប្រភេទ លើកលែងតែប្រភេទសំណង់ដែលមានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**ប្រការ៣._**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោមៈ

- **មន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់** សំដៅដល់ក្រុមការងារត្រួតពិនិត្យនិងបញ្ជាក់សំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មន្ត្រីត្រួតពិនិត្យសំណង់នៃអគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មន្ត្រីត្រួតពិនិត្យសំណង់នៃមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត សម្រាប់សំណង់ដែល

វិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្ដល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីត្រួតពិនិត្យសំណង់នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ សម្រាប់សំណង់ដែលវិញ្ញាបនបត្រប្រើប្រាស់សំណង់ផ្ដល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

– **អង្គភាពមានសមត្ថកិច្ច** សំដៅដល់អគ្គនាយកដ្ឋានសំណង់នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ

– **អាជ្ញាធរមានសមត្ថកិច្ច** សំដៅដល់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

– **ឯកសារបញ្ជាក់អំពីការកាន់កាប់ដីស្របច្បាប់** សំដៅដល់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ បណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ បណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី វិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលអចិន្ត្រៃយ៍ វិញ្ញាបនបត្រសម្គាល់សិទ្ធិជួលរយៈពេលវែង វិញ្ញាបនបត្រសម្គាល់សិទ្ធិផលុបភោគ ភតិសន្យាអចលនវត្ថុ ឬគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាល។ ក្នុងករណីម្ចាស់សំណង់មិនមែនជាម្ចាស់ដី ត្រូវមានការព្រមព្រៀងជាលាយលក្ខណ៍អក្សរពីម្ចាស់ដី។

## ជំពូកទី២
## ការចាត់ថ្នាក់កម្រិតសភាពគ្រោះថ្នាក់

**ប្រការ៤.**_

សភាពគ្រោះថ្នាក់របស់សំណង់ មាន២(ពីរ)ប្រភេទរួមមាន ប្រភេទគ្រោះថ្នាក់អាចកើតឡើងភ្លាមៗនិងប្រភេទគ្រោះថ្នាក់មិនអាចកើតឡើងភ្លាមៗ។

ការចាត់ថ្នាក់កម្រិតសភាពគ្រោះថ្នាក់របស់សំណង់ ត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសសំណង់និងគោលការណ៍ណែនាំរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៥.**_

ក្នុងករណីអាជ្ញាធរមានសមត្ថកិច្ច ទទួលបានបណ្ដឹងឬព័ត៌មានអំពីសំណង់ដែលមានសភាពគ្រោះថ្នាក់ អាជ្ញាធរមានសមត្ថកិច្ច ត្រូវសម្រេចធ្វើការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់នោះ។

អាជ្ញាធរមានសមត្ថកិច្ច ត្រូវចាត់តាំងមន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ដើម្បីចុះត្រួតពិនិត្យវាយតម្លៃ និងធ្វើការសន្និដ្ឋានអំពីការចាត់ថ្នាក់កម្រិតសភាពគ្រោះថ្នាក់របស់សំណង់ជាបន្ទាន់។

ក្នុងករណីពិនិត្យឃើញថាគ្រោះថ្នាក់អាចកើតឡើងភ្លាមៗ មន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធជាបន្ទាន់ តាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន។

**ប្រការ៦._**

របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ត្រូវដាក់ជូនអាជ្ញាធរមានសមត្ថកិច្ច តាមរយៈប្រធានអង្គភាពមានសមត្ថកិច្ច ក្នុងរយៈពេលគិតចាប់ពីថ្ងៃសម្រេចធ្វើការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់៖

- យ៉ាងយូរ១០(ដប់)ថ្ងៃ សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យ៉ាងយូរ៥(ប្រាំ)ថ្ងៃ សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- យ៉ាងយូរ៣(បី)ថ្ងៃ សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

គំរូទម្រង់របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ជាឧបសម្ព័ន្ធ១នៃប្រកាសនេះ។

**ប្រការ៧._**

ក្នុងករណីចាំបាច់ អាជ្ញាធរមានសមត្ថកិច្ចអាចតម្រូវម្ចាស់សំណង់ឱ្យផ្តល់របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ចេញដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់របស់វិស័យឯកជន ដោយរាល់ការចំណាយជាបន្ទុករបស់ម្ចាស់សំណង់។

រាល់ការចំណាយលើសេវាត្រួតពិនិត្យនិងបញ្ជាក់សំណង់របស់វិស័យឯកជនសម្រាប់ចំណែករួមនៃអគារសហកម្មសិទ្ធិឬបុរី ជាបន្ទុករួមគ្នារបស់ម្ចាស់នៃចំណែកឯកជនឬកម្មសិទ្ធិករទាំងអស់ ទៅតាមសមាមាត្រនៃផ្ទៃក្រឡាកម្រាលសំណង់របស់ចំណែកឯកជននីមួយៗ ឬផ្ទៃក្រឡាដីឡូត៍ ដីឡូត៍លំនៅឋាន ឬដីសំណង់ផ្សេងទៀត។

**ប្រការ៨._**

មន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ អាចចូលបំពេញការងារនៅក្នុងទីតាំងណាមួយបាន លុះត្រាតែមានការយល់ព្រមពីម្ចាស់ទីតាំង។

មន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ អាចចូលបំពេញការងារនៅក្នុងអគារឬសំណង់ដែលបើកចំហដល់សាធារណជនតែនៅក្នុងម៉ោងធ្វើការនៅទីតាំងនោះ។

មន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ អាចចូលបំពេញការងារនៅក្នុងទីតាំងអចលនវត្ថុឯកជន នៅក្រោយម៉ោង៦(ប្រាំមួយ)ព្រឹក និងមុនម៉ោង១៨(ដប់ប្រាំបី)ល្ងាច។

ក្នុងករណីចាំបាច់ដែលតម្រូវឱ្យមានការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ នៅក្រៅម៉ោងពេលដូចមានកំណត់ក្នុងប្រការនេះ មន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ត្រូវមានការអនុញ្ញាតពីព្រះរាជអាជ្ញា។

**ប្រការ៩._**

ក្នុងពេលបំពេញបេសកកម្ម មន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ត្រូវស្លៀកពាក់ឯកសណ្ឋាន មានសញ្ញាសម្គាល់ និងលិខិតបញ្ជាបេសកកម្ម។

លិខិតបញ្ជាបេសកកម្មសម្រាប់មន្ត្រីត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ ត្រូវចម្លងជូនម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ ឬអ្នកជួលសំណង់ជាបន្ទាន់តាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបាន។

## ជំពូកទី៣
## ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់

**ប្រការ១០._**

រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានសមត្ថកិច្ចចេញវិធានការបញ្ចៀសគ្រោះថ្នាក់សម្រាប់សំណង់នីមួយៗ ទៅតាមបញ្ញត្តិស្ដីពីសមត្ថកិច្ចផ្ដល់លិខិតអនុញ្ញាតសាងសង់។

ក្នុងករណីគ្រោះថ្នាក់អាចកើតឡើងភ្លាមៗចំពោះសំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្ដល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត មានសមត្ថកិច្ចចេញវិធានការបញ្ចៀសគ្រោះថ្នាក់ផ្អែកតាមរបាយការណ៍ស្ដីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់របស់អង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ។

ការចេញវិធានការបញ្ចៀសគ្រោះថ្នាក់ ត្រូវធ្វើឡើងទៅតាមប្រភេទនិងកម្រិតនៃសភាពគ្រោះថ្នាក់របស់សំណង់និងផ្អែកតាមរបាយការណ៍ស្ដីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់។

អង្គភាពមានសមត្ថកិច្ច ត្រូវយកលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់ទៅបិទផ្សាយជាសាធារណៈនៅទីតាំងសំណង់ដែលមានសភាពគ្រោះថ្នាក់នោះ។

**ប្រការ១១._**

ក្នុងករណីគ្រោះថ្នាក់អាចកើតឡើងភ្លាមៗ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវជូនដំណឹងទៅម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ អ្នកជួលសំណង់ និង/ឬអ្នកកំពុងស្ថិតនៅក្នុងទីតាំងសំណង់ជាបន្ទាន់ តាមគ្រប់មធ្យោបាយដែលអាចធ្វើទៅបានអំពីវិធានការបញ្ចៀសគ្រោះថ្នាក់។

វិធានការបញ្ចៀសគ្រោះថ្នាក់ដែលអាចកើតឡើងភ្លាមៗ មានជាអាទិ៍៖

- ជម្លៀសមនុស្សចេញពីសំណង់ដែលមានសភាពគ្រោះថ្នាក់
- កំណត់អត្តសញ្ញាណសំណង់ជិតខាងដែលអាចរងផលប៉ះពាល់និងជម្លៀសមនុស្សចេញពីសំណង់ទាំងនោះ
- ហ៊ុមព័ទ្ធ ហាមចូល ហាមប្រើប្រាស់ និងហាមអ្នកគ្មានភារកិច្ចចេញចូល

- រុះរើសំណង់ឬផ្នែកណាមួយនៃសំណង់ដែលអាចបង្កគ្រោះថ្នាក់
- កំណត់បរិវេណសុវត្ថិភាព
- បិទផ្សាយជាសាធារណៈនូវលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់នៅទីតាំងសំណង់។

**ប្រការ១២._**

ក្នុងករណីគ្រោះថ្នាក់មិនអាចកើតឡើងភ្លាមៗ អាជ្ញាធរមានសមត្ថកិច្ច ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និង/ឬអ្នកជួលសំណង់អំពីវិធានការបញ្ចៀសគ្រោះថ្នាក់។

វិធានការបញ្ចៀសគ្រោះថ្នាក់ដែលមិនអាចកើតឡើងភ្លាមៗ មានជាអាទិ៍៖

- តម្រូវឱ្យម្ចាស់សំណង់ជួសជុល កែប្រែ ឬរុះរើសំណង់ឬផ្នែកណាមួយនៃសំណង់
- តម្រូវឱ្យម្ចាស់សំណង់រកអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ ដើម្បីសិក្សារកវិធីសាស្ត្របញ្ចៀសគ្រោះថ្នាក់
- តម្រូវឱ្យម្ចាស់សំណង់ចាត់ចែងអនុវត្តតាមការផ្តល់យោបល់បច្ចេកទេសរបស់អ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់
- តម្រូវឱ្យម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និង/ឬអ្នកជួលសំណង់ ចាត់វិធានការចាំបាច់នានាដើម្បីធានាសុវត្ថិភាព សុខភាព និងទ្រព្យសម្បត្តិរបស់អតិថិជន អ្នកប្រើប្រាស់សំណង់ និងអ្នកជិតខាង
- បិទផ្សាយលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់នៅទីតាំងសំណង់។

រាល់ការចំណាយដើម្បីអនុវត្តវិធានការបញ្ចៀសគ្រោះថ្នាក់ ជាបន្ទុករបស់ម្ចាស់សំណង់។

**ប្រការ១៣._**

លិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់ ត្រូវកំណត់រយៈពេលសម្រាប់អនុវត្តវិធានការបញ្ចៀសគ្រោះថ្នាក់ដោយម្ចាស់សំណង់ និងរយៈពេលសម្រាប់អនុវត្តសិទ្ធិតវ៉ារបស់ម្ចាស់សំណង់។

អាជ្ញាធរមានសមត្ថកិច្ចត្រូវកំណត់រយៈពេលសម្រាប់អនុវត្តវិធានការបញ្ចៀសគ្រោះថ្នាក់ដោយម្ចាស់សំណង់ ទៅតាមកម្រិតនៃការប៉ះពាល់ដល់សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ និងកម្រិតនៃហានិភ័យដែលសំណង់អាចបង្កដល់មនុស្សនិងទ្រព្យសម្បត្តិរបស់អ្នកជិតខាងនិងសាធារណជន។

អាជ្ញាធរមានសមត្ថកិច្ចត្រូវកំណត់រយៈពេលសម្រាប់អនុវត្តសិទ្ធិតវ៉ារបស់ម្ចាស់សំណង់ទៅតាមប្រភេទនិងកម្រិតនៃសភាពគ្រោះថ្នាក់របស់សំណង់ ប៉ុន្តែរយៈពេលនេះមិនត្រូវយូរជាង៖

- ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់ សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- ៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់ សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត
- ៣០(សាមសិប)ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់ សម្រាប់សំណង់ដែលលិខិតអនុញ្ញាតសាងសង់ផ្តល់ដោយអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

**ប្រការ១៤._**

ក្នុងករណីម្ចាស់សំណង់មិនយល់ព្រមចំពោះវិធានការបញ្ចៀសគ្រោះថ្នាក់ចេញដោយអាជ្ញាធរមានសមត្ថកិច្ច ម្ចាស់សំណង់មានសិទ្ធិស្នើសុំឱ្យធ្វើការវាយតម្លៃ ឬការចាត់ថ្នាក់កម្រិតនៃសភាពគ្រោះថ្នាក់របស់សំណង់ឡើងវិញ ឬផ្តល់របាយការណ៍ស្តីពីការត្រួតពិនិត្យគុណភាពនិងសុវត្ថិភាពសំណង់ចេញដោយអ្នកត្រួតពិនិត្យនិងបញ្ជាក់សំណង់ក្នុងវិស័យឯកជនផ្សេងទៀត។

**ប្រការ១៥._**

ចំពោះសំណង់ដែលមានសភាពគ្រោះថ្នាក់ ម្ចាស់សំណង់និងអ្នកគ្រប់គ្រងសំណង់ មានកាតព្វកិច្ចរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច និងអនុវត្តតាមវិធានការបញ្ចៀសគ្រោះថ្នាក់ទាំងឡាយដែលកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច។

អាជ្ញាធរមានសមត្ថកិច្ចត្រូវកំណត់ថិរវេលាអតិបរមានិងទណ្ឌកម្មជាយថាហេតុសម្រាប់ម្ចាស់សំណង់ អ្នកគ្រប់គ្រងសំណង់ និង/ឬអ្នកជួលសំណង់ ឱ្យអនុវត្តតាមវិធានការបញ្ចៀសគ្រោះថ្នាក់ ដូចមានកំណត់នៅក្នុងលិខិតជូនដំណឹងអំពីវិធានការបញ្ចៀសគ្រោះថ្នាក់។

**ប្រការ១៦._**

ក្នុងករណីម្ចាស់សំណង់មិនធ្វើការរុះរើសំណង់ដែលមានសភាពគ្រោះថ្នាក់ ដូចមានកំណត់នៅក្នុងសេចក្តីជូនដំណឹងស្តីពីវិធានការបញ្ចៀសគ្រោះថ្នាក់ អាជ្ញាធរមានសមត្ថកិច្ចត្រូវចាត់ចែងធ្វើការរុះរើសំណង់នោះដោយផ្ទាល់តាមលក្ខខណ្ឌនិងនីតិវិធីជាធរមាន ដោយរាល់ចំណាយជាបន្ទុករបស់ម្ចាស់សំណង់។

## ជំពូកទី៤

## នីតិវិធីនៃការគ្រប់គ្រងសំណង់ដែលមានសភាពគ្រោះថ្នាក់

**ប្រការ១៧._**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតបញ្ជីសំណង់ដែលមានសភាពគ្រោះថ្នាក់ចំពោះសំណង់ដែលស្ថិតក្រោមសមត្ថកិច្ចផ្តល់លិខិតអនុញ្ញាតសាងសង់របស់ខ្លួន។

**ប្រការ១៨._**

បញ្ជីសំណល់ដែលមានសភាពគ្រោះថ្នាក់ មានបង្ហាញជាអាទិ៍ ទីតាំងនៃសំណល់ ប្រភេទនៃសំណល់ មុខងារប្រើប្រាស់សំណល់ អត្តសញ្ញាណរបស់ម្ចាស់សំណល់និងអ្នកគ្រប់គ្រងសំណល់ កម្រិតនៃសភាពគ្រោះថ្នាក់ និងវិធានការបញ្ចៀសគ្រោះថ្នាក់ សម្រាប់ត្រួតពិនិត្យ តាមដាន និងចាត់វិធានការពង្រឹងការអនុវត្តច្បាប់។

អង្គភាពមានសមត្ថកិច្ចមានភារកិច្ចគ្រប់គ្រងនិងធ្វើបច្ចុប្បន្នកម្មបញ្ជីសំណល់ដែលមានសភាពគ្រោះថ្នាក់ជាឯកសាររឹង និងឯកសារទម្រង់អេឡិចត្រូនិក។

គំរូទម្រង់បញ្ជីសំណល់ដែលមានសភាពគ្រោះថ្នាក់ ជាឧបសម្ព័ន្ធ២នៃប្រកាសនេះ។

**ប្រការ១៩._**

អង្គភាពមានសមត្ថកិច្ចមានភារកិច្ចត្រួតពិនិត្យនិងតាមដានរាល់សំណល់ដែលត្រូវបានចុះក្នុងបញ្ជីសំណល់ដែលមានសភាពគ្រោះថ្នាក់ និងលើកសំណើជូនអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចេញវិធានការបញ្ចៀសគ្រោះថ្នាក់ ឬដកចេញពីបញ្ជីសំណល់ដែលមានសភាពគ្រោះថ្នាក់។

**ប្រការ២០._**

ម្ចាស់សំណល់ អ្នកគ្រប់គ្រងសំណល់ និង/ឬអ្នកជួលសំណល់ដែលមានក្នុងបញ្ជីសំណល់ដែលមានសភាពគ្រោះថ្នាក់ ត្រូវផ្តល់កិច្ចសហការជាមួយមន្ត្រីនៃអង្គភាពមានសមត្ថកិច្ច ក្នុងការត្រួតពិនិត្យ តាមដាន និងចាត់វិធានការបញ្ចៀសគ្រោះថ្នាក់ និងត្រូវរាយការណ៍អំពីស្ថានភាពនៃការប្រែប្រួលរបស់សំណល់ជូនអាជ្ញាធរមានសមត្ថកិច្ច។

## ជំពូកទី៥

## បណ្តឹងតវ៉ា

**ប្រការ២១._**

បុគ្គលដែលមានទំនាក់ទំនងផលប្រយោជន៍ជាមួយសេចក្តីសម្រេចរបស់អាជ្ញាធរមានសមត្ថកិច្ច ដូចមានចែងក្នុងប្រកាសនេះ មានសិទ្ធិតវ៉ាទៅអាជ្ញាធរមានសមត្ថកិច្ចដែលបានចេញសេចក្តីសម្រេចនោះ ឬទៅរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬទៅតុលាការតាមនីតិវិធីដូចមានចែងក្នុងច្បាប់ស្តីពីសំណង់និងបទប្បញ្ញត្តិដទៃទៀតជាធរមាន។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**ប្រការ២២._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៣._**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្រធានអង្គភាពចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៥ រោចខែ បុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
  **"ដើម្បីជូនជ្រាប"**
- សាលារាជធានី ខេត្ត
- ដូចប្រការ២៣ **"ដើម្បីអនុវត្ត"**
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ